ពុទ្ធសាសនបណ្ឌិត្យ
បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE
០៤

ព្រះរាជបណ្ណាល័យកម្ពុជា

# KAMPUCHEA SURIYA

# កម្ពុជសុរិយា

ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MOEURS & COUTUMES

សៀវភៅទស្សនាវដ្ដីចេញរាល់ខែ ពីព្រះរាជបណ្ណាល័យ

ឆ្នាំគំរប់ ១០

ខែ ១, ២, ៣, រួមគ្នា

កុងសីយសេនាបតីបានអនុញ្ញាតហើយ

សម្ដេចសង្ឃនាយកទាំងពីរគណៈយល់ព្រម

ភ្នំពេញ
ការផ្សាយរបស់ព្រះរាជបណ្ណាល័យ
ព. ស. ២៤៨១
គ. ស. ១៩៣៨

ព្រះរាជបណ្ណាល័យកម្ពុជា

# KAMPUCHEA SURIYA

# កម្ពុជសុរិយា

## សៀវភៅទស្សនាវដ្ដីចេញរាល់ខែ ពីព្រះរាជបណ្ណាល័យ

## ឆ្នាំគំរប់ ១០

ខ្សែ ១, ២, ៣, រួមគ្នា

កុង្ស៊ីយសេនាបតីបានអនុញ្ញាតហើយ

សម្ដេចសង្ឃនាយកទាំងពីរគណៈយល់ព្រម

ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព. ស. ២៤៨១

គ. ស. ១៩៣៨

# បញ្ជីរឿង


ទំព័រ

១ ព្រហ្មចរិយកថា របស់ព្រះមហា វិសេស ក្រុមពុទ្ធសាសនបណ្ឌិត្យ ប្រែនិង
រៀបរៀង . . . . . . . . . . . . . . . . . . . . . . . ៣

២ វិយប្បកាសនី របស់អាចារ្យ ហ៊ិន ក្រុមពុទ្ធសាសនបណ្ឌិត្យ រៀបរៀង . . . ២៣

៣ ពិធីពលិការព្រះពិស្ណុការ (វេស្សកម្ម) ព្រះមហាពិទូរ ក្រសេម រៀបរៀង . . . ៣៩

៤ ពិធីបុណ្យភ្ជាទសមាស តាមទំនៀមលាវ អាចារ្យ ស៊ី - អួន (សុខតិស្ស)
រៀបរៀង . . . . . . . . . . . . . . . . . . . . . . . ៤៧

៥ រឿងព្រេងខ្មែរ ដែលមិនទាន់បោះពុម្ព: រឿងធនញ្ជ័យបណ្ឌិត (សេចក្ដីចាស់) . . ៦៧


# រូបក្រៅរឿង


រូបពាលីនិងទូភីច្បាំងគ្នា (ក្នុងរឿងរាមកេរ្តិ៍) ឆ្លាក់ទុកនៅធ្នឹមទ្វារវត្តចំណោម ឃុំ-
ព្រែកកុយ ស្រុកស្អាង ខេត្តកណ្ដាល . . . . . . . . . . . . . . . ១

# TABLE DES MATIÈRES

Pages

1. Brahmacariyakathā . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 3

2. Vayappakāsinī . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 23

3. Offrandes faites au dieu-architecte (Vessakamma) . . . . . . . . . . . 39

4. Cérémonies des douze mois de l'année selon les coutumes laotiennes . . . . . . . . . . . . . . . . . . . . . . . . . . 47

5. Conte populaire cambodgien inédit : (Légende de Thmenh chey Pandit) . . . . . . . . . . . . . . . . 67

## Hors texte

Linteau de vat Chum-Nom srok de Saang khum Prek-Koy (Kandal) . . . . . . . . . . . . . . . . . . . . . . . . . . . . 1



រូបពាលីនឹងទូរភីច្បាំងគ្នា (ក្នុងរឿងរាមកេរ្តិ៍) ឆ្លាក់ទុកនៅផ្តិមទ្វារវត្តចំណោម ឃុំព្រៃកកុយ ស្រុកស្អាង ខេត្តកណ្ដាល ។

ព្រហ្មចរិយកថា

របៀបពាក្យទេសនា

ព្រះមហា (សែស) ក្រុមជំនុំព្រះត្រៃបិដក

ប្រែនិងរៀបរៀង

នមោ ឱមាត្យារទ្ធស្ស រតនត្តយស្ស សាធុកំ

សូមថ្វាយបង្គំចំពោះ ព្រះរត្នត្រ័យ ដែលប្រពៃហើយជាឧត្តម គឺ អ. ឧ. ម. ដូច្នេះ គឺព្រះពុទ្ធជាម្ចាស់ប្រកបដោយអនន្តគុណ មានឆ្ងាយចាកកិលេសជាដើម នឹងព្រះធម៌ដ៏ខ្ពស់ផុត ដែលព្រះពុទ្ធជាម្ចាស់អង្គនោះ ទ្រង់ត្រាស់សំដែងហើយដោយល្អ នឹងព្រះអរិយសង្ឃ ពពួកធំ មានព្រះសង្ឃដែលបានដល់នូវសោតាបត្តិមគ្គជាដើម សូមឱ្យសំរេចប្រយោជន៍ទាំងពួង ។

ព្រហ្មចរិយកថា

## សំដែងអំពីព្រហ្មចរិយធម៌

ជនជាសប្បុរសទាំងឡាយ ដែលជាសម្មាទិដ្ឋិ មានបញ្ញាយល់ត្រូវល្អ ប្រកបដោយការប្រព្រឹត្តយ៉ាងប្រសើរឯណា ការប្រព្រឹត្តយ៉ាងប្រសើរនោះ បានឈ្មោះថាព្រហ្មចរិយ ។ ព្រោះការដែលប្រព្រឹត្តនោះព្រាសចាកបាបធម៌ មានសេចក្តីកំណាញ់ជាមន្ទិលជាដើម នឹងនាំឲ្យចំរើននៃគុណធម៌មានមេត្តាជាដើម ។

ក៏ឯព្រហ្មចរិយនោះ ព្រះសិរិមង្គលាចារ្យ លោកបាន សំដែងទុកក្នុងគម្ពីរ មង្គលត្ថទីបនី អដ្ឋកថាមង្គលសូត្រថា មាន ១០ ប្រការ ដោយបទបាលីថា

ព្រហ្មចរិយំ នាម ទាន វេយ្យាវច្ច បញ្ចសីល អប្បមញ្ញា មេថុនវិរតិ សទារសន្តោស វីរិយ ឧបោសថង្គ អរិយមគ្គ សាសនវសេន ទសវិធំ ហោតិ ។

(ប្រែថា) ព្រហ្មចរិយធម៌មាន ១០ ប្រការ គឺ ទាន ការឲ្យនូវវត្ថុមានបាយជាដើម ១ វេយ្យាវច្ច សេចក្ដីខ្វល់ខ្វាយក្នុងការកុសលរបស់អ្នកដទៃជាដើម ១ បញ្ចសីល សីលទាំង ៥ មានវៀរសម្លាប់សត្វជាដើម ១ អប្បមញ្ញា គឺព្រហ្មវិហារទាំង ៤ មានមេត្តាជាដើម ១ មេថុនវិរតិ ការវៀរមេថុនធម្ម ១ សទារសន្តោស សេចក្ដីសន្តោសដោយភរិយារបស់ខ្លួន ១ វីរិយ សេចក្ដីព្យាយាមមិនខ្ជិលច្រអូស ១ ឧបោសថង្គ អង្គនៃឧបោសថទាំង ៨ មានវៀរសម្លាប់សត្វជាដើម ១ អរិយមគ្គ ផ្លូវមានអង្គ ៨ ដ៏ប្រសើរ មានសម្មាទិដ្ឋិជាដើម ១ សាសន

ពាក្យប្រៀនប្រដៅទាំងអស់របស់ព្រះសាស្តា ១ ត្រូវជា ១០ ប្រការផងគ្នា ។

ឯទានដែលឈ្មោះថា ព្រហ្មចរិយនោះ មានមកក្នុងវិធុរ-ជាតក សេចក្តីថា ព្រះពុទ្ធជាម្ចាស់នៃយើងទាំងឡាយ ទ្រង់សោយព្រះជាតិជាព្រះពោធិសត្វ ទ្រង់ព្រះនាមថា វិធុរបណ្ឌិត ជាអ្នកប្រាជ្ញមានបញ្ញាឆ្លៀវឆ្លាស ឯវិធុរបណ្ឌិតនោះក៏បានទៅកាន់ពិភពនាគ បានជួបនឹងព្រះបាទវរុណនាគរាជ បានឃើញសម្បត្តិរបស់ព្រះបាទវរុណនាគរាជ ដ៏ថ្កុំថ្កើងថ្លៃថ្លា ហើយក៏ក្រាបទូលសួរថា កាលពីដើមព្រះអង្គបានប្រព្រឹត្តវត្តដូចម្តេច ប្រព្រឹត្តព្រហ្មចរិយធម៌ដូចម្តេច ឫទ្ធិគឺអានុភាពក្តី ជុតិ គឺរស្មីកាយក្តី កំឡាំងកាយក្តី សេចក្តីព្យាយាមក្តី កំណើតក្នុងពិភពនាគនេះក្តី ជាផលនៃកម្មអ្វី នេះជាមហាវិមានរបស់ព្រះអង្គឬអ្វី ?

ព្រះបាទវរុណនាគរាជឆ្លើយថា

អហញ្ច ភរិយា ច មនុស្សលោកេ
សទ្ធា ឧភោ ទានបតី អហុម្ហា

ឧទបានភូតំ មេ ឃរំ តទាសិ
សន្តប្បិតា សមណព្រាហ្មណា ច
មាលញ្ច គន្ធញ្ច វិលេបនញ្ច
បទីបិយំ សេយ្យមុបស្សយញ្ច
អច្ឆាទនំ សយនំ អន្នបានំ
សក្កច្ចំ ទានានិ អទម្ហ តត្ថ
តំ មេ វតំ តម្បន ព្រហ្មចរិយំ
តស្ស សុចិណ្ណស្ស អយំ វិបាកោ
ឥទ្ធី ជុតី ពល វិរិយូបបត្តិ
ឥទញ្ច មេ ធីរ បហារិមានត្ថិ ។

(ប្រែថា) ជនទាំង២នាក់ គឺខ្លួនយើងនឹងភរិយារបស់យើង បានកើតក្នុងមនុស្សលោក ជាអ្នកមានសទ្ធា ជាម្ចាស់នៃទាន ផ្ទះរបស់យើងមានសភាពជាអណ្តូង ជាទីប្រជុំនៃសមណព្រាហ្មណ៍ៗ យើងក៏បានអង្គាសឲ្យឆ្អែតស្កប់ស្កល់ហើយ យើងឲ្យទានទាំងឡាយដោយគោរព ក្នុងមនុស្សលោកនោះ គឺ កម្រងផ្កា ១ គ្រឿងក្រអូប ១ គ្រឿងលាប ១ គ្រឿងប្រទីប ១

សេយ្យា ទីដេកមានពូក កន្ទេល កម្រាលជាដើម ១ ទីលំនៅ ១ បាយ ១ គ្រឿងស្លៀកដណ្ដប់ ១ ទីដេក-អង្គុយមានគ្រែតាំងជាដើម ១ ទឹក ១ ទាននោះជាវត្តរបស់យើង ទាននោះជាព្រហ្មចរិយរបស់យើង ឫទ្ធិគឺអានុភាពក្ដី ជុតិគឺរស្មីកាយក្ដី នឹងកំឡាំងកាយក្ដី នឹងសេចក្ដីព្យាយាមក្ដី នឹងកំណើតក្នុងពិភពនាគនេះក្ដី នេះជាផលរបស់ព្រហ្មចរិយនោះដែលយើងបានប្រព្រឹត្តធ្វើហើយដោយប្រពៃ ម្នាលបុរសជាអ្នកប្រាជ្ញ នេះជាមហាវិមានរបស់យើង ។

ព្រះគាថាដែលព្រះបាទវរុណនាគរាជ ពោលមកនេះសំដៅយកទានជាវត្ត នឹងជាព្រហ្មចរិយរបស់ខ្លួន ព្រោះហេតុនោះ បានជាអដ្ឋកថាចារ្យ លោកអធិប្បាយថា ទានឈ្មោះថាព្រហ្មចរិយ ដោយប្រការដូច្នេះឯង ។

ម្យ៉ាងទៀត ទានប្រែថា ចេតនាជាហេតុបណ្ដាលឡើងគាំឲ្យៗនូវទេយ្យធម៌ដល់អ្នកដទៃ បើនឹងចែកដោយប្រភេទទាននេះមាន ៣ ប្រការ គឺ ជាគចេតនាទាន ១ វិរតិទាន ១ ទេយ្យ-ធម្មទាន ១ ។

ឯចាគចេតនាទាន ប្រែថាចេតនាជាគ្រឿងលះបង់នូវទេយ្យធម៌ដល់អ្នកដទៃ សមតាមព្រះបាលីក្នុងទានសូត្រ គម្ពីរអង្គុត្តរនិកាយ អដ្ឋកនិបាតថា "សទ្ធា ហិរិយំ កុសលញ្ច ទានំ (ប្រែថា) សទ្ធា គឺសេចក្ដីជឿក្ដី ហិរិ គឺសេចក្ដីខ្មាសបាបឬខ្ពើមបាបក្ដី កុសល គឺអំពើដែលល្អ ឬកុសលចិត្តក្ដី បានឈ្មោះថាទាន បំណែកអដ្ឋកថា អធិប្បាយថា បុគ្គលឲ្យទានដោយសទ្ធាឯណា សទ្ធានោះបានឈ្មោះថាទាន បុគ្គលឲ្យទានដោយហិរិឯណា ហិរិនោះបានឈ្មោះថាទាន កុសលគឺអំពើដែលឥតមានទោសបានឈ្មោះថាទាន ចាគចេតនាទានមានសេចក្ដីអធិប្បាយដោយសង្ខេបដូច្នេះ ។

ឯវិរតិទាន គឺការវៀរអំពើទុច្ចរិតមានសម្លាប់សត្វជាដើម បានខាងសីលទាំង ៥ គឺវៀរសម្លាប់សត្វ ១ វៀរលួចទ្រព្យគេ ១ វៀរលួចប្រពន្ធកូនគេ ១ វៀរនិយាយពាក្យកុហក ១ វៀរផឹកទឹកស្រវឹងដែលជាទីតាំងនៃសេចក្ដីប្រមាទ ១ ។

ឯទេយ្យធម្មទាន បានខាងទេយ្យវត្ថុទាំង ១០ មានបាយជាដើម ដូចមានព្រះគាថាថា ៖

អន្នំ បានំ វត្ថំ យានំ   មាលា គន្ធំ វិលេបនំ
សេយ្យាវសថំ បទីបេយ្យំ   ទានវត្ថុ ឥមេ ទស ។

(ប្រែថា) ទានវត្ថុទាំង ១០ នេះ គឺ បាយ ១ ទឹក ១ សំពត់ ១ យាន ១ កម្រងផ្កា ១ គ្រឿងក្រអូប ១ គ្រឿងលាប ១ ទីដេក ១ ទីលំនៅ ១ គ្រឿងប្រទីប ១ ។

ត្រង់ពាក្យថាបាយ សំដៅយកគ្រឿងស៊ី គឺខាទនីយនិងភោជនីយទាំងអស់ ។ ពាក្យថា ទឹក សំដៅយកទឹកបាន[1] ទាំង ៨ ប្រការៈ មានទឹកបានដែលគេធ្វើដោយផ្លែស្វាយជា

---

[1] ទឹកបាន ៨ គឺ អម្ពបានំ ទឹកបាន (ដែលគេធ្វើដោយ) ផ្លែស្វាយ ១ ជម្ពុបានំ ទឹកបានផ្លែព្រីង ១ ចោចបានំ ទឹកបានផ្លែចេកមានគ្រាប់ ១ មោចបានំ ទឹកបានផ្លែចេកឥតគ្រាប់ ១ មធុកបានំ ទឹកបានផ្លែស្រគំ ១ មុទ្ទិកបានំ ទឹកបានផ្លែចន្ទន៍ ១ សាលុកបានំ ទឹកបានមើមនៃផលជាតមានព្រលិតក្រហមជាដើម ១ ផារុសកបានំ ទឹកបានផ្លែមាក់ប្រាង ១ ។

ទឹកបាន ៨ ដទៃទៀតគឺ កោសម្ពបានំ ទឹកបានផ្លែសង្ឃ្យ៉ែរ ១ កោលបានំ ទឹកបានផ្លែពុទ្រាតូច ១ ពទរបានំ ទឹកបានផ្លែពុទ្រាធំ ១ ឃតបានំ ទឹកបានធ្វើដោយទឹកដោះភរឬទឹកដោះថ្លា ១ តេលបានំ ទឹកបានធ្វើដោយប្រេងមានប្រេងល្ងជាដើម ១ បយោបានំ ទឹកបានធ្វើដោយទឹកដោះស្រស់ ១ យាគុបានំ ទឹកបានធ្វើដោយបបរ ១ រសបានំ ទឹកបានធ្វើដោយរសជាតនៃវត្ថុមានបន្លែជាដើម ១ ។

ទឹកបានទាំងនេះ ជាភេសជ្ជៈយាមកាលិក ភិក្ខុឆាន់ក្នុងវិកាលបាន តែទទួលទុកបានត្រឹម ១ ថ្ងៃ ១ យប់ប៉ុណ្ណោះយ៉ាងយូរ បើទុកឲ្យហួសពីកាលកំណត់នេះ ហើយយកមកឆាន់ត្រូវអាបត្តិទុក្កដ ។

ដើម ។ ពាក្យថា សំពត់ សំដៅយកសំពត់សម្រាប់ស្លៀក នឹងសំពត់សម្រាប់ដណ្ដប់ជាដើម ។ ពាក្យថា យាន សំដៅយកវត្ថុដែលញាំងដំណើរឲ្យសំរេច មានរថនឹងវហ៍ជាដើម មានស្បែកជើងជាទីបំផុត ។ ពាក្យថា កម្រងផ្កា សំដៅយកផ្កាឈើទាំងអស់ ដែលផ្សេងគ្នាដោយក្លិន ។ ពាក្យថា គ្រឿងក្រអូប សំដៅយកគន្ធជាតិទាំងអស់នឹងគ្រឿងឧបករណ៍ដល់គ្រឿងក្រអូប ដែលគេកិនក្ដី មិនបានកិនក្ដី ។ ពាក្យថា គ្រឿងលាប សំដៅយកវត្ថុសម្រាប់ធ្វើស្បែកខាងក្រៅឲ្យគួរជាទីត្រេកអរ ។ ពាក្យថា ទីដេក សំដៅយកវត្ថុដែលគួរជាទីដេក-អង្គុយ មានគ្រែតាំងចៀបព្រំជាដើម ។ ពាក្យថា ទីសំនៅ សំដៅយកផ្ទះសំបែងជាទីអាស្រ័យ សម្រាប់បន្ទោបង់នូវសេចក្ដីអន្តរាយ សេចក្ដីលំបាក មានខ្យល់នឹងកំដៅថ្ងៃជាដើម ។ ពាក្យថា គ្រឿងប្រទីប សំដៅយកវត្ថុសម្រាប់ទំនុកបំរុងដល់ប្រទីប មានអំបែងប្រទីបជាដើម ។ ទានមាន ៣ ប្រការដូច្នេះឯង ។

ម្យ៉ាងទៀត ទាននោះលុះតែប្រកបដោយអង្គទាំង ៦ ទើបមានផលច្រើន សមដោយព្រះបាលីពុទ្ធភាសិត ក្នុងគម្ពីរអង្គុត្តរនិកាយ ឆក្កនិបាត មានរឿងថា សម័យមួយ ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។

សម័យនោះឯង ឧបាសិកាឈ្មោះវេឡុកណ្ឌកីនន្ទមាតា កំពុងថ្វាយទានដែលប្រកបដោយអង្គទាំង ៦ ដល់ភិក្ខុសង្ឃ មានព្រះសារីបុត្តនឹងព្រះមោគ្គល្លានជាប្រធាន ។

ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់មានទិព្វចក្ខុ ដ៏បរិសុទ្ធកន្លងហួសចក្ខុរបស់មនុស្សធម្មតា ទ្រង់ឃើញឧបាសិកាឈ្មោះវេឡុកណ្ឌកីនន្ទមាតា កំពុងតែថ្វាយទានដែលប្រកបដោយអង្គទាំង ៦ ដល់ភិក្ខុសង្ឃ មានព្រះសារីបុត្តនឹងព្រះមោគ្គល្លានជាប្រធាន លុះឃើញហើយ ក៏មានព្រះបន្ទូលត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះឧបាសិកាឈ្មោះវេឡុកណ្ឌកីនន្ទមាតា កំពុងថ្វាយទានប្រកបដោយអង្គទាំង ៦ ដល់ភិក្ខុសង្ឃ មានសារីបុត្តនឹងមោគ្គល្លានជាប្រធាន ម្នាលភិក្ខុ

ទាំងឡាយ ក៏ឯទានប្រកបដោយអង្គទាំង ៦ នោះតើដូចម្តេច ម្នាលភិក្ខុទាំងឡាយ អង្គរបស់ទាយកគឺអ្នកឲ្យមាន ៣ អង្គរបស់បដិគ្គាហកគឺអ្នកទទួលមាន ៣ អង្គ ៣ របស់ទាយកនោះតើដូចម្តេច ឥធ ភិក្ខវេ ទាយកោ បុព្វេវ ទានា សុមនោ ហោតិ ទទំ ចិត្តំ បសាទេតិ ទត្វា អត្តមនោ ហោតិ ។ (ប្រែថា) ម្នាលភិក្ខុទាំងឡាយ ទាយកក្នុងលោកនេះ មានចិត្តត្រេកអរក្នុងកាលមុនឲ្យ ១ កំពុងឲ្យញុំាងចិត្តឲ្យជ្រះថ្លា ១ ឲ្យរួចហើយមានចិត្តត្រេកអរទៀត ១ អង្គ ៣ របស់ទាយកដូច្នេះ ។

អង្គ ៣ របស់បដិគ្គាហកនោះ តើដូចម្តេច ឥធ ភិក្ខវេ បដិគ្គាហកា វីតរាគា វា ហោន្តិ រាគវិនយាយ វា បដិបន្នា វីតទោសា វា ហោន្តិ ទោសវិនយាយ វា បដិបន្នា វីតមោហា វា ហោន្តិ មោហវិនយាយ វា បដិបន្នា ។ ម្នាលភិក្ខុទាំងឡាយ បដិគ្គាហកក្នុងសាសនានេះ មានរាគប្រាសហើយ (អស់រាគ) ឬប្រតិបត្តិដើម្បីកំចាត់បង់នូវរាគ ១ មានទោសប្រាសហើយ ឬប្រតិបត្តិដើម្បីកំចាត់បង់នូវទោស ១ មាន

មោហប្រាសហើយ ឬប្រតិបត្តិដើម្បីកំចាត់បង់នូវមោហ ១ អង្គ ៣ របស់បដិគ្គាហកដូច្នេះ ។

ម្នាលភិក្ខុទាំងឡាយ កាលបើទានប្រកបដោយអង្គទាំង ៦ យ៉ាងនេះហើយ បុគ្គលមិនអាចនឹងគណនាត្រារាប់បុណ្យ ជាប៉ុណ្ណេះប៉ុណ្ណោះបានឡើយ គឺជាបុណ្យច្រើនរាប់ពុំបាន ។

ម្យ៉ាងទៀត ទានមាន ២ ប្រការ គឺ បាដិបុគ្គលិកទាន ១ សង្ឃគតាទាន ១ បាដិបុគ្គលិកទាន ជាទានដែលគេឲ្យចំពោះបុគ្គលមួយ ៗ តាមស្រឡាញ់ តាមគាប់ចិត្ត សង្ឃគតាទាន ជាទានដែលតាំងនៅក្នុងសង្ឃ គឺ ទានដែលគេឲ្យចំពោះសង្ឃ មិនបានចំពោះបុគ្គលឡើយ ។

ឯបាដិបុគ្គលិកទាន មាន ១៤ ប្រការ សង្ឃគតាទាន មាន ៧ ប្រការ សមដោយព្រះបាលីក្នុងទក្ខិណាវិភង្គសូត្រ គម្ពីរមជ្ឈិមនិកាយ ឧបរិបណ្ណាសក មាននិទានថា សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងនិគ្រោធារាម ទៀបក្រុងកបិលវត្ថុ ក្នុងសក្កជនបទ ។

គ្រានោះ នាងបជាបតីគោតមី នាំយកសំពត់ថ្មី ១ គូទៅថ្វាយព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយនៅក្នុងទីដ៏សមគួរ ។

លុះនាងបជាបតីគោតមី អង្គុយនៅក្នុងទីដ៏សមគួរហើយ ក៏ក្រាបទូលព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន សំពត់ថ្មី ១ គូនេះ ខ្ញុំម្ចាស់រវៃខ្លួនឯង ត្បាញខ្លួនឯង បំពោះថានឹងប្រគេនព្រះអង្គ សូមព្រះអង្គទទួលយកសំពត់នេះចុះ ដោយសេចក្ដីអនុគ្រោះដល់ខ្ញុំព្រះអង្គ ។

ព្រះដ៏មានព្រះភាគ មានព្រះបន្ទូលនឹងនាងបជាបតីគោតមីថា បពិត្រព្រះនាងគោតមី ចូរព្រះនាងឲ្យដល់សង្ឃចុះ កាលបើព្រះនាងឲ្យដល់សង្ឃហើយ ក៏ឈ្មោះថាបូជាដល់តថាគតផង ដល់សង្ឃផង ។

ព្រះនាងបជាបតីគោតមី ក្រាបបង្គំទូលយ៉ាងនេះជាគំរប់ ២ ដង ៣ ដង ព្រះអង្គក៏មានព្រះបន្ទូលដូច្នោះដដែល ។

ទើបព្រះអានន្ទដ៏ម្ចាស់ ក្រាបទូលព្រះដ៏មានព្រះភាគថា សូមព្រះអង្គទទួលយកសំពត់ថ្មី ១ គូរបស់ព្រះនាងមហាបជាបតី

គោតមីនោះទៅ ព្រោះហិព្រះនាងមហាបជាបតីគោតមីជាព្រះមាតុច្ឆារបស់ព្រះអង្គ មានឧបការច្រើនដល់ព្រះអង្គ ជាអ្នកបិញ្ចឹមរក្សាថ្វាយទឹកក្សីរ ព្រោះហិកាលដែលព្រះមាតាព្រះអង្គសោយព្រះវិលាលៃទៅ មានតែព្រះនាងថ្វាយព្រះក្សីរ (បំបៅដោះ) ព្រះអង្គ បំណែកព្រះអង្គក៏មានឧបការច្រើនដល់ព្រះនាងដែរ លុះព្រះនាងអាស្រ័យនឹងព្រះអង្គហើយ ក៏បានដល់នូវព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាទីពឹង ព្រះនាងអាស្រ័យនឹងព្រះអង្គហើយ ក៏វៀរសម្លាប់សត្វ វៀរលួចទ្រព្យគេ វៀរប្រព្រឹត្តខុសក្នុងកាម វៀរនិយាយពាក្យកុហក វៀរហេតុជាទីតាំងនៃសេចក្តីប្រមាទ ព្រោះទឹកស្រវឹងគឺសុរានឹងមេរ័យ (ហើយថែមទាំង) ប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ នឹងប្រកបដោយសីលជាទីត្រេកអរនៃព្រះអរិយបុគ្គល ព្រះនាងអាស្រ័យនឹងព្រះអង្គហើយ ក៏អស់សេចក្តីសង្ស័យក្នុងកងទុក្ខនឹងតណ្ហាជាហេតុឱ្យកើតទុក្ខ នឹងព្រះនិព្វានជាទីរលត់នៃកងទុក្ខ នឹងសេចក្តីប្រតិបត្តិ ដំណើរទៅ

កាន់ព្រះនិព្វាន ជាទីរលត់នៃកងទុក្ខ ព្រះអង្គមានឧបការច្រើនដល់ព្រះនាងយ៉ាងនេះ ។

ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលអានន្ទ បុគ្គល (ជាកូនសិស្ស) អាស្រ័យនឹងបុគ្គល (ជាអាចារ្យ) ឯណា ហើយបានដល់នូវព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាទីពឹង ហើយធ្វើអភិវាទនកម្ម(១) បច្ចុដ្ឋានកម្ម(២) អញ្ជលិកម្ម(៣) សាមីចិកម្ម(៤) ព្រមទាំងបូជាដោយបច្ច័យ ៤ ចំពោះបុគ្គលនោះ (ដោយការតបគុណ) តថាគតមិនបានពោលថាធ្វើដោយល្អឡើយ ។

ម្នាលអានន្ទ បុគ្គលអាស្រ័យនឹងបុគ្គលឯណាហើយវៀរចាកវេរាទាំង ៥ ហើយធ្វើអភិវាទនកម្មជាដើម ចំពោះបុគ្គលនោះ តថាគតមិនបានពោលថាធ្វើដោយល្អឡើយ ។

ម្នាលអានន្ទ បុគ្គលអាស្រ័យនឹងបុគ្គលឯណា ហើយប្រកបដោយសេចក្ដីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ប្រកបដោយសីលជាទីត្រេកអរនៃព្រះអរិយបុគ្គល

១ ការថ្វាយបង្គំដោយគោរព ។ ២ ការក្រោកទៅទទួល ។ ៣ ការលើកដៃប្រណម្យសំពះ ។ ៤ ការធ្វើសេចក្ដីសមគួរ ។

ហើយធ្វើអភិវាទនកម្មជាដើម បំពោះបុគ្គលនោះ តថាគតមិនបានពោលថា ធ្វើដោយល្អឡើយ ។

ម្នាលអានន្ទ បុគ្គលអាស្រ័យនឹងបុគ្គលឯណា ហើយអស់សេចក្តីសង្ស័យក្នុងអរិយសច្ចទាំង ៤ ហើយធ្វើអភិវាទនកម្មជាដើម បំពោះបុគ្គលនោះ តថាគតមិនបានពោលថា ធ្វើដោយល្អឡើយ ។

ម្នាលអានន្ទ បាដិបុគ្គលិកទានមាន ១៤ ប្រការគឺ បុគ្គលឲ្យទានដល់ព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ ១ ដល់ព្រះបច្ចេកសម្ពុទ្ធ ១ ដល់ព្រះអរហន្តជាសាវករបស់ព្រះតថាគត ១ ដល់បុគ្គលដែលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះអរហត្តផល ១ ដល់ព្រះអនាគាមិបុគ្គល ១ ដល់បុគ្គលដែលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ១ ដល់ព្រះសកិទាគាមិបុគ្គល ១ ដល់បុគ្គលដែលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកិទាគាមិផល ១ ដល់ព្រះសោតាបន្នបុគ្គល ១ ដល់បុគ្គលដែលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ១ ដល់បុគ្គលខាងក្រៅព្រះពុទ្ធសាសនា តែមានសេចក្តីជឿ

ណាយក្នុងកាម ១ ដល់បុថុជ្ជនមានសីលបរិសុទ្ធ ១ ដល់បុថុជ្ជនទ្រុស្សីល[១] ១ ឲ្យទានដល់សត្វតិរច្ឆាន ។

ម្នាលអានន្ទ ឲ្យទានដល់សត្វតិរច្ឆាន បានអានិសង្ស[២] មួយរយអត្តភាព ។

ឲ្យទានដល់មនុស្សបុថុជ្ជនទ្រុស្សីល បានអានិសង្សមួយពាន់អត្តភាព ។

ឲ្យទានដល់បុថុជ្ជនមានសីលបរិសុទ្ធ បានអានិសង្សមួយសែនអត្តភាព ។

ឲ្យទានដល់បុគ្គលខាងក្រៅព្រះពុទ្ធសាសនា ដែលមានសេចក្តីនឿយណាយក្នុងកាម បានអានិសង្សមួយសែនកោដិអត្តភាព ។

ឲ្យទានដល់បុគ្គលដែលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល បានអានិសង្សរាប់ពុំបាន ប្រមាណពុំអស់ឡើយ ។

---

១ បុគ្គលមានសីលអាក្រក់គឺមានសីលដាច់ - ធ្លុះ - ពពាល - ពព្រុះ ឬមិនមានសីល ។

២ អាយុ ១ ពណ៌សម្បុរកាយ ១ សេចក្តីសុខ ១ កំឡាំង ១ ប្រាជ្ញា ១ ទាំង ៥ នេះ ហៅថាអានិសង្ស ។

បំណែកសោតាបន្នបុគ្គលក្តី បុគ្គលដែលប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកិទាគាមិផលក្តី ព្រះសកិទាគាមិបុគ្គលក្តី បុគ្គលដែលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផលក្តី ព្រះអនាគាមិបុគ្គលក្តី បុគ្គលដែលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្តផលក្តី ព្រះអរហន្តជាសាវករបស់ព្រះតថាគតក្តី ព្រះបច្ចេកសម្ពុទ្ធក្តី ព្រះតថាគតជាព្រះអរហន្តសម្មាសម្ពុទ្ធក្តី មិនបាច់និយាយឡើយ ។

ម្នាលអានន្ទ បំណែកសង្ឃគតាទាន មាន ៧ ប្រការគឺ បុគ្គលឲ្យទានដល់ឧភតោសង្ឃ[១] មានព្រះពុទ្ធអង្គជាប្រធាន ១ ដល់ឧភតោសង្ឃ ក្នុងកាលដែលតថាគតបរិនិព្វានទៅហើយ ១ ដល់ភិក្ខុសង្ឃ ១ ដល់ភិក្ខុនីសង្ឃ ១ ដល់បុគ្គលដែលគេឧទ្ទិស[២]យកអំពីឧភតោសង្ឃ ១ ដល់បុគ្គលដែលគេឧទ្ទិសយកអំពីភិក្ខុសង្ឃ ១ ឲ្យទានដល់បុគ្គលដែលគេឧទ្ទិសយកអំពីភិក្ខុនីសង្ឃ ១ ។

---

១ សង្ឃទាំងពីរចំណែក គឺ ភិក្ខុសង្ឃ ១ ភិក្ខុនីសង្ឃ ១ ។ ២ ទាយកទៅនិមន្តអំពីគណសង្ឃ ដោយមិនចំពោះរូបភិក្ខុ ឬភិក្ខុនី ជាតាមបញ្ជីកាត់អំពីគណសង្ឃទៅ ។

ម្នាលអានន្ទ លុះកាលជាអនាគតអង្វែងយូរទៅ មានតែគោត្រភូបុគ្គល[១] ជាអ្នកទ្រុស្តសីល មានធម៌លាមក មានតែសំពត់កាសាវព័ន្ធព័ទ្ធ បើមានគេឱ្យទានឧទ្ទិសសង្ឃ ក្នុងពួកបុគ្គលទ្រុស្តសីលទាំងនោះ គង់នៅមានផលច្រើន ម្នាលអានន្ទ តថាគតពោលថា សង្ឃគតាទាននោះ មានផលច្រើនរាប់ពុំបាន ម្នាលអានន្ទ តថាគត មិនដែលពោលថា បាដិបុគ្គលិកទាន មានផលច្រើនជាងសង្ឃគតាទានដោយបរិយាយឯណាមួយឡើយ ។

(មានតទៅទៀត)

---

១ បុគ្គលគ្រាន់តែរក្សាគោត្រអ្នកបួសឲ្យនៅប៉ុណ្ណោះ គ្រាន់តែមានឈ្មោះថាសមណប៉ុណ្ណោះ គ្មានផ្លូវប្រតិបត្តិ ។

វេយ្យាករណ៍

របស់អាចារ្យ ហិម ក្រុមពុទ្ធសាសនបណ្ឌិត្យ

រៀបរៀង

ធម៌អាថ៌ដែលខ្ញុំបំបែកបេញ ឲ្យសមរម្យនឹងវ័យ ៣ ប្រ-ការនេះ ខ្ញុំតែងតែអធិប្បាយពន្យល់សិស្សានុសិស្សគ្រប់កន្លែង តាំងអំពីខ្ញុំបានទទួលដើរត្រួតត្រាការសិក្សាបរមវិជ្ជាសាលាវត្ត ក្នុងរាជការ លុះដល់ថ្ងៃ ១៤ កើត ខែអស្សុជ ឆ្នាំម្សាញ់ឯកស័ក គឺថ្ងៃ ១៨ ខែឧកតូប ឆ្នាំ ១៩២៧ នោះខ្ញុំបានសរសេរចុះសៀវ-ភៅ តែនៅមិនទាន់សព្វគ្រប់ តាំងពីពេលនោះមកខ្ញុំមានកិច្ចការច្រើនលើខ្លួនមិនបានធ្វើបង្ហើយ ដោយសេចក្តីបំណងនឹងប្តឹងរាជការបោះពុម្ពផ្សាយដល់ពួកអ្នកសិក្សា ដើម្បីសេចក្តីសុខ-បំរើនតាំងពីក្នុងលោកនេះដរាបដល់លោកខាងនាយ ព្រោះសេចក្តីនេះជាគុណអាចនឹងឲ្យសម្រេចប្រយោជន៍ទាំង ២ នោះបាន ទើបតែដល់មកថ្ងៃ ៧ រោច ខែអាសាឍ ឆ្នាំជូតអដ្ឋស័ក គឺថ្ងៃ ១២ ស៊ូយេត ឆ្នាំ ១៩៣៦ នេះ ខ្ញុំមានឱកាសបានទំនេរពេលព្រឹកហើយនឹងថ្ងៃសីលគ្រប់សីល ហេតុនេះខ្ញុំខំឆ្លៀតធ្វើ

បង្ហើយ ដើម្បីនឹងបានសូមអនុញ្ញាតបោះពុម្ពផ្សាយតាមសេចក្ដីបំណងដើម ។

ដោយអំណាចបុញ្ញរាសីនេះ ខ្ញុំសូមឧទ្ទិសផលជូនលោកអ្នកដ៏មានគុណទាំងឡាយ មានមាតាបិតានឹងលោកគ្រូអាចារ្យជាដើម សូមឲ្យលោកបានសេចក្ដីសុខ-ចំរើនគ្រប់កាលទាំងពួង បំណែកឯខ្លួនខ្ញុំសូមបានសម្រេចព្រះនិព្វានក្នុងអនាគតទៅហោង ។

ខ្ញុំព្រះករុណា

សូមនមស្សការចំពោះព្រះរតនត្រ័យដោយសិរសា គឺត្បូង

## ២- វយប្បត្តាសិទ្ធិ

បណ្ដាមនុស្សក្នុងលោកសន្និវាសទាំងមូល លោកអ្នកប្រាជ្ញពោលថាមានវ័យ ៣ ប្រការ គឺ ពីក្មេងហៅថា បឋមវ័យ កណ្ដាលហៅថា មជ្ឈិមវ័យ និងដល់ចាស់ហៅថា បច្ឆិមវ័យ វ័យ បានសេចក្ដីវិសូន្យ បំណែកលោកវោហារ វ័យជាកិរិយាចំរើនទៅវិញ ដោយយល់ថាចំរើនពីតូចទៅធំ ពីក្មេងទៅចាស់ ពីចាស់ទៅស្លាប់ ទាំងនេះយល់ថាចំរើនជាដរាប ពាក្យទាំងពីរយ៉ាងនេះ បើសង្កេតគិតទៅឃើញដូចជាពាក្យរួមត្រូវគ្នាតែម្យ៉ាង សេចក្ដីដែលចំរើនឡើងតាមលំដាប់ដូចបានពោលហើយក៏សមជាចំរើនមែន ប៉ុន្តែថាចំរើនទាំងអម្បាលនោះក៏ចំរើនទៅរកតែសេចក្ដីវិនាសស្លាប់សាបសូន្យដដែល ដូចក្នុងធម៌ថា កើតហើយបណ្ដោញទៅរកទ្រុឌទ្រោមគ្រាំគ្រា សេចក្ដីគ្រាំគ្រាមានហើយបណ្ដោញទៅរកឈឺចាប់ សេចក្ដីឈឺចាប់

មានហើយបណ្តោញទៅរកស្លាប់សាបសូន្យដែរ ម្យ៉ាងទៀត ដូចដំណើរព្រះអាទិត្យ រះឡើងហើយបំរើនឡើងតាមលំដាប់ ប៉ុន្តែបំរើនទាំងអម្បាលណោះ ក៏ស្រុតចុះទៅរកតែអស្តង្គតរលត់សូន្យដែរ ពាក្យដែលថាបំរើនឡើងត្រូវខាងដើម ឃើញថាបំរើនមែនៗ ពាក្យដែលថាសូន្យទៅត្រូវខាងចុង ឃើញថាសូន្យមែនៗដែរ ហេតុនេះពាក្យទាំងពីរយ៉ាងគឺ បំរើននឹងសូន្យ ដូចជារួមទៅលើតែសេចក្តីស្លាប់សូន្យតែម្យ៉ាងប៉ុណ្ណោះឯងអស់លោកអ្នកគប្បីកំណត់តាមត្រូវញ្ញូន វ័យ ថា សេចក្តីសាបសូន្យទៅចុះ ។

៣- វ័យកាលវិធី

លំដាប់នេះខ្ញុំនឹងបំណែកចែកវ័យដូចមានតទៅនេះ កាលពីដើមមនុស្សមានអាយុ ១០០ ឆ្នាំជាអាយុវ័យ លោកចែកថា តាំងពីកើតទៅទល់នឹងអាយុ ៣៣ ហៅថាបឋមវ័យ ពីអាយុ ៣៤ ទៅទល់នឹងអាយុ ៦៦ ហៅថាមជ្ឈិមវ័យ ពីអាយុ ៦៧ ទៅទល់នឹងអាយុ ១០០ ហៅថាបច្ឆិមវ័យ ជំទាត់

មនុស្សឥឡូវនេះ មានអាយុខ្លីថយចុះតាមកាល តាមសម័យ លោកចែកថា តាំងពីកើតឡើងទៅទល់នឹងអាយុ ២៥ ហៅថា បឋមវ័យ ។ ដំបូងឬវ័យទី ១ ពីអាយុ ២៦ ទៅទល់នឹងអាយុ ៥០ ហៅថាមជ្ឈិមវ័យ ឬមធ្យមវ័យ ។ កណ្ដាលឬវ័យទី ២ ពីអាយុ ៥១ ទៅទល់នឹងអាយុ ៧៥ ហៅថាបច្ឆិមវ័យ ។ ខាងចុងឬវ័យទី ៣ ថាបើមានមនុស្សណាមួយមានអាយុវែងកើនលើនដល់ ៨០ ឬ ៨០ ប្លាយឬ ៩០ នោះ អស់លោកអ្នកគប្បីដឹងថា មនុស្សនោះជាអ្នកសមប្រកបដោយគុណមានសីលគុណជាដើម គឺមិនសម្លាប់សត្វ មិនបៀតបៀនសត្វដោយពិត ថាបើមានមនុស្សណាមួយមានអាយុខ្លីរួញចុះមិនដល់ ៧៥ ឆ្នាំ នោះអស់លោកអ្នកគប្បីកំណត់ដឹងថា មនុស្សនោះជាមនុស្សដាច់សីលប្រកបដោយពៀរ គឺសម្លាប់សត្វ បៀតបៀនសត្វនោះឯង ដែលខ្ញុំកំណត់ថា ៧៥ ឆ្នាំជាអាយុខ័យនោះ ដោយហេតុកំណត់តាមព្រះពុទ្ធសាសនា ១០០ ឆ្នាំថយអស់ ១ ឆ្នាំ ឥឡូវព្រះពុទ្ធសាសនាកន្លងទៅ ២៤០០ ប្លាយឆ្នាំហើយ ឃើញថាថយអស់ទៅ ២៥ ឆ្នាំ នៅតែ ៧៥ ឆ្នាំជាកាលកំណត់អាយុខ័យ

ប៉ុណ្ណោះឯង ព្រោះថាកាលដែលត្រូវចាយចុះ ១០០ ឆ្នាំ ចាយអស់ ១ ឆ្នាំ ទោះកាលដែលត្រូវចំរើនឡើងវិញ ក៏ ១០០ ឆ្នាំ ចំរើនឡើង ១ ឆ្នាំដូចគ្នាដែរ ។

## ៤- ត្រៃវិជ្ជា

ក្នុងឱកាសនេះ ខ្ញុំនឹងរៀបរាប់ពីចំណេះវិជ្ជា ដើម្បីនឹងលើកការសិក្សាឲ្យចំរើនឡើង តាមសុភាសិតថា វ័យទី ១ ឲ្យខំស្វែងរករៀនវិជ្ជា វ័យទី ២ ឲ្យខំសន្សំរកទ្រព្យសម្បត្តិ វ័យទី ៣ ឲ្យខំប្រតិបត្តិធម៌អាថ៌ អំពីនេះខ្ញុំនឹងអធិប្បាយរឿងចំណេះវិជ្ជាជាមុន ដែលហៅថាវិជ្ជានោះ មាន ៣ ផ្នែក គឺ បឋមវិជ្ជា មជ្ឈិមវិជ្ជានឹងឧត្តមវិជ្ជា បឋមវិជ្ជានោះចំណែកខាងរៀនអក្សរនឹងលេខនព្វន្ត រៀនអក្សរនោះ រៀនឲ្យចេះមើលពាក្យ ចេះសរសេរនឹងចេះតែងសេចក្តី រៀនលេខនព្វន្តនោះ រៀនឲ្យចេះបូក ចេះសង ចេះគុណនឹងចេះចែក ទាំងចំណេះអក្សរ ទាំងចំណេះលេខនព្វន្ត ខំប្រឹងប្រែងរៀនឲ្យចេះចាំស្ទាត់ចំណាន ល្មមធ្វើការបាន ហើយនឹងចេះធម្មក្រិត្យជាច្បាប់សម្រាប់ចំរើន

ខ្លួនផង នេះឯងឈ្មោះថាបឋមវិជ្ជា មជ្ឈិមវិជ្ជានោះ រៀនច្បាប់ទំលាប់ រៀនកិច្ចរាជការផ្សេងៗ ឲ្យស្ទាត់ស្ទាញក្នុងក្រសួងរដ្ឋបាលនឹងក្រសួងតុលាការ ហើយនឹងចេះគតិលោកគតិធម៌ ល្មមនឹងរក្សាខ្លួនឲ្យសុខបានផង នេះឯងឈ្មោះថាមជ្ឈិមវិជ្ជា ឧត្តមវិជ្ជានោះ រៀនលទ្ធិអក្សរដែលសម្រាប់ប្រើក្នុងភាសាបាលី ឲ្យស្ទាត់ដល់ចេះប្រែភាសាបាលីមកជាភាសាខ្មែរ ហើយនឹងចេះធម៌វិន័យក្នុងព្រះពុទ្ធសាសនា ដល់នូវភាវៈជាអ្នកប្រាជ្ញ នេះឯងឈ្មោះថាឧត្តមវិជ្ជា ។

## ៤- បឋមវិជ្ជា

វិជ្ជាមាន ៣ ផ្នែកដូចបានថ្លែងមកហើយនេះ ប៉ុន្តែវិជ្ជាទាំងនេះជាវិជ្ជាទាក់ទងគ្នា អ្នកដែលមានប្រាជ្ញាចំណេះវិជ្ជាទាំងអស់នោះ លុះតែចេះបឋមវិជ្ជាក្បៀវក្លា ហើយទើបឈោងទៅចាប់វិជ្ជាទាំងនោះៗបាន ប្រសិនបើមិនចេះបឋមវិជ្ជាសោះ ឬចេះតែបន្តិចបន្តួច នោះជាបុគ្គលឆ្ងាយចាកមជ្ឈិមវិជ្ជានឹងឧត្តមវិជ្ជានោះពេកណាស់ បានជាពេលនេះខ្ញុំមានបំណងនឹងពណ៌នា

បរមវិជ្ជា ដើម្បីពន្យល់អស់លោកអ្នកឱ្យភ្ញាក់រឭកស្គាល់ប្រយោជន៍វិជ្ជាដ៏ថ្លៃថ្លា ចំណេះវិជ្ជាដែលចេះអក្សរនឹងលេខនពន្ធនេះ ជាវិជ្ជាមានដំរៃច្រើនណាស់ វិជ្ជានេះហើយដែលជាវិជ្ជាតែងលើកស្ទួយអ្នកសិក្សាមួយ ៗ ឱ្យខ្ពស់ផុតពីថ្នាក់ក្រោមដែលជាថ្នាក់ដុនដាបទាបថោក ឱ្យស្ទុះឡើងទៅកាន់ថ្នាក់លើជាថ្នាក់ប្រសើរថ្កើងថ្កាន គឺ ជាអ្នកមានឬជាអ្នកធំខ្ពង់ខ្ពស់ក្នុងលោក ។

## ៦. សេចក្ដីពន្យល់តាមតារាភពតារា

បរមវិជ្ជានេះជាវិជ្ជាពេញចិត្តក្នុងលោក មិនមែនពេញចិត្តតែត្រឹមអស់យើងនេះទេ ទោះរាជការដ៏ជាធំក៏គង់ពេញចិត្តចំពោះវិជ្ជានេះដែរ ហេតុពីសេចក្ដីពេញចិត្តនេះហើយ បានជារាជការជាធំ ចំណាយប្រាក់បោះពុម្ពសៀវភៅបរមសិក្សាគ្រប់បែប ផ្សាយចែកគ្រប់សាលាបង្រៀនក្នុងព្រះនគរ ហើយមានបញ្ញត្តិឱ្យរៀបសាលាបង្រៀនគ្រប់វត្ត តែងឱ្យមានគ្រូបង្រៀនឱ្យគ្រូបង្រៀនតាំងពីម៉ោង ៧ ទៅដល់ម៉ោង ៥ រាល់ថ្ងៃ លើកតែថ្ងៃសីលនឹងថ្ងៃបុណ្យ ហើយរាជបញ្ញត្តិដល់អ្នកស្រុកដែលមាន

បុត្រប្រុស ៗ មានអាយុ ៧ ខួប ឲ្យបញ្ចូនចូលទៅរៀនក្នុងសាលាវត្ត ក្នុងសាលានោះខ្វះខាតគ្រឿងប្រើប្រាស់ រាជការជាធំតែងជួយទំនុកបំរុងបើកដាក់ឲ្យមិនគិតថ្លៃ នេះហើយដែលថារាជការជាធំពេញចិត្តណាស់ដែរ បើរាជការជាធំមិនពេញចិត្តកាលណានឹងចំណាយធំយ៉ាងនេះបាន គួរពួលចិត្តចុះ ។

## ៧-សេចក្ដីពន្យល់

ហេតុនេះហើយ លោកគ្រូចៅអធិការ លោកគ្រូសូត្រនឹងអ្នកស្រុកជើងវត្ត គប្បីមានសោមនស្សចំពោះផលប្រយោជន៍របស់យើង នឹងប្រហែសធ្វេសមិនបានទេ ត្រូវតែធ្វើឲ្យសមតាមបញ្ញត្តិ ដើម្បីបានជាការជួយទំនុកបំរុងជាតិឲ្យបេះដឹងវិសេសវិសាលថ្លៃថ្លាគ្រប់រូប តម្បន់ណាមួយដែលមិនទំនុកបំរុងសាលារៀន ហើយបណ្ដោតបណ្ដោយពួកកុមារឲ្យដើរលេងឥតប្រយោជន៍ តែ ១ ដំណ ២ ដំណាទៅ តម្បន់នោះឯងដេរ-ដាសទៅដោយមនុស្សល្ងង់ខ្លៅ មនុស្សល្ងង់នេះហើយដែលជាមនុស្សបណ្ដោតបណ្ដោយកូនសិស្ស កូនចង្កៀត កូនខ្ជួយ

នឹងបារិព្ការ ក្នុងបន្ទុកឲ្យឥតប្រយោជន៍ មនុស្សទាំងអស់នោះហើយដែលធ្វើវិជ្ជាឲ្យសាបសូន្យ ធ្វើស្រុកទេសឲ្យសាបសូន្យ ធ្វើទ្រព្យសម្បត្តិឲ្យសាបសូន្យ ធ្វើប្រយោជន៍ក្នុងលោកនេះនឹងលោកខាងមុខឲ្យសាបសូន្យផង ។

## ៨- ពា[illegible]

អស់ទាំងពួកកូនសិស្សក៏ដែរ បាងនៅកំពុងពេញពេលរៀន កុំបីមានសេចក្ដីប្រាថ្នាតិចក្នុងការសិក្សា បើប្រាថ្នាតិចក្នុងគ្រឿងបរិភោគ គឺ អត់ធ្មត់បន្ថយបរិភោគតិចតួចទៅ នេះជាការគួរណាស់ ព្រោះនាំឲ្យបំរើនខ្លួន បំណែកខាងឯការសិក្សារៀនសូត្រ បើបន្ថយឲ្យតិចទៅ រមែងមានសេចក្ដីខ្វិលច្រអូសគ្របសង្កត់បានហើយ បំណេះវិជ្ជាមុខជាចេះដឹងមិនគ្រប់គ្រាន់ បំណេះដែលចេះស្ទាក់ស្ទើរដល់ធ្វើការអ្វីៗ មិនកើត ក៏ប្រហែលគ្នានឹងមិនចេះដែរ តែងធ្លាក់ចុះ គឺថា ស្មុះទៅមិនរួចពីការកាប់គាស់ សែង លី ភ្ជួររាស់ស្រែបំការនោះឡើយ ហេតុនេះពួកកូនសិស្សត្រូវឲ្យមានប្រាថ្នាច្រើនក្នុងការសិក្សា គឺឲ្យមានឧស្សាហ៍

សង្ខាតរៀនសូត្រ របៀបរៀនបើរៀនបេះនេះហើយ ខំខឹងរៀនឲ្យបេះនោះទៀត ឲ្យបានស្ទាត់ស្ទាញបេះគ្រប់គ្រាន់ ហើយជាគ្រឿងបណ្តោយបង់ចោលនូវសេចក្តីល្ងង់ខ្លៅ ព្រោះមនុស្សល្ងង់ខ្លៅនាំឲ្យឥតប្រយោជន៍ធំណាស់ ។

## ៩– សប្បុរិសធម៌

មនុស្សល្ងង់ខ្លៅជាមនុស្សមិនដឹងធម៌ ៧ ប្រការ ជាធម៌របស់ពួកសប្បុរស ធម៌៧ប្រការនោះគឺ ១ ដឹងហេតុ ២ ដឹងផល ៣ ដឹងប្រមាណខ្លួន ៤ ដឹងប្រមាណភោជនាហារ ៥ ដឹងកាល ៦ ដឹងបុគ្គល ៧ ដឹងបរិសទ្យ ។ ដែលថាមិនដឹងហេតុនោះ គឺមិនដឹងថាអំពើដែលខ្លួនធ្វើទាំងអស់ជាហេតុ ធ្វើអំពើល្អហេតុល្អនាំយកសេចក្តីសុខមកឲ្យ ធ្វើអំពើអាក្រក់ហេតុអាក្រក់នាំយកសេចក្តីទុក្ខមកឲ្យ ដែលថាមិនដឹងផលនោះ គឺមិនដឹងថា អំពើសុចរិតឲ្យសំរេចសេចក្តីសុខ អំពើទុច្ចរិតឲ្យសំរេចសេចក្តីទុក្ខ ដែលថាមិនដឹងប្រមាណខ្លួននោះ គឺមិនដឹងថា ខ្លួនអញមានជាតិ ត្រកូល វ័យ បំណេះវិជ្ជា ទ្រព្យសម្បត្តិនឹងកេរ្តិ៍ឈ្មោះយសស័ក្តិត្រឹមប៉ុណ្ណោះ ដែលថាមិនដឹងប្រមាណភោជនាហារនោះ

គឺមិនដឹងថា អាហារដែលស្វែងរកបានមកយ៉ាងនេះ បរិភោគទៅបានសេចក្ដីសុខ ស្វែងរកបានមកយ៉ាងនេះ បរិភោគទៅបានសេចក្ដីទុក្ខ ដែលថាមិនដឹងកាលនោះគឺមិនដឹងថា ពេលនេះគួរប្រកបការនេះ ពេលនេះមិនគួរប្រកបឡើយ ដែលថាមិនដឹងបុគ្គលនោះ គឺមិនដឹងថា មនុស្សនេះល្អគួរសេពគប់ មនុស្សនេះមិនល្អមិនគួរសេពគប់ ដែលថាមិនដឹងបរិសទ្យនោះ គឺមិនដឹងថា ប្រជុំជននេះកាលអញចូលទៅរក គួរធ្វើដោយកាយយ៉ាងនេះ ដោយវាចាយ៉ាងនេះជាដើម ។

## ១០ សាបសូន្យប្រយោជន៍

មនុស្សដែលមិនដឹងធម៌ ៧ ប្រការនេះហើយ ដែលទំនើងតាមចិត្ត គិតធ្វើឲ្យសាបសូន្យចាកប្រយោជន៍ទាំងពួង កាលបើនឹងប្រកបការងារ ក៏ប្រកបតែការណាដែលជាការផ្ទួរផ្តួម ដែលធ្វើទៅបានជាហេតុដំណាមកអាក្រក់ក្រៃលែង ព្រោះមិនដឹងហេតុ បើនឹងបានផលក៏ទទួលសោយតែផលអាក្រក់ជាផល ហឹល ហាង ក្ដៅក្រហាយ ព្រោះមិនដឹងផល បើនឹងធ្វើឫកពាប្រឡើសលើសឥតសណ្ដាប់ធ្នាប់ វាយឫកស្មើតែ

នឹងលោកអ្នកប្រាជ្ញ លោកអ្នកធំ ព្រោះមិនដឹងប្រមាណខ្លួន បើនឹងស្វែងរកភោជនាហារក៏ប្រាសចាកការត្រឹមត្រូវ ស្រវាទៅរកមិច្ឆាអាជីវ[១] ព្រោះមិនប្រមាណភោជនាហារ បើនឹងប្រកបផលប្រយោជន៍ ពេលដែលត្រូវរៀនបែរទៅប្រកបការរបរ ទាល់តែផុតពេលរៀន វាត្រឡប់មករករៀនវិញ ព្រោះមិនដឹងកាល បើនឹងសេពគប់មិត្តភ័ក្តិក៏សេពគប់តែបាបមិត្ត គឺទៅចូលដៃតែនឹងពួកចោរនឹងពួកក្បត់ ព្រោះមិនដឹងបុគ្គល បើនឹងចូលជុំបំណោមក៏ធ្វើកិរិយាប្រឆេងប្រឆាំង ឆ្គាំឆ្គងដោយកាយវាចាជាដើម ព្រោះមិនដឹងបរិសទ្យ ។

## ១១- សុភាសិត

មនុស្សល្ងង់ខ្លៅដូចវែកដួសសំឡ ក៏ឯវែកនោះទោះត្រាំនៅក្នុងសំឡជានិច្ច វែកសូម្បីនឹងដែលដឹងថា សំឡនេះសាប សំឡនេះប្រៃដូច្នេះក៏គ្មានឡើយ ដូចមនុស្សល្ងង់ខ្លៅមិនដឹងរសធម៌ ៧ ប្រការហើយ នឹងមិនដឹងបាបបុណ្យគុណទោសដូចវែកដែរ ។ ម្យ៉ាងទៀតមនុស្សល្ងង់ខ្លៅដូចគោ ឯសត្វគោតែងតែ

---

១ លក់គ្រឿងអាវុធ ១ លក់មនុស្ស ១ លក់សាច់ ១ លក់គ្រឿងស្រវឹង ១ លក់ថ្នាំពុល ១ ។

ត្រេកត្រអាលនឹងស៊ីស្មៅ ហើយនឹងសេពមេថុនប៉ុណ្ណោះ ឥតមានឧបាយប្រាជ្ញាណាមួយនឹងដោះខ្លួនឲ្យរួចពីការបំរើម្ចាស់នោះឡើយ មនុស្សល្ងង់ដូចគោដែរ ត្រេកត្រអាលតែក្នុងកាមគុណ ជំហរតែខាងស៊ីនឹងសេពមេថុន ឥតមានឧបាយប្រាជ្ញាណាមួយនឹងពិចារណារើរលាស់ខ្លួនឲ្យរួចចាកវដ្តសង្សារ ដែលវិលកើតវិលស្លាប់នោះឡើយ ។

១២-វិនាសប្រយោជន៍

ក្លាក់របស់មនុស្សល្ងង់ខ្លៅ តែងធ្វើប្រយោជន៍របស់ខ្លួនឲ្យវិនាសយ៉ាងនេះ ប្រសិនបើមានបុគ្គលដទៃទៅសេពគប់ផង ក៏តែងណែនាំគេឲ្យវិនាសប្រយោជន៍ដូចខ្លួនដែរ ហេតុដូច្នោះ អស់ទាំងលោកអ្នកគប្បីធុញទ្រាន់ នឹងសេចក្ដីល្ងង់ខ្លៅកុំឲ្យមាននៅក្នុងបន្ទុក ត្រូវតែមានខ្នះខ្នែងដោយឧបាយបំបរបង់បោលនូវសេចក្ដីល្ងង់ខ្លៅឲ្យខ្ចាត់ខ្ចាយបេញដោយរហ័សរួសរាន់ ការដែលគិតនឹងបន្ទោបង់ល្ងង់ខ្លៅ នោះគោងប្រតិបត្តិតាមសេចក្ដីបញ្ញត្តិខាងដើមកុំឲ្យឃ្លៀងឃ្លាត ។

(មានតទៅទៀត)

# ពិធីពលីការព្រះពិស្ណុការ

(គឺព្រះវិស្សុកម្ម)

ព្រះមហាពិទូរ ក្រសេម រៀបរៀង

## ពិធីពលីការ

## ព្រះពិស្ណុការ ដ៏ជាគ្រូដើមខាងវិជ្ជាជាង

ពាក្យថា ពិស្ណុការ នេះជាឈ្មោះអ្នកណា៖ គួរឲ្យពិចារណាស្រាវជ្រាវរក ។ តាមដែលធ្លាប់ដឹងមក ពិស្ណុ ជាឈ្មោះព្រះនារាយណ៍ សឹងប្លែងចេញមកពីពាក្យដើមថាវិស្ណុ នឹងថាគេបូជាព្រះនារាយណ៍ មើលទៅក៏ដូចជាមិនមែន ព្រោះមិនមានប្រាកដក្នុងទីណាថា ព្រះនារាយណ៍ជាជាងកសាងផ្ទះសំបែងជាដើមសោះ មានប្រទះតែថា ទេវបុត្រ ១ អង្គឈ្មោះវិស្សុកម្មជាជាងរបស់ព្រះឥន្ទ្រ ដូចមានប្រាកដក្នុងគម្ពីរព្រះពុទ្ធសាសនាជាច្រើនអន្លើថា កាលព្រះឥន្ទ្រត្រិះការនឹងកសាងអ្វី រមែងត្រាស់ប្រើព្រះវិស្សុកម្មទេវបុត្រ ឲ្យទៅកសាងជាដរាប សូម្បីពាក្យថាវិស្សុកម្មនេះក៏ប្រែបានសេចក្ដីសមរឿងថា ការកសាងទីលំនៅ ឬថា អ្នកកសាងទីលំនៅ ។ ដោយសេចក្ដីសន្និដ្ឋានឃើញថា ដែលប្រើជា ពិស្ណុការ នោះគង់ឃ្លៀងឃ្លាតមកពីពាក្យថាវិស្សុកម្មនោះឯង ។

អំពីនេះនឹងពណ៌នាពីរបៀបបូជាព្រះពិស្ណុការឬព្រះវិស្សុកម្ម នោះតទៅ ជាងខ្មែរកាលនឹងកសាងរបស់ដែលសំខាន់ ដូចយ៉ាងប្រាសាទ វិហារ ផ្ទះនឹងធ្វើទូកធំៗជាដើម មានទំនៀមរៀបពលីការបូជាព្រះពិស្ណុការដែលជាគ្រូកសាងដើមដោយមានគតិកាន់ មនុស្សលោកយើងនេះដែលនឹងចេះការវិជ្ជាជាងធ្វើសារពើកិច្ចការទាំងពួង អាស្រ័យដោយព្រះពិស្ណុការឬព្រះវិស្សុកម្មប្រសិទ្ធិប្រសាធឲ្យមក ហេតុនេះ កាលគេនឹងធ្វើអ្វីរមែងបូជាគ្រូដើមនោះ ដើម្បីឲ្យការនោះសម្រេចទៅដោយស្រួល កុំឲ្យមានគ្រោះថ្នាក់ មានធ្លាក់ ឬមុតដៃមុតជើងជាដើម ទំនៀមនេះក៏ចេញមកតែពីគតិព្រហ្មញ្ញសាសនានោះឯង ។

ក៏ឯរបៀបគ្រឿងពលីការនោះ តាមក្បួនបុរាណលោកកំណត់ទុកជា ៣ យ៉ាង ផ្សេងគ្នាដោយធំនឹងតូច ដូច្នេះ :

របៀបទី ១

កាលនឹងធ្វើការធំមានប្រាសាទ វិហារជាដើម ត្រូវរៀបពលីការយ៉ាងធំតាមនោះគឺ:

ពាន ៥ ថ្នាក់ ១ មានរបស់ពលីការដាក់បូជានៅពាននោះ បាយសី ៥ ថ្នាក់ ១ គូ បាយសីប៉ាកឆាម ១ គូ ស្លាធម៌ ៤ ដម ៤ ទឹកអប់ ៤ ទៀន ៥ ធូប ៥ ផ្កា ៥ លាជ ៥ សំពត់សក្រាលពាន ៥ ហត្ថ ប្រាក់ ៤ បាទ ឬក្រដាសមាសក្រដាសប្រាក់ ក្បាលជ្រូក ២ នឹងមានភ្លេងពិណពាទ្យ ១ វង់ ។

ដល់វេលានឹងពលីការ ត្រូវយកគ្រឿងប្រដាប់ធ្វើការទាំងប៉ុន្មាននោះ មានដឹង ដែកឈូស ពន្លាក ជាដើម មករៀបតាំងនៅមុខពានទេវតា ។ មេជាងផ្ដើមសូត្រអារាធនាអញ្ជើញព្រះពិស្ណុការដ៏ជាគ្រូជាង នឹងទេវតាដែលរក្សាទីកន្លែងដែលកសាងនោះ សូមឲ្យអញ្ជើញមកទទួលសេពសោយគ្រឿងពលីការ នឹងសូមឲ្យជួយប្រសិទ្ធិការនេះឲ្យសម្រេចទៅដោយរួសរាន់ កុំឲ្យមានគ្រោះថ្នាក់ មានមុតដៃមុតជើងជាដើមឡើយ ។ ចប់ហើយអ្នកភ្លេងលេងភ្លេង ៣ ដង តាមទំនៀម ជាសូបេ ។

## របៀបទី ២

កាលនឹងធ្វើការជាយ៉ាងកណ្ដាល មិនតូច មិនធំ ត្រូវរៀបគ្រឿងពលីការយ៉ាងកណ្ដាល មានតទូកនិងជាដើមដូច្នេះ ។

រានទេវតា ៣ ថ្នាក់ ១ មានគ្រឿងពលីការ គឺ បាយសី ប៉ាកឆាម៤ ស្លាធម៌៤ ជម៤ ទឹកអប់៤ ទៀន៥ ធូប៥ ផ្កា៥ លាជ៥ សំពត់ស ៥ហត្ថ និងប្រាក់ ៦ស្លឹង ឬក្រដាស មាសក្រដាសប្រាក់ ។ និងមានសំពត់ជាតិ ២ បន្ទះ ទំហំ ទទឹងបណ្តោយ ១ហត្ថ ៤ជ្រុង គូរជាយន្តក្បាល ៤ បញ្ចុះអក្ខរ សិម្ពលី វេលាធ្វើបានជារាងហើយឲ្យយកទៅបិទត្រង់ខ្តរនឹង មាត់គ្នា ខាងក្បាល ១ ខាងកន្សៃ ១ ។ មេផាងត្រូវរៀប ពលីការដូចពោលហើយខាងលើ ។

## របៀបទី ៣

កាលនឹងធ្វើផ្ទះ គប្បីរៀបគ្រឿងពលីការដូច្នេះ :

រានទេវតា ៣ ថ្នាក់ ១ មានគ្រឿងពលីការ គឺ បាយសី ប៉ាកឆាម ១ គូ ស្លាធម៌ ១ គូ ជម ១ គូ ទឹកអប់ ១ គូ ទៀន ៥ ធូប ៥ ផ្កា ៥ លាជ ៥ សំពត់ស ៥ ហត្ថ និងក្រដាសមាស ក្រដាសប្រាក់ ។ និងមានសំពត់ជាតិប្រមាណ ១ ហត្ថ ៤ ជ្រុង គូរយន្តក្បាល ៤ តែដម្រាខ្ទះហាឲ្យគូរយន្តក្រប ។ ឲ្យយក

សំពត់យន្តនេះទៅបិទភ្ជាប់នឹងមេដំបូល ស្រេចហើយទើបរៀបពលីការដូចពោលហើយខាងលើ ។

អំពីនេះ នឹងអធិប្បាយអំពីសំពត់យន្តបន្តិចទៅទៀត ដើម្បីនឹងបំបាត់សេចក្តីសង្ស័យរបស់អ្នកខ្លះ ដែលអាចនឹងកើតសង្ស័យឡើងបាន ដ្បិតមានក្បួនខ្លះថា ឲ្យគូរយន្តក្បាល ៤ ក្បួនខ្លះថា ឲ្យគូយន្តក្រួចបញ្ចុះបាលីវដ្តកបរិត្ត ដើម្បីការពារកុំឲ្យភ្លើងឆេះផ្ទះនោះ ដោយអាងយករឿងក្នុងវដ្តកបរិត្តដែលថា កាលព្រះពុទ្ធអង្គនៅជាពោធិសត្វកើតជាកូនសត្វក្រួច វេលាមួយនោះមាតាបិតាមិននៅ ទទួលមានភ្លើងព្រៃឆេះមកដល់ទៀបសំបុក កូនក្រួចនោះភ័យក៏ភាវនាវដ្តកបរិត្ត ភ្លើងក៏រលត់ទៅ មិនបានឆេះដល់សំបុក ។

តាមសេចក្តីសន្និដ្ឋានថា យន្តក្បាល ៤ នោះជារបស់ដើម មានមកអំពីបុរាណកាល ដល់មកវេលាដែលខ្មែរកាន់ព្រះពុទ្ធសាសនាដេរដាសពេញពាសស្រុកហើយ ទើបកើតមានទំនៀមធ្វើយន្តក្រួច ១ យ៉ាងឡើងទៀត ដោយសេចក្តីនិយមដូចពោលហើយ ។

សំពត់នោះ អ្នកខ្លះហៅថា សំពត់នាងល័ក្ខណ៍ផ្ទះ អ្នកខ្លះហៅថា សំពត់ព្រះភូមិ អ្នកខ្លះហៅថាសំពត់ព្រះពិស្ណុការ ។

ការពលីការព្រះពិស្ណុការនេះ គេតែងធ្វើក្នុងវេលាដែលនឹងប្រុងរបស់ដែលត្រូវធ្វើនោះ គឺពីព្រឹកត្រូវរៀបបូជាព្រះពិស្ណុការដល់ថ្ងៃរសៀលត្រូវរៀបបូជាក្រុងពលី ។ តែបើនឹងធ្វើក្នុងវេលាដែលប្រមូលគ្រឿងទ្រព្យសម្ភារៈមកសព្វគ្រប់ហើយ ចាប់ផ្ដើមនឹងឈូសសិទ្ធគ្រឿងនោះ ក៏ធ្វើពិធីពលីការព្រះពិស្ណុការតែម្ដងដល់វេលាឈូសសិទ្ធស្រេចហើយនឹងប្រុង ត្រូវសែនក្រុងពលីដូច្នេះវិញ ឃើញទំនងជាងនឹងពលីការក្នុងថ្ងៃជាមួយគ្នាតែម្ដងក្នុងវេលាប្រុងនោះ ឃើញមិនសូវសម ព្រោះការបានធ្វើមកពាក់កណ្ដាលហើយ ទើបមកធ្វើជាក្រោយ បើនឹងមានគ្រោះថ្នាក់អ្វីអាចនឹងមានរូបទៅហើយក៏បាន ព្រះពិស្ណុការនឹងចាប់ទោសថា មិនអើពើនឹងបូជារំលឹកដល់លោកក៏បាន ខនេះនឹងគួរយ៉ាងណា អ្នករាប់អានទំនៀមទម្លាប់បុរាណ គួរតែពិចារណាមើលចុះ ។

ពិធីបុណ្យខ្មានសភាស

នៅ

# នគរ សតនាគនហុត (លាវ)

## លោកអាចារ្យ ស៊ី-អួន សុមនតិស្សោ

បានតែង នឹង រៀបរៀង

## លោកអាចារ្យ ឈឹម-ស៊ុម ក្រុមជំនុំព្រះត្រៃបិដក

បានពិនិត្យកែពាក្យ

បុណ្យទី ១ ខែចេត្រ

ខ្ញុំនឹងឈ្មោះដើមអក្សរ អ័ ស្រៈអ្នខ្យល់នដាក់ប្រកប អ្នកអានត្រូវលៃឲ្យរបប ប្រកបឋាបុះកុំបីធ្វល់ ។ ខ្ញុំម្ចាស់សូមថ្វាយបង្គំផ្ទង់ លុតលើកកំបង់ដរាបដល់ សិរសាទុកដួចដួងកមល ប្រតិស្ឋដំកល់ទុកលើត្បូង ។ ចំពោះព្រះពុទ្ធព្រះធម៌សង្ឃ ដែលជាអង្គរត្នបំភ្លឺប្រឹង ជាទីទង់ទាញស្រោបយកហ្វូងសត្វពីអណ្តូងគឺសង្សារ ។ រួចហើយខ្ញុំសូមរលឹកដល់ គុណលោកសេសសល់គឺមេបា គ្រូឧបជ្ឈាយ៍ទាំងអាចារ្យ បង្កើតអាត្មាជាតាមប្រាណ ។ ចប់បទប្រណាមដោយបរិយាយ សូមអស់អន្តរាយអន្តរជាន វិនាសបាត់បង់កុំកើតមាន ដល់តាមដល់ប្រាណនៃខ្ញុំផង ។ សូមតែសិរីនូវក្តីសុខ សួស្តីគ្រប់មុខឥតមានភ្លេង បំរើនដល់ខ្ញុំដូចបំណង រាល់ពេលរាល់ផង ដោយអភិរម្យ ។ ខ្ញុំម្ចាស់សូមតែងថ្លែងអំពី កំណត់ពិធីបុណ្យធំៗ ដែលពួកអ្នកស្រុកគេនិយម ជាបុណ្យឧត្តមក្នុងសាសនា ។ របៀបរបស់បុរាណព្រឹទ្ធ ជាតិជាបណ្ឌិតប្រាជ្ញា មានចិត្តជឿជាក់ក្នុងសាសនា តាក់តែងបូជាព្រះត្រៃរ័ត្ន ។

ឯបុណ្យអ្នកផងតែងធ្លាប់ធ្វើ ចាត់ជាអំពើហ្មត់ចត់ រាល់ឆ្នាំ
តែងធ្វើជាប្រាកដ តាមពាក្យកំណត់អ្នកប្រាជ្ញចាស់ ។ ត្រង់ខែ
ទី ១ ឈ្មោះខែចេត្រ ជាខែអណ្ណតឆ្លងទៅប្រាស ពីខែដែល
ជាប់ក្នុងឆ្នាំចាស់ ហើយទើបនឹងផ្លាស់ចូលឆ្នាំថ្មី ។ ខែនេះគេ
តាំងពិធីបុណ្យ គេនឹកដល់គុណព្រះជិនស្រី ជងទឹកស្រោច
ស្រង់អង្គចេតិយ ទាំងប្រុសទាំងស្រីរាល់រូបប្រាណ ។ មាន
ខ្លះធ្វើបុណ្យពូនភ្នំខ្សាច់ របៀបរៀបស្រេចដោតទង់ផ្កាន ឧទ្ទិស
បំពោះដោយស្មោះស្មាន ទៅរកទីស្ថានព្រះសុគត ។ អ្នកខ្លះ
ចូលវត្តអារាមា ស្ដាប់ធម៌ទេសនាតាមកំណត់ តាមរឿង
សាស្ត្រាមានប្រាកដ ថ្លែងរឿងត្រៃវត្សជាដើមទង ។ និមន្ត
ព្រះសង្ឃទៅសូត្រមន្ត តាមដោយតម្កល់ស្ថានអ្នកផង ជាការ
មង្គលដើមឆ្នាំម្ដង នេះជាទំនង់លោកចាស់ៗ ។ ខ្លះលេង
បាចទឹកសើចទ្រហោ មោះអារីរីទើសយ៉ាណាស់ ខ្លះលេង
របួតដល់ថ្ងៃរះ ពុំមានវៀនខ្លាសគេសោះឡើយ ។ ខ្លះនិមន្ត
លោកគង់លើរហ៍ លោកនេនឈ្មះឆោតក្នុងខ្សួយ បែរលោកគង់
រហ៍ទៅដល់ហើយ តាមឫស្សីរឹងល្វើយជាប្រហែ ។ អស់

ពួកអ្នកស្រុកផងទាំងឡាយ ក្មេងចាស់ពោះម៉ាយស្រីសារកែ
ដងទឹកចាំស្រង់លោកហូរហែ ដរាបតាំងតែពីចុងភ្លស់ ។
ហែលោកដរាបអស់ថ្ងៃបី ហៅបុណ្យឆ្នាំថ្មីមានមកដល់ ជ្រួល
ជ្រើមគ្រប់វត្តពុំមានសល់ សព្វទីមណ្ឌលពុំអាក់ខាន ។ រូប
ស្រេចហែអង្គម្ចាស់ជីវិត ដែលទ្រង់សណ្ឋិតលើរាជយាន អស់
ទាំងមន្ត្រីរាស្ត្រអ្នកមាន ហែទ្រង់កិសាន្តអស់ថ្ងៃបី ។ នេះ
ហៅបុណ្យធំក្នុងខែចេត្រ ធ្វើនៅគ្រប់ខែត្រខណ្ឌបុរី ជាបុណ្យ
ដើមខែនៅឆ្នាំថ្មី ថ្លែងជាសេចក្ដីបប់ដោយឃ្លា ។៚—

## បុណ្យទី ២ ខែវិសាខ

ដល់ខែវិសាខជាទីពីរ គេរៀបពិធីបុណ្យបូជា ឧទ្ទិសថ្វាយ
ដល់ព្រះភគវា កាលព្រះសាស្ដាចូលនិព្វាន ។ នឹងកាលព្រះ
អង្គទ្រង់ប្រសូតិ កាលទ្រង់សម្ដោធត្រាស់ដឹងញាណ ក្រោម
ពោធិព្រឹក្សជាទីស្ថាន ឧត្ដមក្រៀមក្សាន្តទន្លឹកក្រៃ ។ ឯពិធី
បុណ្យដែលគេធ្វើ ប្រាប់តាមដំណើរកុំសង្ស័យ តែងធ្វើដោយ
ច្រើននៅត្រង់ថ្ងៃ ពេញបូណ៌មីនៃខែវិសាខ ។ អស់បណ្ដាពួក
មហាជន ទោះមានទ្រព្យធនឬតោកយ៉ាក ដល់ថ្ងៃពេញបូណ៌

ខែវិសាខ ចូលវត្តឥតស្រាកដោយសោមនស្ស ។ រួចរៀបតែង តាំងគ្រឿងបូជា ថ្វាយព្រះភគវាដោយផ្កាស្រស់ ទាំងគ្រឿងសក្ការៈទាំងអស់ តាំងចិត្តសោមនស្សឧទ្ទិសថ្វាយ ។ រួចស្តាប់ទេសនាអស់ ១ យប់ ដោយការគោរពតាមផ្លូវកាយ វាចាចិត្ត ចប់ដោយបរិយាយ ជាពាក្យសម្រាយតាមភាសា ។ ពេលព្រឹកព្រាងឡើងរៀបចង្ហាន់ បាយទឹកណែនណាន់ក្នុងសាលា ប្រគេនព្រះសង្ឃក្នុងសាសនា ឧទ្ទិសផលាទៅដល់ញាតិ ។ ឯជនពួកខ្លះគេមិនធ្វើ មិនមែនអំពើគាប់ដល់ជាតិ ធ្វើកម្មតាមចិត្តយល់ឃ្លៀងឃ្លាត ទំប្រឹងខ្នីឃ្នាតតាមប្រាថ្នា ។ មានតែពួកពុទ្ធបរិសទ្យ ដែលជឿធម៌អត្ថក្នុងសាសនា បង្កើតបសាទក្តីជ្រះថ្លា តាក់តែងភ្ញីផ្កាឧទ្ទិសថ្វាយ ។ នេះឯងចាត់ជាវិធីបុណ្យ អ្នកចាស់ជាន់មុនតែងខ្វល់ខ្វាយ ហៅបុណ្យវិសាខជាដង្វាយ សម្រាប់អោយថ្វាយត្រៃរតនា ។ ០៚—

បុណ្យទី ៣ ខែជេស្ឋ

ដល់ខែទី ៣ គឺខែជេស្ឋ គ្រប់ស្រុកប្រទេសក្រុងគាមា បញ្ឈប់កិច្ចការស្មើររាល់គ្នា ធ្វើបុណ្យបព្វជ្ជាបំបួសភិក្ខុ ។ ព្រោះ

ជាខែជិតព្រះវស្សា កុមារបួសភ្លាមប្រញាប់សិក្ខ បួសត្រឹម ៣ ខែហោច ១ ទឹក បួសបែបនេះញឹកជាហូរហែ ។ របៀបដែលគេបំពេញផ្នួស រកអ្នកប្រុងបួសទុកយូរខែ បំបួសកូនចៅក៏មានដែរ មិនបាច់រកតែអ្នកដទៃ ។ អ្នកខ្លះលោះយកខ្ញុំកំដរ ទុរគតទ័លក្រជ្រកអាស្រ័យ ពីនាយចៅហ្វាយមកដោយថ្លៃ ជូនតាមដំឡៃដែលជំពាក់ ។ យកមកបំបួសជាកូនធម៌ ដោយសារខ្លួនល្អពុំល្អបលាក់ គេយល់ឃើញថាខ្លួនជាអ្នក អាចបិត្តស្មោះស្ម័គ្រក្នុងសាសនា ។ រួបស្រេចដល់ថ្ងៃដែលសន្មត កោរសក់ពុកមាត់ពុកចង្កា ពួកឧបាសកបាសិកា រៀបគ្រឿងបរិក្ខារផងទាំងឡាយ ។ គប់គ្រាន់ឲ្យនាគឡើងជិះសេះ ភ្លេងភ្លាត់ក្លូតកេះតាមសប្បាយ ហែហមគ្នាទៅតាមបម្ងាយ អារាមនៅឆ្ងាយឬនៅជិត ។ ដល់ហើយអ្នកនាគកាន់យកផ្នួស ព្រះសង្ឃបំបួសតាមធម៌ពិត ពុំឲ្យទាស់ខុសនឹងក្រមក្រឹត្យ សង្ឃតិបកម្រិតត្រឹម ៥ រូប ។ ឯពួកឧបាសកសិកា រៀបចំភិក្ខាបាយទឹកម្ហូប ពេលយប់ស្តាប់ទេសន៍ងុយងងុប ព្រឹកឡើងរៀបស្លូបអង្គាសសង្ឃ ។

នេះហើយគេចាត់ជាបុណ្យបួស ជាកិច្ចសាងផ្លូវសួគ៌ផ្លូវផង ជាហេតុកំចាត់នូវកាំកង់ ដែលវិលព័ទ្ធវង់ក្នុងសង្សារ ។ បុណ្យនេះថ្លែងមកយ៉ាងខ្លី ៗ មិនអស់សេចក្តីគ្រប់ប្រការ បើពោលតាមក្រឹត្យក្រែងពិស្តារ បំប្រួញមកហើយដោយផ្ចិតផ្ចង់ ៗ ៙៚—

បុណ្យទី ៤ ខែអាសាឍ

ដល់ខែទី ៤ គឺអាសាឍ ព្រះទ្រង់អនុញ្ញាតឲ្យព្រះសង្ឃចូលកាន់វស្សារាល់ ៗ អង្គ គង់នៅតែត្រង់កន្លែងមួយ ។ ខែនេះឧបាសកសិកា មានចិត្តជ្រះថ្លាដុះដូចត្រួយ លូតលាស់ធំឡើងពុំរលួយ ជុំជួយគ្នាធ្វើទៀនវស្សា ។ ខ្លះតូចខ្លះធំមានខ្លីវែង រៀបចំតាក់តែងតាមប្រាជ្ញា ទាំងគ្រឿងក្រអូបធូបបុប្ផា សម្រាប់បូជារាល់យប់ថ្ងៃ ។ ឯពួកអ្នកស្រុកទាំងប៉ុន្មាន ដែលមានទីស្ថានជ្រកអាស្រ័យ ដល់ដប់បួនកើតខែនោះនៃ បួសសូមអភ័យនឹងត្រៃរតន៍ ។ ប្រជុំគ្នាក្នុងអារាម ប្រណម្យប្រណាមតាមបែបបទ សូមរតនត្រ័យឲ្យអំណត់ ទាំងសង្ឃក្នុងវត្តផងទាំងឡាយ ។ ចំណែកព្រះសង្ឃក្នុងទីវត្ត ដល់ថ្ងៃកំណត់ពុំក្លែង

ក្លាយ ប្រកាសខែត្រវត្តតាមជិតឆ្ងាយ បញ្ចេញបរិយាយ កំណត់កាន់ ។ នៅជាប់រហូតអស់ ៣ ខែ ពុំបានប្រួលប្រែ កែកំណាន់ នេះជាបែបបទដែលសំខាន់ អង្គព្រះភគវន្តទ្រង់ តាំងទុក ។ ដើម្បីរក្សានូវមារយាទ កុំឲ្យរវាតបិត្តអ្នកស្រុក ព្រោះដីសើមទឹកញឹកមានភក់ ជាទីនៅបុកសត្វតាតា ។ ជា ខែសាបព្រោះបណ្ដុះភ្នូត[1] កំពុងឡើងលូតលាស់ធារា ទ្រង់ ហាមដំណើរតាមមាគ៌ា ដល់សង្ឃរាល់គ្នាក្នុងសាសនា ។ នេះក៏បាត់ជាវិធីបុណ្យ គេនឹកដល់គុណព្រះសាស្ដា ប្រតិបត្តិ ធ្វើតាមព្រះវាចា ឈ្មោះបុណ្យចូលវស្សាចប់ហូរហែ ។៚—

## បុណ្យទី ៤ ខែស្រាពណ៍

ដល់ខែទី ៥ គឺខែស្រាពណ៍ ចាប់ដើមដរាបអស់ ១ ខែ ស្រុកក្រុងស្រុកក្រៅចំការស្រែ ខ្វល់ខ្វាយខាងតែពីធ្វើបុណ្យ ។ គឺបុណ្យដាក់បាត្រស្ដាប់ទេសនា បញ្ឈប់កិច្ចការពីពេលមុន បំពេញកុសលជាទ្វេគុណ និមន្តព្រះសង្ឃឆាន់អាហារ ។

---

១ ភ្នកតាម ។

ដរាបដល់ថ្ងៃ ១៣ រោច ខែស្រាពណ៍រនោចនោះកាលណា អ្នកស្រុកក្រុងក្រៅស្រែចំការ រៀបខ្លួនចុះផ្សារទិញរបស់ ។ បម្រុងធ្វើបុណ្យថ្ងៃខែដាច់ ចាត់ចែងធ្វើស្រែបពីយប់អស់ រៀបធ្វើបំណាំយ៉ាងស្រស់ ៗ គួរជារបស់រៀបអាហារ ។ លុះដល់ស្អែកព្រឹកពេលព្រលឹម រៀបភ្ញាក់ព្រឹមព្រះសុរិយា អ្នកស្រុកស្រីប្រុសរៀបកាយា ចាត់ចែងអាហាររាប់បាត្រសង្ឃ ។ មហាជនទាំងឡាយនៅគ្រប់ថ្នល់ ទៅមករវិលវល់តាមបំណង សែងរែកអាហារចូលដម្រង់ និមន្តព្រះសង្ឃមកវេរថ្វាយ ។ រសៀលព្រលប់គ្រប់តំបន់ ព័ទ្ធព័ន្ធតាក់តែងស្ថានទាំងឡាយ ស្តាប់ធម៌ទេសនាដោយបរិយាយ ជាពាក្យសម្រាយតាមវេលា ។ បុណ្យនេះគេតែងនិយាយថា តាមដោយភាសាគេគ្រប់គ្នា ហៅបុណ្យហ៉ខារធ្វើនៅនា ខែស្រាពណ៍ជាគ្រាបុណ្យភ្ជុំធំ [១] ។ បុណ្យភ្ជុំខែស្រាពណ៍ចប់ប៉ុណ្ណោះ បុណ្យនេះវិសេសថ្លៃឧត្តម នរជនគ្រប់ស្រុកតែងខិតខំ ចាត់ចែងសន្សំពុំមានអាក ។

---

១ លោកធ្វើបុណ្យភ្ជុំនៅខែស្រាពណ៍រាល់ឆ្នាំ ។

## បុណ្យទី ៦ ខែភទ្របទ

ដរាបមកដល់ខែភទ្របទ អ្នកស្រុកសន្មតបុណ្យខារសាក ដែលពួកអ្នកផងតែងបរិច្ចាគ បាលីហៅសលាកភត្តហោង ។ ខែនេះសម្បូណ៌បន្លែណាស់ តាមបឹងមាត់ស្រះស្លួនអ្នកផង ហូរហែពាសពេញគរជាកង ដោយផ្ការផ្សេងផងគ្រប់អន្លើ ។ ខែនេះគេច្រើននៅទំនេរ កិច្ចស្រែបំការគេឈប់ធ្វើ មានតែជួញប្រែតាមដំណើរ ដែលជាអំពើពុំអាក់ខាន ។ ទើបពួកពុទ្ធបរិសទ្យ ជឿជាក់ត្រៃរតន៍ទាំងប៉ុន្មាន ដុសខាត់មន្ទិលក្នុងសន្តាន ធ្វើទានដល់សង្ឃក្នុងសាសនា ។ កាលបើដល់ថ្ងៃដែលសន្មត អ្នកស្រុកដើរវត្តគ្រប់គាមា ចាត់ចែងសលាកភត្តទាំងអស់គ្នា នាំទៅវិហារថ្វាយព្រះសង្ឃ ។ ខ្លះតិចខ្លះច្រើនតាមដោយមាន ទុកជាអត់ឃ្លានមានបំណង់ អាចកាន់ទៅបានប៉ុន្មានអង្គ ចំពោះទ្រព្យបង់ជាបំណាយ ។ ទិញដូរបំណាំនូវបរិក្ខារ នូវម្ហូបអាហារផងទាំងឡាយ ត្រីសាច់ស្រស់ក្រៀមអង្ករបាយ មិនបាច់បរិយាយដោយសព្វគ្រប់ ។ បុណ្យ

នេះលោកហៅសលាកភត្ត គេតែងប្រតិបត្តិដោយគោរព ស្រុកលាវហៅថាបុណ្យខែដប់(១) សេចក្ដីនេះចប់ដោយយ៉ាងខ្លី ៚—

បុណ្យទី ៧ ខែអស្សុជ

ដល់ខែអស្សុជទីប្រាំពីរ អាទិត្យលិស្ថិតត្រង់រាសី ប្រាំពីរ រៀបចូលទីប្រាំបី ពេញបូណ៌មីជាថ្ងៃចេញវស្សា ។ ព្រះសង្ឃគ្រប់អង្គសឹងរីកមុខ ព្រោះមានទុកចិត្តបវារណា និងបានដំណើរតាមត្រិវការ ទៅទីណា ៗ មិនព្រួយហោង ។ ខែនេះជាខែគេធ្វើបុណ្យ បញ្ឈប់រែកពុនការងារផង ខាត់ចិត្តជ្រះស្អាតចាកសៅហ្មង មកធ្វើបុណ្យសងគុណត្រៃរ័ត្ន ។ ខ្លះធ្វើទៀនធូបដោតបូជា តាក់តែងតារាតាមកំណត់ រៀបគ្រឿងបូជាយ៉ាងហ្មត់ចត់ អណ្ដែតវិលវាត់តាមទន្លេ ។ ខ្លះធ្វើគោមហោះលែងលើមេឃ ពន្លឺភ្លើងឆានឆេ(២) អាចារ្យអ្នកចេះគេស្មូត្រពីរ បូជាដល់កេរ្ដិ៍ព្រះសុគត ។ ខ្លះរៀបធ្វើបុណ្យដោយបង្សុកូល ធ្វើផ្ទះកំឡូលញាតិសាលីតាត់ ទាំងគ្រឿងបរិក្ខារមិន

---

១ ហៅតាមឈ្មោះខែ ។ ២ ឆេ ប្រែថា ភាគាល ។

កំណត់ ហែចូលទៅវត្តរូបផ្សេង ៗ បុណ្យខែអស្សុជខាងរនោច ធ្វើថ្ងៃ ១ រោចប្រាកដហោង គឺក្នុង ១ ឆ្នាំមានត្រឹមម្តង ដែលពួកជនផងគេតែងធ្វើ ។ បើសិនណាការអធិប្បាយបរិយាយហូរហែគ្រប់អន្លើ សឹងមានបែបផែនគួរសរសើរ គង់ចង់ដំណើរមើលពុំខាន ។ នេះថ្លែងសេចក្តីដោយខ្លីៗ លោកអ្នកប្រុសស្រីស្តាប់ឲ្យបាន វិធីថ្លែងមកទាំងប៉ុន្មាន ចាស់ៗបុរាណលោកតែងធ្វើ ។ នៅតាស្រុកនេះពុំឃើញមាន គេធ្វើពុំខាននៅស្រុកលើ ថ្លែងដោយសង្ខេបតាមដំណើរ តាមដោយអន្លើបប់បុះដែរ ។ ០៚—

បុណ្យទី ៨ ខែកត្តិក

ក្នុងខែកត្តិកខ្នើតដប់បី ហែម្ចាស់ផែនដីបុះកាន់ដែះនាហ្មឺនមន្ត្រីនូវចៅកែ មហាជនអ៊ូអែពន្លឹកក្រៃ ។ អ្នកក្រុងអ្នកស្រែអ្នកចំការ ពួកកួយម៉ែវខាភ្នងម៉យនៃ សង់ផ្ទះនៅជ្រកតាមមាត់ព្រៃ ក្នុងខែត្រផែនដីម្ចាស់ជីវិត ។ នាំគ្នាទៅមើលពិធីបុណ្យ វែកពុនរបស់តាមឆ្ងាយជិត ចូលទៅរកអ្នកដែលជាមិត្តសំចតនៅជិតគេហស្ថាន ។ ដល់ថ្ងៃរៀបហែម្ចាស់ជីវិត យាង

ទៅសន្តិតទីរៀបថ្កាន ទុកបុណ្យអ៊ុំទូកបែបបុរាណ ជាការកំសាន្តព្រះបិត្តា ។ ឯពួកមហាជនគ្រប់តំបន់ ទៅមើលលាន់ៗ ភ្លាស់នាវា គ្រប់ផ្លូវគ្រប់ថ្នល់បង្កៀតគ្នា តាន់តាប់មហិមាសន្ធឹកហោង ។ ដល់ថ្ងៃពេញបូណ៌មីកាលណា ទ្រង់រៀបកាយាពុំមានហ្មង មន្ត្រីតូចធំរាស្ត្រគឹកកង ហែទ្រង់ស្តេចឆ្លងបុះកាន់ស្នាម(១) ។ កាលទ្រង់ស្តេចយាងទៅទីនោះ ពិត្តាពុំឆ្ពោះទៅរកកាម និមន្តព្រះសង្ឃក្នុងអារាម ឲ្យទេសនាតាមអធ្យាស្រ័យ ។ រូបទតមហោស្រពតាមវេលា ការល្បែងនានាច្រើនពេកក្រៃ អស់ពេលមួយយប់នឹងមួយថ្ងៃ ហែមហាក្សត្រថ្លៃវិលត្រឡប់ ។ ឯពួកឧបាសកសិកា ស្តាប់ធម៌ទេសនាក្នុងមណ្ឌប កំណត់ ១ថ្ងៃនឹង១យប់ ពុំទៅប្រសព្វនឹងការល្បែង ។ បុណ្យនេះបំពោះក្រុងឡានពាង គឺល្អងព្រះបាងប៉ុណ្ណោះឯង ជាបែបប្រាជ្ញចាស់រៀបចាត់ចែង ខ្ញុំពោលសំដែងពុំសព្វគ្រប់ ។ នេះជាបុណ្យធំខែកត្តិក ដែលគេរំលឹកដោយគោរព បំពោះសាសនាព្រះបរមភព សន្មតថាចប់ដោយបរិយាយ ។

---

១ ទីកន្លែងសំរាប់កំសាន្តនៅជើងវត្ត ១ ឈ្មោះវត្តថាតល្ងង ។

បុណ្យទី៩ ខែមិគសិរ និងបុស្ស

ខែមិគសិរនឹងខែបុស្ស មហាជនស្រីប្រុសផងទាំងឡាយ រកស៊ីមានបានគ្រាន់ធូរបាយ ជាទីសប្បាយដល់អ្នកលោក ។ ឯផលបន្លែស្រែចំការ ល្មមជាអាហារដំឡូងបោក ពោរពេញហូរហៀរជាគរគោក ប្រើនគ្រឿងបរិភោគក្រៃពេកណាស់ ។ ហេតុនេះឧបាសកសិកា រាប់អានសាសនាព្រះជាម្ចាស់ ខ្វល់ខ្វាយបាត់បែងតែងរហ័ស ធ្វើទានរៀនលះក្តីកំណាញ់ ។ គេប្រើនតែធ្វើបង្អាន់សង្ឃ ដោយម្ហូបផ្លិតផ្ងង់បង់ប្រែងខ្លាញ់ សុទ្ធសឹងរបស់មានរសឆ្ងាញ់ អង្គាសលោកខ្ញាញ់ក្នុងទីស្ថាន ។ តាមមានតាមក្រតាមយសស័ក្តិ តាមចិត្តស្មោះស្ម័គ្រដែលរាប់អាន ទទួលយកលោកបានប៉ុន្មាន មិនឲ្យលោះខានការកុសល ។ មុនថ្ងៃរាប់បាត្រមានទេសនា ដោយនូវសាស្ត្រាសំដែងផល ឲ្យពួកអ្នកផងដែលងឿងឆ្ងល់ បានស្គាល់យល់ច្បាស់ផ្លូវបុណ្យបាប ។ តាំងពីព្រលប់ទាល់យប់ជ្រៅ មានទេសនានៅជាដរាប ខ្លះធ្វើបង្អែមនូវបំអាប ខ្លះផ្កាប់មុខក្រាបស្តាប់ទេសនា ។ រហូតដល់ព្រឹកពេលព្រលឹម ពេលរះពព្រឹម

ព្រះតុរិយោ អស់ពួកឧបាសកសិកា តាក់តែងអាហារថ្វាយ ព្រះសង្ឃ ។ រួចទើបឧទ្ទិសដោយវាចា ចែកជូនផលតាម បំណង ទៅដល់ពួកញាតិដែលបាត់បង់ ឲ្យផលពិម្រង់ទៅដល់ ពិត ។ នេះជាបុណ្យមួយក្នុងសាសនា ជាយ៉ាងអស្ចារ្យតាម ភាសិត នៃពួកប្រាជ្ញចាស់បេះធម៌ល្អិត ដែលជាឲ្យគិតការ បុណ្យទាន ។ ខ្ញុំបានពណ៌នាមកប៉ុណ្ណេះ សូមលោកអ្នកបេះ ដឹងប៉ុន្មាន ខំប្រឹងស្តាប់ចុះតាមលំអាន សង្ខេបនិទានចប់ សេចក្តី ។៚—.

បុណ្យទី ១១ ខែមាឃ

ខែទី ១១ គឺខែមាឃ ត្រជាក់តិតស្រាកទាំងយប់ថ្ងៃ ជើងមេឃស្រទំរងាពេកក្រៃ មនុស្សញ័រជើងដៃជល្លាប់ភ្លួយ ។ ស្រុកលាវខែនេះគេច្រើនធ្វើ កុសលប្រសើរប្រការមួយ ហៅ បុណ្យឌឿនសោមនាំគ្នាជួយ តាំងពិធីតែមួយទាំងប្រុសស្រី ។ តាំងពីដើមខែគេរៀបចំ បាយទឹកនំនៅភោជន៍បំណាំ ជម្រះ កន្លែងតែងឃ្លាតខ្មី ប្រយោជន៍ដើម្បីស្តាប់ទេសនា ។ លុះ ដល់ពេញបូណ៌ខែនោះហោង គេទៅគិកកងព្រៃព្រឹក្ស រំពង

សម្រែកស្រែកថា ខ្លះស្ដាប់ទេសនាពុំកក្រើក ។ តាំងពី
ព្រលឹមដល់ថ្ងៃត្រង់ ព្រះសង្ឃទេសនាជាច្រើនលើក ទីព្រៃត្រង់
នោះស្ទើររបើក ជ្រួលជ្រើមកក្រើកអស់មួយថ្ងៃ ។ បុណ្យនេះ
អ្នកស្រុកគេបង្កើត នាខែមាឃខ្នើតពេញបូណ៌មី ហៅបុណ្យ
ហ្វឹនថានណាប្រុសស្រី ស្ដាប់យកសេចក្ដីនេះឲ្យបាន ។ សឹង
រាប់ជាបុណ្យក្នុងសាសនា នៃព្រះភគវាគេរាប់អាន អ្នកស្រុក
ឡានធាងទាំងប៉ុន្មាន គេធ្វើនាស្ថានព្រៃព្រឹក្សា ។ ត្រង់
មាឃបូជាពុំឃើញមាន តែងខាងបុណ្យទានដោយអាហារ
គេផ្ចិតផ្ចង់ធ្វើជាឧឡារ នៅស្រែបំការក៏ដួបគ្នា ។ បុណ្យនៅ
ខែមាឃចប់ដោយខ្សែក ដែលជាបុណ្យប្លែកពីបូជា គង់បាត់
ជាបុណ្យក្នុងសាសនា នៃព្រះសាស្ដាឥតមានហ្មង ។៚—

បុណ្យទី ១១ ខែផល្គុន

នៅខែផល្គុនជាបុងឆ្នាំ ស្រេចកិច្ចដំណាំនៃអ្នកផង
អ្នកស្រុកធ្វើការតាមបំណង ព្រះសង្ឃត្រូសង់ទៅធុតង្គ ។
ព្រោះខែនេះរាំងពុំមានភ្លៀង ស្រុកព្រៃរាបរៀងពុំមានជុំង គួរ

ដល់ព្រះសង្ឃចេញបម្រើង ធ្វើកិច្ចធុតង្គតាមប្រាថ្នា ។ ព្រះ
សង្ឃគ្រប់វត្តសន្និតគ្នា រៀបចំវិហារនូវគោលោ ដល់
ថ្ងៃកំណត់នោះកាលណា ចូលកាន់ព្រៃក្បាខិស្នាធ៌ស្ទឹង ។
ប្រតិបត្តិធុតង្គទាំងដប់បី តាំងនៅដោយព្រៃស្ងាត់បាត់ឈឹង
កាន់បាននៅដោយនូវធូរតឹង តាមកិច្ចដែលដឹងក្នុងគម្ពីរ ។
អស់ពួកឧបាសកសិកា បាត់បែងអាហារទៅដល់ទី ប្រគេន
ព្រះសង្ឃគង់គីរី នេះជាពិធីបុណ្យធុតង្គ ។ សេចក្តីបំព្រួញ
ត្រឹមប៉ុណ្ណោះ សូមលោកអ្នកត្រិះគិតដើមចុង បើឃើញគាប់
គួរសូមបម្រុង សូមប្រុងធ្វើតាមគេនោះហោង ។ បុណ្យនេះ
ជាបុណ្យធំ ១ យ៉ាង ក្រុងល្វង់ព្រះបាងធ្វើរាល់ដង ហៅបុណ្យ
ខារិប៉ាមួយឆ្នាំម្តង ថ្លែងតាមទំនងបប់សេចក្តី ។ រឿងរ៉ាវថ្លែង
មកអម្បាលមាណ បើស្តាប់ពុំបានពិរោះឃ្លាខ្លី សូមអស់
លោកអ្នកទាំងប្រុសស្រី អត់ទោសអភ័យក្តីខុសខ្ញុំ ។ ព្រោះ
មានឃ្លាខ្លះមិនត្រូវព្រះ ទាស់ខុសអក្ខរៈដោយដុំៗ ត្រង់ខ្លះខុស

ពាក្យពុំសមរម្យ ទាំងនេះព្រោះខ្ញុំពុំទាន់ស្ទាត់ ។ មួយទៀត ខ្ញុំសោតជាតិជាលាវ បំណេះតួបរាវស្តួបស្តើងក្តាត់ ពាក្យខ្មែរ រៀនក្មេងទើបបេះស្ទាត់ ខ្ញុំរៀនតែងភ្លាត់ព្រោះរៀនចាស់ ។ មួយទៀតខ្លួនខ្ញុំនៅស្រុកខ្មែរ ប្រាំពីរឆ្នាំហ្វេហៃរៀនបេះខ្វះ បំណេះវិជ្ជាតាមធម៌ព្រះ ពុំបានបេះណាស់ដូចអ្នកផង ។ គ្មានវត្ថុអ្វីដម្កល់ទុក ផ្ញើកេរ្ត៍ទៅមុខជាសំណាង គុណាគ្រូញាធ្យាបេ សមដូចប៉ង ទាំងលោកអ្នកផងបានបង្រៀន ។ បានតែរឿងរ៉ាវក្នុងពុទ្ធសាសន៍ ដំណើរស្រុកខ្លះខំប្រិតប្រៀន ដូចមានហ្សូរហៃជាបៀន ដែលខ្ញុំកត់ទៀនទុកខាងដើម ។ ទុកជាកេរ្ត៍ឈ្មោះខ្ញុំទៅមុខ មួយទៀតសូមទុកសងគុណាផ្ញើម នៃលោកបាធ្យាយជាគ្រូផ្តើម វិជ្ជាថ្លៃឆ្នើមឲ្យខ្ញុំបេះ ។

កាលដែលខ្ញុំបានរៀបរៀងស្រេច រឿងរ៉ាវសម្រេចត្រឹមប៉ុណ្ណោះ ដោយសារខ្លួនខ្ញុំមិនសូវពេះ ទើបនាំរឿងនេះទៅប្រគេន ។ បំពោះព្រះគុណព្រះនាមសុះ ដែលជាគ្រូខ្ញុំតាំងពីនេន សូមឲ្យពិនិត្យតាមបែបដែន ឲ្យត្រឹមត្រូវមែនតាម

ពាក្យខ្មែរ ។ ប្អូនជាពេលនោះលោករវល់ កិច្ចការកង្វល់មិនមានស្អើ លោកបានពិនិត្យឲ្យខ្លះដែរ បានទាំងកែប្រែសព្ទពាក្យពេចន៍ ។ បុណ្យទ្រាទសមាសដូច្នេះឯង ខ្ញុំបរបារបែងចប់ជាស្រេច មិនបានពិស្ដារសព្វសេចគ្រប់ សង្ខេបចប់ស្រេចប៉ុណ្ណោះហោង ។

ធ្វើនៅវត្តលង្ការាម ឃុំលេខ ៤ ក្រុងភ្នំពេញ

ចប់នៅថ្ងៃ ២៥ ឧកត្តូបឆ្នាំ ១៩៣៤

ប៉ុ - ម៉ែន

# រឿងធនញ្ជ័យបណ្ឌិត

(ត)

ខ្ញុំបង្ហាញដុំដៃថា អញចង់នឹងកែងដៃ ចិនបង្ហាញទាំង ៥ ថា គ្នាគេច្រើន ខ្ញុំបង្ហាញម្រាមដៃ ១ នោះថា អញតែម្នាក់ឯង អញវាយអញមិនខ្លាចទេ លោកចៅហ្វាំឮដូច្នោះហើយក៏វិលទៅផ្ទះវិញ ឯព្រះមហាក្សត្រស្ដេចឲ្យហៅធនញ្ជ័យទៅសួរថា កាលអាចារ្យចិនគេចោទថាដូចម្ដេច ធនញ្ជ័យក្រាបទូលថា កាលអាចារ្យចិនគេមកដល់ធ្វើដៃជាឧបបង្ហាញខ្ញុំទូលបង្គំ ឯទូលបង្គំបត់កែងដៃបញ្ឈរបង្ហាញទៅវិញ ហើយអាចារ្យចិនបង្ហាញម្រាមដៃទាំង ៥ ខ្ញុំទូលព្រះបង្គំបង្ហាញម្រាមដៃ ១ ទៅវិញ ទើបស្ដេចមានព្រះបន្ទូលដណ្ដឹងថា ដូចម្ដេចបើដូច្នោះ ទើបធនញ្ជ័យក្រាបទូលថា ឯចិនឧបដៃបង្ហាញមកសួរថា ក្នុងទ្វីបទាំង ៤ នេះតើមានអ្វីខ្លះ ខ្ញុំទូលបង្គំបត់ដុំដៃបង្ហាញនោះប្រាប់ថា មានភ្នំព្រះសិនេរុត្រង់កណ្ដាល ទើបចិនបង្ហាញម្រាមដៃទាំង ៥ នោះដណ្ដឹងថា មានព្រះពុទ្ធ ៥ ព្រះអង្គបានត្រាស់ក្នុងកល្បនេះ ទើបខ្ញុំទូលបង្គំបង្ហាញម្រាមដៃ ១ នោះប្រាប់ថា ៥ អង្គ ប៉ុន្តែបានត្រាស់ ៤ អង្គទៅហើយ នៅតែ ១ អង្គទៀត

មិនទាន់បានត្រាស់នៅឡើយ ប្រស្នានេះដូច្នេះឯង សូមទ្រង់ជ្រាប ហើយធនញ្ជ័យក្រាបបង្គំលាទៅផ្ទះវិញ ។

ឯលោកសង្គ្រាជនឹងសម្តេចចៅហ៊្វាទៅជួបនឹងមហាក្សត្រ ហើយនិយាយតាមដំណើរដែលបានដណ្តឹងធនញ្ជ័យ កាលពោទប្រស្នានឹងបិទ ក្រាបទូលស្តេច ៗ ស្តាប់ហើយមានព្រះបន្ទូលថា វាប្រាប់លោកសង្គ្រាជផ្សេង ប្រាប់សម្តេចចៅហ៊្វាផ្សេង វាប្រាប់អញផ្សេង នឹងឲ្យប្រាកដជាប្រស្នាដូចម្តេចនោះមិនបាន ស្តេចនូវអស់ទាំងនាម៉ឺនខ្លាចប្រាជ្ញាធនញ្ជ័យណាស់ ។

ឯធនញ្ជ័យក៏វិលទៅផ្ទះវិញ ហើយឲ្យយកខ្មៅដែលដុសក្តារ ៤ ជ្រុង ក្រដាសសនឹងគម្ពីរដែលឲ្យគេរក ហើយនឹងក្តាមដែលដាក់ក្នុងក្អមទាំង ៤ នោះមក ហើយក៏យកក្តាមដាក់ត្រង់កណ្តាល ហើយយកថាសដាក់ទឹកខ្មៅ ដាក់គ្រប់ជ្រុងទាំង ៤ ហើយយកក្រដាសក្រាលលើក្តារ ហើយយកក្តាមដាក់ក្នុងថាសទឹកខ្មៅឲ្យវាវារឡើងលើក្រដាសនោះ ឯទឹកខ្មៅដែលប្រឡាក់នូវជើងក្តាមវានោះជិតជាប់នឹងក្រដាសនោះច្រើន ហើយ

យកទៅហាលថ្ងៃ លុះធ្វើដូច្នេះឯងបានច្រើនហើយ ឲ្យយកគម្ពីរមករុំទុក ហើយយកក្រដាសមកដាក់ឲ្យក្មេងវាវារជាច្រើនទៀត រួចហើយឲ្យយកក្តារនឹងទឹកខ្មៅទៅទុក ទើបឲ្យកូនក្មេងមកអង្គុយច្រើន ហើយឲ្យក្រដាស ១ ពុម្ពម្នាក់ៗ ឲ្យអស់ក្មេងនោះទន្ទេញហាត់ផ្តេសផ្តាសទៅ តាមតែក្មេងណាចង់ជាដូចម្តេចក៏ជាទៅ ឲ្យពួកក្មេងរៀនអក្សរ មើលសាស្ត្រា ៗ ឯអ្នកប្រាជ្ញប៊ិននោះ លុះដល់ព្រឹកឡើងហើយឡើងពីសំពៅមកផ្ទះធនញ្ជ័យនឹងចោទប្រស្នា ឯធនញ្ជ័យមើលទៅឃើញអាចារ្យប៊ិនមកដល់ហើយ ក៏ដើរទៅទទួលចាប់ដៃចូលមកអង្គុយលើកៅអី ហើយធនញ្ជ័យឲ្យយកតែមកឲ្យអាចារ្យប៊ិនផឹក ឯក្មេងទាំងអស់នោះក៏រៀនអក្សរឮកងរំពង នឹងស្តាប់ភាសាគ្នាមិនបាន ឯអាចារ្យប៊ិនឃើញអស់ក្មេងរៀនសំបុត្រ ហើយឲ្យយកមកមើលមិនស្គាល់តួអក្សរដល់ ១ សោះ ឯធនញ្ជ័យសួរថា អាចារ្យស្គាល់អក្សរនេះឬទេ ឯអាចារ្យប៊ិនថា ទេ ទើបធនញ្ជ័យថា នេះគេហៅអក្សរមឹងឆ្វេង អក្សរព្រាហ្មណ៍ចាម បើមិនស្គាល់ដូច្នេះនឹងឆ្លើយប្រស្នានឹងគ្នាមិនបានទេ អ្នកឯងចាញ់

អញនឹងអក្សរនេះហើយ ឯអាចារ្យបិនក៏ទទួលថា មិនស្គាល់អក្សរនោះមែន ឯធនញ្ជ័យនោះថា បើដាច់ហើយអញយកតែរបស់ក្នុងសំពៅទាំង ៤ ឯសំពៅនោះអញឲ្យវិលទៅស្រុកវិញ ឯគេក៏អញថ្វាយទៅស្ដេចក្រុងបិនវិញដែរ តែអំពីថ្ងៃនេះទៅ បើឮឈ្មោះធនញ្ជ័យអ្នកប្រាជ្ញ ឲ្យខ្លាចគ្រប់ប្រទេសទៅ ឯអាចារ្យបិនក៏ព្រមឲ្យរបស់ក្នុងសំពៅទាំង ៤ នោះ ហើយក៏បើកសំពៅទៅស្រុកវិញ ឯធនញ្ជ័យនោះកាលបើបានរបស់អំពីសំពៅទាំង ៤ នោះហើយ ឲ្យដឹកញ្ជូនអស់របស់ទ្រព្យនោះទៅថ្វាយព្រះបាទជាអម្ចាស់ទាំងអស់ នឹងមានយកជារបស់ខ្លួនក៏ទេ ឯព្រះមហាក្សត្រ បានឮធនញ្ជ័យឈ្នះប្រស្នាអាចារ្យបិនដូច្នោះហើយ លុះដល់ឃើញធនញ្ជ័យឲ្យដឹកញ្ជូនអស់របស់ទ្រព្យមកថ្វាយដូច្នោះ ក៏ត្រេកអរក្នុងព្រះរាជហឫទ័យ ហើយមានព្រះបន្ទូលថា ធនញ្ជ័យឯងបានយកទុកខ្លះឬទេ? របស់ទាំងអស់នេះ ធនញ្ជ័យក្រាបទូលថា ទូលព្រះបង្គំពុំបានទុកទេ ស្ដេចស្ដាប់ហើយក៏មានព្រះបន្ទូលថា បើដូច្នោះអញនឹងឲ្យយកស្រីក្នុងវាំងធ្វើជាប្រពន្ធឯង ហើយនឹងរបស់ទ្រព្យទាំងអស់

គ្រប់មុខកុំឲ្យមានខ្វះខាតរបស់អ្វី ឯធនញ្ជ័យក្រាបទូលថា ខ្ញុំទូលបង្គំមិនចង់បានទេប្រពន្ធនោះ ដ្បិតមិនមែនជាស្រីទេ ឈ្មោះញី មិនប្រាកដជាស្រី សូមជ្រាប ស្ដេចស្ដាប់ហើយក៏មានព្រះបន្ទូលសួរថា ឯណាឈ្មោះស្រីនោះ ទើបធនញ្ជ័យថា ខ្ញុំទូលបង្គំនឹងក្រាបថ្វាយបង្គំលាទៅរក បើបាននឹងនាំមកថ្វាយ ហើយទូលថា សូមព្រះអង្គព្រះរាជទានសំពត់ហូលព្រែឲ្យច្រើននឹងទៅរកស្រីនោះទើបឃើញ ស្ដេចស្ដាប់ហើយព្រះរាជទានហូលព្រែឲ្យធនញ្ជ័យជាច្រើន ហើយទ្រង់ផ្ដាំថា បើរកបានឲ្យវិលមកឆាប់ ឯធនញ្ជ័យក្រាបថ្វាយបង្គំលា យករបស់នោះរៀបស្រេចហើយស្ពាយសំពាយដើរទៅរកស្រីនោះ ។

លុះដល់ទីណាមានគេនៅច្រើននោះ ចូលទៅសួរគេថា ស្រុកនេះមានស្រីឬទេ អ្នកស្រុកប្រាប់ថាស្រីមានដែរ ទើបធនញ្ជ័យថា មិនមែនស្រីទេ នេះគេហៅឈ្មោះញី មិនមែនស្រីទេ ធនញ្ជ័យថាហើយដើរទៅរកភូមិគេឯទៀតវិញ ហើយចូលទៅសួរថា ក្នុងស្រុកនេះតើមានស្រីឬទេ អស់អ្នកស្រុកប្រាប់ថា ខ្ញុំឆ្ងល់ណាស់ ចុះអស់ទាំងស្រីនេះតើគេហៅថាជា

អ្វីញ បើមិនជាស្រីទេ ឯធនញ្ជ័យថា ទេ នេះគេហៅញីទេ ជាហើយក៏ដើរទៅសួររកស្រីទៀត លុះទៅដល់ភូមិផ្ទះនាងសួស្ដី ហើយដើរចូលទៅសួររកស្រី ក៏បានប្រទះនឹងនាងសួស្ដីមកអង្គុយនៅដីមុខផ្ទះនោះឯង ឯធនញ្ជ័យចូលទៅដល់ហើយក៏ផណ្ដឹងថា អ្នកប្អូន នៅនេះមានស្រីទេ ឯនាងសួស្ដីស្ដាប់ហើយឆ្លើយថា អ្នកឯងនេះនៅស្រុកណា មានទេប្រុសក្នុងស្រុកអ្នកឯង ឯធនញ្ជ័យស្ដាប់ហើយក៏គិតថា នេះហើយគេហៅស្រីសួស្ដី ទើបធនញ្ជ័យប្រាប់ថា ឯស្រុកខ្ញុំមានប្រុសដែរ តើនាងដឹងឬទេឈ្មោះប្រុសនោះឯង នាងសួស្ដីថា ខ្ញុំដឹង បានជាគេហៅប្រុសនោះ ដ្បិតគេឈ្មោះជ័យនោះឯង ជ័យនោះប្រែថាធំជាងអស់ឈ្មោះផង ជ័យឈ្នះអស់ក្នុងផែនដីនេះឯង បានជាហៅប្រុស ៗ នោះដ្បិតឈ្មោះជ័យនោះឯង ទើបនាងសួស្ដីថា អ្នកឯងស្គាល់ទេស្រីនោះ ទើបធនញ្ជ័យថា ខ្ញុំស្គាល់ បានជាគេហៅស្រី ៗ នោះដ្បិតតែឈ្មោះសួស្ដីនោះឯងជាសួស្ដីមង្គលជាធំក្នុងផែនដីនេះនឹងរកឈ្មោះណាឲ្យផ្ទឹមគ្មាន បានជាគេហៅស្រី ៗ

នោះផ្សិតតែឈ្មោះសួស្ដី ទើបធនញ្ជ័យសួរថា នាងមានខ្លាចឬគ្មានខ្លាចទេ ទើបនាងសួស្ដីឆ្លើយថាខ្ញុំគ្មានខ្លាចទេ ថាអ្នកឯងតើមានក្រែងឬមិនក្រែងទេ ទើបធនញ្ជ័យឆ្លើយថាខ្ញុំគ្មានក្រែងអ្វីទេ ហើយធនញ្ជ័យដណ្ដឹងថា ខ្ញុំសួរនាងថា ខ្លាចឬគ្មានខ្លាច នោះតើនាងដឹងឬទេ នាងសួស្ដីឆ្លើយថា ខ្ញុំដឹងហើយ គឺអ្នកដណ្ដឹងថា មានប្ដីឬនៅឡើយ បើមានប្ដីហើយខ្លាចប្ដីដែរ បើគ្មានប្ដីទេនោះថា មិនខ្លាចទេ ទើបនាងសួស្ដីដណ្ដឹងថា ក្រែងឬមិនក្រែង នោះតើអ្នកថាដូចម្ដេច ទើបធនញ្ជ័យប្រាប់ថា ខ្ញុំដឹង នាងឯងសួរខ្ញុំថា មានប្រពន្ធហើយឬនៅទេ បើមានប្រពន្ធហើយក្រែងចិត្តប្រពន្ធនោះ បើគ្មានប្រពន្ធទេ ថាមិនក្រែងចិត្តនរណាទេ ឯធនញ្ជ័យបានដឹងជានាងសួស្ដីគ្មានប្ដីដូច្នេះហើយក៏ដាក់សំពាយអំពីស្មា ហើយស្រាយសំពាយហូលព្រៃបេញឲ្យម្ដាយអាពុកនាងសួស្ដីឃើញ ។

# បញ្ជីរឿង


ទំព័រ

១ ព្រហ្មចារិយកថា របស់ព្រះមហាសែស ក្រុមពុទ្ធសាសនបណ្ឌិត្យ ប្រែនិងរៀបរៀង (ត) . . . . . . . . . . . . . . . . . . . . . . ៨៣

២ សុភាសិតភិតាកថា របស់ព្រះគ្រូញាណសំវរ ញាណ-ឈឹម ក្រុមពុទ្ធសាសនបណ្ឌិត្យ ប្រែនិងរៀបរៀង . . . . . . . . . . . . . . . . . . ១០៩

៣ ធាតុវង្គបទ របស់ព្រះមហាពិទូរ ក្រសេម . . . . . . . . . . . . . . . . ១២៣

លោកន័យ ពាក្យកាព្យ របស់ឧកញ៉ាវង្សាសរពេជ្ញ (នង) . . . . . . . . ១៣៣

រឿងព្រេងខ្មែរដែលមិនទាន់បោះពុម្ពផ្សាយ រឿងធនញ្ជ័យបណ្ឌិត . . . . . . ១៤៩


# រូបក្រៅរឿង


ប្រាសាទព្រះខ្នាយ នៅស្រុកបារាយ កំពង់ធំ . . . . . . . . . . . . . . . ៨១

# TABLE DES MATIÈRES

Pages

1. Brahmacariyakathā . . . . . . . . . . . . . . . . . . . . . . . . 83

2. Subhāsitā vācākathā. . . . . . . . . . . . . . . . . . . . . . . . 109

3, Cāturaṅgapada. . . . . . . . . . . . . . . . . . . . . . . . . . 123

4. Lokaneya (Poème) . . . . . . . . . . . . . . . . . . . . . . . . 133

5. Conte populaire cambodgien inédit :

(Légende de Thmenh chey Pandit) (suite). . . . . . . . . . . . 149

## Hors texte

Prasat Prah Khnay Barai (Kompong-Thom) . . . . . . . . . 81



ប្រាសាទព្រះខ្ជាយ នៅស្រុកបារាយ កំពង់ធំ

ព្រហ្មចរិយកថា

របស់

ព្រះមហាសែស ក្រុមជំនុំប្រែព្រះត្រៃបិដក

នៅពុទ្ធសាសនបណ្ឌិត្យ

រៀបរៀង (ត)

ម្នាលអានន្ទ ទក្ខិណាវិសុទ្ធិ គឺការបរិសុទ្ធនៃទានមាន ៤ ប្រការ ទាយកតោ វិសុជ្ឈតិ នោ បដិគ្គាហកតោ គឺ ទានបរិសុទ្ធអំពីអ្នកឲ្យ មិនបរិសុទ្ធអំពីអ្នកទទួល១ បដិគ្គាហ-កតោ វិសុជ្ឈតិ នោ ទាយកតោ ទានបរិសុទ្ធអំពីអ្នកទទួល មិនបរិសុទ្ធអំពីអ្នកឲ្យ ១ នេវ ទាយកតោ វិសុជ្ឈតិ នោ បដិគ្គាហកតោ ទានមិនបរិសុទ្ធអំពីអ្នកឲ្យផង មិនបរិសុទ្ធអំពីអ្នកទទួលផង ១ ទាយកតោ ចេវ វិសុជ្ឈតិ បដិគ្គាហកតោ ច ទានបរិសុទ្ធអំពីអ្នកឲ្យផង អំពីអ្នកទទួលផង ១ ។

ក៏ឯទានដែលបរិសុទ្ធអំពីអ្នកឲ្យ មិនបរិសុទ្ធអំពីអ្នកទទួល នោះ គឺអ្នកឲ្យមានសីលបរិសុទ្ធ មានធម៌ល្អ អ្នកទទួល ទ្រុស្តសីល មានធម៌អាក្រក់ ។

ទានដែលបរិសុទ្ធអំពីអ្នកទទួល មិនបរិសុទ្ធអំពីអ្នកឲ្យ នោះ គឺអ្នកឲ្យជាអ្នកទ្រុស្តសីល មានធម៌អាក្រក់ អ្នកទទួល ជាអ្នកមានសីលបរិសុទ្ធ មានធម៌ល្អ ។

ទានដែលមិនបរិសុទ្ធអំពីអ្នកឲ្យផង មិនបរិសុទ្ធអំពីអ្នកទទួលផងនោះ គឺអ្នកឲ្យក៏ជាអ្នកទ្រុស្តសីល មានធម៌អាក្រក់ អ្នកទទួលក៏ជាអ្នកទ្រុស្តសីល មានធម៌អាក្រក់ដូចគ្នា ។

ទានដែលបរិសុទ្ធអំពីអ្នកឲ្យផង អំពីអ្នកទទួលផងនោះ គឺអ្នកឲ្យក៏ជាអ្នកមានសីលបរិសុទ្ធ មានធម៌ល្អ អ្នកទទួលក៏ជាអ្នកមានសីលបរិសុទ្ធ មានធម៌ល្អដូចគ្នា ទាំងពីរខាង ។

ចប់ទក្ខិណាវិភង្គសូត្រ ។

ម្យ៉ាងទៀត ទានដែលបុគ្គលបានឲ្យដោយប្រពៃហើយ រមែងកើតមានអានិសង្ស ៥ ប្រការ ដល់បុគ្គលអ្នកឲ្យនោះមិនខាន ព្រោះហេតុនោះបានជាព្រះដ៏មានព្រះភាគ ទ្រង់សំដែងធម៌ទេសនាដល់សេនាបតីឈ្មោះថា សីហ មានក្នុងគម្ពីរអង្គុត្តរនិកាយ បញ្ចកនិបាតថា ទាយកោ សីហ ទានបតិ ពហុនោ ជនស្ស បិយោ ហោតិ មនាបោ ។ ល ។ តទម្បិ សីហ សន្ទិដ្ឋិកំ ទានផលំ ។ ម្ចាស់សីហសេនាបតី បុគ្គលជាអ្នកឲ្យជាម្ចាស់នៃទាន រមែងជាទីស្រឡាញ់ ជាទីគាប់ចិត្តនៃជន

ច្រើនគ្នា ម្នាលសីហសេនាបតី នេះជាផលទានកើតមានក្នុងបច្ចុប្បន្ន ១ ។

បុនបរំ សីហ ទាយកំ ទានបតឹ សន្តោ សប្បុរិសា ភជន្តិ ។ល។ ឥទម្បិ សីហ សន្ទិដ្ឋិកំ ទានផលំ ។ ម្នាលសីហសេនាបតី មួយវិញទៀត ពួកសប្បុរសដែលមានចិត្តស្ងប់រម្ងាប់ រមែងសេពគប់នូវបុគ្គលជាអ្នកឲ្យ ជាម្ចាស់នៃទាន ម្នាលសីហសេនាបតី នេះជាផលទានកើតមានក្នុងបច្ចុប្បន្ន ១ ។

បុន បរំ សីហ ទាយកស្ស ទានបតិនោ កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ ។ល។ ឥទម្បិ សីហ សន្ទិដ្ឋិកំ ទានផលំ ។ ម្នាលសីហសេនាបតី មួយវិញទៀត កិត្តិសព្ទដែលល្អរបស់បុគ្គលដែលជាអ្នកឲ្យ ជាម្ចាស់នៃទាន រមែងផ្សាយទៅសព្វទិស ម្នាលសីហសេនាបតី នេះជាផលទានកើតមានក្នុងបច្ចុប្បន្ន ១ ។

បុន បរំ សីហ ទាយកោ ទានបតិ យញ្ញទេវ បរិសំ ឧបសង្កមតិ យទិ ខត្តិយបរិសំ យទិ ព្រាហ្មណបរិសំ យទិ

គហបតិបរិសំ យទិ សមណបរិសំ វិសារទោ ឧបសង្កមតិ អមង្កុភូតោ ។ល។ ឥទម្បិ សីហ សន្ទិដ្ឋិកំ ទានផលំ ។ ម្នាលសីហសេនាបតី មួយវិញទៀត បុគ្គលជាអ្នកឲ្យ ជាម្ចាស់នៃទាន ទោះបីចូលទៅកាន់បរិសទ្យឯណាៗ គឺខត្តិយបរិសទ្យក្តី ព្រាហ្មណបរិសទ្យក្តី គហបតិបរិសទ្យក្តី សមណបរិសទ្យក្តី រមែងជាអ្នកក្លៀវក្លា ឥតកោតញញើត មានមុខមិនឱនចុះ ម្នាលសីហសេនាបតី នេះជាផលទានកើតមានក្នុងបច្ចុប្បន្ន ១ ។

បុនបរំ សីហ ទាយកោ ទានបតិ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ ។ ល ។ ឥទំ សីហ សម្បរាយិកំ ទានផលំ ។ ម្នាលសីហសេនាបតី បុគ្គលជាអ្នកឲ្យ ជាម្ចាស់នៃទាន កាលបើមានកាយបែកធ្លាយទៅហើយ ខាងមុខអំពីសេចក្តីស្លាប់ ក៏រមែងចូលទៅកាន់លោកគឺស្ថានសួគ៌ជាសុគតិ ម្នាលសីហសេនាបតី នេះជាផលទានកើតមានក្នុងបរលោក ១ ។

មួយវិញទៀត ទានមាន២ប្រការ គឺ អាមិសទាន ១ ធម្មទាន ១ សមដោយភាសិតដែលព្រះដ៏មានព្រះភាគទ្រង់សំដែងទុកមក មាននៅក្នុងគម្ពីរអង្គុត្តរនិកាយ ទុកនិបាតថា ទ្វេមានិ ភិក្ខវេ ទានានិ កតមានិ ទ្វេ អាមិសទានញ្ច ធម្មទានញ្ច ។ ឯតទគ្គំ ភិក្ខវេ ឥមេសំ ទ្វិន្នំ ទានានំ យទិទំ ធម្មទានំ ។ ម្នាលភិក្ខុទាំងឡាយ ទានមាន២ប្រការ ឯទាន ២ប្រការនោះតើដូចម្តេច ទាន២ប្រការនោះគឺៈ អាមិសទាន១ ធម្មទាន១ ម្នាលភិក្ខុទាំងឡាយ បណ្តាទានទាំង២ប្រការនេះ បំណែកធម្មទានប្រសើរជាងអាមិសទាន ។

ឯអាមិសទាន គឺ ចេតនាជាគ្រឿងលះបង់នូវអាមិសវត្ថុ បានដល់បច្ច័យទាំង៤ គឺ ចីវរប្បច្ច័យ១ បិណ្ឌបាតប្បច្ច័យ ១ សេនាសនប្បច្ច័យ១ គិលានភេសជ្ជប្បច្ច័យ១ ដ៏សមគួរតាមពុទ្ធានុញ្ញាត ។

បុគ្គលដែលប្រកបដោយសទ្ធា បានធ្វើទានដោយបច្ច័យទាំង៤នោះ រមែងបានអានិសង្សផ្សេងៗ រមែងបានប្រយោជន៍និងសេចក្តីសុខជាច្រើន ដូចមានវត្ថុនិទានថាៈ

អតីតេ ពារាណសិភាសី ឯកោ កុដុម្ពិកោ ក្នុងកាលដ៏កន្លងទៅហើយ មានកុដុម្ពីមួយនាក់ នៅក្នុងនគរពារាណសី មានកាលមួយថ្ងៃត្រាចដើរទៅក្នុងព្រៃ បានជួបនឹងព្រះបច្ចេកពុទ្ធ ១ អង្គកំពុងដេរចីវរ នៅខ្វះសំពត់មិនទាន់គ្រប់គ្រាន់ត្រង់អនុវាតបណ្តោយ ។

ឯកុដុម្ពីនោះ ក៏មានចិត្តជ្រះថ្លា ហើយយកសំពត់សំរាប់បង់ករបស់ខ្លួនប្រគេនទៅព្រះបច្ចេកពុទ្ធ ។ ដោយអានុភាពនៃបុញ្ញកម្មនោះ បុរសនោះក៏បានទៅកើតក្នុងស្ថានតាវតឹង្ស-ទេវលោក បានសោយទិព្វសម្បត្តិជាយូរអង្វែង លុះច្យុតអំពីទេវលោកនោះមក ក៏បានមកកើតក្នុងត្រកូលអមាត្យ នៅក្នុងទីចម្ងាយ ១ យោជន៍អំពីនគរពារាណសី បុរសនោះក៏មានវ័យវិឌ្ឍនាការចំរើនធំឡើង មានកាលមួយថ្ងៃ ជាថ្ងៃលេងនក្ខត្ត-ឫក្ស បុរសនោះនិយាយនឹងមាតារបស់ខ្លួនថា បពិត្រអ្នកម៉ែ ប្ដូរឲ្យសំពត់ ១ មកខ្ញុំៗ នឹងទៅលេងនក្ខត្តឫក្សនឹងគេ មាតានោះក៏ឲ្យសំពត់ស្អាតមួយទៅ បុរសនោះនិយាយថាសំពត់នេះមានសាច់គ្រោតគ្រាតណាស់ខ្ញុំមិនយកទេ មាតាក៏ឲ្យសំពត់ដទៃ

ទៀត បុរសនោះក៏មិនព្រមយកសំពត់នោះទៀត ។ មាតាក៏និយាយថា ក្នុងផ្ទះយើងមិនមានសំពត់ឯណាល្អជាងសំពត់នេះទៀតទេ ។ បុរសនោះនិយាយថា បើដូច្នោះខ្ញុំទៅស្វែងរកសំពត់គួរជាទីគាប់ចិត្តឲ្យបាន ។ មាតានិយាយថា ម្នាលកូន ម្តាយមិនស្អប់កូនទេ សព្វថ្ងៃនេះម្តាយមានចិត្តចង់ឲ្យកូនឯងបានសោយរាជ្យក្នុងនគរពារាណសីនេះផង ។ បុរសនោះក៏ថ្វាយបង្គំមាតាដើរចេញទៅ ហេតុតែមានកុសលរាសីអំពីបុព្វជាតិ ក៏ត្រូវមានកំណត់បុណ្យមកដះទៀន បុរសនោះដើរចូលទៅកាន់នគរពារាណសី ក៏ចូលទៅដេកទន្ទូរលើផែនថ្មមង្គលសិលាក្នុងសួនឧទ្យាន ។ កាលនោះ ជាថ្ងៃដែលព្រះរាជាក្នុងនគរពារាណសី ទ្រង់សោយព្រះទីវង្គតទៅបាន ៧ ថ្ងៃហើយ ។ ពួកជនមានអមាត្យជាដើម នាំគ្នាធ្វើសរីរកិច្ចដល់ព្រះរាជាជាស្រេច ក៏ប្រឹក្សាគ្នាថា ឥឡូវព្រះរាជាមានតែព្រះរាជធីតា ១ ឯព្រះរាជបុត្រពុំមានឡើយ ធម្មតាស្រុកនគរបើឥតមានស្តេចនឹងមិនបានស្ថិតស្ថេរនៅឡើយ គឺថានឹងវិនាសទៅជាប្រាកដ ហើយក៏រៀបចំបុស្សរថ ទឹមសេះសិន្ធព ៤ មានសម្បុរដូចផ្កា

កុមុទ ហើយយករាជកកុធភណ្ឌ(១) ទាំង៥ប្រការ ដំកល់ទុកលើរថ ហើយក៏លែងបុស្សរថទៅ ។ បំណែកបុស្សរថក៏ចេញទៅតាមទ្វារខាងកើត ហើយបួលទៅកាន់សួនឱទ្យាន ហើយប្រទក្សិណកុមារដែលដេកក្នុងទីនោះ ហើយឈប់នៅស្ងៀមបំរុងប្រុងប្រៀបនឹងឲ្យកុមារឡើងជិះ ។

បំណែកបុរោហិតក៏បើកដាយសំពត់ដណ្ដប់ឡើង ហើយរមិលមើលផ្ទៃជើងសព្វគ្រប់ ហើយទាយថាបុរសនេះគួរនឹងសោយរាជ្យបាន ហើយក៏ប្រគំតូរ្យតន្ត្រីអស់វារៈ ៣ ដង ។ លំដាប់នោះ កុមារបើកមុខឡើងសួរថា អ្នកទាំងឡាយនាំគ្នាមករកអ្វី ជនទាំងឡាយតបថា បពិត្រព្រះសម្មតិទេព ឥឡូវរាជសម្បត្តិធ្លាក់លើព្រះអង្គហើយ ។ កុមារសួរថា បុះព្រះរាជារបស់អ្នកទាំងឡាយទៅឯណា ។ ព្រះរាជារបស់យើងខ្ញុំទាំងឡាយ ទ្រង់សោយព្រះទិវង្គតទៅហើយ ។ សោយព្រះទិវង្គតទៅប៉ុន្មានថ្ងៃហើយ ។ មកដល់ថ្ងៃនេះ៧ថ្ងៃហើយ ។

---

១ គ្រឿងប្រដាប់សម្រាប់អភិសេកស្ដេច គឺ ខគ្គ ព្រះខ័ន ១ ឆត្តំ ឆត្រ ១ ឧណ្ហិសំ មកុដឬក្បាំង ១ បាទុកា ទ្រនាប់ជើង (ស្បែកព្រះបាទ) ១ វាលវីជនី ផ្លិតរោមកន្ទុយសត្វ ១ ។

បុះព្រះរាជបុត្រក្តី ព្រះរាជធីតាក្តី មិនមានទេឬ ។ មានតែព្រះរាជធីតា ព្រះរាជបុត្រពុំមានទេ ។ កុមារឆ្លើយថា បើដូច្នោះយើងនឹងសោយរាជ្យបុះ ។ ជនទាំងនោះ ក៏ធ្វើមណ្ឌបសម្រាប់អភិសេកមួយរំពេច ហើយក៏រៀបចំអភិសេកក្នុងមណ្ឌបនោះនាំយកសំពត់មានដំឡៃ ១ ពាន់កហាបណទៅថ្វាយ ។ ព្រះរាជានោះ មានព្រះបន្ទូលថា សំពត់នេះ ជាសំពត់មានសាច់គ្រោតគ្រាតណាស់ យើងមិនត្រូវការទេ អ្នកទាំងឡាយ ចូរយកកុណ្ឌីមាសមក យើងមុខជានឹងបានសំពត់ល្អ ហើយក៏ក្រោកឡើងយកព្រះហស្តកាន់ទឹកបាចសាចទៅក្នុងទិសខាងកើត ។ ដើមកល្បព្រឹក្ស ៨ ដើមក៏ទំលាយផែនដីតាន់ផុសឡើងភ្លាម ។ ទិសខាងត្បូងក្តី ខាងលិចក្តី ខាងជើងក្តីមានដើមកល្បព្រឹក្ស ៨ ដើម ៗ ផុសឡើងដូចគ្នា ។ មានដើមកល្បព្រឹក្ស ៣២ ដើម ផុសឡើងដោយប្រការដូច្នេះ ។ សំពត់ក៏កើតឡើងបរិបូណ៌ ក្នុងដើមកល្បព្រឹក្សទាំងអម្បាលនោះ។ ព្រះរាជានោះក៏ទ្រង់ស្លៀកសំពត់ទិព្វ ១ ដណ្តប់សំពត់ទិព្វ ១ ហើយទ្រង់ឲ្យវាយស្គរភេរីប្រកាសប្រាប់មនុស្សទាំងអស់នៅក្នុង

ដែនថា ពួកស្ត្រីក្នុងដែនព្រះបាទនន្ទរាជ កុំបាច់រវៃសូត្រអម្បោះឡើយ ហើយទ្រង់ឲ្យលើកឆត្រឡើង ទ្រង់គង់លើកដំរីដ៏ប្រសើរ យាងចូលទៅកាន់ព្រះនគរ ទ្រង់ឡើងកាន់ប្រាសាទសោយសម្បត្តិដ៏ថ្កុំថ្កើង ទ្រង់រៀបចំដែនទាំងមូលឲ្យស្អាតល្អប្រ-ហែលនឹងឧត្តរកុរុទ្វីប ទ្រង់ព្រះរាជទានសំពត់ទិព្វដល់ពួកមនុស្សដែលមកទាំងអម្បាលម៉ាន លុះកាលជាបំណែកខាងក្រោយមក ទ្រង់មានសេចក្តីនឿយណាយក្នុងឃរាវាស ហើយទ្រង់ព្រះផ្នួសជាមួយនឹងនាងទេវីជាអគ្គមហេសី ទ្រង់គង់នៅក្នុងសួនឧទ្យាន ក៏បានឈានសមាបត្តិ មានសភាពជាបុគ្គលមិនបានសាបសូន្យចាកឈាន លុះអស់ព្រះជន្មាយុទៅ ក៏បានទៅកើតក្នុងព្រហ្មលោកនាយ ។ ព្រះបាទនន្ទរាជនោះ គឺព្រះមហាកស្ស-បត្ថេរ ក្នុងកាលឥឡូវនេះ ។ បំណែកខាងនាងទេវី គឺនាងភទ្ទាកាបិលានី ជាភរិយាព្រះថេរ ក្នុងកាលនៅជាគ្រហស្ថ ។ រឿងព្រះបាទនន្ទរាជនេះ មានមកក្នុងអដ្ឋកថា សំសារមោចក-បេតវត្ថុ ។

សំដែងរឿងនេះ ដើម្បីញុាំងសាធុជនឲ្យជ្រាប ក្នុងអានិសង្សបរិវទាន ដែលបុគ្គលបានធ្វើដល់ព្រះអរិយបុគ្គលជាបុញ្ញក្ខេត្តដ៏វិសេស ។

មានរឿងមួយទៀតថា ក្នុងនគរសាវត្ថី មានធីតានៃនាយមាលាការម្នាក់ ជាស្រីមានរូបល្អ មានបញ្ញាច្រើន មានអាយុ ១៦ ឆ្នាំ ។ មានកាលមួយថ្ងៃ នាងធីតានោះយកនំ ៣ ដុំដាក់ក្នុងប្រែងដែលសម្រាប់ដាក់ផ្កា ដើរទៅកាន់ច្បារផ្កា នាងក៏បានឃើញព្រះសាស្ដាព្រមទាំងព្រះភិក្ខុសង្ឃ កំពុងនិមន្តចូលទៅកាន់នគរដើម្បីបិណ្ឌបាត នាងក៏មានចិត្តត្រេកអរ យកនំទៅដាក់ក្នុងបាត្រព្រះសាស្ដា រួចហើយថ្វាយបង្គំ ញុាំងបីតិមានព្រះពុទ្ធជាអារម្មណ៍ ឲ្យកើតឡើងហើយឈរនៅក្នុងទីដ៏សមគួរ ។ ព្រះសាស្ដាទ្រង់រមិលមើលនាងធីតានោះ ទ្រង់ធ្វើព្រះភក្ត្រញញឹម ព្រះអានន្ទត្ថេរក្រាបទូលសួរអំពីហេតុដែលទ្រង់ញញឹម ព្រះអង្គមានព្រះបន្ទូលថា ម្នាលអានន្ទ នាងកុមារិកានេះនឹងបានជាអគ្គមហេសី នៃព្រះបាទកោសលរាជក្នុងថ្ងៃនេះ ដោយ

អំណាចផលទាននំនេះមិនខានឡើយ ហើយទ្រង់យាងចៀសចេញទៅ ។ ក៏ឯនាងធីតានោះដើរចូលទៅកាន់ច្បារផ្កា ស្រែកច្រៀងបណ្តើរ បេះផ្កាបណ្តើរ ។ ចួនជាក្នុងថ្ងៃនោះឯង ព្រះបាទកោសលរាជ ទ្រង់ច្បាំងគ្នានឹងព្រះបាទអជាតសត្តុរាជ ចាញ់ទ័ពព្រះបាទអជាតសត្តុរាជ ក៏រត់ចេញមកទ្រង់គង់លើព្រះទីន័ងសេះបរមក បានឮសំឡេងនាងធីតានោះច្រៀង ក៏មានព្រះរាជហឫទ័យប្រតិព័ទ្ធទ្រង់យាងចូលទៅក្នុងច្បារផ្កា ទ្រង់ជ្រាបថានាងនោះមិនទាន់មានប្តី ហើយទ្រង់ឲ្យនាងនោះឡើងជិះលើខ្នងសេះ មានពួកពលហ៊ោមរោមជាបរិវារ ហែហមចូលទៅកាន់ព្រះនគរ ទើបទ្រង់បញ្ជូននាងនោះឲ្យត្រឡប់ទៅកាន់ផ្ទះនៃត្រកូលរបស់ខ្លួនវិញ ។ វេលាថ្ងៃរសៀលទ្រង់ឲ្យហែហមនាំយកអំពីត្រកូលនោះមកវិញ ដោយគ្រឿងសក្ការដ៏ថ្កុំថ្កើង ហើយទ្រង់អភិសេកលើគំនរកែវ តាំងជាមហេសីធំក្នុងព្រះនគរ ។ ឯមហេសីនោះជាទីស្រឡាញ់ពេញព្រះហឫទ័យរបស់ព្រះរាជា ជាស្ត្រីស្និទ្ធស្នាលនឹងព្រះរត្នត្រ័យមានព្រះពុទ្ធជាដើម មាននាម

ប្រាកដថា មល្លិកាទេវី ។ រឿងមល្លិកាទេវីនេះ មានក្នុងអដ្ឋ-កថាកុម្មាសបិណ្ឌិយជាតក ក្នុងសត្តកនិបាត ។ សំដែងរឿងនេះដើម្បីញ៉ាំងសាធុជនឲ្យជ្រាបក្នុងបិណ្ឌបាតទានដែលបុគ្គលបានធ្វើដល់ព្រះពុទ្ធជាម្ចាស់ ជាមហេន្ទអតុលខេត្ត ។

មានរឿងមួយទៀតថា តេន ប សមយេន ធរមានកកស្សបពុទ្ធស្ស សាសនេ ឯកោ ថេរោ អរញ្ញវាសំ វសតិ ។ សម័យនោះ ក្នុងសាសនា ព្រះពុទ្ធទ្រង់ព្រះនាមកស្សប ទ្រង់មានព្រះជន្មាយុគង់នៅឡើយ មានព្រះថេរ ១ អង្គគង់នៅក្នុងព្រៃជាវត្ត ។ ព្រះបរមពោធិសត្វកើតក្នុងត្រកូលគហបតី ថ្ងៃ ១ ព្រះបរមពោធិសត្វចូលទៅកាន់ព្រៃដោយការងាររបស់ខ្លួន បានឃើញព្រះថេរនោះ ក៏ចូលទៅជិតថ្វាយបង្គំ ហើយរមិលមើលទីកន្លែងដែលព្រះថេរអង្គុយនឹងបង្ក្រមជាដើម ហើយទូលសួរព្រះថេរថា លោកម្ចាស់មកគង់ក្នុងទីនេះឬអ្វី ។ ព្រះថេរឆ្លើយថា អើឧបាសក អាត្មាមកនៅក្នុងទីនេះ ។ ព្រះបរមពោធិសត្វគិតពិចារណាថា បើអាត្មាអញធ្វើបណ្ណសាលាប្រគេនលោកម្ចាស់ក្នុងទី

នេះ យល់ជាការគួរប្រពៃណាស់ លុះគិតដូច្នោះហើយ ក៏លះបង់ការងាររបស់ខ្លួនចោលចេញ ចាត់ចែងគ្រឿងទព្វសម្ភារសាងជាបណ្ណសាលាមួយប្រក់ហើយស្រេច យកដីស្អិតមកលាបបូកជញ្ជាំង ហើយធ្វើឲ្យមានទ្វារបើកបិទចេញចូល ក្រាលដោយរនាបឈើ ហើយអង្គុយក្នុងទីដ៏សមគួរ ដោយសេចក្តីត្រិះរិះថា លោកម្ចាស់នឹងប្រើប្រាស់បណ្ណសាលានេះ ឬក៏មិនប្រើប្រាស់ទេ ។ គ្រានោះព្រះថេរលោកក៏និមន្តមកអំពីខាងក្នុងនៃស្រុក ហើយចូលទៅកាន់បណ្ណសាលាគង់នៅលើរនាបឈើ ។ ឯឧបាសក គឺពោធិសត្វ ក៏មកថ្វាយបង្គំហើយអង្គុយជិតព្រះថេរទូលសួរថា លោកម្ចាស់ បណ្ណសាលានេះសប្បាយឬទេ ។ ព្រះថេរឆ្លើយថា ម្នាលអ្នកមានឧមុខស្រស់បស់ បណ្ណសាលានេះសប្បាយណាស់ ហើយសមគួរដល់អ្នកបួសផង ។ ឧបាសកទូលសួរថា លោកម្ចាស់មុខជានឹងគង់នៅក្នុងទីនេះឬអ្វី ។ ព្រះថេរឆ្លើយថា អើឧបាសក មើលទៅអាត្មាប្រហែលជាទៅក្នុងទីនេះហើយ ។ ឧបាសកនោះដឹងច្បាស់ថាព្រះថេរទទួលនិមន្តហើយ

ក៏និយាយប្តេជ្ញានឹងព្រះថេរថា សូមលោកម្ចាស់និមន្តទៅកាន់ទ្វារផ្ទះខ្ញុំជានិច្ច ហើយសូមពរអំពីព្រះថេរថា សូមលោកម្ចាស់ប្រទានពរ ១ ដល់ខ្ញុំ ។ ម្នាលឧបាសក ធម្មតាអ្នកបួសមានពរកន្លងអស់ហើយ គឺថាឥតមានពរអ្វីឡើយ ។ បពិត្រលោកម្ចាស់ ពរណាដែលគួរ ពរណាដែលឥតទោស ខ្ញុំសូមពរនោះឯង ។ ម្នាលឧបាសក អ្នកចូរនិយាយចុះ ។ បពិត្រលោកម្ចាស់ មនុស្សទាំងឡាយរមែងប្រាថ្នាចង់ឲ្យលោកម្ចាស់និមន្តទៅក្នុងទីលំនៅរបស់ខ្លួន ក្នុងកិច្ចជាមង្គលក្តីមិនមែនជាមង្គលក្តី កាលបើលោកម្ចាស់មិននិមន្តទៅ គេក៏ខឹង ព្រោះហេតុនោះបើទុកជាលោកម្ចាស់ទៅកាន់ទីដែលគេនិមន្តដទៃ ក៏សូមនិមន្តទៅកាន់ផ្ទះខ្ញុំ សម្រេចភត្តកិច្ចក្នុងផ្ទះខ្ញុំកុំខាន ។ ព្រះថេរក៏ទទួលនិមន្តស្រេច ។ ទើបឧបាសកនោះ យកកន្ទេលផែងទៅក្រាល យកគ្រែតាំងទៅរៀបចំក្នុងសាលា ហើយដាក់ភ្នាក់ដៃដកល់ទុកគ្រឿងសំរាប់ជូតជើង ជីកស្រះបោក្ខរណី ១ ធ្វើទីចង្ក្រម ១ យកដីខ្សាច់ទៅពោយរាយក្នុងទីនោះ កាលបើឃើញ

ពួកសត្វម្រឹគមកត្រដុសជញ្ជាំងធ្វើដីស្អិតឲ្យធ្លាក់ចុះ ក៏យកឈើមានបន្លាមកធ្វើជារបងព័ទ្ធជុំវិញ កាលបើឃើញពួកសត្វម្រឹគចុះទៅក្នុងស្រះបោក្ខរណី ធ្វើទឹកឲ្យល្អក់កករ ក៏យកថ្មទៅរៀបក្នុងស្រះ យកឈើមានបន្លាមកធ្វើជារបងព័ទ្ធអំពីខាងក្រៅជុំវិញ ហើយដាំដើមត្នោតជាជួររៀបខាងក្នុងរបង កាលបើឃើញពួកសត្វម្រឹគចូលមកក្នុងទីចង្ក្រម ធ្វើទីកន្លែងរលីងស្អាតឲ្យខូចខាតវឹកវរ ក៏ធ្វើរបងព័ទ្ធជុំវិញទីចង្ក្រម ហើយដាំដើមត្នោតជាជួររៀបខាងក្នុងរបង ឧបាសកញ៉ាំងអាវាសទានឲ្យសម្រេចយ៉ាងនេះហើយ ក៏ប្រគេនត្រៃចីវរពង្ហាន់បិណ្ឌបាត ថ្នាំកែរោគ ភាជនសំរាប់ប្រើប្រាស់ ដែកស្ទាន កាំបិតតូច កាំបិតសម្រាប់កាត់ក្របក ម្ជុល ឈើប្រត់ ស្បែកជើង លក្ខបាន់សម្រាប់ដាក់ទឹក ឆត្រ អំបែងប្រទីប វត្ថុសម្រាប់នាំបង់នូវមន្ទិលគឺប្រែះក្អែល បាត្រ សៀនទឹក សំពត់ដម្រង ធម្មក្រក នឹងប្រគេនបរិក្ខារឯទៀត ៗ ដែលជាគ្រឿងប្រើប្រាស់របស់អ្នកបួសដល់ព្រះថេរ ។ បរិក្ខារអ្វីដែលពោធិសត្វមិនបានប្រគេនដល់ព្រះថេរ

នោះមិនមានឡើយ ។ ពោធិសត្វនោះក៏រក្សានិច្ចសីល ធ្វើឧបោសថកម្មបំរើព្រះថេរអស់ ១ ជីវិត ។ ព្រះថេរក៏បានសម្រេចព្រះអរហត្តហើយបរិនិព្វានក្នុងទីនោះ ។ ពោធិសត្វខំសាងសន្សំបុណ្យដរាបដល់អស់អាយុ បានទៅកើតក្នុងទេវលោក ច្យុតអំពីទេវលោកមកកាន់មនុស្សលោកវិញ បានមកកើតក្នុងក្រុងកុសាវតីរាជធានី បានសោយរាជ្យជាស្តេច ទ្រង់ព្រះនាមថា មហាសុទស្សនចក្រពត្តិនោះហោង ។

អានិសង្សដែលកើតអំពីអាវាសទានជាដើម ដែលពោធិសត្វបានធ្វើមានសេចក្តីអស្ចារ្យផ្សេង ៗ ដូចមានក្នុងមហាសុទស្សនសូត្រ គម្ពីរទីឃនិកាយមហាវគ្គ ។

សំដែងរឿងនេះ ដើម្បីញ៉ាំងសាធុជនឲ្យជ្រាប ក្នុងសេនាសនទាន ដែលបុគ្គលបានធ្វើដល់ភិក្ខុក្នុងព្រះពុទ្ធសាសនាដែលមានសេចក្តីប្រតិបត្តិ បែរមុខទៅរកមគ្គ-ផលព្រះនិព្វាន ។

មានរឿងមួយទៀតថា អតីតេ ពារាណសិយំ ឯកោ មធុវាណិជោ អាបណោ មធុំ វិក្កិណិ ។ ក្នុងកាលដ៏កន្លង

ទៅហើយ ក្នុងនគរពារាណសី មាននាយឈ្នួញលក់ទឹកឃ្មុំម្នាក់ នៅលក់ទឹកឃ្មុំក្នុងរានផ្សារ ។ គ្រានោះ មានព្រះបច្ចេកពុទ្ធ១អង្គកើតរោគដំបៅ ។ លំដាប់នោះ មានព្រះបច្ចេកពុទ្ធ១អង្គទៀត ដើរស្វែងរកសូមទឹកឃ្មុំ ដើម្បីជាថ្នាំដល់ព្រះបច្ចេកពុទ្ធនោះ លោកក៏ចុះអំពីភ្នំគន្ធមាទន៍មកកាន់នគរពារាណសី ។ មាននាងកុម្ភទាសីម្នាក់កំពុងដើរទៅកាន់កំពង់ស្ទឹង បានឃើញព្រះបច្ចេកពុទ្ធនោះ ទូលសួរតាមដំណើរ បានឮសេចក្ដីនោះសព្វគ្រប់ហើយ ក៏លាដៃឡើងចង្អុលបង្ហាញរានផ្សារលក់ទឹកឃ្មុំ. និយាយថា លោកម្ចាស់ នាយឈ្នួញលក់ទឹកឃ្មុំគេនៅក្នុងទីឯណោះ សូមលោកម្ចាស់និមន្តទៅក្នុងទីនោះចុះ ហើយនាងក៏គិតពិចារណាថា បើនាយឈ្នួញគេមិនប្រគេនទឹកឃ្មុំដល់លោកម្ចាស់ទេ អាត្មាអញនឹងទៅក្នុងទីនោះ យកទឹកឃ្មុំប្រគេនលោកម្ចាស់ឲ្យបាន. ហើយចាំស្វែងរកទ្រព្យជាដំឡៃឲ្យគេជាខាងក្រោយវិញ ហើយក៏ទៅឈរចាំក្នុងទីនោះ ។ ព្រះបច្ចេកពុទ្ធក៏និមន្តទៅក្នុងទីនោះឯង ។ នាយឈ្នួញបានឃើញ

ព្រះបច្ចេកពុទ្ធនោះហើយ ក៏មានចិត្តត្រេកអរ ប្រគេនទឹកឃ្មុំត្រា តែពេញបាត្រ លុះឃើញទឹកឃ្មុំហូរហៀរកំពប់អំពីមាត់បាត្រ ធ្លាក់មកលើផែនដី ក៏រឹងរិតតែមានសេចក្ដីជ្រះថ្លាឡើង តាំងសេចក្ដីប្រាថ្នាថា បពិត្រលោកម្ចាស់ ដោយអំណាចបុញ្ញកម្មនេះ ខ្ញុំម្ចាស់សូមឲ្យបានជាស្ដេចឯករាជក្នុងជម្ពូទ្វីប ម្យ៉ាងទៀត ខ្ញុំម្ចាស់សូមឲ្យមានអំណាចផ្សាយទៅក្នុងអាកាស ១ យោជន៍ ក្នុងផែនដី ១ យោជន៍ ។ ព្រះបច្ចេកពុទ្ធមានព្រះពុទ្ធដីកាថា ម្នាលឧបាសក ផលនៃសេចក្ដីប្រាថ្នារបស់អ្នក ចូរសម្រេចយ៉ាងនេះចុះ ហើយក៏និមន្តត្រឡប់ទៅភ្នំគន្ធមាទន៍វិញ ។ ឯនាងកុម្ភទាសីនោះ បានឃើញព្រះបច្ចេកពុទ្ធនោះហើយទូលសួរថា លោកម្ចាស់បានទឹកឃ្មុំឬទេ ។ ព្រះបច្ចេកពុទ្ធប្រាប់ថា អើនាង អាត្មាបានទឹកឃ្មុំហើយ នាយឈ្មួញនោះគេប្រគេនដល់អាត្មា ហើយ គេប្រាថ្នាជាស្ដេចឯករាជក្នុងជម្ពូទ្វីប ។ នាងកុម្ភទាសីនោះ លុះបានឮពាក្យនោះហើយ ក៏ប្រាថ្នាជាអគ្គមហេសីនៃស្ដេចនោះ ។ បណ្ដាជនទាំង ២ នោះ នាយឈ្មួញលក់ទឹក

ឃុំបានជាអសោកកុមារ ជាព្រះរាជបុត្រច្បងបង្អស់នៃព្រះរាជបុត្រទាំង ១០១ របស់ព្រះបាទពិន្ទុសាររាជ ក្នុងក្រុងបាដលិបុត្រ លុះអំណើះអត់អំពីព្រះបិតាទៅហើយ ក៏សំឡាប់ប្អូន ៗ ទាំងអស់ចោលចេញ ទុកតែតិស្សកុមារ ១ ដែលមានមាតាជាមួយគ្នា ហើយបានគ្រប់គ្រងរាជសម្បត្តិ ដោយពុំទាន់បានអភិសេកអស់ ៤ ឆ្នាំ ទើបបានរាជាភិសេកជាឯករាជក្នុងសកលជម្ពូទ្វីប ក្នុងរវាងពុទ្ធសករាជ ២១៨ ឆ្នាំ គិតអំពីបរិនិព្វាននៃព្រះបរមសាស្ដាមក ។ រាជឫទ្ធិទាំងអម្បាលនេះក៏មកដល់ព្រះរាជានោះ ដោយអានុភាពនៃអភិសេក ។ សេចក្ដីថារាជឫទ្ធិទាំងឡាយដែលស្ដេចត្រូវបានដោយអានុភាពនៃបុណ្យ រមែងមកដោយអានុភាពនៃអភិសេក ដែលសម្រេចមកអំពីបយោគសម្បត្តិ ប្រៀបដូចគុណវិសេសទាំងឡាយមានបដិសម្ភិទាជាដើម រមែងមកជាមួយនឹងអរហត្តមគ្គ ។ គឺអំណាចប្រព្រឹត្តទៅបាន ១ យោជន៍ក្នុងផែនដី ១ យោជន៍ក្នុងអាកាស ។ ពួកទេវតានាំយកទឹក ១៦ ក្អមអំពីអនោតត្តស្រះមកថ្វាយសព្វ ៗ ថ្ងៃ នាំយកឈើស្ទន់ជាវិការនៃវល្លិមព្រៃ ដែលទន់ស្និទ្ធមានរសល្អ

នឹងផ្លែស្រម៉ជាថ្នាំ ផ្លែកន្ទួតព្រៃជាថ្នាំនឹងផ្លែស្វាយទុំមានសម្បុរដូចមាស បរិបូណ៌ដោយក្លិននឹងរសអំពីព្រៃហិមពាន្តមកថ្វាយសព្វៗថ្ងៃ ។ មួយវិញទៀត ពួកទេវតានាំយកសំពត់សំរាប់ស្លៀក សំរាប់ដណ្ដប់មានពណ៌ ៥ នឹងសំពត់មានពណ៌លឿង នឹងសំពត់សំរាប់ជូតដៃ នឹងទឹកទិព្វអំពីវិមានទេវតា ដែលតាំងនៅទៀបឆទ្ទន្តស្រះមកថ្វាយសព្វៗថ្ងៃ ។ ពួកនាគរាជនាំយកគ្រឿងក្រអូបសំរាប់ងូត គ្រឿងក្រអូបសំរាប់លាប នឹងសំពត់ផ្កាម្លិះ[១] គេមិនត្បាញដោយសូត្រ[២] ដើម្បីជាសំពត់ដណ្ដប់ នឹងថ្នាំសំរាប់លាបភ្នែកមានដំឡៃច្រើនអំពីពិភពនាគមកថ្វាយសព្វៗថ្ងៃ ពួកសត្វសេកនាំយកស្រូវសាលីកើតឯងក្នុងឆទ្ទន្តស្រះចំនួន ៩ ពាន់រទេះ[៣] មកថ្វាយសព្វៗថ្ងៃ ។ ពួកកណ្ដុរនាំគ្នាបកស្រូវសាលីទាំងនោះធ្វើជាអង្ករ មិនឲ្យមាន

---

១ សំពត់នោះមានសាច់ម៉ដ្ឋល្អ មានក្បាច់ផ្កាម្លិះនៅក្នុងផ្ទៃសំពត់នោះ ។ ២ សំពត់នោះកើតអំពីដើមកល្បព្រឹក្ស ជាសំពត់ទិព្វ គេមិនត្បាញដោយសូត្រឬអំបោះឡើយ ។ ៣, ៤ ក្ដាប់ដៃត្រូវជា ១ កុឌវ (កម្សង់) ។ ៤ កុឌវជា ១ បត្ថ (នាឡិ) ។ ៤ បត្ថជា ១ អាឡ្ហក ។ ៤ អាឡ្ហកជា ១ ទោណ ។ ៤ ទោណជា ១ មានិកា ។ ៤ មានិកាជា ១ ខារិ (អម្រែក) ។ ២០ ខារិជា ១ វាហគឺ ១ រទេះ ។

អង្កាមនឹងកុណ្ឌក ។ អង្ករនោះមិនមានអង្ករបាក់ ១ គ្រាប់ឡើយ ។ ពួកមេឃ្មុំនាំគ្នាមកធ្វើទឹកឃ្មុំក្នុងទីជិតបង្កើយ ។ ពួកខ្លាឃ្មុំនាំគ្នាពុសឧសក្នុងរោងដាងដែក ។ ពួកសត្វករវិកនាំគ្នាមកច្បូបហ្លួបយំប្រគំថ្វាយព្រះរាជា ប្រៀបដូចបុគ្គលអ្នកធ្វើពលីកម្មនៅក្នុងដែនជាប្រក្រតី ។

នាយឈ្មួញលក់ទឹកឃ្មុំនោះ បានជាអសោកធម្មរាជប្រកបដោយរាជឫទ្ធិទាំងអម្បាលនេះ ដោយអំណាចឲ្យទានទឹកឃ្មុំសម្រាប់ជាភេសជ្ជដោយប្រការដូច្នេះ ។ ឯនាងកុម្ភទាសីនោះ បានជាអគ្គមហេសីទ្រង់ព្រះនាមអសន្ធិមិត្តា របស់ព្រះបាទអសោកធម្មរាជនោះ ។ បានឮថាសន្លាក់ដៃ-ជើង របស់នាងអសន្ធិមិត្តានោះស្មើរលើងស្អាត ឥតមានប្រាកដដូចជនដទៃឡើយ វៀរលែងតែកាលដែលនាងបត់បួល ដោយអានិសង្សនៃបុញ្ញកិរិយាវត្ថុ គឺសេចក្ដីខ្វល់ខ្វាយបង្អួលប្រាប់រានផ្សារលក់ទឹកឃ្មុំនោះឯង ព្រោះហេតុនោះបានជាគេថ្វាយព្រះនាមថា នាងអសន្ធិមិត្តា ។

រឿងអសោកធម្មរាជនេះ មានមកក្នុងគម្ពីរទាំងឡាយមានគម្ពីរមហាវង្សជាដើម ។ សំដែងរឿងនេះ ដើម្បីញ៉ាំងសាធុជនឲ្យជ្រាបក្នុងគិលានភេសជ្ជទាន ដែលបុគ្គលបានធ្វើដល់ព្រះអរិយបុគ្គល ជាបុញ្ញក្ខេត្តដ៏វិសេស ។

ឯវំ ចតុប្បច្ចយទាយកោ សុខំ វិន្ទតិ តស្មា ទានំ សយម្បិ បវត្តេតព្វំ ។ បុគ្គលអ្នកឲ្យបច្ច័យ ៤ រមែងបានសេចក្ដីសុខដោយប្រការដូច្នេះ ព្រោះហេតុនោះ អ្នកមានប្រាជ្ញាគួរញ៉ាំងទានឲ្យប្រព្រឹត្តទៅដោយខ្លួនឯង ។

ចប់អាមិសទានដោយសង្ខេបតែប៉ុណ្ណោះ ។

(មានត)

សុភាសិតវាចាកថា

# ព្រះគ្រូញាណសំវរ ញាណ-ឈឹន

ក្រុមពុទ្ធសាសនបណ្ឌិត្យ

ប្រែនិងរៀបរៀង

# សុភាសិតវាចាកថា

## នមត្ថុរតនត្តយស្ស

*សូមនមស្សការចំពោះព្រះរតនត្រ័យគឺៈ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ដោយសេចក្ដីគោរព ។*

គ្រានេះនឹងរៀបរៀងសេចក្ដីក្នុងមង្គលទី ១០ តាមន័យដែលព្រះដ៏មានព្រះភាគ ទ្រង់សំដែងទុកក្នុងមង្គលសូត្រថា សុភាសិតា ច យា វាចា ឯតម្មង្គលមុត្តមំ ប្រែថា វាចាឯណាដែលបុគ្គលពោលដោយល្អដោយពីរោះដោយប្រពៃនេះ ជាមង្គលដ៏ឧត្ដម ។

ក៏ឯវាចាសព្ទនេះព្រះអដ្ឋកថាចារ្យលោកអធិប្បាយចងវិគ្គហថា វុច្ចតីតិ វាចា ធម្មជាតិឯណាដែលបុគ្គលពោល ធម្មជាតិនោះ ហៅថា វាចា ។

ឯវាចានោះលោកកំណត់យកសំឡេងជាប្រមាណ វាចាសព្ទក្នុងបទដទៃ ដូចក្នុងវចីកម្មកថា លោកសំដែងអំពីវចីសុចរិតទាំង ៤ គឺ វៀរពាក្យកុហក ពាក្យទ្រគោះ ពាក្យញុះញង់

ពាក្យពោលរាយឥតប្រយោជន៍ លោកកំណត់យកចេតនាជាប្រមាណ គឺបុគ្គលមានចេតនាជាកុសល ។

ពោលពាក្យពិតមិនកុហកជាដើម ហៅថា វចីសុចរិត ឬហៅថា ពាក្យសុភាសិតក៏បាន តែមិនរាប់ចូលក្នុងមង្គលទី ១០ នេះឡើយ ឯមង្គលទី ១០ នេះលោកសំដៅយកតែសំឡេងជាប្រមាណ គឺបុគ្គលមានចេតនាយ៉ាងណាៗក៏ដោយ ឲ្យតែពោលបញ្ចេញល្អពីរោះនាំឲ្យកើតសេចក្ដីជ្រះថ្លា ឬឲ្យកើតសេចក្ដីនឿយណាយបាកររាគាទិកិលេសកើតមគ្គកើតផល ហៅថា សុភាសិតាវាចា គឺពាក្យជាសុភាសិត ។

ម្យ៉ាងទៀត ឯលក្ខណៈរបស់ពាក្យសុភាសិតនោះព្រះដ៏មានព្រះភាគទ្រង់សំដែងទុកក្នុងសុភាសិតសូត្រ គម្ពីរអង្គុត្តរនិកាយ បញ្ចកនិបាតថា មាន ៥ ប្រការដោយបាលីថា៖

បញ្ចហិ ភិក្ខវេ អង្គេហិ សមន្នាគតា វាចា សុភាសិតា ហោតិ ន ទុព្ភាសិតា អនវជ្ជា ច អននុវជ្ជា ច វិញ្ញូនំ ។

ម្នាលភិក្ខុទាំងឡាយ វាចាប្រកបដោយអង្គ ៥ ឈ្មោះថាសុភាសិត មិនបានឈ្មោះថាទុព្ភាសិតឡើយ ជាវាចាប្រាស

ចាកទោសគឺរាគាទិកិលេស ទាំងមិនលុះទៅដោយអំណាចអគតិទាំង ៤ ជាដើមផង ជាវាចាដែលអ្នកប្រាជ្ញទាំងឡាយមិនគប្បីតិះដៀលផង ។

លុះព្រះអង្គទ្រង់សំដែងដូច្នេះរួចហើយ ទើបទ្រង់សំដែងជាពាក្យកបេិតុកម្យតាបុច្ឆាថា កតមេហិ បញ្ចហិ វាចាប្រកបដោយអង្គ ៥ នោះតើដូចម្ដេចខ្លះ?

ទើបទ្រង់វិសជ្ជនាដោយព្រះអង្គឯងថា អង្គ៥នោះគឺ កាលេន ភាសិតា ហោតិ វាចាដែលបុគ្គលពោលក្នុងកាលគួរ ១ ។

សច្ចា ច ភាសិតា ហោតិ វាចាដែលបុគ្គលពោលដោយពិតត្រង់ ១ ។

សណ្ហា ច ភាសិតា ហោតិ វាចាដែលបុគ្គលពោលដោយល្អិតល្អពីរោះ ១ ។

អត្ថសញ្ហិតា ច ភាសិតា ហោតិ វាចាដែលបុគ្គលពោលប្រកបដោយប្រយោជន៍ខ្លួននឹងប្រយោជន៍អ្នកដទៃ ១ ។

មេត្តចិត្តេន ច ភាសិតា ហោតិ វាចាដែលបុគ្គលពោលប្រកបដោយចិត្តមេត្តា ១ ។

ន័យមួយទៀតលក្ខណៈពាក្យសុភាសិតនោះ ព្រះដ៏មានព្រះភាគទ្រង់សំដែងទុកក្នុងសុភាសិតសូត្រ គម្ពីរអង្គុត្តរនិកាយ ចតុក្កនិបាតថា មាន ៤ ប្រការ ដោយបាលីថា ចតូហិ ភិក្ខវេ អង្គេហិ សមន្នាគតា វាចា សុភាសិតា ហោតិ ន ទុព្ភាសិតា អនវជ្ជា ច អននុវជ្ជា ច វិញ្ញូនំ ម្នាលភិក្ខុទាំងឡាយ វាចាប្រកបដោយអង្គ ៤ ឈ្មោះថាសុភាសិត មិនបានឈ្មោះថាទុព្ភាសិតឡើយ ជាវាចាប្រាសចាកទោស គឺរាគាទិក្កិលេសទាំងមិនលុះទៅដោយអំណាចអគតិទាំង ៤ ជាដើមផង ជាវាចាដែលអ្នកប្រាជ្ញទាំងឡាយមិនគប្បីតិះដៀលផង ។ល។ ឯវាចាប្រកបដោយអង្គ ៤ នោះគឺ

ឥធ ភិក្ខវេ ភិក្ខុ សុភាសិតំយេវ ភាសតិ នោ ទុព្ភាសិតំ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពោលវាចាជាសុភាសិត ១ ។

ធម្មំយេវ ភាសតិ នោ អធម្មំ ពោលវាចាដែលមានធម៌ មិនពោលវាចាដែលមិនមានធម៌ ១ ។

បិយមេវ ភាសតិ នោ អប្បិយំ ពោលវាចាជាទីស្រឡាញ់ មិនពោលវាចាមិនជាទីស្រឡាញ់ ១ ។

សច្ចំយេវ ភាសតិ នោ អលិកំ ពោលវាចាពិតត្រង់ មិនពោលវាចាកុហក ១ ។

លុះព្រះអង្គសំដែងជួប្រេះរួបហើយ ទើបទ្រង់ត្រាស់ជាបទគាថានេះតទៅទៀតថា សុភាសិតំ ឧត្តមមាហុ សន្តោ ធម្មំ ភណេ នាធម្មំ តំ ទុតិយំ បិយំ ភណេ នាប្បិយំ តំ តតិយំ សច្ចំ ភណេ នាលិកំ តំ ចតុត្ថំ ប្រែថា សប្បុរសទាំងឡាយមានព្រះពុទ្ធជាដើម តែងពោលសរសើរពាក្យសុភាសិតថាជាពាក្យដ៏ឧត្តម បុគ្គលគប្បីពោលពាក្យដែលមានធម៌ មិនគប្បីពោលពាក្យដែលមិនមានធម៌ឡើយ ពាក្យនោះជាទី២ បុគ្គលគប្បីពោលពាក្យដែលជាទីស្រឡាញ់ មិនគប្បីពោលពាក្យដែលមិនជាទីស្រឡាញ់ឡើយ ពាក្យនោះជាទី៣ បុគ្គលគប្បីពោលពាក្យពិតត្រង់ មិនគប្បីពោលពាក្យកុហកឡើយ ពាក្យនោះជាទី ៤ ។

*ទោសនៃទុព្ភាសិតវាចា*

លំដាប់តពីនេះនឹងសំដែងខាងទោសនៃទុព្ភាសិតវាចាជាមុន ទោសនៃទុព្ភាសិតវាចានោះ ក៏គឺវចីទុច្ចរិតទាំង ៤ យ៉ាងនោះឯង ដូចនឹងសំដែងតទៅនេះ ៖

១ ទោសពោលពាក្យមិនពិត ជាហេតុដកចោលនូវគុណគឺសច្ចវាចា ។

២ ទោសពោលពាក្យបេសុញ្ញវាទ ឬបិសុណវាទ ជាហេតុដកចោលនូវគុណ គឺ សុភាសិត ទឹងគុណគឺសេចក្ដីនៅរួបរួម ដោយមិត្រសំឡាញ់ខ្លួន ។

៣ ទោសពោលពាក្យផរុសវាទ ជាហេតុដកចោលនូវគុណគឺបិយវាចាដែលគេស្រឡាញ់ ។

៤ ទោសពោលពាក្យសម្ផប្បលាប ជាហេតុដកចោលនូវគុណគឺសម្មាវាចា ដែលជាពាក្យធម៌ ។

*ន័យដទៃទៀតថា*

១ ទោសពោលពាក្យមុសាវាទ ជាហេតុឲ្យគេពោលបង្កាច់មិនពិត ។

២ ទោសពោលពាក្យបិសុណាវាទ ជាហេតុឲ្យគេបំបែកមិត្រសំឡាញ់ខ្លួន ។

៣ ទោសពោលពាក្យផរុសវាទ ជាហេតុឲ្យគេស្អប់ព្រោះពាក្យសំដីខ្លួន ។

៤ ទោសពោលពាក្យសម្ផប្បលាប ជាហេតុឲ្យគេមិនអើពើនឹងពាក្យសំដីខ្លួន ទាំងនាំឲ្យខាតខូចប្រយោជន៍ដែលខ្លួនត្រូវបាន ត្រឡប់ទៅជាមិនបានវិញក៏មាន សមដូចនិទានដែលមានក្នុងគម្ពីរតេរសនិបាត នាំមកសំដែងអំពីទោសនៃមុសាវាទថា កាលក្នុងអតីតកាលកន្លងទៅយូរហើយ ព្រះសម្មាសម្ពុទ្ធជាម្ចាស់នៃយើងនៅជាពោធិសត្វនៅឡើយ ទៅកើតក្នុងត្រកូលបណ្ឌាលក្នុងចណ្ឌាលគ្រាម ព្រះអង្គជាបណ្ឌិតបេះមន្តធ្វើឈើឲ្យមានផ្កាផ្លែក្នុងរដូវមិនគួរកាល ។ ថ្ងៃមួយពោធិសត្វចេញទៅព្រៃពីព្រឹក ទើបរាយមន្តធ្វើដើមស្វាយមួយដើម នៅចម្ងាយ ៧ ជំហានអំពីកន្លែងដែលព្រះអង្គឈរ ទើបព្រះអង្គយកទឹកចំនួន ១០០ កំបង់ទៅស្រប់លើដើមស្វាយ ៗ នោះមានស្លឹកចាស់ជ្រុះអស់មួយរំពេច លាស់ស្លឹកខ្ចីឡើង

បញ្ចេញផ្កាផ្លែទុំក្នុងពេលនោះ ពោធិសត្វបេះយកមកបរិភោគ ក៏មានឱជារសប្រហែលដូចរសទិព្វ ព្រះអង្គបរិភោគល្មមត្រាតែឆ្អែត ហើយបេះដាក់ម្រែករែកទៅផ្ទះ ចែកបុត្តភរិយាផង លក់ដូរផង ។

កាលនោះ មានព្រាហ្មណ៍ម្នាក់ បានសូមរៀនមន្តពីពោធិសត្វ ៗ ក៏ឲ្យរៀនហើយផ្តាំថា បើមានអ្នកណាមួយសួរថាព្រាហ្មណ៍ឯងរៀនមន្តនេះពីសំណាក់អ្នកណា ៗ ចូរព្រាហ្មណ៍ឯងប្រាប់គេឲ្យត្រង់កុំកុហកបោក តែប្រាប់ដោយមុសាវាទហើយមន្តនេះនឹងវិនាសទៅវិញមិនលែងឡើយ ព្រាហ្មណ៍ទទួលបណ្តាំហើយ ដើររៀង ៗ ទៅដល់ក្រុងពារាណសី បានចូលទៅធ្វើជាតាយប្បារក្នុងសំណាក់ព្រះបាទពារាណសី តែងប្រតិបត្តិតាមវិធីមន្ត ផ្លែស្វាយក៏បេះតែផ្លែឥតអាក់មិនថារដូវណា ព្រាហ្មណ៍ក៏បានរង្វាន់ច្រើនបរិបូណ៌ ។

ថ្ងៃជាខាងក្រោយទៀត ព្រះបាទពារាណសីមានបន្ទូលសួរថា នែព្រាហ្មណ៍អ្នកឯងរៀនមន្តនេះមកពីសំណាក់អ្នកណាគ្រូដើមរបស់អ្នកឈ្មោះអ្វី ព្រាហ្មណ៍អៀនខ្មាសមិនហ៊ានក្រាប

ទូលទៅឈ្មោះពោធិសត្វជាគ្រូដើម ព្រោះពោធិសត្វនៅក្នុងត្រ-កូលបណ្ឌាល ប្រែជាក្រាបទូលដោយពាក្យមុសាវាទថា រៀនមន្តនេះពីសំណាក់អាចារ្យទិសាបាមោក្ខវិញ មន្តក៏អន្តរធានបាត់ទៅក្នុងមួយរំពេចនោះ ព្រាហ្មណ៍មិនដឹងជាមន្តរបស់ខ្លួនវិនាសសោះ ៗ លុះដល់ព្រះបាទពារាណសីយាងទៅប្រពាតឧទ្យានស្ដេចមានបន្ទូលថា នែមាណព ចូរអ្នកនាំផ្លែស្វាយមកមើល ព្រាហ្មណ៍វាយមន្តទៅមិនបានកើតផ្លែស្វាយដូចបំណង ទើបដឹងជាក់ថា មន្តរបស់អាត្មាវិនាសហើយ ស្ដេចសួរពីរបីដង ទើបព្រាហ្មណ៍ក្រាបទូលតាមពិត ស្ដេចទ្រង់ខ្ញាល់បង្គាប់ឲ្យធ្វើទោស រាជបុរសក៏ធ្វើទោសតាមព្រះរាជឱង្ការហើយប្រាប់ថា បើព្រាហ្មណ៍ឯងទៅសូមទោសគ្រូដើមរបស់អ្នក ក្រែងអ្នកនឹងបានមន្តនេះមកវិញ ទើបអ្នកនឹងបាននៅក្នុងដែននេះតទៅទៀត បើអ្នកមិនទៅសូមទោសទេ ចូរអ្នកដើរចេញពីដែននេះឲ្យឆាប់ទៅ ព្រាហ្មណ៍ដល់នូវទោសរកទីពឹងមិនបាន ទើបដើរទៅកាន់សំណាក់ពោធិសត្វជាគ្រូដើម សូមរៀនមន្តទៀត ព្រះអង្គមិនព្រមឲ្យរៀន ហើយទ្រង់ត្មះតិះដៀល

ថា ឲ្យរៀនទៀតឯណាបាន មនុស្សពោលពាក្យមុសាវាទដូចព្រាហ្មណ៍ឯងនេះមានមន្តមកពីណា ចូរព្រាហ្មណ៍ឯងចៀសចេញទៅ យើងមិនគាប់ចិត្តនឹងបុគ្គលពោលមុសាវាទដូចព្រាហ្មណ៍ឯងនេះទេ ព្រាហ្មណ៍ដល់នូវទោសរកទីពឹងមិនបាន ទើបមកគិតក្នុងចិត្តថា បើអាត្មាអញរកទីពឹងមិនបានដូច្នេះ ហើយនឹងរស់នៅជាមនុស្សធ្វើអ្វី ស្លាប់ទៅវិញប្រសើរជាង គិតហើយក៏ដើរចូលទៅក្នុងព្រៃ ដល់នូវមរណភាពឥតទីពឹងឡើយ ។

បុគ្គលអ្នកប្រព្រឹត្តពោលពាក្យមុសាវាទ(១)ហើយ គង់នឹងដល់នូវទោសទុក្ខដូចរឿងព្រាហ្មណ៍នេះឯង ។

ចប់រឿង អម្ពមន្តជាតក

---

១ ត្រូវគ្នានឹងឧបក្កិលេសទី ៨ គឺមក្ខ ដែលហៅថាមក្ខនោះគឺរមិលគុណគេឬរមើលគុណគេ គឺរមើលគុណរបស់គ្រហស្ថឬបព្វជិត ដែលគេបានធ្វើល្អមកចំពោះខ្លួន ។ ដូចយ៉ាងគ្រហស្ថខ្លះ ដែលជាអ្នកក្រីក្រលំបាក ហើយមានអ្នកណាមួយគេមានសេចក្តីអនុគ្រោះជួយទំនុកបំរុងផ្គងផ្ដើមលើកដំកើងឲ្យបានខ្ពង់ខ្ពស់ ជាមនុស្សមានទ្រព្យសម្បត្តិគ្រាន់បើឡើង ស្រាប់តែដល់ពេលក្រោយ គ្រហស្ថនោះក៏រំលុបបំបាត់អំពើល្អដែលគេបានធ្វើមកចំពោះខ្លួននោះថា “អ្នក

ឯងឥតបានធ្វើអ្វីបន្តិចបន្តួចដល់ខ្ញុំទេ យ៉ាងនេះទៅវិញ ។ ឬដូចជាបព្វជិតខ្លះ តាំងពីនៅជាសាមណេរតូច ហើយមានលោកអង្គណាមួយ គឺអាចារ្យឬឧបជ្ឈាយ៍ លោកបានជួយទំនុកបំរុងដោយបច្ច័យទាំង ៤ ទាំងបានបង្រៀនបាលីអដ្ឋកថា ហើយថែមទាំងបានពន្យល់ឲ្យមានសេចក្តីឈ្លាសវៃក្នុងគម្ពីរដីកាតាមផ្លូវធម៌និងទៀត ស្រាប់តែដល់ពេលក្រោយ អ្នកបួសនោះមានស្តេចឬរាជមហាមាត្យ ធ្វើសក្ការគោរពរាប់អាន (ដល់ខ្លួន) ហើយក៏លែងគោរពកោតក្រែងចំពោះអាចារ្យនឹងឧបជ្ឈាយ៍របស់ខ្លួនវិញ ដោយពោលថា កាលពីដើមអាចារ្យនឹងឧបជ្ឈាយ៍នេះ លោកបានជួយទំនុកបំរុងយ៉ាងនេះផង បានឲ្យដុះដាលល្អតលាស់យ៉ាងនេះផង ក៏តែឡូវនេះ លោកលែងមានសេចក្តីស្នេហានឹងឯងហើយ ហើយក៏ស្រាប់តែរំលុបបំបាត់អំពើល្អរបស់អាចារ្យនឹងឧបជ្ឈាយ៍ទាំងនោះចេញទៅថា លោកទាំងអស់នេះគ្មានធ្វើអ្វីបន្តិចបន្តួចដល់អញទេ ការបំបាត់អំពើល្អដែលគេធ្វើមកចំពោះខ្លួនយ៉ាងនេះឯង ហៅថាមក្ខ (រំលើគុណគេ) លុះមក្ខកើតឡើងហើយក៏ធ្វើចិត្តឲ្យប្រទុស្តមិនឲ្យមានរស្មីភ្លឺបាន ព្រោះហេតុនោះបានជាលោកពោលថា ចិត្តនោះជាឧបក្កិលេស ។

(បបញ្ចសូទនី អដ្ឋកថាមជ្ឈិមនិកាយ)

មានតទៀត

ចាតុរង្គបទ បទទី ១

របស់

# ព្រះមហាពិទូរ ក្រសេម គន្ថរបនបណ្ឌិត

# ចាតុរង្គបទ បទមានអង្គ ៤

## ចាតុរង្គបទ បទទី ១

### ជីវិតសម្បត្តិ

### *មនុស្ស គឺ អ្វី?*

មនុស្សយើងនេះ តាមដែលគេយល់ដោយច្រើន ក៏គឺស្រីប្រុស ទាំងក្មេង ទាំងចាស់ ដែលមានចិត្តខ្ពស់ មានរូបរាងខ្ពស់បញ្ឈរឡើងទៅលើ ហៅថា មនុស្ស ។ តែសេចក្ដីយល់ត្រឹមប៉ុណ្ណោះនូវមិនទាន់ល្មម គួរនឹងបន្ថែមសេចក្ដីយល់ឲ្យល្អិតបេញទៅទៀត ដើម្បីជាឧបាយឲ្យភ្លឺក្នុងបញ្ហាថា បណ្ដាសភាវៈទាំងឡាយរមែងកើតអំពីហេតុ បើគ្មានហេតុជាអ្នកតាក់តែងនឹងកើតឡើងមិនបាន សឹងប្រៀបដូចផ្ទះ បើគ្មានអ្នកធ្វើនឹងសម្រេចឡើងជាផ្ទះពុំបាន ។ មនុស្សនេះក៏ជាសភាវៈមួយយ៉ាងទើបតោងមានហេតុជាដែនកើត ។ ឯហេតុជាដែនកើតមនុស្សឡើងនោះគឺអ្វី បើកាន់តាមគោលព្រះពុទ្ធសាសនាលោកថា អវិជ្ជា តណ្ហា ឧបាទាន កម្ម ហេតុអំបាលនេះឯងមិនមែនដទៃ តែងឲ្យកើតធម្មតា ២ យ៉ាង គឺ ធម្មតាខាងទាប ១ ធម្មតាខាង

ខ្ពស់ ១ ។ ធម្មតាខាងទាបលោកថា បានដល់រូបធម៌ដែលមាន ចិត្តគ្រប់គ្រង គឺ រូបកាយ ។ ធម្មតាខាងខ្ពស់លោកថា បាន ដល់នាមធម៌ ដែលមិនអាចឃើញបានដោយភ្នែក មិនអាច ស្តាប់បានដោយត្រចៀក មិនអាចធុំក្លិនដោយច្រមុះ មិនអាច ភ្លក់រសបានដោយអណ្តាត មិនអាចប៉ះពាល់បានដោយកាយ បើនឹងថាឲ្យខ្លីក៏គឺចិត្ត ដែលអាស្រ័យខាងក្នុងនៃរូបកាយ ។ រាងកាយរស់នៅបានដោយអាហារ និងខ្យល់ដង្ហើមចេញចូល បើមិនបានបរិភោគអាហារនិងដាច់ខ្យល់ដង្ហើមកាលណាហើយ កាលនោះ រាងកាយក៏តោងដេកស្តឹងស្តូកលើផែនដី ដូចជា កំណាត់ឈើដែលប្រាសចាកប្រយោជន៍ ភាគផ្សេង ៗ ដែល មកនៅរួមគ្នា ក៏បែកខ្ញែកចេញទីទៃពីគ្នា ភាគដែលរួមគ្នា មាន ប្រភេទជាធាតុដី ក៏ត្រឡប់ក្លាយទៅជាធាតុដីទៅ ភាគដែល រួមជាធាតុទឹក ក៏ត្រឡប់ក្លាយជាធាតុទឹកទៅ ។ល។ តាមធម្មតា របស់រូបកាយ ដែលត្រូវតែដូច្នេះ ដូចគ្នាគ្រប់រូប ហើយក្នុង វេលានោះនឹងប្រើធ្វើអ្វីក៏មិនបាន ។ មួយយ៉ាងទៀត បំពោះ តែកាយមួយយ៉ាងគ្មានចិត្តផង នឹងធ្វើអ្វីពុំបាន ដោយន័យ

នេះលោកទើបប្រៀបថា ចិត្តដូចចៅហ្វាយនាយ កាយដូចខ្ញុំ ឈ្មោះថាខ្ញុំត្រូវធ្វើតាមបង្គាប់របស់ចៅហ្វាយនាយ ចៅហ្វាយប្រើឲ្យធ្វើអ្វី តោងធ្វើតាមគ្រប់យ៉ាងទទឹងមិនបាន ហេតុនេះកាយទើបបានឈ្មោះធម្មតាខាងទាប ។ នៅមានគោលបាលីថា បណ្ដាធម្មតាទាំងឡាយ មានចិត្តជាប្រធាន មានចិត្តជាធំ សម្រេចបានដោយចិត្ត បើចិត្តខឹងក្រោធហើយ នឹងធ្វើនឹងនិយាយអ្វីក៏ដោយ សេចក្ដីទុក្ខរមែងជាប់តាមទៅដូចកង់រទេះទៅតាមជើងគោដូច្នោះ ។ បើចិត្តថាបរិសុទ្ធហើយ នឹងធ្វើនឹងនិយាយអ្វីក៏ដោយ សេចក្ដីសុខរមែងជាប់តាមទៅ ដូចស្រមោលអន្ទោលទៅតាមខ្លួនដូច្នោះ ។ ដោយន័យនេះ មនុស្សយើងនឹងបានទុក្ខបានសុខ ក៏ព្រោះចិត្ត នឹងអាក្រក់ឬល្អ ក៏ព្រោះចិត្ត ចិត្តទើបជាចៅហ្វាយនាយរបស់កាយ ព្រោះហេតុនោះចិត្តទើបបានឈ្មោះថា ធម្មតាខាងខ្ពស់ ។ ធម្មតា ២ យ៉ាងនេះឯង រមែងជាទីកត់សំគាល់ចូលចិត្តជារាស់គ្នាថា មនុស្សគឺស្រី-ប្រុសជាដើម ហើយអាចសម្រិតមនុស្សឲ្យធ្លាក់ថោកទាប ដូចយ៉ាងធ្វើសេចក្ដីអាក្រក់ផ្សេងៗ ដែល

ជាផ្លូវខូបខាតក៏បាន ស្ដួយមនុស្សឲ្យឡើងខ្ពស់ជាងភាវៈដើម ដូចយ៉ាងធ្វើសេចក្ដីល្អ ទាល់តែបានលើកឲ្យជានេះជានោះ ដែលជាផ្លូវចំរើនក៏បាន ព្រោះហេតុនោះលោកទើបឲ្យឈ្មោះថា ធម្មតាខាងទាប នឹងធម្មតាខាងខ្ពស់ មួយបរិយាយទៀត ។

មនុស្សរស់នៅបានព្រោះជីវិត

មួយបរិយាយទៀត កាយរបស់យើងដែលមើលឃើញច្បាស់ជារូបជារាងនេះ មានគ្រោងឆ្អឹងផ្គុំចូលគ្នា ជាន់ក្រៅមានស្បែកស្រោបស្ដើងខ្លះ ក្រាស់ខ្លះ សមតាមភាពរបស់រាងកាយដែលត្រូវប្រើធ្វើការស្រាលខ្លះ ធ្ងន់ខ្លះ ឆ្អឹងអំបាលនេះជាកំណាត់ៗ ភ្ជាប់គ្នាតាមរយៈវែងខ្លី មានសាច់នឹងសរសៃធំតូបរុំឥតឃើតទុកឲ្យបត់ទៅបត់មក នឹងប្រែប្រួលទៅបានផ្សេង ៗ តាមត្រូវការ តាមសន្លាក់ដំណមានខ្លាញ់ហាក់ដូចជាយន្តនៅខាងក្នុង ធ្វើឲ្យកម្រើកទៅមកបាន មានសរសៃលោហិតជាលទៅទាំងខ្លួន អប់កាយឲ្យក្ដៅអ៊ុននឹងស្រស់នៅជានិច្ច នៅក្បាលមានខួរនឹងសរសៃប្រសាទវែងទាក់ទាមចូលទៅទាំងសរ-ពាង្គកាយ សម្រាប់នាំសេចក្ដីដឹងផ្សេង ៗ មក ។ ក្នុងផ្ទៃមាន

គ្រឿងសម្រាប់លំអិតអាហារដែលបរិភោគចូលទៅរាល់ ៗ ថ្ងៃ អាហារថ្មីចូលទៅជំនួសអាហារចាស់ អាហារចាស់ក៏ក្លាយទៅជាឧច្ចារៈនិងបស្សាវៈទៅ ។ អវយវៈនៃរាងកាយនៅមានច្រើនជាងនេះ កាលនឹងពណ៌នាឲ្យល្អិតល្អសព្វគ្រប់ ក៏ហួសត្រូវការទៅ និងជាការលំបាកផង គួរកំណត់ដឹងតាមដែលអ្នកប្រាជ្ញលោកពោលទុកថា ក្នុងចំណែកអំបាលនោះ ចំណែកឯណាដែលមានលក្ខណៈរឹងទំនងដូចជាដី ដូចយ៉ាងសក់ រោម ក្រចក ធ្មេញ ស្បែក សាច់ សរសៃ ឆ្អឹង ជាដើម ចំណែកនោះលោកតាំងឈ្មោះហៅថា ធាតុដី ។

ចំណែកឯណាមានលក្ខណៈហូរជ្រិតជ្រាបទំនងដូចជាទឹក ដូចយ៉ាង ឈាម ខ្លាញ់ ទឹកមាត់ ទឹកមូត្រជាដើម ចំណែកនោះលោកតាំងឈ្មោះហៅថា ធាតុទឹក ។

ចំណែកឯណាមានលក្ខណៈក្តៅអប់អ៊ុនទំនងដូចជាភ្លើង ដូចយ៉ាងចំហាយក្តៅ ចំហាយអ៊ុនក្នុងខ្លួនមនុស្សយើងជាដើម ដែលរស់នៅ ចំណែកនោះ លោកតាំងឈ្មោះហៅថា ធាតុភ្លើង ។

បំណែកឯណាមានលក្ខណៈបក់ទៅមកបាន ទំនងដូចយ៉ាងខ្យល់ ដូចខ្យល់ដង្ហើមចេញចូលជាដើម បំណែកនោះលោកតាំងឈ្មោះហៅថា ធាតុខ្យល់ ។ កាលធាតុទាំង ៤ នេះជុំគ្នាត្រូវភាគគ្នាហើយ ទើបផ្គុំចូលជារាងកាយ កើតមានទ្វារខាងក្រៅ ៥ អន្លើ គឺភ្នែក ត្រចៀក ច្រមុះ អណ្ដាត កាយ និងមានទ្វារកាយសិទ្ធ ១ នៅខាងក្នុងគឺចិត្ត ដែលជាទីរួមនៃផ្លូវដែលចូលទៅដោយទ្វារខាងក្រៅទាំង ៥ អន្លើនោះ រួមចូលជាមួយគ្នាជា ៦ ទ្វារ ទ្វារខាងក្រៅ ៥ អន្លើសម្រាប់តនឹងរូបឲ្យបានឃើញ តនឹងសំឡេងឲ្យបានឮ តនឹងក្លិនឲ្យបានធុំ តនឹងរសឲ្យបានភ្លក់ តនឹងរបស់ដែលប៉ះពាល់ឲ្យបានត្រូវ កាលប្រជួបឱកាសស្រួល ក៏រត់ចូលទៅដល់ទ្វារកាយសិទ្ធិគឺចិត្ត កើតជាអារម្មណ៍ឡើងថ្មី ជាបំណែកនាមធម៌ ល្អិតជាងរូបធម៌ជាច្រើនភាគណាស់ ទើបមើលដោយចក្ខុទទេមិនឃើញ គ្រាន់តែដឹងបានដោយអាការ គឺមានអាការដឹងបានថា មនុស្ស សត្វ វត្ថុ ជាដើម ត្រូវប្រជួបអាការនោះហើយមានអាការជាសុខខ្លះ ទុក្ខខ្លះ ព្រងើយ មិនសុខមិនទុក្ខខ្លះ មានអាការកំណត់ដឹង

បាំបាន តាំងចិត្តគិតអានព្រះរិះពិចារណាផ្ទៀងផ្ទាត់ពិនិត្យវិនិច្ឆ័យ កើតស្រឡាញ់ពេញចិត្ត នឹងស្ងប់ខ្ពើម តាមសមគួរដល់រឿងដែលមកប្រាកដ ត្រូវចិត្តឬខុសចិត្ត ត្រូវបំណងឬខុសបំណង ក៏កើតជាសេចក្តីត្រូវការឡើង ដូចយ៉ាងត្រូវការឲ្យមានគ្រឿងស្លៀកដណ្តប់សម្រាប់បិទកាយ ត្រូវការឲ្យមានអាហារសម្រាប់បរិភោគ ត្រូវការឲ្យមានទីលំនៅសម្រាប់អាស្រ័យ ។ ល ។ រហូតដល់ទៅត្រូវការរួមគ្នាបួលជាជាតិមួយ ៗ ដើម្បីជួយគ្នារក្សាឥស្សរភាព ត្រូវការមានសាសនាជាគោលរបស់ជាតិនឹងជាគោលរក្សាចិត្ត ត្រូវការមានព្រះមហាក្សត្រិយ៍ជាប្រមុខរបស់ជាតិ ត្រូវការមានរដ្ឋបាលគ្រប់គ្រងប្រទេសជាដើម ។ បើទ្វារ ៥ ខាងក្រៅគ្មានហើយ កាយនេះក៏គង់ដូចជារូបដែលស្និទ្ធទុក ឬនឹងមានតែទ្វារខាងក្រៅបំពោះប្រការខ្លះ ក៏គង់ដូចជាដើមឈើដែលបេះដក់យកជាតិទឹកដីជាអាហារចិញ្ចឹមដើម ក្រៅអំពីនេះមិនមានបេះដឹងអ្វីឡើយ ព្រោះគ្មាននាមធម៌ ឬទោះបីមានគ្រប់ព្រមទាំងពីរយ៉ាង បើខ្វះជីវិត

មនុស្សនឹងរស់នៅពុំបានតោងបែកបេញជាបំណែក ៗ ដូចពោលហើយ ឧទាហរណ៍ដែលឲ្យឃើញងាយ ៗ ដូចយ៉ាងផ្ទះដែលជាងប្រុងដោយគ្រឿងទព្វសម្ភារៈផ្សេង ៗ បញ្ចូលមកបានជារូបផ្ទះ បើរើបេញហើយនឹងឃើញទៅជាកំណាត់ឈើយ៉ាងនេះខ្លះ យ៉ាងនោះខ្លះ គឺជាសសរ មេដំបូល ផ្ទោងផ្ដាន ជញ្ជាំង ទ្វារជាដើមប៉ុណ្ណោះ ពាក្យដែលធ្លាប់ហៅថាផ្ទះក៏បាត់ទៅ ក្លាយទៅជាឈ្មោះរបស់កំណាត់ឈើអំបាលនោះដោយយ៉ាង ៗ ទៅ កាលនាយជាងយកកំណាត់ឈើអំបាលនោះមកផ្គុំគ្នាហើយ ឈើអំបាលនោះក៏ឃឹតទប់គ្នានូវគ្នាក្នុងខ្លួនសម្រេចបានជាផ្ទះឡើង អ្នកម្ចាស់ផ្ទះក៏បានអាស្រ័យនៅខាងក្នុងជាស្ថានទីសម្រាប់ការពារអន្តរាយទាំងឡាយ ដែលកើតអំពីហេតុខាងក្រៅ ដូចយ៉ាងភ្លៀងជាដើមក៏បាន ។ បំណែកឯមនុស្សគឺរូបទាំងកាយទាំងចិត្តផងគ្នា កាលមានជីវិតនៅដរាបណា ក៏ឈ្មោះថារស់នៅដរាបនោះ ។

# លោកន័យ

## របស់ឧកញ៉ាវង្សាសរពេជ្ញ នង

(ត)

'ឥឡូវអានេះ កុហកដល់ម្ល៉េះ មកបំពោតអញ អានេះ ស្មេស្មោ ស្មើហោរល្បបវិញ ត្អូយស្មើហោរពេញ ថ្លៃកុំប្រណី ។ ត្រូវពៃពបួន រកឲ្យបានធួន ទើបអារូបក្ដី ឯម្ចាស់ផ្កែនោះ ឆ្លើយស្មោះរឹងខ្មី ខ្ញុំបង់ទ្រព្យប្ដី ខ្ញុំពុំព្រមឡើយ ។ ឧដុក សេនា- បតីជេរថា អាហោរឥតត្រើយ អញឲ្យធ្វើទោស កុំ សន្ដោសឡើយ អានោះឮហើយ ភិតភ័យតក្កមា ។ លើកដៃ ទាំងពីរ ទូលលើសិរសី ស្រែកយំសោះសា រូតរត់ចេញខ្មី អំពីសាលា កាលនោះគាប់មហា បុរសរតន៍ថ្លៃ ៗ នឹងអ្នក ប្រាជ្ញទាំង បីចេញពីវាំង អានោះឯងនៃ ស្គាល់ពោធិសត្វ បុរសរតន៍ថ្លៃ ភរត់ឆ្តោះឮ ប្ដានព្រះពោធី ។ ក្រាបទៀបបា- ទា ទ្រហោយំថា ថ្លៃងសព្វសេចក្ដី ប្រាប់ពោធិសត្វ បពិត្រ តារី ខ្ជូនខ្ញុំឥតបី ពំនាក់ទៀតឡើយ ។ អស់អ្នកទាំងឡាយ នគរនៅអាយ សោតសឹងឥតត្រើយ បានកណ្ដាប់ដៃ លុះនៃ ព្រមហើយ លក់ឥតស្ដែស្ដើយ ពុំតាមមាត្រា ។ ដូចកល់ មណីរតន៍ បានលុះដៃសត្វ តិរច្ឆានសីហា ដូចកល់កូនទ្រាយ ទាំងឡាយព្រាត់បា បានលុះដៃខ្លា ក៏ណាបអប្រិយ៍ ។ ព្រះ

រើយទុក្ខ អស់ទាំងអ្នកស្រុក សេនាបតី វាគិតនឹងផ្ចាញ ឲ្យលាញជានី កណ្ដាប់ដៃពី ដើមលុះឥឡូវ ។ ព្រះពោធិ-សត្វ មហាបុរសរតន៍ ពន្លកឥតគូ អ្នកមានមេត្តា ករុណា ព្រោះក្លូវ គិតថាឥឡូវ សេនាបតី ។ នឹងជាគំនុំ សំអប់ ហើយសម ជាទោសឥតបី ស្រាកស្រានស្ដោះ រង្គោះពៀរពី អញហើយព្រោះឥ- ឡូវលែងម្ដេចបាន ។ ធម្មតាអ្នកកាប វែងស្លប់អ្នកប្រាជ្ញ បើអញនេះបាន ពុំជួយដោះទុក្ខ ទោស សន្ដោសក្សាន្ត វាហោរសាមាណ្យ សង្កត់លុះក្ស័យ ។ មួយ សោតលោកថា បុរសប្រាជ្ញ ជាពុទ្ធញាណាហៀយ ពុំស្ដាយ ជីវិត ពុំគិតក្បែនក្ស័យ ស្ងួរលោកបង់នៃ ជីវិតឯងណា ។ លែងលោកបានធ្វើ ប្រយោជន៍សារពើ ឲ្យអ្នកនានា ពុំស្ដាយ ជីវិត ហេតុចិត្តសទ្ធា ពុំបង់ធម៌ជា ពំនាក់លោកឡើយ ។ ព្រះពង្សពុទ្ធា យកព្រះប្រាជ្ញា សារពេជ្ជជាត្រើយ ជាទីពំនាក់ សំណាក់ព្រោះហើយ ទើបថាចៅរើយ អញជួយចៅហោង ។ អញនឹងយាត្រា ទៅឋានសាលា ជួយដោះសារសង អញជា សំណាក់ ពឹងពាក់ចៅហោង កាលគ្រានេះម្ដង កុំចៅគិត

ឡើយ ។ ឯរាជបណ្ឌិត ទាំងបីនាក់គិត ថាគ្នាយើងអើយ
យើងទៅចង់យល់ យោបល់គេឆ្លើយ គិតដូច្នោះហើយ បបួល
គ្នាទៅ ។ ព្រះពង្សពុទ្ធា ទៅឋានសាលា បញ្ជាន់សឹងនៅ ឯ
ម្ចាស់ផ្តែនោះ តាមស្មោះក្រោយទៅ ដល់អង្គុយនៅ ខាងពង្ស
ពុទ្ធា ។ បទពំនោលនៅបរបា កាលនោះសេនា- បតីយង់
យល់ហើយនែ ។ ថាហៃម្ចាលចៅធនញ្ជ័យ អញមានទោស
ពៃរ៍ នឹងចៅពីកាលឯណា ។ ចៅមកកាន់ក្តីឯអា ម្ចាស់ផ្តែ
នេះណា ឲ្យជាមន្ទិលអប្រិយ៍ ។ អ្នកជាសេនាបតី ដំណើរ
អំពី នោះកុំអាលខឹងនឹងខ្ញុំ ។ រង់ចាំដំណឹងដោយដំ- ណើរ
នឹងជំនុំ ពិគ្រោះតាមដោយមាត្រា ។ សេនាបតីឆ្លើយថា ក្តី
នេះឯងណា ចូរចៅបង្គាប់ជាថ្មី ។ ហេតុខ្លាបអំណាបពោធិ
សេនាបតី ពុំហានឃាត់ខាំងរាំងរា ។ ទើបពោធិសត្វអ្នកថា
ហៃអ្នកសេនា- បតីកុំអ្នកបារម្ភ ។ សេចក្តីបើអ្នករកពុំ
ឃើញហើយឲ្យខ្ញុំ ក្តីនេះស្រេចហើយឬនៅ ។ សេនាបតី
ឆ្លើយទៅ ក្តីនេះឯងចៅ ធ្វើម្តេចនឹងស្រេចហើយណា ។
ព្រះពោធិសត្វឆ្លើយថា ងាយណាស់កុំបា- រម្ភឡើយខ្ញុំរក

ឃើញឆាប់ ។ បទពាក្យអានេះឃើញស្រាប់ វាពុំឮសព្ទ ពុំឮសំឡេងឡើយណា ។ ម្ដេចអ្នកស្រដីថាវា ពុំដឹងហើយ ថា បំពោតកុហកភូតក្រៃ ។ ទើបអ្នកបង្គាប់ឲ្យព្ន័យ លក់ វាដាច់ថ្លៃ ទ្វមួយជាប្ដូរវិញហោង ។ ឥឡូវនេះយើងនឹង លង ដណ្ដឹងបានម្ដង ឯអាទ្រមាក់ពពៃ ។ សេនាបតីថាឯ ទ្រមាក់ពពៃ ចូរហៅដណ្ដឹងគ្នាឯង ។ អ្នកដណ្ដឹងថាព្រះស្ដេង ឃ្វាលពពៃតែង ចាំមើលរក្សាសត្វថ្ងៃ ។ បម្ងាយប៉ុន្មានពីព្រៃ ម្ចាស់ផ្កែស្ថិតនៃ ទៅស្ថានផ្កោវាចាំនោះ ។ ចូរអាប្រាយប្រាប់ ឲ្យស្មោះ បម្ងាយពីនោះ ប្រមាណយល់ជាប៉ុន្មាន ។ ទ្រមាក់ ពពៃឆ្លើយថ្កាន ខ្ញុំថាប្រមាណ យល់ជាហុកសិបព្យាម ហោង ។ អម្ចាស់ឆ្លើយទៅរឹងស្នង ហុកសិបព្យាមផង ត្រូវ ដូចទ្រមាក់ពពៃ ។ ពីមាត់ព្រៃទៅដល់ស្រែ ខ្ញុំឯងនោង ដង្គំព្រៃមួយទៀតនៃ ។ រឹងជាឆ្ងាយពន់ពេកក្រៃ ពោធិសត្វ ថ្ងៃ ដណ្ដឹងទ្រមាក់ពពៃ ។ ថាមែនដូចទ្រមាក់ផ្កែ ទ្រមាក់ ពពៃ ថាមែនពិតដូច្នោះហោង ។ អ្នកដណ្ដឹងដោយទំនង បើមែនច្នោះហោង អញនឹងដណ្ដឹងមួយវិញ ។ បើបម្ងាយ

ដូច្នោះមិញ អាឯងប្រាប់អញ ប្រមាណជាឮឬទេ ។ សមីន-
សកោមេ អាទោះហាង ខ្ញុំពុំអាចហ៊ានថា ។ ពោធិសត្វ
ស្តាប់វាថា ហើយបន្ទូលថា ម្តេចអាពុំហ៊ានថាឡើយ ។
ឯចៅក្រមឯងឥតត្រើយ បង្គាប់គេហើយ ថាជាគេដឹងវិញ
នៃ ។ ហើយបង្គាប់លក់ដាច់ថ្លៃ ត្រូវក្រយាត្នួយ ជាគូពពែបួន
ផង ។ ហើយថាកុហកកន្លង មិនដណ្តឹងសង ខាងឲ្យប្រាកដ
សេចក្តី ។ ថាបើដើមក្តីស្រដី ពាក្យមែនគប្បី បង្គាប់ដូច្នោះត្រូវ
ហោង ។ អ្នកក្តីមានពាក្យសាសង ពាក្យគេមានផង ឱហេតុ
តែរៀបមោសា ។ សេនាបតីឆ្លើយថា ចៅពិចារណា ក្តីនេះ
បង្គាប់ដូចម្តេច ។ ពោធិពន្លកសារពេជ្ញ ថាខ្ញុំនឹងផ្តាប់ ឲ្យអា
ទ្រមាក់ពពែ ។ រកកូនពពែសងគេ វាមិនបង្កែ ឲ្យរត់
ចេញពីហ្វូងទៅ ។ រីអម្ចាស់ឆ្កែនេះកូវ ពុំគប្បីត្រូវ ឲ្យសង
ពពែឡើយនៃ ។ ហេតុវាមានពាក្យប្រពៃ ទៀងព្រមដូចនៃ
ទ្រមាក់ពពែនោះហោង ។ ឯអស់ទាំងមហាជនផង ស្រែក
សព្ទអឺងកង ឲ្យសាធុការពោធិ ។ ស្រៀវស្រែកស្ទើរបែក
ប្រថពី មហាក្សត្រធិបតី ឮសព្ទដូច្នោះហើយណា មានព្រះ

បន្ទូលត្រាស់ថា អមាត្យអើយបា នេះតើមានហេតុដូចម្ដេច ។ អមាត្យក្រាបបាទសម្ដេច ទើបទូលដោយកិច្ច ដំណើរស្ដេចជ្រាបហើយណា ។ មានព្រះបន្ទូលត្រាស់ថា ឲ្យហៅព្រះមហា- បុរសន្ធរសេនាបតី ។ ហៅក្រមតែងជំនុំក្ដី ឡើងទៅដល់ខ្មី ប្រាសាទព្រះមហាក្សត្រថ្លៃ ។ កាលណោះឯក្សត្រជេស្ឋជ័យ បន្ទូលថាហៃ ហៅជំនុំសេចក្ដីអ្វី ។ ពោធិសត្វទូលរឿងខ្មី ដោយដំណើរពី សេចក្ដីសព្វគ្រប់ហើយណា ។ ទើបស្ដេចដណ្ដឹងទៅមហា- ឧដុកសេនា- បតីមែនពិតដូច្នេះ ។ សេនាបតីពុំវេះ ទូលថាក្ដីនេះ មែនពិតដូចធនញ្ជ័យទូល ។ នេះបទកាកា- តិទើបព្រះមហា ក្សត្របើកព្រះស្ទូរ ទ្រង់ព្រះអំណរ សាទរមធុរ ថាធនញ្ជ័យបួរបង្គាប់សេចក្ដី ។ អញឲ្យហៅជា ហៅក្រមសាលា ឲ្យបាស្រដី ជាហៅក្រមធំ ជំនុំអ្វីៗ ឲ្យបាស្រដី តាមដោយប្រាជ្ញា ។ ពោធិសត្វស្ដាប់ អស់អាថ៌សាស័ព្ទ បង្គំទូលថាបពិត្រអម្ចាស់ ត្រាស់លើសិរសា ខ្ញុំនេះណា ពុំហ៊ានទទួល ។ អង្វរព្រះទ័យ តាមតែក្សត្រថ្លៃ អម្ចាស់អនុកូល ដ្បិត

អស់អ្នកកាច កំណាចពុំចូល ចិត្តវៀចពុំមូល នឹងខ្ញុំឡើយណា ៗ បើខ្ញុំបង្គាប់ ប្រែវិលក្រឡាប់ ត្រង់វិញក្សត្រា គេប្រួតប្រោមស្អប់ សំភពនឹងគ្នា ហេតុនេះខ្ញុំថា ពុំព្រមឡើយហោង ៗ បពិត្រចិត្តអ្នក កំណាចអប្បល័ក្ខ ពុំដែលស្នេហ៍ស្នង ចូលនឹងអ្នកត្រង់ ព្រះអង្គច្បាស់ច្បង អ្នកវៀចចូលផង អ្នកវៀចផងគ្នា ៗ បពិត្រព្រះអង្គ រីឯអ្នកត្រង់ មានចិត្តសាធារណ៍ បើនឹងសំភព ប្រសព្វនឹងគ្នា អ្នកត្រង់ទើបជា មិត្រមូលស្នេហ៍ស្និទ្ធ ៗ បពិត្រក្សត្រថ្លៃ ពាក្យនេះឯងនែខ្ញុំទូលដោយពិត ខ្ញុំពុំថាឯង ខ្ញុំថ្លែងពិនិត តាមធម៌សុចរិតក្នុងព្រះគាថា ៗ សាធុនចេ វិសាធនេ បពិត្រក្សត្រា អ្នកមានរបស់ យសស័ក្តិសាធារណ៍ ប្រសព្វផងគ្នា ស្រណុកចិត្តក្រៃ ៗ អសាធុន អសាទុជ បពិត្រក្សត្រថ្លៃ រីអ្នកទុជនពេកពន់វិស័យ នោះទើបប្រាស្រ័យ គប់នឹងគ្នាបាន ៗ សច្ចំសច្ចេ ហិសច្ចេនេ រីឯអ្នកមាន ពាក្យសត្យមេត្រី ស្រដីទៅថ្កាន អ្នកពាក្យសត្យបាន គប់គ្នាទើបជា ៗ អលិក្ខេអលិក្ខេហិច រីអ្នកមោសា ចេះតែពុំសួត ភភូតមោសា ប្រសព្វ

គប់គ្នា ទើបមូលមេត្រី ។ សោលិហិប សោលិបេរ បតិត្រភូមី រីអ្នកលេះលោះ អសុរោះអប្រិយ៍ ជួបបួលមេត្រី ស្រឡាញ់គ្នាក្លាត់ ។ ទមិលិបេ វិទិមលេ ទ្វិលនឹងទ្វិលពិត ទើបស្រឡាញ់គ្នា ស្នេហាមូលមិត្រ មេត្រីបួលចិត្ត មូលមួយចិត្តា ។ បោរាណញ្ចេ វិហិបោរេ បើអ្នកឯណា កាន់ច្បាប់បុរាណ មែនបានរក្សា ទើបគប់នឹងគ្នា ស្រឡាញ់ពេកក្រៃ ។ បុរាណញ្ចេ វិហិបុរេ បតិត្រក្សត្រថ្លៃ អ្នកបោះកំណាចកាចក្រៅវិស័យ ប្រសព្វគ្នានៃ ទើបបួលចិត្តា ។ សមាសុខំតបោចិត្តំ រីអ្នកឯណា បួលទៅសំភព ប្រសព្វនឹងគ្នា ជួប្នះទើបជា ស្រឡាញ់ស្នេហ៍ស្និទ្ធ ។ បើបៀសវៀងនោះ មេត្រីពុំស្មោះ ពុំសប្បាយចិត្ត ពុំបានស្រឡាញ់ អស់អញស្នេហ៍ស្និទ្ធហេតុចិត្តគំនិត ទីទៃពីគ្នា ។ បតិត្រក្សត្រថ្លៃ ខ្ញុំសព្វថ្ងៃពុំបេះមុសា សេនាបតី មន្ត្រីក្សត្រា សោភសិងតែសមា-ទានកាន់ពាក្យភូត ។ នោះឋាជាត្រង់ ខ្ញុំព្រះអង្គ ជាតិជាអ្នកស្លូត មកគប់នឹងគ្នា អ្នកជានឹងភូត ពុំជាមិត្រមូត

ស្និទ្ធស្នេហ៍ឡើយនែ ។ បពិត្រក្សត្រា ពុំទទួលជា ចៅក្រម ក្សត្រថ្លៃ ១សូមម្ចាស់ស្តាប់ សាស័ព្ទប្រពៃ សំដែងច្បាប់ផ្ទៃ- ក្រោមថ្វាយក្សត្រា ។ រាជានិវ សអាណាញ្ញ វីព្រះអាជ្ញា ព្រះបាទអម្ចាស់ ត្រាស់លើសិរសា ប្រើធ្វើត្រង់ណា ធ្វើទីទៃវិញ ។ នញ្ញមញ្ញា វិសអាណា ឯអមាត្យមិញ មកតែងឲ្យធ្វើ អំពើក្រៅវិញ ធ្វើរឹងជាបេញ ពីព្រះអាជ្ញា ។ យថាធម្មំ បរាជានំ រឹងក្សត្រា រក្សាព្រះធម៌ សម្មាថ្លៃថ្លា កាលនោះឯងអា- មាត្យធ្វើកម្មវិញ ។ យទាធម្មំ វិបេក្ខានំ អមាត្យនោះមិញ រក្សាព្រះធម៌ សមាអស់អញ មហាក្សត្រប្រែបេញ ទៅធ្វើកម្មផង ។ បពិត្រមហារាជ ទ្រើសទ្រង់អំណាប ឥត្យរប្រាស់ប្បង បើអ្នកឯណា ធ្វើការប្ចេះបោង ពុំតាមគន្លង ក្នុងព្រះមាត្រា ។ ប្រទេសនោះនឹង លះលាញវិលវឹង ទាំងនគរា នៅកើតជំនៀល តិះដៀលក្សត្រា ថាឥតបេស្តា. អសារពេកក្រៃ ។ ៧សោតលោកថា ព្រៀងលានតេះណា សាប់ញាតិវិស័យ ទោះបងទោះប្អូន ទោះកូនសោត

នែ សំឡាញ់សព្វថ្ងៃ ភរិយាស្នេហា ។ បើឥតមារយាទ
ពុំគិតប្រុងប្រា- ជ្ញាស្មានស្លូគាំ មករិះគិតធ្វើ អំពើកម្មជា
និច្ចកាលពុំឃ្លា ឃ្លាតឡើយក្សត្រថ្លៃ ។ លោកពុំឲ្យមហា
ក្សត្រយកពាក្យវា ហោរគាបបង្វែ កុំយកគំនិត យកចិត្តមូល
មៃ- ត្រីបើក្សត្រថ្លៃ យកពាក្យវានោះ ។ តែងស្រដីភូត
កុហកពុំស្លូត ពាក្យពាលដូច្នោះ នឹងលាញនគរ អន្តរធាន
ស្មោះ វិនាសសូន្យសោះ បាត់បង់នគរ ។ មហាក្សត្រ
ស្តែងស្តាប់ អស់អាថិសាស័ព្ទ ដូច្នោះហើយណា យកពាក្យ
ទុកក្នុង កំលុងទ័យា ស្តេចជ្រាបសេនា- បតីហ្នោះនែ ។
ជាអ្នកបង្គាប់ ក្តីខុសក្រឡាប់ ធ្វើកម្មច្រើនក្រៃ ពុំមានបន្ទូល
ព្រះសួរឡើយនែ ស្តេចចូលទៅវិញ ក្នុងប្រាសាទឋាន ។
រីឯសេនា- បតីឫស្យា ចិត្តហោរសាមាន្យ មានចិត្តរឹងប៉ឹង
ខេរខឹងបំពាន ចំអកទៅថ្កាន ឋាម្នាលធនញ្ជ័យ ។ ក្នុងលោក
នេះណា មានតែចៅជា ប្រសើរលើសក្រៃ គ្មានអ្នកលើស
លើ នឹងស្មើតេជដៃ ប្រាជ្ញាឈ្លាសវៃ ស្មើចៅឡើយណា ។

អញមើលអំពើ គេនឹងគិតធ្វើ ទៅមុខផងគ្នា ពោធិសត្វស្តាប់សាស័ព្ទសេនា- បតីឆ្លើយថា បំអកប្បោះហើយ ។ អ្នកជាអ្នកកាយ ឱមនុស្សទាំងឡាយ យល់ខ្លួនឥតត្រើយ ខ្លួនឯងមានទោស ពុំសន្តោសឡើយ ថាគេខុសហើយ មានទោសដល់ប្រាណ ។ ធម្មតាធ្យូងខ្មៅ ក្រឡេកមើលទៅ អ្នកដទៃស្មានសោតសឹងពិភាល់ សំគាល់ថាមាន ខ្មៅនោះដូចប្រាណ ពុំថាមាសឡើយ ។ បើអ្នកណាមាន គុណធ្ងន់លើសប្រាណ តបគុណឲ្យហើយ ថាបើសត្រូវ ពុំត្រូវផងឡើយ លំអិតឲ្យហើយដូចកល់បន្លា ។ ជាប់នៅក្នុងជើង លោកប្រើដោះឡើងបោលចេញឃ្លាតឃ្លា អ្នកជាដូច្នោះ បរឆ្ពោះយាត្រា ទៅបានអាត្មា លំនៅនោះនែ ។ រីឯសេនា-បតីអង្គអា- មាត្យផងដទៃសឹងបុះទៅឋាន គ្រឹះថានវិញនៃ ដោយត្នូទៃ កាលនោះឯងណា ។ វិនិច្ឆ័យ បណ្ឌាវណ្ណ នានិដ្ឋិតា យើងនឹងសំដែងថាថ្លែងប្រស្នា បង្គាប់ក្តីជា ស្លរបម្លែះហោង ។

នេះបទព្រហ្មគិត យើងថ្លែងពិតពីទំនង ពោធិសត្វ

ប្លាស់ប្លង់ នូវអ្នកប្រាជ្ញទាំងបីនាក់ ។ អាយុបរិបូណ៌គ្រប់ មួយដណ្ដាប់ឆ្នាំជៀងជាក់ ពោធិសត្វថ្កើងយសស័ក្តិ ប្រុះប្រាជ្ញប្រាយពេកពន្លឹក ។ កាលនោះគាប់វេលា ចូលមួយរោចខែកត្តិក ស្ដេចផ្អកព្រះទ័យនឹក ក្នុងរាត្រីនោះឯងណា ។ ស្ដេចចេញគង់កណ្ដាល អស់បរិវារពពួកអា- មាត្យព្រាហ្មណ៍ព្រឹទ្ធសេនា- បតីគង់គាល់ក្សត្រថ្លៃ ។ បរោហិតមួយជាធំ អង្គុយជុំគាល់ក្សត្រថ្លៃ ក្រសាលព្រះហឫទ័យ ដោយរស្មីព្រះចន្ទ្រា ។ រីអ្នកប្រាជ្ញទាំង ៤ សឹងបួបបួនគាល់ក្សត្រា ឲ្យយកភោជនា- ហារត្រីសាច់ស្រាបាយផង ។ ផឹកស៊ីលេងកណ្ដាល ត្រាញ់នាកាលនោះឯងហោង ស្ដេចបើកបន្ទូលសង់ សានសាកសួរដណ្ដឹងថា ។ ឥឡូវរស្មីព្រះ ចន្ទ្រត្របះរុងរឿងថ្លា ដូចប្រាក់ត្រជាក់សា- ប្បាយបរិបូណ៌ក្រេមស្រណុក ។ តើយើងនឹងគិតលេង ល្បែងអ្វីនឹងបង្កើតសុខ ក្រេមក្សាន្តលះលែងទុក្ខឲ្យសប្បាយក្នុងចិន្តា ។ ព្រះពោធិសត្វស្ដាប់ អស់សាស័ព្ទទើបទូលថា បពិត្រមហាក្សត្រា ដោយយោបល់ខ្ញុំគិតយល់ ។

គួរគប្បីម្ចាស់លេង ឯណាល្បែងជាមង្គល បង្កើតជាសុខសល់
នោះប្រសើរឯក្សត្រា ។ សុន្ទរាល័យទូល ក្សត្រតស្សូរលើសិរសា
បង្កើតសុខនោះណា មានតែបញ្ចកាមគុណ ។ សេពហើយ
បង្កើតសុខ លះលែងទុក្ខសប្បាយលន់ ឯតិដ្ឋារម្មណ៍ប- ណ្ឌិត
ទូលមហាក្សត្រា ។ បពិត្រវីឯល្បែង នានឹងលេងនោះឲ្យ
សា- ប្បាយបានលាភហើយណា ប្រែជាបង់ៗ ហើយបាន ។

# រឿងធនញ្ជ័យបណ្ឌិត

(ត)

ឯម្ដាយអាពុកនាងសួស្ដីឃើញហូលព្រៃធនញ្ជ័យ ក៏ដើរមកមើលហើយសួរថា អ្នកកូននឹងយកទៅណា ឯធនញ្ជ័យសំពះជំរាបថា ខ្ញុំយកមករកប្រពន្ធទេ បើលោកម្ដាយលោកឪពុកមេត្តាខ្ញុំៗ នឹងបំរើនៅជាកូនក្នុងផ្ទះ ដងទឹក កាប់ឧសបុកស្រូវ ខ្ញុំបាទបេះតែព្រមមិនបេះខ្ជិលប្រអូសឡើយ ឯម្ដាយអាពុកនាងសួស្ដី នឹងខ្លួននាងសួស្ដីក៏ឡើងទៅលើផ្ទះ ហើយប្ដីនឹងប្រពន្ធនិយាយគ្នាថា ពៅកំឡោះនេះចង់បានកូនយើង ហើយគិតតែពីរនាក់ថា បើដោយស្មានមើលទៅឃើញជាកូនគេអ្នកមានណាស់ មានទាំងហូលព្រៃនោះច្រើន យើងល្មមឲ្យកូនយើងហើយ ឯធនញ្ជ័យកាលបើម្ដាយអាពុកក្មេកឡើងទៅលើផ្ទះហើយ ក៏វេចបង្វិចដើរទៅរកទីណាកំបាំង ហើយយកក្រដាសមកសរសេរកត់ជាបំណាំឈ្មោះនាម៉ឺនធំតូចដែលជំពាក់ប្រាក់ ខ្លះជំពាក ១០ ដម្លឹង ខ្លះជំពាក់ ៤០០ ដម្លឹង ខ្លះជំពាក់ ៥០០ ដម្លឹង បានច្រើនហើយចង ១· ជាប់ដាក់ក្នុងសំពាយឡើងទៅលើផ្ទះ សំពះម្ដាយអាពុកក្មេក ហើយអង្គុយស្ងៀម

ហាំស្តាប់ ។ ម្តាយអាពុកនាងសួស្តីក៏ជណ្តាំងថា អញនឹង
បង់សួរចិត្តជឹងឯង ៗ ចង់បានកូនអញមែនឬទេ ? ទើបធនញ្ជ័យ
សំពះហើយជំរាបថា ក្នុងចិត្តខ្ញុំចង់បាន ក្រែងតែលោកមិន
ឲ្យទានខ្ញុំបាទ បើលោកមេត្តាជាកូនជាចៅ នោះក៏អរនឹងព្រះ
គុណណាស់នឹងនៅបំរើឲ្យអស់ចិត្ត ឯម្តាយអាពុកនាងសួស្តី
ថា យើងឲ្យហើយ ប្តូរឯងទៅរកទិញមាន់ ១ ជ្រូក អណ្តើក
កុំឲ្យខាន បើមិនបានអណ្តើកនោះមេបាយើងមិនទទួលទេ ។

ឯធនញ្ជ័យបានឮពាក្យម្តាយអាពុកក្មេកបង្គាប់ថាដូច្នោះ
ហើយ ក៏ដើរទៅរកអស់អ្នកស្រុកភូមិទាំងនោះ រើសរកអ្នក
ដែលមានប្តីប្រពន្ធអំពីកំឡោះក្រមុំទើបយក ហើយឲ្យឈ្មោះថា
មេអណ្តើក ទើបរកស្រី ៤ នាក់ទៀត នេះបើបានប្រើនដល់
៨ នាក់ ឬ ១៤ នាក់នោះរឹងរឹតតែជាការល្អ តែឲ្យមានប្តីអំពី
ក្មេង បើទើបនឹងមានកូន ១ នោះក៏បានដែរ ឲ្យឈ្មោះថា កូន
អណ្តើក ទើបរកមនុស្សប្រុសម្នាក់ដែលមានយសសក្តិ មាន
ប្រាជ្ញាឲ្យឈ្មោះជាអ្នកមហា អស់អ្នកប្រុសស្រីទាំងនេះ យក

មកដណ្ដឹងកូនគេហើយ ធនញ្ជ័យឲ្យទិញអស់ទំនិញតាមបង្គាប់ម្ដាយអាពុកនាងសួស្ដី លុះទិញបានសព្វគ្រប់ហើយឲ្យអ្នកមហានាំទៅជូនម្ដាយអាពុកខាងស្រីខ្លះទុកខ្លះ ហើយរៀបសួដណ្ដាំធ្វើនំគ្រប់មុខ ឲ្យហៅភ្ញៀវមកស៊ីផឹកសង្កត់រោងរួបហើយ ព្រឹកឡើងទៀតបានជ័យល្អហើយ អ្នកមហានឹងមេអណ្ដើកក៏រៀបអស់បណ្ណាការនូវបិញ្ជៀន ត្រសាល់ ទៅបំពាក់កូនស្រីនោះ ហើយឲ្យខាងស្រីរៀបរោងចាំទទួលអស់អ្នកមហានូវអស់បណ្ណាការនោះ ។ ឯអ្នកមហា មេអណ្ដើកនឹងអស់ក្មេងដែលកាន់គ្រឿងបណ្ណាការដើរទៅដល់ហើយ អ្នកមេបាមកទទួលអ្នកមហាឡើងទៅលើរោង ទើបអ្នកមហាឲ្យយកស្រា ២ ដបដីកល់នឹងជើងពានហើយ ទើបយកប៉ង់ហឹបមក យកក្មេងឲ្យកាន់រងចង់ហឹបហើយអ្នកមហាជំរាបថា យើងមកជំរាបអស់លោកមេបាបាស់ទុំសូមជ្រាប ដ្បិតយើងបានយកបិញ្ជៀននឹងបារត្រសាល់មកសូមបំពាក់កូនស្រី ហើយសូមលើកស្លាដក់ស្លាកឡែង ជំរាបរួបហើយ ទើបអស់មេអណ្ដើក បួលទៅ

បំពាក់បំពៀនកូនស្រីនោះរួចហើយ ទើបខាងស្រីនោះលើកជាសបាយនឹងស្រាមកស៊ីផឹករួចហើយលាគ្នាទៅផ្ទះទីទៃ ៗ នេះហៅថ្ងៃកំណត់ហោង ។

លុះដល់ព្រឹកឡើងបានពេលា អ្នកមហានឹងមេអណ្ដើកកូនអណ្ដើកនាំកូនប្រុសឈ្មោះធនញ្ជ័យ ទៅសម្ដះម្ដាយអាពុកហើយយកកូនស្រីឈ្មោះនាងសួស្ដីមកផ្ទឹមនឹងធនញ្ជ័យ ហើយរាំបើកបាយខន់បងដៃរួចហើយ ដល់យប់ផ្សំដំណេកអ្នកដៃនឹងនាងសួស្ដីជាប្ដីប្រពន្ធ រួចការរវល់ពីថ្ងៃនេះទៅ ហើយទើបធនញ្ជ័យនិយាយនឹងអាពុកម្ដាយក្មេកនឹងប្រពន្ធថា នឹងទៅទារប្រាក់ដែលអស់នាម៉ឺនជំពាក់ ។

ធនញ្ជ័យទៅដល់សាលាជំនុំអស់នាម៉ឺនធំតូចច្រើន ហើយដើរឡើងទៅលើសាលា ហើយនិយាយនឹងអស់នាម៉ឺនថា បើបង់ភ្ញាល់នឹងខ្ញុំ ៗ នឹងប្រើស្ដេចឲ្យបាន ទើបអស់នាម៉ឺនថា អើយើងភ្នាល់គ្នា បើឯងប្រើបាន អញនឹងឲ្យប្រាក់ បើឯងប្រើមិនបាន ឯងឲ្យរបស់អ្វីយើង ធនញ្ជ័យថាខ្ញុំឲ្យប្រាក់ ហើយ

ធនញ្ជ័យយកសំបុត្រដែលធ្វើនោះមានឈ្មោះគ្រប់តាម៉ឺន ហើយសូមបោះត្រាទទួលជំពាក់រូបហើយ ឲ្យទៅប្រើល្បួងនឹងមើលឯធនញ្ជ័យថាបើដូច្នោះអស់លោកទៅទូលថា ដ្បិតធនញ្ជ័យវាថា វានឹងប្រើល្បួងឲ្យបានដូចបំណងវា ៗ ជានឹងមកឥឡូវនេះហើយ ឯអស់តាម៉ឺនបានស្ដាប់ហើយ ក៏យកសេចក្ដីទៅក្រាបទូលល្បួង ទៅដល់ហើយក្រាបថ្វាយបង្គំគាល់ទូលថា សូមទានដ្បិតធនញ្ជ័យវាថា វានឹងមកប្រើអម្ចាស់ឲ្យបានដូចបំណងវា ឯព្រះមហាក្សត្រិស្ដាប់ហើយ ក៏ទ្រង់ព្រះក្រោធនឹងធនញ្ជ័យវាមាក់ងាយ ហើយត្រាស់ថាទៅហៅអាដែមកឲ្យឆាប់ អមាត្យស្ដាប់ព្រះបន្ទូលត្រាស់ប្រើដូច្នោះ ក៏រត់ទៅហៅធនញ្ជ័យ តាមព្រះបន្ទូល ដល់ហើយប្រាប់ធនញ្ជ័យថា ល្បួងមានព្រះបន្ទូលឲ្យហៅ ដ្បិតទ្រង់ព្រះក្រោធនឹងឯងណាស់ ឯធនញ្ជ័យស្ដាប់ហើយក៏ទៅតាមអមាត្យ ដល់ហើយក៏ក្រាបថ្វាយបង្គំស្ងៀមនៅហើយព្រះមហាក្សត្រមានព្រះបន្ទូលសួរថា អាដែអាថានឹងមកប្រើអញមែនឬ ធនញ្ជ័យទូលថាព្រះករុណាវិសេស ប៉ុន្តែ

# TABLE DES MATIÈRES


| | Pages |
|---|---|
| 1. Brahmacariyakathā (suite) | 163 |
| 2. Caturangapada (suite) | 185 |
| 3. Lokaneya (suite) | 193 |
| 4. L'explication du mot calendrier | 211 |
| 5. Faits divers | 223 |


## Hors texte


Prasat Prah Khnay Barai (Kompong-Thom) . . . . . . . . . . 161



ប្រាសាទព្រះខ្លាយ នៅស្រុកបារាយ កំពង់ធំ

នឹងប្រើមិនទាន់បាន បើបែរព្រះភក្ត្រមើលទៅក្រោយរួបហើយ ទើបប្រើបាន ស្តេចស្តាប់ហើយក៏បែរព្រះភក្ត្រទតមើលទៅក្រោយហើយបែរមកវិញ ថាអញមើលទៅហើយអាឯងមិនប្រើបុះ ឯធនញ្ជ័យក្រាបទូលថា នេះហៅប្រើហើយ គឺប្រើឲ្យព្រះអង្គបែរទៅក្រោយបានហើយ នឹងមានប្រើអម្ចាស់ឲ្យទៅទូលរែករបស់អ្វីក៏ទេ ។

# បញ្ជីរឿង


ទំព័រ

១ ព្រហ្មចរិយកថា របស់ព្រះមហាសែស ក្រុមពុទ្ធសាសនបណ្ឌិត្យ ប្រែនិង រៀបរៀង (ត) . . . . . . . . . . . . . . . . . . . . . ១៦៣

២ ធាតុវង្គបទ របស់ព្រះមហាពិទូរ ក្រសេម (ត) . . . . . . . . . . . . ១៨៥

៣ លោកន័យ របស់ឧកញ៉ាវង្សាសរពេជ្ញ នង (ត) . . . . . . . . . . . ១៩៣

៤ សេចក្ដីអធិប្បាយពាក្យថា សង្ក្រាន្ត របស់អាចារ្យ គីម-អាន ក្រុមពុទ្ធសាសន-បណ្ឌិត្យ . . . . . . . . . . . . . . . . . . . . . . . ២១១

៥ ដំណឹងផ្សេងៗ: ពាក្យសាន្តិភាព . . . . . . . . . . . . . . . . . ២២៣


# រូបក្រៅរឿង


ប្រាសាទព្រះខ្ពាយ នៅស្រុកបារាយ កំពង់ធំ . . . . . . . . . . . . . ១៦១

ព្រហ្មចរិយកថា

របស់

ព្រះមហាសែស ក្រុមពុទ្ធសាសនបណ្ឌិត្យ

ឯធម្មទាន គឺការឱ្យទានធម៌ដល់អ្នកដទៃ បានសេចក្ដីថា បង្ហាត់បង្រៀនធម៌ដល់អ្នកដទៃ សំដែងធម៌ដល់អ្នកដទៃ សមតាមពាក្យអដ្ឋកថាជាវ្យលោកសំដែងទុកក្នុងអដ្ឋកថាអង្គុត្តរៈនិកាយទុកនិបាតថា

ធម្មទានន្តិ ឥធេកច្ចោ អមតប្បត្តិប្បដិបទំ កថេត្វា ទេតិ ឥទំ ធម្មទានំ នាម បុគ្គលពួក ១ ក្នុងលោកនេះ សំដែងសេចក្ដីប្រតិបត្តិជាគ្រឿងដល់ព្រះនិព្វានឱ្យដល់អ្នកដទៃ នេះហៅថា ធម្មទាន ។

ក្នុងអដ្ឋកថា ឥតិវុត្តកថា បុគ្គលពួក ១ ក្នុងលោកនេះចែកកុសលកម្មបថ នឹងអកុសលកម្មបថ ដូច្នេះថា “ធម៌នេះជាកុសល ធម៌នេះជាអកុសល ធម៌នេះប្រកបដោយទោស ធម៌នេះមិនមានទោស ធម៌នេះអ្នកប្រាជ្ញតិះដៀល ធម៌នេះអ្នកប្រាជ្ញសរសើរ ធម៌នេះបើបុគ្គលធ្វើឱ្យបរិបូណ៌ហើយ សមាទានយកហើយ រមែងប្រព្រឹត្តទៅដើម្បីសេចក្ដីសាបសូន្យ ដើម្បី

សេចក្ដីទុក្ខ ធម៌នេះប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្ដីសុខ" ហើយសំដែងកម្មនឹងផលនៃកម្មឲ្យប្រាកដក្នុងលោកនេះ នឹងលោកខាងមុខ ហាក់ដូចជាបង្អុលប្រាប់ដោយជាក់ច្បាស់ នឹងសំដែងធម៌ញ៉ាំងជនដទៃ ឲ្យងាកបែរចេញអំពីអកុសលធម៌ ដំកល់នៅក្នុងកុសលធម៌ នេះហៅថា ធម្មទាន ។

ម្យ៉ាងទៀត បុគ្គលឯណាសំដែងសច្ចៈទាំង ៤ ថា "ធម៌នេះបុគ្គលគួរត្រាស់ដឹង ធម៌នេះបុគ្គលគួរកំណត់ដឹង[១] ធម៌នេះបុគ្គលគួរលះបង់[២] ធម៌នេះបុគ្គលគួរធ្វើឲ្យជាក់ច្បាស់[៣] ធម៌នេះបុគ្គលគួរបំរើន[៤]" នឹងសំដែងធម៌ គឺ សេចក្ដីប្រតិបត្តិដើម្បីបានព្រះនិព្វាន នេះហៅថា ធម្មទានជាកំពូល ។

ម្យ៉ាងទៀត បុគ្គលដែលអាស្រ័យនូវវិវដ្ដគាមិធម្មទាន រមែងរួចចាកសេចក្ដីវិនាសទាំងពួង រមែងប្រព្រឹត្តកន្លងនូវវដ្ដទុក្ខទាំងអស់ ។ បំណែកលោកិយធម្មទាន ជាហេតុនៃទានទាំងពួង ជាមូលនៃសម្បត្តិទាំងពួង ។ ម្យ៉ាងទៀត បណ្ដាទាន

---

១ កងទុក្ខ ។ ២ តណ្ហា ។ ៣ ព្រះនិព្វាន ។ ៤ អដ្ឋង្គិកមគ្គ ។

ទាំងនេះ អភយទានសង្គ្រោះដោយធម្មទានដែរ ។ ក្នុងអដ្ឋ-កថាមង្គលសូត្រថា ការសំដែងធម៌ដែលព្រះសម្មាសម្ពុទ្ធទ្រង់ជ្រាបច្បាស់ ជាធម៌នាំឲ្យអស់ទៅនៃសេចក្ដីទុក្ខ នាំមកនូវសេចក្ដីសុខ ក្នុងឥធលោកនឹងបរលោក ដោយសេចក្ដីប្រាថ្នានូវប្រយោជន៍ដល់អ្នកដទៃ ហៅថា ធម្មទាន ។

ម្យ៉ាងទៀត ធម្មទានជាទានប្រសើរថ្លៃថ្លា ព្រោះឈ្នះអស់អាមិសទានទាំងពួង ។ ព្រោះហេតុនោះ បានជាព្រះដ៏មានព្រះភាគ ទ្រង់សំដែងធម៌ដល់សក្កទេវរាជជាធំជាងទេវតាក្នុងតណ្ហាវគ្គនៃគម្ពីរធម្មបទថាៈ

សព្វទានំ ធម្មទានំ ជិនាតិ សព្វរសំ ធម្មរសោ ជិនាតិ
សព្វរតិំ ធម្មរតិ ជិនាតិ តណ្ហក្ខយោ សព្វទុក្ខំ ជិនាតិ ។

ធម្មទានឈ្នះអស់ទានទាំងពួង រសធម៌ឈ្នះអស់រសទាំងពួង សេចក្ដីត្រេកអរក្នុងធម៌ឈ្នះអស់សេចក្ដីត្រេកអរទាំងពួង សេចក្ដីអស់ទៅនៃតណ្ហា ឈ្នះអស់ទុក្ខទាំងពួង ។ អដ្ឋកថាអធិប្បាយថា បើបុគ្គលឲ្យបីវរដែលល្អដូចបណ្ដូលចេក ដល់ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធនឹងព្រះខីណាស្រព ដែលប្រជុំគ្នាត្រៀបត្រា

ឥតមានចន្លោះ ក្នុងផ្ទៃចក្កវាឡរហូតដល់ព្រហ្មលោក នៅក្នុងទីសមាគមនោះ មានធម្មកថិកអង្គណាមួយ ធ្វើអនុមោទនាដោយគាថា ៤ បាទ ក៏ប្រសើរជាងបរិវារទាននោះ ។ ឯបរិវារទាននោះ មិនបាន ១ បំរៀកនៃគាថានោះដែលគេច្រៀកជា ១៦ បំរៀក ១៦ ដង ។ ការសំដែងធម៌ក្តី ការបង្រៀនធម៌ក្តី ការស្តាប់ធម៌ក្តី ជាការប្រសើរយ៉ាងនេះឯង ។ ការស្តាប់ធម៌នោះ បើបុគ្គលឯណាបានផ្តួចផ្តើមធ្វើហើយ អានិសង្សច្រើននឹងមានដល់បុគ្គលនោះមិនខាន ។ ធម្មទានដោយហោចទៅគ្រាន់តែបុគ្គលធ្វើដោយអនុមោទនាដោយគាថា ៤ បាទ ក៏នៅតែប្រសើរជាងទានដែលបុគ្គលយកបង្ហាន់បិណ្ឌបាតដ៏ឧត្តម ដាក់ពេញក្នុងបាត្រហើយឲ្យដល់បរិសទ្យមានសភាពដូច្នោះផង(១) ជាងភេសជ្ជទានដែលបុគ្គលយកសប្បិនឹងប្រេងជាដើមដាក់ពេញក្នុងបាត្រហើយឲ្យដល់បរិសទ្យមានសភាពដូច្នោះផង ជាងសេនាសនទាន ដែលបុគ្គលកសាងវិហារដូចយ៉ាងមហាវិហារ កសាងប្រាសាទដូចយ៉ាងលោហប្រាសាទរាប់សែនមិនតែ ១ ហើយ

---

១ ពាក្យចង្អុលទៅរកព្រះវិណាស្រិតខាងដើម ។

ឲ្យដល់បរិសទ្យមានសភាពដូច្នោះផង ជាងបរិច្ចាគដែលអនាថ-
បិណ្ឌិកសេដ្ឋីធ្វើប្រារព្ធនូវវិហាររបស់ខ្លួនផង ។ ព្រោះហេតុអ្វី ។
ព្រោះថាបុគ្គលធ្វើបុណ្យមានសភាពដូច្នោះ លុះតែបានស្តាប់ធម៌
ហើយទើបធ្វើ បើមិនបានស្តាប់ធម៌ទេ មិនបានធ្វើឡើយ ។

សេចក្តីពិតថា សត្វទាំងឡាយបើមិនបានស្តាប់ធម៌ហើយ
សូម្បីតែបបរមួយបោយក្តី បាយមួយវែកក្តី ក៏មិនអាចនឹងធ្វើ
ទៅជាទានបានឡើយ ។ ធម្មទានបានឈ្មោះថា ប្រសើរជាង
ទានទាំងពួងដោយហេតុនេះឯង ។

ម្យ៉ាងទៀត លើកលែងតែព្រះពុទ្ធនឹងព្រះបច្ចេកពុទ្ធចេញ
ព្រះថេរទាំងឡាយមានព្រះសារីបុត្តជាដើម ដែលប្រកបដោយ
បញ្ញាអាចនឹងរាប់ដំណក់ទឹកគឺគ្រាប់ភ្លៀងដែលធ្លាក់ចុះអស់កល្ប
ទាំងមូល ក៏មិនអាចនឹងត្រាស់ដឹងនូវផលមានសោតាបត្តិផល
ជាដើមបានឡើយ លុះតែបានស្តាប់ធម៌ដែលព្រះថេរទាំងឡាយ
មានអស្សជិត្ថេរជាដើមលោកសំដែងហើយ ទើបធ្វើឲ្យជាក់
ច្បាស់នូវសោតាបត្តិផលបាន បានធ្វើឲ្យជាក់ច្បាស់នូវសាវក-
បារមីញាណ ដោយធម្មទេសនារបស់ព្រះសាស្តា ។ ធម្មទាន

បានឈ្មោះថាប្រសើរដោយហេតុនេះឯង ។ ព្រោះហេតុនោះ បានជាព្រះដ៏មានព្រះភាគសំដែងថា ធម្មទានឈ្នះអស់ទាន ទាំងពួង ។

ម្យ៉ាងទៀត រសទាំងពួងមានរសនៃទឹកឃ្មុំជាដើមក្តី រសនៃសុធាភោជនរបស់ទេវតាយ៉ាងឧក្រិដ្ឋក្តី ជាបច្ច័យនាំឲ្យលិចនៅត្រង់ជាបត្រដ្ឋសក្នុងសង្សារវដ្ត ហើយសោយនូវសេចក្តីទុក្ខជាច្រើន ។ ចំណែករសនៃធម៌ ពោលគឺពោធិបក្ខិយធម៌ទាំង ៣៧ ក្តី លោកុត្តរធម៌ទាំង ៩ ក្តី ប្រសើរជាងរសទាំងពួង ព្រោះហេតុនោះបានជាព្រះដ៏មានព្រះភាគសំដែងថា រសនៃធម៌ឈ្នះអស់រសទាំងពួង ។

ម្យ៉ាងទៀត សេចក្តីត្រេកអរមានប្រភេទច្រើន គឺសេចក្តីត្រេកអរនឹងកូនប្រុស ត្រេកអរនឹងកូនស្រី ត្រេកអរនឹងស្រី ត្រេកអរនឹងល្បែង មានរបាំនឹងចំរៀងជាដើម សេចក្តីត្រេកអរនោះ ក៏សុទ្ធតែជាបច្ច័យនាំសត្វឲ្យលិចនៅ ត្រង់ជាបត្រដ្ឋសក្នុងសង្សារវដ្ត ហើយសោយនូវសេចក្តីទុក្ខជាច្រើន ។ ចំណែកសេចក្តីត្រេកអរគឺបីតិដែលកើតឡើងក្នុងចិត្តនៃបុគ្គលអ្នកសំដែង

ធម៌ក្តី អ្នកស្តាប់ធម៌ក្តី នាំឲ្យកើតសេចក្តីអរំភើតអណ្តូង លន្លង់លន្លោចចិត្តក៏មាន នាំឲ្យស្រក់ហៀរហូរទឹកភ្នែកក៏មាន នាំឲ្យព្រឺព្រួចរោមក៏មាន សេចក្តីត្រេកអរគឺបីតិនោះ អាចធ្វើនូវទីបំផុតនៃសង្សារវដ្តបាន មានព្រះអរហត្តជាទីបំផុតកិច្ច សេចក្តីត្រេកអរក្នុងធម៌បែបនេះ ឈ្មោះថាប្រសើរជាងសេចក្តីត្រេកអរទាំងពួង ។ ព្រោះហេតុនោះ បានជាព្រះដ៏មានព្រះភាគទ្រង់សំដែងថា សេចក្តីត្រេកអរក្នុងធម៌ ឈ្នះអស់សេចក្តីត្រេកអរទាំងពួង ។

ម្យ៉ាងទៀត សេចក្តីអស់ទៅនៃតណ្ហា បានខាងព្រះអរហត្តដែលកើតឡើងក្នុងទីបំផុតនៃកិរិយាអស់ទៅនៃតណ្ហា ឯព្រះអរហត្តនោះឈ្មោះថាប្រសើរជាងធម៌ទាំងពួង ។ ព្រោះហេតុនោះបានជាព្រះដ៏មានព្រះភាគទ្រង់សំដែងថា សេចក្តីអស់ទៅនៃតណ្ហា ឈ្នះអស់ទុក្ខទាំងពួង ។

មួយវិញទៀត បុគ្គលអ្នកសំដែងធម៌ ត្រូវមានចិត្តទន់ផ្សាយនូវប្រយោជន៍ដល់អ្នកស្តាប់ មិនត្រូវគោរពក្នុងលាភឡើយ ។ ព្រោះថាធម្មទានមិនមានផលច្រើនដល់បុគ្គលអ្នក

សំដែងដែលគោរពក្នុងលាភនោះឡើយ ។ ព្រោះហេតុនោះបាន ជាព្រះអដ្ឋកថាចារ្យពោលទុកក្នុងអដ្ឋកថាសង្គីតិសូត្រថា អ្នក សំដែងធម៌ពួកមួយចង់ឲ្យតែគេស្គាល់ខ្លួនថាជាធម្មកថិក ហើយ មានសេចក្ដីគោរពក្នុងលាភ សំដែងធម៌ដល់អ្នកដទៃ ធម្មទាន នោះមិនមានផលច្រើនឡើយ ។ អ្នកសំដែងធម៌ពួកមួយ មិន ប្រាថ្នាលាភសក្ការៈ ហើយសំដែងធម៌ដែលខ្លួនចេះចាំស្ទាត់ ដល់អ្នកដទៃ ធម្មទាននេះឈ្មោះថា ទេសនាមយបុញ្ញកិរិយាវត្ថុ ប្រែថា អំពើបុណ្យសំរេចមកអំពីការសំដែងធម៌ ។

មួយវិញទៀត បុគ្គលអ្នកសំដែងធម៌ ត្រូវដំកល់ធម៌ ៥ ប្រការទុកក្នុងខ្លួន ។ សមតាមព្រះពុទ្ធភាសិត ដែលទ្រង់ សំដែងទុក ក្នុងគម្ពីរអង្គុត្តរនិកាយ បញ្ចកនិបាតថា ម្នាល អានន្ទ ការសំដែងធម៌ដល់អ្នកដទៃមិនងាយឡើយ ម្នាលអានន្ទ បុគ្គលអ្នកសំដែងធម៌ដល់អ្នកដទៃ គួរដំកល់ធម៌ ៥ ប្រការទុក ក្នុងចិត្ត ហើយទើបសំដែងធម៌ដល់អ្នកដទៃបាន ។ ធម៌ ៥ ប្រការនោះគឺអ្វីខ្លះ ?

អនុបុព្វិកថំ កថេស្សាមីតិ បរេសំ ធម្មោ ទេសេតព្វោ ត្រូវសំដែងធម៌ដល់អ្នកដទៃ ដោយគិតថា "អាត្មាអញនឹងសំដែងធម្មកថាជាលំដាប់ គឺសីលជាលំដាប់នៃទាន ស្ថានសួគ៌ជាលំដាប់នៃសីលជាដើម នឹងសំដែងធម្មកថា សមគួរដល់សូត្រនឹងគាថានោះៗ ១ ។ បរិយាយំ ទស្សាមិ(១) កថំ កថេស្សាមីតិ បរេសំ ធម្មោ ទេសេតព្វោ ត្រូវសំដែងធម៌ដល់អ្នកដទៃដោយគិតថា "អាត្មាអញនឹងចង្អុលប្រាប់ហេតុនៃអត្ថនោះៗ ហើយសំដែងធម្មកថា ១ ។ អនុទ្ទយតំ បដិច្ច កថំ កថេស្សាមីតិ បរេសំ ធម្មោ ទេសេតព្វោ ត្រូវសំដែងធម៌ដល់អ្នកដទៃដោយគិតថា "អាត្មាអញនឹងសំដែងធម្មកថា អាស្រ័យសេចក្ដីអនុគ្រោះ គឺបំណងនឹងដោះសត្វដែលជាប់ជំពាក់ដោយសេចក្ដីបង្អៀតធំ ឲ្យរួចអំពីសេចក្ដីបង្អៀតចេញ ១ ។ ន អាមិសន្តរោ កថំ កថេស្សាមីតិ បរេសំ ធម្មោ ទេសេតព្វោ ត្រូវសំដែងធម៌ដល់អ្នកដទៃដោយគិតថា "អាត្មាអញមិនមានអាមិសជាហេតុ គឺថាមិនប្រាថ្នានូវលាភ

---

១ បាលីសៀវភៅសៀម ច្បាប់សម័យថ្មីថា បរិយាយទស្សាវី ។

គឺបច្ច័យទាំង ៤ ហើយសំដែងនូវធម្មកថា ១ ។ អត្តានញ្ច បរញ្ច អនុបហច្ច កចំ កបេសព្វាមីតិ បរេសំ ធម្មោ ទេសេ-តព្វោ ត្រូវសំដែងធម៌ដល់អ្នកដទៃដោយគិតថា "អាត្មាអញមិនបានបៀតបៀនខ្លួនឯង(១) ទំាំងអ្នកដទៃហើយសំដែងនូវធម្មកថា ១ ។

ចប់ធម្មទានដោយសង្ខេប តែប៉ុណ្ណេះ ។

ប្រភេទទានដូចបានសំដែងមកនេះ ចាត់ជាព្រហ្មចរិយទី ១ ហៅថា ទានព្រហ្មចរិយ ។

ឯព្រហ្មចរិយទី ២ គឺវេយ្យាវច្ច សេចក្ដីខ្វល់ខ្វាយនោះមានមកក្នុងអង្គុរបេតវត្ថុ ។

សេចក្ដីប្រារព្ធខាងដើមរបស់ព្រះសិរិមង្គលាចារ្យថា វេយ្យា-វច្ចករណន្តុ វុឌ្ឍតរានំ វត្តប្បដិបត្តិករណាទិវសេន លព្ភតិ សេចក្ដីថា ការធ្វើនូវសេចក្ដីខ្វល់ខ្វាយ អ្នកប្រាជ្ញសង្កេតយកសេចក្ដីបានតាមទំនងកិច្ចមានធ្វើវត្តប្រតិបត្តិ ដល់បុគ្គលដែល

---

១ មិនបានបំពាល់ខ្លួនឯងទំាំងអ្នកដទៃ គឺមិនលើកដំកើងខ្លួនឯង ហើយបង្អាប់បង្អោនអ្នកដទៃជាដើម ។

ចាស់ជាងខ្លួន ឬមានគុណចំរើនជាងខ្លួនជាដើម ។ ព្រោះហេតុនោះបានជា អដ្ឋកថាចារ្យពោលទុកក្នុងអដ្ឋកថាសង្គីតិសូត្រថា សេចក្ដីខ្វល់ខ្វាយ អ្នកប្រាជ្ញគប្បីដឹងតាមទំនងដែលគ្រហស្ថនឹងបព្វជិតធ្វើវត្តប្រតិបត្តិ ដល់បុគ្គលចាស់ជាងខ្លួន ឬមានគុណចំរើនជាងខ្លួន ១ តាមទំនងដែលបុគ្គលបានឃើញភិក្ខុចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត ក៏នាំយកបាត្រអំពីភិក្ខុហើយបបួលណែនាំអ្នកស្រុកឲ្យយកបាយមកដាក់បាត្ររូបហើយនាំយកបាត្រទៅប្រគេនភិក្ខុវិញ ១ តាមទំនងដែលបុគ្គលបានឮសំឡេងគេស្រែកប្រាប់ថា ឲ្យទៅយកបាត្រភិក្ខុមកដាក់បាយ ហើយក៏ស្ទុះទៅប្រញាប់ប្រញាល់យកបាត្រមកឲ្យគេជាដើម ១ ។ ដូចមានវត្ថុនិទានថា៖

អតីតេ ឯកោ ឥស្សរោ ពហិនគរេ នហាត្វា អាគច្ឆន្តោ អន្តរាមគ្គេ ឯកំ បច្ចេកពុទ្ធំ អទ្ទស ក្នុងកាលកន្លងទៅហើយមានឥស្សរជនគឺជនជាធំម្នាក់ ទៅងូតទឹកខាងក្រៅក្រុង លុះត្រឡប់វិលមកវិញដល់ពាក់កណ្ដាលផ្លូវ បានជួបនឹងព្រះបច្ចេក-ពុទ្ធ ១ អង្គ ។ ឯព្រះបច្ចេកពុទ្ធនោះ និមន្តចូលទៅបិណ្ឌបាត

ក្នុងក្រុង ត្រូវមារមកបញ្ចូលចិត្តអ្នកស្រុកទាំងអស់មិនឲ្យនឹកនា ថ្វាយបាយដាក់បាត្រ ព្រះបច្ចេកពុទ្ធក៏មិនបានបាយសោះ មាន តែបាត្រទទេហើយនិមន្តចេញទៅវិញ ។ ឥស្សរជនបានឃើញ ព្រះបច្ចេកពុទ្ធ ហើយក៏ថ្វាយបង្គំទូលសួរថា លោកម្ចាស់បាន បាយខ្លះដែរឬ ។ ព្រះបច្ចេកពុទ្ធឆ្លើយថា ម្នាលអាវុសោ អាត្មា ភាពត្រេចទៅបិណ្ឌបាត ឥឡូវត្រឡប់មកវិញហើយ ។ ឥស្សរ ជនគិតថា លោកម្ចាស់មិននិយាយត្រង់ពាក្យដែលអញសួរ ត្រឡប់ទៅជានិយាយពាក្យដទៃវិញ ប្រហែលជាមិនបានវត្ថុអ្វី ទេយ៉ាង ហើយក៏សូមបើកបាត្រមើល ឃើញបាត្រទទេ ក៏អន្ទះ សាឆ្អែឆ្អា ព្រោះមិនដឹងថាក្នុងផ្ទះខ្លួនមានបាយឆ្អិនហើយឬមិន ទាន់ឆ្អិន ក៏មិនហ៊ានយកបាត្រទៅ គ្រាន់តែនិយាយឃាត់ថា លោកម្ចាស់រង់ចាំបន្តិចសិន ហើយក៏រត់ទៅផ្ទះប្រញាប់ប្រញាល់ ដឹងច្បាស់ថាបាយឆ្អិនហើយ ក៏ប្រើបំរើម្នាក់ទៅថា អ្នកឯងរត់ ទៅយកបាត្រលោកមកឲ្យឆាប់ ។ អ្នកបំរើនោះ ក៏ស្ទុះរត់ទៅ យកបាត្រភ្លាម ។ ឯឥស្សរជនយកបាយមកដាក់ពេញបាត្រ ស្រេចហើយ និយាយថា អ្នកឯងយកបាត្រនេះទៅប្រគេន

លោកឲ្យឆាប់ អញឲ្យបំណែកបុណ្យអំពីបិណ្ឌបាតនេះដល់អ្នកឯង ។ អ្នកបំរើនោះក៏រត់ទៅជាប្រញាប់ ប្រគេនបាត្រដល់ព្រះបច្ចេកពុទ្ធ ហើយថ្វាយបង្គំទូលថា បពិត្រលោកដ៏បំរើនពេលឆាន់ជិតណាស់ហើយ ខ្ញុំម្ចាស់រត់ទៅរត់មកដោយការប្រញាប់ឲ្យទាន់ពេល ដោយអំណាចផលនៃកំឡាំងរបស់ខ្ញុំនេះ សូមឲ្យកើតពាហនអាចដើរទៅក្នុង ១ ថ្ងៃបាន ៥០ យោជន៍ខ្លះ ៦០ យោជន៍ខ្លះ ១០០ យោជន៍ខ្លះ ១២០ យោជន៍ខ្លះ កុំបីឃ្លាតឡើយ ។

ម្យ៉ាងទៀត ខ្ញុំម្ចាស់រត់ទៅរត់មក មានកាយក្តៅក្រហាយដោយតេជៈព្រះអាទិត្យ ដោយអំណាចផលកម្មរបស់ខ្ញុំនោះ ខ្ញុំបានទៅកើតទីណា ៗ សូមឲ្យមានអំណាចដូចតេជៈព្រះអាទិត្យ បំណែកបុណ្យក្នុងបង្ហាន់បិណ្ឌបាតនេះ នាយហៅហ្វាយក៏បានបែកឲ្យខ្ញុំហើយ ដោយអានិសង្សបិណ្ឌបាតនោះ ខ្ញុំម្ចាស់សូមឲ្យបានបំណែកធម៌ដែលលោកម្ចាស់ត្រាស់ដឹងហើយ ។ ព្រះបច្ចេកពុទ្ធមានពុទ្ធដីកាថា ផលនៃសេចក្តីប្រាថ្នារបស់អ្នក ចូរសំរេចយ៉ាងនេះចុះ ហើយធ្វើអនុមោទនា ដោយបច្ចេកពុទ្ធ-

គាហាទាំងឡាយ ហើយក៏ចៀសចេញទៅ ។ ឯអ្នកបំរើនោះ អន្ទោលទៅមក លុះដល់មកពុទ្ធុប្បាទនេះ បានជាព្រះរាជាទ្រង់ព្រះនាមថា ចណ្ឌប្បជោត ក្នុងនគរឧជ្ជេនី ។ ពាហនៈទាំង ៥ ក៏កើតមានដល់ព្រះរាជានោះ ដោយអានិសង្សបុញ្ញកម្មនោះឯង គឺមេដំរី ១ ឈ្មោះភទ្ទវតី ដើរបាន ៥០ យោជន៍ក្នុង ១ ថ្ងៃ ខ្ញុំម្នាក់ឈ្មោះកាក ដើរបាន ៦០ យោជន៍ក្នុង ១ ថ្ងៃ សេះ ២ ឈ្មោះវេលកំសី ១ ឈ្មោះមុញ្ជកេសី ១ ដើរបាន ១០០ យោជន៍ ក្នុង ១ ថ្ងៃ ដំរីឈ្មោល ១ ឈ្មោះនាឡាគិរី ដើរបាន ១២០ យោជន៍ក្នុង ១ ថ្ងៃ ។

វេយ្យាវច្ច សេចក្ដីខ្វល់ខ្វាយជួយឈឺឆ្អាលក្នុងការកុសល របស់អ្នកដទៃ អ្នកប្រាជ្ញគប្បីដឹងដូចព្រះបាទចណ្ឌប្បជោតនោះចុះ ។

យាចកានំ មគ្គាចិក្ខនម្បិ វេយ្យាវច្ចំ នាម ម្យ៉ាងទៀត ការប្រាប់ផ្លូវដល់ពួកស្មូមទាំងឡាយ ក៏ឈ្មោះថា វេយ្យាវច្ចដែរ ដូចមានវត្ថុនិទានថា ៖

អតីតេ ឧត្តរាបថេ អសិតញ្ជនគរេ មហាកំសរញ្ញោ ទេវិគព្ភា នាម ធីតា អហោសិ ក្នុងកាលកន្លងទៅហើយ ព្រះបាទមហាកំសរាជ ក្នុងនគរអសិតញ្ជ ក្នុងដែនឧត្តរាបថ មានព្រះរាជធីតា ១ ព្រះនាមទេវិគព្ភា ។ ព្រះរាជធីតានោះ អាស្រ័យនឹងព្រះរាជកុមារ ព្រះនាមឧបសាគរ ជាព្រះរាជបុត្រ របស់ព្រះបាទមហាសាគររាជ ជាអធិបតីក្នុងដែនឧត្តរ ។ ព្រះរាជធីតានោះបានប្រសូតិបុត្រ ១១ អង្គ គឺនាង អញ្ជនទេវី ១ វាសុទេវិកុមារ ១ ពលទេវិកុមារ ១ បន្ធទេវិកុមារ ១ សុរិយ-ទេវិកុមារ ១ អគ្គិទេវិកុមារ ១ វរុណកុមារ ១ អជ្ជុនកុមារ ១ បជ្ជុនកុមារ ១ ឃដបណ្ឌិតកុមារ ១ អង្កុរកុមារ ១ ។ បណ្ដាបុត្រទាំង ១១ នោះ កុមារទាំង ១០ មានវាសុទេវិជាដើម នាំគ្នាសំឡាប់ព្រះរាជាទាំងអស់ ក្នុងនគរទាំង ៦ ហ្មឺន ៣ ពាន់ ក្នុងសកលជម្ពូទ្វីប មានអសិតញ្ជនគរជាដើម មានទ្វារវតីនគរជាទីបំផុត នាំគ្នាទៅនៅក្នុងទ្វារវតីនគរ ហើយបែងចែករាជសម្បត្តិជា ១០ ចំណែក ភ្លេចនឹកដល់នាងអញ្ជនទេវីជាប្អូនបង្អស់ ។ លុះដល់ថ្ងៃក្រោយទៀត ក៏រឭកនឹកឃើញនាងទេវី

ជាបង ក៏ប្រឹក្សាគ្នាគិតនឹងចែកជា ១១ ចំណែកវិញ ទើប អង្គកុមារជាប្អូនបង្អស់និយាយថា អ្នកទាំងឡាយចូរឲ្យចំណែករបស់ខ្ញុំដល់នាងទេវីជាបងចុះ ខ្ញុំនឹងរកស៊ីលក់ដូរចិញ្ចឹមជីវិតទៅចុះ តែថាអ្នកទាំងឡាយឲ្យខ្ញុំរួបពន្ធក្នុងជនបទរបស់ខ្លួនៗ ។ ព្រះរាជាទាំងនោះ ក៏ឲ្យចំណែករបស់អង្គកុមារដល់នាងទេវីជាបង ហើយនៅក្នុងនគរទ្វារវតីជាមួយនឹងនាងទេវីជាបងនោះ ។ ឯអង្គកុមាររកស៊ីធ្វើជំនួញមានទ្រព្យសម្បត្តិច្រើន បានឲ្យទានធំជានិច្ច ។ មានខ្ញុំម្នាក់របស់អង្គកុមារនោះ ជានាយឃ្លាំងមានអធ្យាស្រ័យល្អ ប្រាថ្នាសេចក្ដីចំរើនដល់ម្ចាស់ ។ អង្គកុមារក៏នាំយកស្រីម្នាក់មកឲ្យជាប្រពន្ធខ្ញុំនោះ ។ កាលបើមានកូនមកចាប់បដិសន្ធិក្នុងផ្ទៃភរិយាហើយ ខ្ញុំនោះក៏ស្លាប់ទៅ ។ កាលបើកូននោះមានវ័យវឌ្ឍនាការចំរើនធំឡើងហើយ ក៏កើតវិវាទក្ដីនឹងគ្នាព្រោះកូននោះ គឺអ្នកខ្លះនិយាយថា កូននោះនៅជាខ្ញុំគេដដែល ព្រោះបិតាវាជាខ្ញុំគេ អ្នកខ្លះនិយាយថា កូននោះមិនមែនជាខ្ញុំគេទេ ខ្ញុំគេតែបិតារបស់វា ឥឡូវស្លាប់ទៅហើយ ត្រង់មាតារបស់វាមិនមែនជាខ្ញុំគេទេ រឿងក្ដីនោះក៏កើត

ឡើងក្នុងរាជត្រកូល ។ នាងអញ្ចនទេវីបានឮរឿងនេះហើយ ក៏នាងកាត់សេចក្ដីដោយយុត្តិធម៌ នាងអធិប្បាយប្រៀបដូចមេគោម្នាស់ ១ អាស្រ័យនឹងគោឈ្មោលម្ចាស់ដទៃ ហើយបានកូនគោកើតឡើង កូនគោនោះត្រូវបានទៅអ្នកម្ចាស់មេគោ អ្នកម្ចាស់គោឈ្មោលមិនត្រូវបានកូនគោនោះឡើយ រឿងនេះដូច្នោះដែរ មាតានោះជាអ្នកជា កូននោះក៏ជាអ្នកជាដែរ ហើយនាងដោះកូននោះឲ្យរួចអំពីសភាពជាខ្ញុំគេ ។ ក៏ឯទារកនោះ មានសេចក្ដីអៀនខ្មាសមិនហ៊ានទៅក្នុងនគរនោះ ក៏រត់ទៅនៅក្នុងរោរុវនគរ ទៅយកកូនស្រីជាងដុលធ្វើជាភរិយា ហើយសំរេចទីលំនៅក្បែរផ្ទះអសយ្ហមហាសេដ្ឋី ចិញ្ចឹមជីវិតដោយការងាររបស់ជាងដុល ។ ក្នុងកាលនោះ អសយ្ហមហាសេដ្ឋីញ៉ាំងទានធំឲ្យប្រព្រឹត្តទៅដល់មហាជន ។ ពួកស្មូមឯណាមិនបានដឹងផ្លូវទៅកាន់ផ្ទះអសយ្ហមហាសេដ្ឋី ពួកស្មូមនោះក៏ចូលទៅសួរជាងដុលនោះ ។ ជាងដុលនោះ ក៏គិតពិចារណាថា “អាត្មាអញហេតុតែមិនបានធ្វើបុណ្យមកអំពីបុព្វជាតិ បានជាឥឡូវនេះមិនអាចនឹងឲ្យទានបន្តិចបន្តួចដល់ស្មូមយ៉ាងនេះ អាត្មាអញ

គ្រាន់តែបង្គុលប្រាប់រោងទានដល់ស្មូមទាំងនេះ ហើយញ៉ាំងបីតិឲ្យកើតឡើង ដោយការប្រាប់ឧបាយនៃលាភ ក៏នឹងបានសោយបុណ្យជាច្រើន ដោយកម្មប៉ុណ្ណេះ" គិតហើយក៏ញ៉ាំងសេចក្ដីអើពើ សេចក្ដីគោរពឲ្យកើតឡើង ហើយលាដៃស្ដាំបង្គុលប្រាប់ថា អ្នកទាំងឡាយទៅឯនោះនឹងបានទ្រព្យដែលគួរបាន ។ លុះកាលជាខាងក្រោយ ជាងជុលនោះធ្វើមរណកាលទៅ ក៏បានទៅកើតជាភុម្មទេវតា ស្ថិតនៅក្នុងដើមជ្រៃធំ ១ដើមក្នុងព្រៃ មានផ្លូវលំបាកដោយដីខ្សាច់ ដើមជ្រៃនោះមានម្លប់ជិតល្អ មានឫសច្រើនពាន់ មានទំហំ ៤ យោជន៍ ទាំងបណ្ដោយ-ទទឹង នឹងកំពស់ ។ ដៃស្ដាំរបស់ទេវតានោះអាចឲ្យសេចក្ដីប្រាថ្នាទាំងពួងបាន ។ ក្នុងកាលជាខាងក្រោយទៀត អង្កុររាជបុត្រនាំយកទំនិញដោយរទេះ៥០០ទៅ ដើម្បីជួញប្រែ លុះដល់ផ្លូវលំបាកនោះ ក៏វង្វេងផ្លូវ ដើរវិលវល់ក្នុងទីនោះច្រើនថ្ងៃ អស់ទាំងស្មៅគោ អស់ទាំងទឹកផឹក អស់ទាំងស្បៀងអាហារ ។ គ្រានោះភុម្មទេវតា រឭកឃើញឧបការដែលអង្កុររាជបុត្រ បានធ្វើដល់ខ្លួនអំពីបុព្វជាតិ ហើយក៏បង្គុលប្រាប់

ដើមជ្រៃរបស់ខ្លួនដល់អង្កុររាជបុត្រនោះ ។ អង្កុររាជបុត្រនោះបានឃើញដើមជ្រៃនោះហើយ ក៏មានចិត្តត្រេកអររីករាយ ទៅនៅក្រោមដើមជ្រៃនោះ ។ ទេវតាក៏លាដៃស្តាំឡើង បង្ហូរទឹកឲ្យជនទាំងអស់គ្នាផឹកឆ្អែតស្កប់ស្កល់ជាដំបូង ។ តាំងអំពីកាលនោះមក ជនឯណាៗចង់បានវត្ថុឯណាៗ ទេវតាក៏ឲ្យវត្ថុនោះៗដល់ជននោះៗ ។ អង្កុររាជបុត្រឃើញហេតុនោះហើយក៏សួរទេវតា ពោលគាថាក្នុងអង្កុរបេតវត្ថុថា ៈ

បាណិ តេ សព្វសោវណ្ណោ បញ្ចធារោ មធុស្សវោ
កេន តេ ព្រហ្មចរិយេន បុញ្ញំ បាណិម្ហិ ឥជ្ឈតិ ។

ដៃរបស់អ្នកឯង សុទ្ធសឹងមាស មានទ្វារជាទីហូរនៃវត្ថុគួរជាទីប្រាថ្នា អំពីម្រាមទាំង ៥ ជាទីហូរចេញនៃវត្ថុមានរសផ្អែមឆ្ងាញ់ពីសា ផលបុណ្យសំរេចក្នុងដៃរបស់អ្នកឯង ដោយព្រហ្មចរិយដូចម្តេច ។ លំដាប់នោះ ទេវតាប្រាប់សេចក្តីដល់អង្កុររាជបុត្រថា ក្នុងបុរិមជាតិខ្ញុំជាជាងជុលនៅក្នុងភេរុវនគរសំរេចទីនៅជិតផ្ទះអសយ្ហមហាសេដ្ឋី ខ្ញុំមិនមានទ្រព្យបន្តិចបន្តួច ដែលគួរឲ្យឡើយ ពួកស្មូមមិនដឹងផ្លូវទៅកាន់រោងទាន

របស់អសយ្ហមហាសេដ្ឋី ក៏នាំគ្នាមកសួរខ្ញុំ ៗ ក៏បានប្រាប់ផ្លូវដល់ពួកស្មូមទាំងនោះ ផលនេះសំរេចដោយបុញ្ញកម្មនោះឯង ហើយក៏ពោលគាថាថា ៈ

តេន បាណិ កាមទទោ តេន បាណិ មធុស្សវោ
តេន មេ ព្រហ្មចរិយេន បុញ្ញំ បាណិម្ហិ ឥជ្ឈតិ ។

ដៃរបស់ខ្ញុំអាចឲ្យនូវសេចក្ដីប្រាថ្នាទាំងពួងបាន ដោយការចង្អុលប្រាប់ផ្លូវនោះ ដៃរបស់ខ្ញុំជាទីហូរចេញនៃវត្ថុមានរសផ្អែមឆ្ងាញ់ពីសា ដោយការចង្អុលប្រាប់ផ្លូវនោះ ផលបុណ្យសំរេចក្នុងដៃរបស់ខ្ញុំ ដោយព្រហ្មចរិយនោះ ។ ត្រង់ពាក្យថា ដោយព្រហ្មចរិយនោះ អ្នកប្រាជ្ញគប្បីដឹង ដោយសេចក្ដីខ្វល់ខ្វាយរបស់ទេវតា កាលនៅជាជាងដុល មានសេចក្ដីខ្វល់ខ្វាយជួយប្រាប់ផ្លូវទៅកាន់រោងទានដល់ពួកស្មូម ដូចបានពោលមកហើយ ។ វេយ្យាវច្ច សេចក្ដីខ្វល់ខ្វាយដូចបានសំដែងមកនេះ ចាត់ជាព្រហ្មចរិយទី ២ ហៅថា វេយ្យាវច្ចព្រហ្មចរិយ ។

# ឆាតុរង្គបទ បទទី ១

# របស់ព្រះមហាពិទូរ ក្រសេម គន្ធរបទបណ្ឌិត

(ត)

*ជីវិតជាសម្បត្តិក្នុងខ្លួនដ៏សំខាន់*

ដូចពោលហើយថា មនុស្សយើងនេះនឹងរស់នៅបាន ព្រោះជីវិត ប៉ុណ្ណេះក៏ល្មមឃើញបានហើយថា ជីវិតជាសម្បត្តិក្នុងខ្លួនដ៏សំខាន់ យ៉ាងណា កាលជីវិតរស់នៅ នឹងត្រូវការធ្វើខ្លួនយើងឲ្យមានបំណេះវិជ្ជា ឲ្យមានគុណធម៌សេចក្ដីល្អឆ្លាសក្នុងវិធីប្រើអាហារ យល់ក្នុងវិធីគិតអានឲ្យវិសេសឡើងទៅ ឬនឹងឲ្យជាអ្នកសម្បូណ៌ដោយទ្រព្យដោយយសស័ក្ដិ ។ល។ សោត ក៏មានអំណាចនឹងធ្វើបាន ទាំងមានអំណាចនឹងទំនុកបម្រុងខ្លួនឲ្យបានសុខ ប្រាសចាកទុក្ខទាំងពួងក្នុងលោកនេះ ពោលយ៉ាងសម្បត្តិខាងក្រៅទាំងជាចលនវត្ថុ ទាំងជាអចលនវត្ថុ ជារបស់កណ្ដាលនៅសម្រាប់ក្នុងលោក បើត្រូវកាន់យកជាកម្មសិទ្ធិរបស់ខ្លួន ដោយត្រឹមត្រូវតាមគន្លងធម៌នឹងកាន់កាប់តាមច្បាប់ ឬនឹងគិតចាត់ធ្វើឡើងប្រើក៏បាន គ្មានអ្នកណាហាមប្រាម រួមសេចក្ដីថា សម្បត្តិខាងក្រៅដែលជារបស់មាននៅក្នុងលោកដែលមនុស្សធ្វើឡើង រហូតដល់ទៅសម្បត្តិ

ខាងក្នុង គឺសេចក្ដីល្អផ្សេង ៗ ទាំងអស់ កើតមានឡើងព្រោះជីវិតសម្បត្តិ តែអ្នកខ្លះមិនបានដឹងថា ខ្លួនមានជីវិតជាសម្បត្តិនៅក្នុងកណ្ដាប់ដៃ បើចេះប្រើឲ្យត្រូវរបៀបឲ្យជាប្រយោជន៍មែនទែនហើយ អាចនឹងមានអំណាចភ្ជាប់សម្បត្តិខាងក្រៅនិងខាងក្នុង មកជាសម្បត្តិរបស់ខ្លួនបាន គេច្រើនតែលះបង់ចោល ទើបតោងឱនចិយជាងសាធុជនទាំងឡាយដែលបានធ្វើដូច្នោះ ព្រោះហេតុនេះ ជីវិតសម្បត្តិទើបប្រៀបដូចដើមទុនដែលជាគ្រឿងសម្រាប់ប្រកបកិច្ចឲ្យកើតផលបំណេញ សមគួរណាស់តែនឹងដឹងថា ជីវិតរបស់មនុស្សយើងនេះជាសម្បត្តិក្នុងខ្លួនដ៏សំខាន់តែម្ដង បណ្ដាអ្នកមានជីវិតរស់នៅហើយគួរជាសាទរឲ្យសមតាមភូមិរបស់ខ្លួនដោយពិត ។

*ជីវិតជារបស់មានដំឡៃ*

ព្រោះហេតុអ្វី មនុស្សទើបតោងស្រឡាញ់ជីវិតរបស់ខ្លួនគ្រប់រូប ក្រៅអំពីសេចក្ដីដែលពោលមកហើយក៏គួរជាឃើញថាព្រោះជីវិតរបស់មនុស្សនេះរកបានដោយក្រ បណ្ដារបស់ផ្សេង ៗ

ដែលមាននៅក្នុងលោកនេះដែលនិយមថាជារបស់មានដំឡៃ ក៏នូវមិនស្មើនឹងដំឡៃរបស់ជីវិតនេះនូវឡើយ ព្រោះរបស់ដំឡៃទាំងនោះកាលសាបសូន្យទៅហើយ បើមានជីវិតរស់នៅទាំងមានទ្រព្យផងអាចនឹងរកថ្មីជំនួសក៏បាន ព្រោះហេតុនេះជីវិតរបស់មនុស្សទើបជារបស់មានដំឡៃជាងដំឡៃនៃវត្ថុផ្សេង ៗ ក្នុងលោកនេះ លគិតមើល ឧបមាថា យើងស្លាប់ហើយ ទទួលមានអ្នកវិសេសជប្បឲ្យត្រឡប់រស់មកវិញ ហើយទារយកបំណាប់អំពីយើងយ៉ាងច្រើនជាបំផុត បើយើងគ្មានទ្រព្យរបស់នឹងឲ្យគេ ក៏គង់ជានឹងយកខ្លួនទៅនៅបំរើអ្នកនោះ ជាការតបគុណគេ កុំថាឡើយដល់ទៅស្លាប់ សូម្បីតែអវយវៈឯណានីមួយពិការ ដូចភ្នែកខ្វាក់ ត្រចៀកថ្លង់ ។ ល ។ បើជាមានគ្រូពេទ្យវិសេសអាចរក្សាឲ្យត្រឡប់សះជាដូចដើមវិញ ហើយទាមទារយកបំណាប់តាមត្រូវការ ជឿថា អ្នកសាមីខ្លួនគង់ជាសុខចិត្តឲ្យដោយស្រួល ទាំងអំណរគុណគេជាយ៉ាងច្រើនទៀតផង ឧទាហរណ៍ប៉ុណ្ណោះ ក៏ល្មមឃើញបានហើយថា ជីវិត

ជារបស់មានដំឡៃយ៉ាងណា បើបេះប្រើឲ្យជាប្រយោជន៍ពិតប្រាកដហើយ ក៏នឹងទ្វេដំឡៃផុតវិស័យនឹងគ្រាប់ប្រាប់បាន ។

### ត្រូវបេះប្រើជីវិតឲ្យជាប្រយោជន៍

ជីវិតរបស់មនុស្សនេះដែលនឹងមានដំឡៃខ្ពស់បំផុត លុះតែបេះប្រើឲ្យជាប្រយោជន៍មែនៗផង បើមិនបេះប្រើ ទោះបីជីវិតជារបស់មានដំឡៃមកអំពីដើម (វៀរតែជីវិតរបស់ជនពាល) ក៏គោងឥតថ្លៃមួយរំពេច ខនេះសូមឲ្យមើលតួយ៉ាង អ្នកដែលមានទ្រព្យដើមទុននៅស្រាប់ហើយ បើមិនបេះប្រើ មិនយល់ក្នុងវិធីជំនួញ ហើយធ្វើការបេញថ្លួញ ក៏នឹងខាតបង់ទាំងទុនទាំងកំរៃ ឬដល់នូវរលំរលាយទៅតែម្ដងក៏មាន ហេតុនេះទើបគោងបេះប្រើជីវិតឲ្យជាប្រយោជន៍ មានដើមថា ទំនុកបំរុងរាងកាយឲ្យមានកំលាំងរឹងប៉ឹង ប្រាសចាករោគាពាធ មានកល្យាណមិត្រទុកជាគូជីវិត មានអាហារជាគ្រឿងសប្បាយប្រាសចាកទោស មានស្ថានទីនៅជាទីសប្បាយ ត្រូវតាមអនាម័យនឹងសុខវិទ្យា មានធម៌ជាគោលជំរះនឹងទំនុកបម្រុង

ចិត្តឲ្យថ្លាស្រឡះជាសុខសប្បាយ ។ នូវមានធម្មតាប្រចាំនៅក្នុងលោក ១ពួកទៀត ដែលហៅលោកធម៌ ៨ គឺ មានលាភនឹងឥតលាភ ១គូ មានយសនឹងឥតយស ១គូ និន្ទានឹងសរសើរ ១គូ សុខនឹងទុក្ខ ១គូ ឲ្យកើតត្រេកអរនឹងស្អប់តាមពេលដែលមកប្រសពត្រឡប់ទៅត្រឡប់មកជាធម្មតា លោកធម៌នោះលោកប្រៀបដូចខ្យល់ព្យុះ សេចក្ដីត្រេកអរនឹងស្អប់ ប្រៀបដូចរលកក្នុងមហាសមុទ្រ ជីវិតប្រៀបដូចភេត្រា ។ លោកធម៌នេះជាគូជីវិត ដល់វេលាបានលាភ យស សរសើរ សុខក៏នាំឲ្យត្រេកអរ បួលមកធ្វើចិត្តឲ្យប៉ោងឡើងនឹងទ្រោមបុះទំនងដូចជាភេត្រាដែលនៅក្នុងកណ្ដាលសមុទ្រ សឹងត្រូវខ្យល់ព្យុះ នឹងរលកបោកបក់ឲ្យខ្ទាស់ៗទាបៗ ហេតុនោះ កាលប្រាថ្នានឹងឲ្យជីវិតនៅជាសុខសប្បាយ ទើបគួរប្រើសតិសម្បជញ្ញៈឲ្យបួលជួយឧបត្ថម្ភ ទោះបីត្រូវលោកធម៌មករំអុកក្ដី ក៏នឹងបានរំភាត់ទាត់ឲ្យឆ្ងាយទៅ សមតាមបុរាណភាសិតថា "កុំរេតាមខ្យល់កុំរំលំតាមរលក" ដូច្នេះ ។

មនុស្សយើងនេះ ដែលនឹងមានសេចក្តីបំព្រែកប្លែកអស្ចារ្យ ក៏តែក្នុងវេលាមានជីវិតរស់នៅ ជីវិតទើបជាសម្បត្តិដ៏សំខាន់ របស់មនុស្ស ជាទីប្រមូលមកនៃសម្បត្តិខាងក្នុងខាងក្រៅ ព្រោះ អំណាចសម្បត្តិដែលប្រមូលមកនុះឯង ជីវិតទើបជារបស់មានដំឡៃ តែបើមិនបេះប្រើ អាចនឹងបានទទួលទោសទុក្ខច្រើនជាង ។ ហេតុនោះ ទើបត្រូវបេះប្រើឲ្យជាប្រយោជន៍ដោយប្រពៃ ក៏នឹង មិនបង់ជីវិតដែលកើតមកជាមនុស្ស មានអរិយវៈសមប្រកបគ្រប់ ភាគ ជីវិតក៏មិនជារបស់ឥតផល ស្ងួប្បីរស់នៅបានតែមួយថ្ងៃ ក៏នៅគ្រាន់បើជាងដែលលះលែងបង់ កាលជីវិតបែកទំលាយ ទៅតាមធម្មតារបស់សង្ខារ បំណែកឯកេរ្តិ៍ឈ្មោះនឹងសេចក្តីល្អ ដែលធ្វើទុក នឹងបានសាបសូន្យទៅក៏ទេ រមែងឋិតបើរគង់ នៅរហូតកល្បាវសានៈ ។

លោកគជ័យ

របស់ទកញ្ញ៉ាវង្សសរពេជ្រ នង

(ត)

នោះនឹងបង្កើតសុខ លះលែងទុក្ខសុខក្សេមក្សាន្ត រីឯលាភបើបាន មានអំណរពន់ពេកក្រៃ ។ អភ័យបណ្ឌិតថា បពិត្រមហាក្សត្រថ្លាថ្លៃ ល្បែងលេងជណ្ដើមជ័យ នោះសោតសប្បាយបានសុខ ។ ឈ្នះហើយសឹងត្រេកអរ ចិត្តសាទរលះលែងទុក្ខ បពិត្រស្រីស្រណុក ចិត្តគឺល្បែងនេះឯងណា ។ ស្ដេចស្ដាប់ពាក្យនេះហើយ ពុំលង់ឡើយជណ្ដឹងថា អភ័យបណ្ឌិតថា ម្ដេចព្រះស្ដែងថ្លែងឈ្មោះនែ ។ អភ័យបណ្ឌិតទូលក្សត្រឥស្សរលើភពត្រៃ មើលគេជណ្ដើមជ័យ បានលំពែងប្រុំបាក់គ្នា ។ ខ្លះកាន់ដាវប្រកាប់ ខ្លះចំបាប់ចូលពានពារយុទ្ធយកជ័យបេស្ដា ខ្លះសោតភិរដល់ជីវី ។ អ្នកខ្លះប្រជល់គោសត្វឆោឡោឡូងភិរី ជល់មាន់ពពៃក្ដី ជណ្ដើមជ័យបង្កើតសុខ ។ ឥន្ទ្រារម្មណ៍ក្រាបទូល ក្សត្រឥស្សរវិផ្សះទុក្ខ ឲ្យសប្បាយស្រណុក នោះមានតែល្បែងនេះណា ។ គឺបៀស្កាបត្រង្គ បាះហើយបង់ៗទ្រព្យា បង់ហើយបានវិញណា នោះជាសុខពន់ពេកក្រៃ ។ សុន្ទរាល័យថា បពិត្រមហាក្សត្រជេស្ឋជ័យ កំណើតសុខនោះនែ គឺពីល្បែង ៥ នោះណា ។

១ យល់រូបត្រីធំ ពេញក្រម៉ុំសមកាយា ១ ឮសំឡេងថា
ស្រដីហើយកើតអាល័យ ។ ១ បានឱបថើបហើយ ចិត្តពុំ
ស្បើយគិតមមៃ រំងឹកភ្លឹកអាល័យ ១ គឺបានរួមស្នេហា ។
១ គឺផ្សព្វប្រួបប្រួល ចិត្តមិត្រមូលមួយវាស្នា សោតសឹងបង្កើត
ជា សុខលើសលន់ពន់ពេកក្រៃ ។ កាលនោះមហាក្សត្រា
បន្ទូលថាហៃធនញ្ជ័យ ពាក្យអ្នកទាំងនេះនៃ ថាដូច្នេះតើត្រូវ
ហើយ ។ ពោធិសត្វទូលថា បពិត្រមហា ក្សត្រិត្រាណត្រើយ
សុន្ទរាល័យឆ្លើយ ថាបញ្ចកាមគុណនោះ ។ គាត់ឆ្លើយដោយ
ដំណឹង ហេតុគាត់ដឹងដោយចិត្តស្មោះ ជាកូនឯកទងនោះ
គាត់សរសើរឯរូបស្រី ។ ឯឥដ្ឋារម្មណ គាត់គិតគន់ទើប
ស្រដី សរសើរលោកអំពី បង់ហើយបានមកវិញណា ។ ថា
កូនអ្នកសសន់ ចិត្តលោភលន់ស្នេហ៍ទ្រព្យា អភ័យបណ្ឌិតថា
សរសើរឯឈ្មោះបាញ់នោះ ។ ដោយដំណើរគាត់ឯង កូនអ្នក
លេងមែនបំពោះ បង្ហាញគ្មានស្មានស្មោះ ពុំលាក់ឡើយក្សត្រ
ឧត្តម ។ រីកាមគុណបើ សេពលោកប្រើឲ្យសេពសម ឯណា
មិនគួរកុំ សេពលោកពុំឲ្យសេពឡើយ ។ បពិត្រក្សត្រធិបតី

បើពុំពិចារណាឡើយ សេពកើតទុក្ខឥតស្បើយ ជាទំងន់ពន់ប្រមាណ ។ ១ សោតរិត្រង់ទ្រព្យ ឯណាគាប់គួរបើបានលោកឲ្យយកកុំមាន មន្ទិលបិត្តបារម្ភឡើយ ។ ទ្រព្យណាពុំគួរបាន កុំឲ្យហ៊ានយកទាំងខំ ហើយនឹងកើតទុក្ខធំ លោកពុំឲ្យយកឡើយនៃ ។ ក្ដីមួយគប្បីឈ្នះ ដោយតេជៈបុណ្យតេជដៃ លោកឲ្យឈ្នះហើយនៃ បើពុំគួរឈ្នះឡើយណា ។ កុំឲ្យគិតបង់ឈ្នះ ក្រែងនឹងប្រាសប្រែរិលជា បង់ទ្រព្យស្លាប់អាត្មាលោកពុំឲ្យឈ្នះឡើយនៃ ។ អស់ទាំងអំបាលនេះ ថាបើបេះអធ្យាស្រ័យ ពិចារណាហើយនៃ បើបេះសេពបង្កើតសុខ ។ បើពុំបេះសេពហើយ ពុំលង់ឡើយនឹងកើតទុក្ខ ពុំដែលនៅបានសុខ ហេតុពុំបេះពិចារណា ។ ស្ដេចស្ដេចស្ដាប់ពាក្យហើយ ពុំលង់ឡើយត្រាស់ថាបា ធនញ្ជ័យបណ្ឌិតថា នាបញ្ចកាមគុណនោះ ។ ឯណាគួរសមសេព កុំសង្កៀបបាប្រាប់ស្មោះ ឯណាអសារសោះ ប្ដូរចៅបែងថ្លែងបរបា ។ ឯពង្សពោធិសត្វ បុរសរ័តន៍ក្រាបទូលថា រីគុណទាំងប្រាំប្រ-ការ ១ គឺរូបារម្មណ៍ ។ ប្រើយករូបព្រះពុទ្ធ ព្រះសង្ឃសុទ្ធិសីល

ឧត្តម ទុកជាទីអារម្មណ៍ កើតសុខភ្នែកសុខក្នុងចិត្ត ។ ឲ្យដល់លោកនេះទៅ បរលោកសល់បានត្រិពិធ សម្បត្តិសុខ ស្នេហ៍ស្និទ្ធ រៀងរូបរាល់ដល់និព្វាន ។ នេះគួរគប្បីមើល ជាប្រសើរសុខក្សេមក្សាន្ត រីអ្នកខ្លៅផងបាន យល់រូបស្រីផងទាំងឡាយ ។ មើលកើតក្តីស្រឡាញ់ យង់យល់ពេញចិត្តរីករាយ អាលោះអាល័យស្តាយ ខ្លួនបង់រូមប្រដិព័ទ្ធ ។ បើបង់ពុំបានឡើយ បប់ពុំស្បើយទុក្ខពេកក្តាត់ កង្វល់អំពល់ចិត្ត ដ្បិតពុំបានរួមមេត្រី ។ ទោះបីប្រាថ្នាបាន ហើយសឹងមានទុក្ខទៀតឬ រក្សាព្យាបាលពិ- ភ័ក្តិក្រែងអ្នកដទៃបង់ ។ បរលោកសឹងពុំគាប់ ខុសនឹងច្បាប់ដ្បិតបោះបង់ ធម៌ហើយតាមបំណង់ នឹងធ្លាក់ទៅនរកនាយ ។ មួយសោតរីសទ្ទា-រម្មណាអ្នកប្រាជ្ញប្រាយ លោកប្រើស្តាប់និយាយ គឺរសធម៌លក្ខណា ។ ពុំនោះលោកឲ្យស្តាប់ គួរត្រងត្រាប់ធម៌ទេស្នា សុខចិត្តសុខកាំម៉ា ដល់បរលោកបាននិព្វាន ។ ក្តីមួយបើឮស័ព្ទ លោកឲ្យស្តាប់គាប់គួរហោន ចិត្តប្ញលមួលទៅឋ្កាន ស្តាប់ត្រាប់ត្រងរងរសធម៌ ។ មួយគឺឮសំដី សំឡេងស្រីហោរ

សាហា វាប្រៀងលេងខ្សៀវខ្សារ ហើយវាសើចពុំថ្លរកាល ។ ឮហើយកើតស្រឡាញ់ វែងជាពេញចិត្តស្នេហ៍ស្នាល វីអ្នកអន្ធពាល ប្រាថ្នាបង់ពុំបានឡើយ ។ វែងកើតទុក្ខទោះធ្ងន់ធ្ងន់ពេកពន់ពុំត្រាស្បើយ បើបង់បានមកហើយ វែងជាទុក្ខមួយសាក្រៃ ។ ព្រួយចិត្តគិតរក្សា ខ្លាចក្រែងគេអ្នកដទៃ ដណ្ដើមលួចយប់ថ្ងៃ ទើបលោកហាពុំគួរស្ដាប់ ។ វីគន្ធារម្មណា គន្ធឯណាពុំគួរគាប់ គឺសីលគួរត្រងត្រាប់ ប្រព្រឹត្តដោយយានប្រសាទ ។ បើបុគ្គលអសោច៌ គំរង់ខ្មោចពុំគួរស្អាត ប្រព្រឹត្តយានប្រសាទ ជាអសុភកម្មដ្ឋាន ។ វីយោគាវចរ មានអំណរសួមស្មាទាន សីលសោតសឹងបង់បាន ឋាននិព្វានពន់ទុក្ខា ។ ហេតុអ្វីមានបំណង ប្រព្រឹត្តបងដោយនោអា- សុភកម្មដ្ឋានា នោះហេតុយល់ក្ដីសង្ខារ ។ អនិច្ចំធម៌ពុំ- ទៀងអារម្មណ៍ពិចារណា នឹងសុខក្នុងយានទ្វារ សុខក្នុងចិត្តទាលោកិយ ។ លុះដល់បរលោកបាន ឋាននិព្វានសិរីទ្ធី ដូចចិត្តគិតគប្បី បើបលោកប្រើឲ្យបើបហោង ។ មួយនីវិក្ខិនស្រី ផុំអប្រិយបុរសផង បើបផុំក្លិនហើយស្រង ក្លិនដែលដឹងដូច្នោះណា ។ បង្កើត

ក្តីបំណង ប្រាថ្នាចង់ៗរូបា ពុំបានឡើយរឹងជា កើតទុក្ខធ្ងន់ ពន់ប្រមាណ ។ បើបានសឹងកើតទុក្ខ ពុំស្រណុកពុំក្សេមក្សាន្ត រក្សាខ្លាចក្រែងមាន អ្នកដទៃលួចយកទៅ ។ នេះពុំគប្បីស្រើប ចិត្តចង់បើបអាហារហៅ ក្តីនេះឲ្យហ្មងសៅលោកពុំឲ្យបើបឡើយណា ។ ឯរសារម្មណា អ្នកប្រាជ្ញគិតស្រាយថា សរសើរពិចារណា រសធម៌នោះប្រសើរក្រៃ ។ រៀនចាំទុកក្នុងចិត្ត គួរឲ្យស្អាតធម៌ប្រពៃ គប្បីបរិភោគក្រៃ នៃរសធម៌នេះឯងណា ។ មួយនារីរស្រី កាចអប្រិយពោរឫស្យា អ្នកផងបងស្នេហា បើពុំបានជាទុក្ខក្រៃ ។ បើបានមកហើយណា ព្រួយរក្សាទុកយប់ថ្ងៃ បើបាត់ទៅហើយនៃរឹងព្រួយចិត្តគិតក្តាត់ណា ។ ពុំគួរបើភោពឡើយ ហេតុដល់ត្រើយសួស្តីសោះសា ផោដ្ឋព្វារម្មណា ផ្សព្វឯណាបើប្រពៃ ។ ពុំកក្រើកលោកធម្ម ធម៌ទាំងប្រាំបីនោះនៃ ឲ្យផុត្រាក្តីសង្ស័យគាហៅលោកធម៌នោះ ។ ១ គឺបានពុំអរ ពុំសាទរស្ងៀមស្ងួតស្ងសោះ ១ បាត់ពុំស្តាយសោះ ពុំអាឡោះអាល័យឡើយ ។ ១ មានយសពុំឆ្មើង ពុំកន្ត្រើងអង្គជាត្រើយ ១ ប្តូរលែងយស

ហើយ ពុំគិតស្តាយគិតអាល័យ ។ ១ គេដេរដៀលក្តី គេស្រដីដើមយប់ថ្ងៃ ពុំដែលខឹងឡើយនៃ ១ គេសរសើរពុំអរ ។ ១ បានសុខសម្បត្តិ ពុំត្រេកចិត្តឥតសាទរ ១ មានទុក្ខដល់មរណ៍ ពុំដែលថ្កុំបថយព្រួយប្រាណ ។ មហារាជរីលោកធម៌ទៀងទាំងប្រាំបីបើបាន ផ្សព្វហើយដល់និព្វាន នេះគួរបើផ្សព្វពេកក្រៃ ។ រីផ្សព្វសម្បូរស្រី នោះអប្រិយពុំប្រពៃ សេពមេថុនធម្មនៃ ចិត្តរន្ធត់ពុំគិតស្បើយ ។ ហើយបង្កើតបំណង់ក្លួបចិត្តចង់ពុំបានឡើយ រឹងកើតទុក្ខពុំស្បើយ ព្វដរលោកនេះឯងណា ។ ទោះបានមកហើយប្រាស ព្រាត់និរាសបេញឃ្លាតឃ្លា ជាទុក្ខឈឺធៀបផ្សា ពេកព្រួយចិត្តគិតថៃថប់ ។ នេះហៅពុំគាប់បើ ផ្សព្វលោកប្រើពុំឲ្យផ្សព្វ ពុំគួរសេពសំភពនឹងអស់ទាំងនេះឡើយនៃ ។ នេះបទកាកា- គតិទើបព្រះមហាក្សត្រក្សាន្តជេស្ឋជ័យ ស្តេចបើកព្រះសួរ មន្ត្របាហៃ ម្តេចហៅធនញ្ជ័យ គប្បីបង់នោះ ។ ព្រះពោធិសត្វ មហាបុរសរ័ត្ន ក្រាបទូលរឹងដោះ រីទ្រព្យទាំងឡាយ ចាយវាយឲ្យស្មោះ ឲ្យទានបំពោះ ស្រមណ៍ព្រាហ្មណ៍ស្មមផង ។ ១ គាប់បើ

បាយ ថែកបិញ្ចឹមម្ដាយ អាពុករៀមច្បង ញាតិសាច់សន្ដាន
កល្យាណមិត្រផង នេះបង់គាប់បេកង តាមដោយធម៌ហ៎ា ។
មិនគប្បីបង់ គឺតាមបំណង់ លេងល្បៀហ្សា មួយបាននឹងធ្វើ
អំពើទោជា ចោរឆក់ទ្រព្យា លួចយកនោះនៃ ។ មួយបាន
នូវអំ- ណាចខូចចិត្តខំ ទ្រព្យអ្នកដទៃ នូវកោលាការ អសារ
ពោកក្រៃ ទ្រព្យនោះឯងនៃ ពុំចម្រើនឡើយ ។ នាលោក
នេះណា បើបានទ្រព្យា នេះបួលមកហើយ នឹងកើតជាទុក្ខ
អធ្យុកជាត្រើយ ដល់បរលោកហើយ សឹងសោយទុក្ខា ។
នៅភូមិអវិចី ពុំស្ដោះពីភ័យ ពីចតុរា- បាយបទវិវង្ង ពុំ
ក្រែងអាត្មា ហេតុនោះលោកហ៎ា ពុំគួរបានឡើយ ។ មួយ
គួរបើបាន បាននឹងផលទាន បានសាងមកហើយ មកកើត
ជាទ្រព្យ សម្រាប់ជាត្រើយ ផលនោះឯងហើយ តែងតាម
អាត្មា ។ បានមកជាតិនេះ បើអ្នកណាបេះ ឲ្យទាន
ទៀតណា បានទៅភ្នកាយ [illegible] សម្បត្តិ
ថ្លៃថ្លា នេះគួរបើបាន ។ [illegible] ជួបម្ដេច
មិញបា គួរផ្លាញ់នោះដាន ប្រការខ្ទបខ្ទប លេបត្រៃបាភ្លាន

ឆ្លើយមកឲ្យបាន ដឹងដើមសេចក្តី ។ ព្រះពោធិសត្វ ក្រាប
ទូលវឹងថ្វាត់ ថាគួរគប្បី ផ្ចាញ់វេរាកម្ម នាំអំពី បូរាណ
មួយនី សង្កត់បោះបង់ ។ សម្លាប់ចិត្តបាប ចិត្តពុំសូភាព
ពុំធ្វើដោយត្រង់ នោះគប្បីផ្ចាញ់ បោលបេញព្រះអង្គ កុំឲ្យ
មានស- ង្ស័យក្នុងហឫទ័យ ។ ឧដុកសេនា- បតីឮថា
ដូច្នោះហើយនៃ ទៀងទើបឆ្លើយទៅ ថាចៅធនញ្ជ័យ ផ្ចាញ់
សង្កត់នៃ ចោរនោះគាប់ហោង ។ ដ្បិតវាពុំខ្លាច ចិត្តចោរ
ទ្រើសកាច ពេកពន់កន្លង នោះគួរបើកាប់ សម្លាប់ត្រូវហោង
ដ្បិតវាច្រើនឃ្នង ក្រៃក្រៅវិស័យ ។ អ្នកស្តាប់ពាក្យពី
សេនាបតី ថាដូច្នោះនៃ អ្នកបើកមាត់សើច សំណើចខ្លាំង
ក្រៃ ស្រដីថាហៃ សេនាបតី ។ នេះស្រដីចេះ ដ្បិតមាន
បំណោះ បង្គាប់សេចក្តី ចោរហើយខ្លាចវា ពាធាស្រដី ថា
គាប់គួរបី សង្កត់ចោរនោះ ។ សេនាបតី យល់ព្រះពោធិ-
សត្វសើចដូច្នោះ ខេរខឹងពេកពន់ លើសលន់កាលនោះ មាន
ពាក្យអសុរស ស្រដីទៅថា ។ ធនញ្ជ័យចេះបែង ម្តេចក៏ព្រះ
ស្តែង ថាផ្ចាញ់វេរា ដោយនូវពលំ កំលាំងអាត្មា តើព្រះ

ស្តេចថា ជុំឈ្មោះត្រីអ៊ី ។ ពោធិសត្វសើច រឹងមានសំណើច ក្រៃលែងអំពី មុនទើបអ្នកថា សេនាបតី ពុំស្គាល់ពៀរវេ- រា ឈ្មោះអ្នកស្លាប់ ។ អញនឹងសំដែង និទានបារំបង អស់អាថ៌ ប្រាយប្រាប់ វេរាទាំងប្អូន ចូរចាំត្រង់ត្រាប់ វង់សេចមិគាប់ ជា ប្រាប់ទូន្មាន ។ មួយភ័យអំពី អមនុស្សមួយគឺ ភ័យពីតិរច្ឆាន មួយភ័យពីស្តេច នឹងដាច់បង់ប្រាណ មួយនោះសោតមាន ភ័យពីមនុស្ស ។ មួយភ័យពីខ្លួន ឯងអាចប្អូនប្អូន ជាទុក្ខ អាត្មា កបំម្តេចនៃ ហៅភ័យនោះណា តិរច្ឆានសត្វសា- មាន្យកាចអប្រិយ ។ គឺរមាសខ្លា ចចកស្វានស្វា ឆ្កែព្រៃដំរី គោឧសុភរាជ នូវរាជសីហ៍ ក្អែបខ្ទួយផងក្តី សាមាន្យ ឬស្សា ។ វាបៀតបៀនប្រាណ មរណាចាកឋាន ដោយកម្ម វេរា សឹងកើតពីចិត្ត គំនិតឲ្យជា វេរានឹងគ្នា អស់កាលដ៏ លុង ។ មួយគឺភយា ពីអមនុស្ស ខ្មោចប្រេតយក្ខយង់ បិសាចអារក្ស ទេព្រក្សាបង់ បៀតបៀនក្នុងអង្គ ឲ្យអន្តរាយ ក្សយ ។ មួយភ័យអំពី ស្តេចគឺកើតក្តី ស្តេចកោះស្តេចព្ន័យ ទុកនៅចំណង គេបង្ខាប់ក្រៃ ដំឡោះយសនៃ ខ្លួនបោះបង់

ស្រុក ។ មួយឲ្យសម្លាប់ រឹបយកអស់ទ្រព្យ សឹងកើតជាទុក្ខ
មួយភ័យខ្លួនឯង ពីព្រេងពុំសុខ ឈឺក្បាលវិលមុខ ឈឺមាត់
ឈឺផ្ទៃ ។ កើតឃ្លង់កើតស្រែង កើតឆ្កួតវង្វេង ឈឺសព្វសរសៃ
ឈឺត្រចៀកភ្នែក បង្វែកជើងដៃ ទល់ទុក្ខសព្វថ្ងៃ អស់អង្គ
រូបា ។ ផលាជាគំ- រប់ប្រាណនេះពុំ សុខរងវេទនា ដូចនៅនរក
ទល់ទុក្ខឈឺផ្សា ខំគិតឧបមា ដូចនរកហោង ។ ហេតុនោះ
អញថា សព្វសត្វនេះណា គំនិតធ្វើឆ្គង ដ្បិតគិតពុំធ្លួន បៀន
ខ្លួនឲ្យម៉ង ផៀរផោរង កម្មកាយវេទនា ។ វាសង្កត់បាត់
ហេតុចិត្តពុំស្ងាត់ ប្រដូចទាសា ខំជើងកន្ទេល ពុំដែលនឹងថា
ប្រក្ខតបរហា ប្រកែកប្រណាំង ។ មួយសោតចិត្តចោរ ទាំង
ប្រាំវែងយោរ គឺកាមឆន្ទ គឺពៀរព្យាបាទ ថីនមិទ្ធ ឧទ្ធច្ចកុក្កុច្ច
វិចិកិច្ឆា ។ ហេតុអ្វីលោកយក ចិត្តប្រាំនេះមក ថាចោរហេតុវា
តែងរំលោងផ្លូស អ្នកបួសនោះណា បាំងផ្លូវសួគ៌ា ឲ្យឆ្ងាយ
ពេកក្លាត់ ។ នេះនៅឧបមា ដូចអ្នកពាលា កាន់គ្រឿងអាវុធ
ទាំងប្រាំប្រការ ស្រើបស្រាលគំនិត ប្រយោជន៍លំអិត សត្រូវ
ទាំងឡាយ ។ រីឯកល្យាណ បុរសអ្នកមាន យោបល់ប្រាជ្ញ

ប្រាយ រំពឹងមេត្តា ភាវនាស្វាធ្យាយ សង្រួមអង្គកាយ កសិណ
បរិកម្ម ។ ប្រយោជន៍រំងាប់ រំលោងសំឡាប់ ចិត្តហោរទាំងប្រា
ភតែងយាយី ជានិវរណធម៌ បំបាត់បាបកម្ម ឧបមាឈ្មោះ
ហោង ។ បពិត្រមហារាជ ទ្រើសទ្រង់អំណាច លើសលែង
កន្លង បើចង់សម្លាប់ រំងាប់ចិត្តផង ភាវនាទើបបង ចិត្ត
ហោរនោះណា ។ តេនវុត្តំ សត្ថាធម្មំ បកាសេត្វា ព្រះពុទ្ធជា
ម្ចាស់ បានត្រាស់ប្រាជ្ញា សារពេជ្រទេស្នា ទុន្នានសព្វសត្វ ។
លោកឋាឲ្យយក សមាធិមក រំងាប់កំបាត់ ចិត្តកាមឆន្ទ
កំណាន់ឲ្យបាត់ បោះបង់បានកាត់ ចិត្តហោរនោះណា ។
មួយសោតឲ្យយក បញ្ចប៉ីតិមក បំរើនមេត្តា រំពឹងរំងាប់
សំឡាប់ចិត្តព្យា- បាទបោះបង់ភា ឲ្យបានក្ដីគាប់ ។ វីរិយមិទ្ធ
ឲ្យយកកំឡាំង វិតក្កសំឡាប់ មួយមិញឲ្យយក សុខមក
រម្ងាប់ ភាវនាសំឡាប់ ឧទ្ធច្ចកុក្កុច្ចំ ។ វិចិកិច្ឆា យក
ពិចារណា ឲ្យជាកម្លាំង នោះមករម្ងាប់ សំឡាប់អស់ទាំង
ចិត្តហោរភាំង នូវកើតសុខក្លាត់ ។ បានដល់និព្វាន បរិ-
បូណ៌ក្សេមក្សាន្ត ទៀងប្រាកដក្ដាត់ ហេតុនោះគួរបើ ផ្ចាញ់

ធ្វើឲ្យបាត់ បោះបង់ស្មៀមស្ងាត់ បោលបេញឃ្លាតឃ្លា ។ តាបីគាប់បើ គួរឲ្យផ្គាញ់ប្រើ ផ្គាញ់បៀបាស្កា ផ្គាញ់សឹក រឿងរង់ បត្រង្គផ្គាញ់ស្រា ផ្គាញ់មាតុគ្រាមា អំបាលនោះ នៃ ។ ទរណាមួយបើ បបេសបង់ធ្វើ ហើយនឹងកើតភ័យ នៅកើតទោសា ដូបគាថាថ្លៃ ប្រាកដពេកក្រៃ ទើបអ្នកសូត្រ ថា ។ ឥតិសេវ កំសេវិយ យញ្ញនរា អសាធូនំ ភយវីតា សេតិអាបា យេគបួន្តិ ។ បទបន្ថែថា នរអ្នកណា សេព ស្រាទូរស្រី បៀស្កាបត្រង្គ ការសង្គ្រាមជ័យ ភ្លាំងភ្លាត់ស្មារតី មួមិនលែងឡើយ ។ នឹងធុកបង់ប្រាណ បង់ទ្រព្យធនធាន អសារឥតត្រើយ ធ្លាក់ទៅនរក ទល់ទុក្ខពុំស្បើយ គួរបៀស ឲ្យហើយ កុំសេពឡើយណា ។ ព្រះពោធិសត្វ មហាបុរស រតន៍ ពង្សពុទ្ធសាស្ដា សំដែងស្រេបហើយ ទើបឆ្លើយទៅថា បំអកសេនា- បតីថាម្ដេប ។ ពាក្យអញសំដែង មែនដូបអ្នក ឯង អ្នកដឹងសេបគ្រេប តើរេរាបោរ បិត្តស្រើបស្រួលស្រេប ឬមានដូបម្ដេប ទីទៃទៀតផង ។ សេនាបតី ខេវខឹងឥត បី មានពាក្យសាសង អង្គុយមមឹង ស្មៀមឈឹងទៅហោង

កាលនោះស្ដេចសង់ សាស្សរពោធិ ។ ថាធនញ្ជ័យបា ពាក្យ
ប្រស្ដែងថា ស្វែងមង្គលរី អ្វីជាមង្គល សួរសល់វិញ្ញី ប្តូរបា
ស្រដី ប្រាប់អញសោះធ្វល់ ។ ព្រះពោធិសត្វ ក្រាបទូលវឹង
ថ្វាត់ ថារីមង្គល មានតែតបៈ ធម៌ព្រះយង់យល់ សឹងហៅ
មង្គល ក្រៃលែងនានា ។ បុរោហិតស្ដាប់ អស់អាថ៌សាស័ព្ទ
ទៀងទើបឆ្លើយថា ដ្បិតមានមង្គល យង់យល់ជាក់ថា មែន
ពិតក្តាត់ណា ប្ដូរបៅស្រដី ។ ពោធិសត្វស្ដាប់ បុរោហិត
គាប់ ហាក់ដឹងសេចក្ដី ស្មានជាថាត្រូវ ឈ្មោះកូរពោធិ ស៊ើប
ហើយស្រដី តិះដៀលទៅថា ។ ឱបុរោហិត ឆ្លើយដោយ
គំនិត បំណោះប្រាជ្ញា ហេតុតែជាព្រាហ្មណ៍ ឆ្លើយតាមតែ
ថា ដ្បិតខ្លួនរក្សា សំលតបៈនោះ ។ បុរោហិតឲ្យ អ្នក
លេញលេងឬ ក្នុងប្លើមពង់ពោះ ពុំស្រណុកឡើយ ឆ្លាស់
ឆ្លើយរឹងស្មោះ ស្រដីដោយដោះ ថ្កានព្រះពោធិ ។ ហៃបៅ
ធនញ្ជ័យ ពៅបានរៀនត្រៃ ភេទក្នុងគម្ពីរ វេទាគមសាស្ត្រ
បៅឆ្លាសស្រដី តែងដឹងត្បូះពី គម្ពីរនោះណា ។ ព្រះ
ពោធិសត្វ ឆ្លាស់ឆ្លើយរឹងថ្វាត់ ទៅថ្កានព្រាហ្មណ៍ថា ឈ្មោះអ្នក

ចាយបែង សំដែងវិត្ថារ ឲ្យបានដឹងប្រា- កដកាលឥឡូវ ។ រីបុរោហិត ស្មានជាពិតៗ ថាថ្លៃងដោយនូវ ក្បួនធ្វើប្រដាប់ សំរាប់តែងទៅ បូជាយ័ជក្ញ ថាជាតបៈ ។ ពោធិសត្វថ្លៃ ស្តាប់ពាក្យនោះនៃ អ្នកយកដៃទះ ដើមដៃសើចក្អាក ថា ពាក្យព្រាហ្មណ៍ត្បៈ មង្គលព្រាហ្មណ៍ព្រះ ស្តែងពុំស្គាល់ទេ ។ សិងយកពាក្យភូត កុហកពុំសួត មកបញ្ឆោតគេ តែងយក ទ្រព្យធន ពេកពន់ឥតល្ហែ ស្តេចត្រាស់ថាឯ ចៅតើថា ម្តេច ។ អ្នកក្រាបទូលថា បពិត្រក្សត្រា រីឯត្រង់សេច- ក្តី នេះជាគា- ថាថាបន្តិច ត្បៈនោះគឺកិច្ច បន្ថែថាក្តៅ ។ លោក ថាឲ្យយក ធម៌ប្រសើរមក ដុតចិត្តកំឡៅ គឺចិត្តលោភោ ទោសោកំដៅ ខ្លួនឲ្យទុក្ខទៅ កាន់ព្រះរ័តន៍ត្រ័យ ។ កំដៅ ស្ងួរិល ឯងកុំឲ្យខ្វិល ឲ្យអរសព្វថ្ងៃ នឹងព្រះសាស្នា តថាគត ថ្លៃ ដ្បិតកើតក្រក្រៃ បាននាទ់ម្តងៗ ។ ព្រះបន្ទូលព្រះ ថ្លែងថាតបៈ ដូច្នេះឯងហោង មួយសោតឯអ្នក អបល័ក្ខណ៍ កន្លង បិត្តបោរទ្រើសឃ្នង កំណាចឫស្យា ។ ជេរពោល ហើយបើក ខ្មាសរឹងរំលើក ឮដល់កាំម៉ា ហើយគុំនឹងកាប់

សំឡាប់អាត្មា គួរខឹងក្តាត់ណា គួរតបតស្នង ។ មួយបើគេ
យក គ្រឿងផងចូលមក ពិឃាតប៉ុនប៉ង កាប់ចាក់បាញ់ពោះ
បំពោះខ្លួនហោង គួរគិតរងសង ទោសទៅវិញណា ។
បើអ្នកទោះពុំ ខឹងតបគំនុំ រំងាប់ចិត្តា បានដោយបំណោះ
ហេតុប្រេះមេត្តា នេះហោងហៅជា តបៈមង្គល ។

# សេចក្ដីអធិប្បាយអំពីពាក្យថា

# សង្ក្រាន្ត

របស់អាចារ្យ គិម-អាន

# សង្ក្រាន្ត

ក្នុងឆ្នាំមួយ ៗ សឹងតែមានពាក្យថា "សង្ក្រាន្ត គ្រប់ឆ្នាំទៅទាំងអស់ តែអ្នកខ្លះក៏បានដឹងសេចក្ដីអធិប្បាយ អ្នកខ្លះក៏មិនបានដឹង ។

ឯពាក្យថា "សង្ក្រាន្ត ក្លាយមកពីពាក្យសំស្ក្រឹតថា សំក្រាន្តិ Entrée du soleil sous un nouveau signe du Zodiaque ការដែលព្រះអាទិត្យចូលកាន់រាសីមេសាចូលក្នុងឆ្នាំថ្មី គឺត្រង់ពេលបែកឆ្នាំ" សេចក្ដីអធិប្បាយតទៅនេះ ខ្ញុំបេះឯងក៏ទេ គឺមានរឿងរ៉ាវជានិទានប្រកបពាក្យនិយាយត ៗ គ្នាមក តាមដំណឹងថា មានប្រាកដក្នុងក្បួនហោរាសាស្ត្រ "Astrologie" ដែលខ្ញុំនឹងនាំមកសំដែងក្នុងទីនេះ ដើម្បីនឹងឲ្យពួកខ្មែរយើងបានយល់ពាក្យប្រវេណីថា "សង្ក្រាន្ត" នោះខ្លះ តាមសមគួរដល់កំឡាំង ដូចមានសេចក្ដីថា៖

ក្នុងកាលខាងដើមនៃភទ្រកល្បនេះ មានសេដ្ឋីម្នាក់មានទ្រព្យសម្បត្តិច្រើនស្ដុកស្ដម្ភ តែមិនមានកូន មានផ្ទះនៅជិតអ្នក

ប្រមឹកស្រាម្នាក់ អ្នកប្រមឹកនោះមានកូនប្រុសពីរនាក់ មានរូបឆោមសមរម្យល្អ មានពណ៌សម្បុរដូចជាមាស គួរជាទីពិតពិលរមិលមើលនៃមនុស្សទាំងពួង ថ្ងៃមួយអ្នកប្រមឹកស្រានោះចូលទៅនិយាយពាក្យអាក្រក់ទ្រគោះបោះបោកនឹងសេដ្ឋីៗ ទើបសួរថា ឯងហេតុអ្វីបានជាហ៊ានមកពោលពាក្យប្រមាទមើលងាយយើងជាអ្នកមានទ្រព្យសម្បត្តិច្រើនដល់ម្ល៉េះ អ្នកប្រមឹកស្រាឆ្លើយតបវិញថា លោកសេដ្ឋី លោកគ្រាន់តែមានទ្រព្យសម្បត្តិច្រើននោះក៏មែន តែលោកគ្មានកូន កាលបើលោកស្លាប់ទៅហើយ សម្បត្តិទាំងនោះក៏នឹងវិនាសខ្ចាត់ខ្ចាយសូន្យទៅទទេមិនខាន យើងខ្សត់ទ្រព្យ តែមានកូនឃើញថាប្រសើរជាងលោក ហេតុដូច្នោះបានជាយើងមើលងាយ លោកសេដ្ឋីឈរទ្រឹងគិតមួយស្របក់ទៅឃើញមែន សមតាមពាក្យអ្នកប្រមឹកថា ក៏មានសេចក្ដីអៀនខ្មាសតូចចិត្តនឹងខ្លួនគ្មានកូន ទើបខំបួងសួងបន់ស្រន់ព្រះអាទិត្យព្រះចន្ទ្រ តាំងអធិដ្ឋានសេចក្ដីប្រាថ្នា សូមឲ្យបានកូនរហូតដល់ ៣ ឆ្នាំ ក៏មិនបានកូន ១ សោះ លុះយូរមកដល់ថ្ងៃនក្សត្រឫក្ស (Nakṣatra ṛkṣa les Pleiades

ជាឈ្មោះផ្កាយមួយពួកមាន ៧ ដែលក្លាយមកពីកូនទាំង ៧ របស់ Atlas នឹង Pléione ដែលខ្មែរយើងធ្លាប់និយាយថា នក្ខត្តឫក្ស ល្អឬអាក្រក់គឺបំពោះត្រង់ផ្កាយនោះឯង ) ព្រះអាទិត្យឡើងកាន់រាសី សេដ្ឋីទើបនាំបរិវារទៅកាន់ដើមជ្រៃធំមានមែកត្រសុំត្រសាយសាខា ដែលជាទីនៅនៃហ្វូងសត្វបក្សីបក្សាទាំងពួង នៅទៀបឆ្នេរសមុទ្រ លុះទៅដល់ហើយយកអង្ករមកលាងទឹក ៧ ដងឲ្យស្អាតហើយ ទើបបំអិនបូជាដល់អារក្សព្រះជ្រៃ "Génie qui garde ce banian ប្រគំភ្លេងតាំងអធិដ្ឋានសុំកូន អារក្សព្រះជ្រៃមានសេចក្ដីករុណា ទើបហោះទៅគាល់ព្រះឥន្ទ្រាធិរាជក្រាបបង្គំទូលសូមបុត្រឲ្យសេដ្ឋី ព្រះឥន្ទ្រក៏បាត់ឲ្យធម្មបាលទេវបុត្រច្យុតចុះមកចាប់បដិសន្ធិក្នុងគភ៌ភរិយាសេដ្ឋីនោះ លុះគម្រប់ ១០ ខែហើយទើបប្រសូតិបុត្រមក សេដ្ឋីមានសេចក្ដីត្រេកអរពន់ពេក ដោយបានសមតាមបំណង ទើបឲ្យឈ្មោះបុត្រនោះថា "ធម្មបាល" សេដ្ឋីបានសាងប្រាសាទ ៧ ជាន់ ឲ្យធម្មបាលកុមារនៅជិតដើមជ្រៃធំក្បែរឆ្នេរសមុទ្រនោះ កុមារបានស្ដាប់សត្វបក្សីនៅលើដើមជ្រៃនោះនិយាយគ្នាវា

រាល់ៗថ្ងៃតាំងពីតូចមក លុះចំរើនធំឡើងក៏ចេះស្ដាប់ភាសាសត្វបាន តមកបានរៀនត្រៃវេទ(១)ចេះចាំចប់សព្វគ្រប់ ជាកុមារឆ្លៀវឆ្លាសក្នុងវិទ្យាសាស្ត្រ Connaissance តាំងពីអាយុ ៧ ខួប ទើបបានឡើងជាទីអាចារ្យបង្ហាត់បង្រៀនមង្គលការផ្សេង ៗ ដល់មនុស្សទាំងពួង ។ ក្នុងខណៈនោះមនុស្សទាំងឡាយប្រកាន់ជឿកបិលមហាព្រហ្ម ថាជាអ្នកសំដែងមង្គលដល់ពួកមនុស្ស កាលបើកបិលមហាព្រហ្មជ្រាបហេតុនោះហើយ ទើបហោះចុះមកសួរប្រស្នានឹងធម្មបាលកុមារ ៣ យ៉ាង សន្យាគ្នាថា បើធម្ម-បាលកុមារដោះប្រស្នាបាន នឹងកាត់ក្បាលខ្លួនបូជា បើដោះមិនបាននឹងកាត់ក្បាលធម្មបាលកុមារវិញ ធម្មបាលកុមារសូមថយគិត ៧ ថ្ងៃ គ្រាកន្លង ៦ ថ្ងៃហើយ ក៏គិតមិនយល់តិចតួចសោះ ទើបនឹកថាព្រឹកនេះអញនឹងត្រូវស្លាប់ដោយអាជ្ញាស្ដេចកបិលមហាព្រហ្មមិនខាន អាត្មាអញមិនគួរស្លាប់ដោយហេតុ

---

១ ត្រៃវេទជាឈ្មោះគម្ពីរព្រាហ្មណ៍ដោយប្រួម ចែកចេញទៅមាន ៣ គឺ: ឫគ្វេទ (ស. ឫគវេទ ṛgveda) ១ យជុវេទ (ស. យជុវ៌េទ yajurveda) ១ សាមវេទ (ស. សាមវេទ Sāmaveda) ១ ប៉ុន្តែកាលក្នុងគម្ពីរសំស្ក្រឹតគេចែកជាឈ្មោះវេទមាន ៤ គឺ: អថវ៌វេទ atharvaveda ១ ឫគវេទ ṛgveda ១ យជុវ៌េទ yajurveda ១ សាមវេទ Sāmaveda ១ ។

នេះឡើយ នឹងរត់ចេញទៅណាក់ខ្លួនពួនអាត្មាឲ្យស្លាប់នឹងហេតុជទៃល្អជាង ទើបចុះពាកប្រាសាទទាំងកណ្តាលអាធ្រាត្ររត់ទៅពួនដេកនៅទីជាបន្លោះគល់ត្នោតលៃពីរដើម ដែលមានសត្វឥន្ទ្រីយ៍ Aigles មួយគូញីឈ្មោលវាធ្វើសំបុកអាស្រ័យនៅលើចុងត្នោតនោះ ចួនជាវេលានោះ សត្វឥន្ទ្រីយ៍ញីសួរស្វាមីថាព្រឹកនេះយើងនឹងបានអាហារមកពីទីណា ឥន្ទ្រីយ៍ឈ្មោលប្រាប់ថា ឯងកុំថប់បារម្ភអ្វីនឹងអាហារបំណីនោះ យើងនឹងបានស៊ីសព (ខ្មោចស្រស់) ធម្មបាលកុមារដែលស្តេចកបិលមហា-ព្រហ្មនឹងសំឡាប់ព្រោះដោះប្រស្នាមិនរួច ឥន្ទ្រីយ៍ញីសួរថាប្រស្នានោះពិបាកយ៉ាងណាទៅ បានជាឆ្លើយមិនរួច ឥន្ទ្រីយ៍ឈ្មោលប្រាប់ថា ស្តេចកបិលមហាព្រហ្មសួរពីសិរី ៣ យ៉ាងរបស់ពួកមនុស្ស តើនៅត្រង់ណាខ្លះ? ឥន្ទ្រីយ៍ញីសួរថា បើប្រស្នាបែបនេះនឹងដោះបែបណាទើបត្រូវ ឥន្ទ្រីយ៍ឈ្មោលប្រាប់ថា ឱ! ឯងមិនយល់ប្រស្នានេះទេ បើដូច្នោះចាំស្តាប់អញចុះពេលព្រឹកសិរីស្ថិតនៅមុខ ពួកមនុស្សទើបយកទឹកលុបលាងមុខ នេះជាពាក្យឆ្លើយប្រស្នាទី ១, ពេលថ្ងៃត្រង់សិរីស្ថិត

នៅទ្រូង ពួកមនុស្សទើបយកគ្រឿងលាបមកប្រស់ព្រំទ្រូង នេះជាពាក្យឆ្លើយប្រស្នាទី ២, ពេលអស្តង្គត[១] សិរីស្ថិតនៅជើង ពួកមនុស្សទើបយកទឹកលាងជើង នេះជាពាក្យឆ្លើយប្រស្នាទី ៣, ធម្មបាលកុមារខំផ្ទៀងស្តាប់បានឮដូច្នោះហើយ ក៏មានសេចក្តីត្រេកអរគិតថា អញនឹងរួចអំពីសេចក្តីស្លាប់ហើយម្តងនេះ ទើបត្រឡប់មកប្រាសាទខ្លួនវិញ លុះព្រឹកឡើង ស្តេចកបិលមហាព្រហ្មមកសួរប្រស្នាដដែលនោះទៀត ធម្មបាល-កុមារក៏ដោះតាមពាក្យសត្វឥន្ទ្រីយ៍ ស្តេចកបិលមហាព្រហ្មថា អើ ត្រូវហើយៗ បើដូច្នោះ ខ្ញុំត្រូវកាត់ក្បាលខ្ញុំបូជាអ្នក ហើយក៏ត្រាស់ហៅនាងទេវធីតាទាំង ៧ ដែលជាបរិចារិការបស់ព្រះឥន្ទ្រមកជួបជុំហើយ ទើបប្រាប់ថា យើងនឹងកាត់ក្បាលបូជាធម្មបាលកុមារ តែក្បាលយើងនេះបើនឹងតាំងទុកនៅលើផែនដី ភ្លើងនឹងឆេះទួទៅទាំងលោកធាតុ បើនឹងបោះបណ្តោតទៅលើអាកាស ភ្លៀងក៏នឹងរាំង បើនឹងបោះទៅក្នុងមហាសមុទ្រ ទឹកក៏រីង បើដូច្នោះ ត្រូវឲ្យកូនឯងទាំង ៧ នាក់នេះ

១ ថ្ងៃលិច ។

យកពានមាសមកទទួលព្រះសិរ (ក្បាល) អញ ហើយក៏កបិលមហាព្រហ្មកាត់សិរប្រគល់ឲ្យទៅនាងធុង្សជាបុត្រីច្បង នាងធុង្សយកពានមាសមកទទួលព្រះសិរបិតា ហើយហោះប្រទក្សិណភ្នំសុមេរុ ៦០ នាទី ទើបយកទៅប្រតិស្ឋានទុកក្នុងមណ្ឌប នៅតាទីគុហាគន្ធមូលី ភ្នំកៃលាស បូជាដោយគ្រឿងទិព្វផ្សេង ៗ ព្រះវិស្សកម្មទេវបុត្របាននិម្មិតរោងកែវទាំង ៧ ប្រការ ឈ្មោះភគវតី ឲ្យជាទីប្រជុំទេវតាទាំងឡាយ ទេវតាទាំងនោះ ក៏នាំគ្នាយកព្រះសិរស្ដេចកបិលមហាព្រហ្មមកលាងទឹកក្នុងស្រះអនោតត្ត ៧ ដង ហើយបែកគ្នាបួងសួងគ្រប់ ៗ គ្នា រាប់តាំងពីថ្ងៃនោះមករហូតដល់គ្រប់កំណត់ ៣៦៥ ថ្ងៃ លោកសន្មតថាឆ្នាំ ១ ហៅថា "សង្ក្រាន្ត" នាងទេពធីតាទាំង ៧ អង្គត្រូវវេនផ្លាស់ប្ដូរគ្នារាល់ឆ្នាំ ក្នុងឆ្នាំមួយត្រូវនាងទេវធីតាម្នាក់ អញ្ជើញព្រះសិរស្ដេចកបិលមហាព្រហ្មចេញហែប្រទក្សិណជុំវិញភ្នំព្រះសុមេរុ ហើយត្រឡប់ទៅទេវលោកវិញដូច្នេះឯង ។

នាងសង្ក្រាន្តទាំង៧នោះ មានតាមដំរាហោរាសាស្ត្រថា ថ្ងៃអាទិត្យឈ្មោះធុង្ស សៀតផ្កាទទឹម (ផ្កាក្រទឹម) ប្រដាប់ដោយគ្រឿងបទុមរាគ សោយផ្លែល្វាជាអាហារ ព្រះហស្តស្តាំទ្រង់ចក្រ ព្រះហស្តឆ្វេងទ្រង់ស័ង្ខ គ្រុឌជាពាហន ។

ថ្ងៃចន្ទ្រ ឈ្មោះគោរាគ ទ្រង់ផ្កាមន្ទារបុស្ស(១) ប្រដាប់ដោយកែវមុក្តា សោយប្រេងល្ងជាអាហារ ព្រះហស្តស្តាំទ្រង់ព្រះខ័ន(២) ព្រះហស្តឆ្វេងទ្រង់ចាប់មុខព្រះខ័ន ព្យគ្ឃរាជជាពាហន ។

ថ្ងៃអង្គារ ឈ្មោះរាក្សស សៀតផ្កាឈូកក្រហម ប្រដាប់ដោយគ្រឿងមោរា សោយលោហិតជាអាហារ ព្រះហស្តស្តាំទ្រង់ត្រីសូល ព្រះហស្តឆ្វេងទ្រង់ធ្នូ សូករជាពាហន ។

ថ្ងៃពុធ ឈ្មោះមណ្ឌា សៀតផ្កាចម្ប៉ា ប្រដាប់ដោយគ្រឿងពិទូរ្យ សោយទឹកដោះជាអាហារ ព្រះហស្តស្តាំទ្រង់ដែកស្រួច (ម្ជុល) ព្រះហស្តឆ្វេងទ្រង់ឈើច្រត់ លាជាពាហន ។

---

១ក្បួនខ្លះថា សៀតផ្កាត្រកៀត ។ ២ក្បួនខ្លះថា ទ្រង់ឈើច្រត់ ។

ថ្ងៃព្រហស្បតិ៍ ឈ្មោះកិរិណី សៀតផ្កាមណ្ឌា ប្រដាប់ដោយកែវមរកត សោយសណ្តែកលួជាអាហារ ព្រះហស្តស្តាំទ្រង់កង្វេរ ព្រះហស្តឆ្វេងទ្រង់អាវុធ (កាំភ្លើង) ហត្ថីជាពាហន ។

ថ្ងៃសុក្រ ឈ្មោះកិមិទា សៀតផ្កាចង្កុលណី ប្រដាប់ដោយគ្រឿងបុសរ៉ាគាំ សោយបេកទឹកជាអាហារ ព្រះហស្តស្តាំទ្រង់ព្រះខ័ន ព្រះហស្តឆ្វេងទ្រង់ពិណ ក្របីជាពាហន ។

ថ្ងៃសៅរ៍ ឈ្មោះមហោធរា សៀតផ្កាត្រកៀត[1] ប្រដាប់ដោយគ្រឿងកែវនិលរត្ន សោយសាច់ទ្រាយជាអាហារ ព្រះហស្តស្តាំទ្រង់ចក្រ ព្រះហស្តឆ្វេងទ្រង់ត្រីសូល៍[2] មយូរាជាពាហន ។

---

១ ក្បួនខ្លះថា ផ្កាក្រូច ។ ២ ក្បួនខ្លះថា ព្រះហស្តស្តាំទ្រង់ត្រីសូល៍ ព្រះហស្តឆ្វេងទ្រង់អាវុធ ។

# ដំណើរដើម

## កាព្យសាន្តិភាព

## CHANT DE PAIX

ព្រះរាជបណ្ណាល័យបានបោះពុម្ពសៀវភៅ ១ សិងហៅក្នុងទីនេះថា "កាព្យសាន្តិភាព" ជារបស់ដែល (មគ្គលីផល) បានតែងឡើងជាភាសាបារាំងសែស សម្រាប់បំណាយផ្សាយនៅព្រះរាជបណ្ណាល័យ ។

សៀវភៅនេះ កាលផ្សាយទៅដល់មហានគរបារាំងសែសហើយ មានពួកបណ្ណាធិការនៃក្រុមកាសែតធំៗ នៅក្រុងបារីសដូចយ៉ាងក្រុមកាសែត គ្រាំងគ្វា (Gringoire) ឡឺស្សួរណាល់ (Le Journal) ឡូពីនីញ៉ុង ឌុយ ស៊ុតដែស (L'Opinion du Sud-Est) និងឡេនូវ៉ែល លិត្តេរ៉ែ (Les Nouvelles littéraires) បានមើលហើយ ចុះសេចក្តីសរសើរដល់អ្នករៀបរៀងថា ជាអ្នកមានគំនិតជ្រៅ គិតដឹកនាំមនុស្សទៅកាន់សាន្តិភាព (សេចក្តីសុខ

សម្រាន) នាំមនុស្សឲ្យកន្លងផុតមហាទុក្ខវេទនា ដែលលោកកំពុងតែរំជួលគិតប្រាំងគ្នាសព្វថ្ងៃនេះ ។

មិនតែប៉ុណ្ណោះ នៅស្រុករបស់មគ្គលីផល (ក្រុងកម្ពុជា) សព្វថ្ងៃនេះ កំពុងតែបោះពុម្ពផ្សាយធម៌ ដែលជាសាន្តិភាពធម៌របស់ព្រះពុទ្ធតទៅទៀតគឺ ព្រះត្រៃបិដកនោះឯង ។ ៚

ព្រះរាជបណ្ណាល័យកម្ពុជា

# KAMPUCHEA SURIYA

# កម្ពុជសុរិយា

## សៀវភៅទស្សនាវដ្ដីចេញរាល់ខែ ពីព្រះរាជបណ្ណាល័យ

## ឆ្នាំគំរប់ ១០

ខែ ៤, ៥, ៦, រួមគ្នា

កុង្សីយសេនាបតីបានអនុញ្ញាតហើយ

សម្ដេចសង្ឃនាយកទាំងពីរគណៈយល់ព្រម

BIBLIOTHÈQUE ROYALE DU CAMBODGE

ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព. ស. ២៤៨១

គ. ស. ១៩៣៨

# សូមជូនដំណឹង

ដល់អស់លោក-អ្នកជាវសៀវភៅកម្ពុជសុរិយា តាមដែលជូនដំណឹងមកម្ដងមុននេះ ឥឡូវនេះសម្រេចហើយ សូមឱ្យមើលចុះ តាំងពីសៀវភៅខ្សែ ៤ ទៅ នឹងឃើញប្រើអក្សរតូច តែឯសាច់រឿងយើងបានបញ្ចុះរឿងល្អៗ ប្លែកៗ ច្រើន ទាំងកម្រាស់ក៏ក្រាស់ជាងសៀវភៅក្នុងឆ្នាំមុនៗនេះផង អ្នកដែលមិនទាន់ជាវ ក៏គួរជាប្រញាប់ជាវទៅមើល ។

ព្រះរាជបណ្ណាល័យ

ព្រះរាជបណ្ណាល័យកម្ពុជា

# KAMPUCHEA SURIYA

# កម្ពុជសុរិយា

សៀវភៅទស្សនាវដ្តីចេញរាល់ខែ ពីព្រះរាជបណ្ណាល័យ

ឆ្នាំគំរប់ ១០

ខែ ៤, ៥, ៦, រួមគ្នា

ក្រសួងសេនាបតីបានអនុញ្ញាតហើយ

សម្តេចសង្ឃនាយកទាំងពីរគណៈយល់ព្រម

ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព. ស. ២៤៨១

គ. ស. ១៩៣៨

# បញ្ជីរឿង

ទំព័រ


១ ព្រហ្មចរិយកថា របស់ព្រះមហាវិសេស ក្រុមពុទ្ធសាសនបណ្ឌិត្យ ប្រែនិងរៀបរៀង (ត) . . . . . . . . . . . . . . . . . . . . ៣

២ ពាក្យនាំក្នុងរឿងសិលាចារិកនគរវត្ត . . . . . . . . . . . . . . . . ១៣

៣ វយប្បកាសិនី របស់អាចារ្យ ហែម ក្រុមពុទ្ធសាសនបណ្ឌិត្យរៀបរៀង (ត) . . . ២៥

៤ សេចក្ដីអធិប្បាយអំពីរចនាខ្មែរ របស់លោកម៉ារសាល . . . . . . . . . . ៣៧

៥ បញ្ជីសៀវភៅផ្សេង ៗ នៅព្រះរាជបណ្ណាល័យ . . . . . . . . . . . . . ៤១

៦ លទ្ធិទំនៀមទម្លាប់ "ក្បួនដំរះឧត្បាទវ៉" របស់បុរាណ . . . . . . . . . . . ៤៩

៧ រឿងព្រេងខ្មែរដែលមិនទាន់ចេញផ្សាយ : រឿងធនញ្ជ័យបណ្ឌិត (ត) ចប់ . . . . ៥៧


# រូបក្រៅរឿង


ប្រាសាទកំពង់ព្រះ នៅខេត្តទន្លេសាប (កំពង់ឆ្នាំង) . . . . . . . . . . . ១

# TABLE DES MATIÈRES


Pages.

I. Brahmacariyakatha par Préas Maha Sès de l'Institut Bouddhique (suite) .......... 3

II. Les inscriptions de Nokor Vat : introduction (à suivre) .. 13

III. Vayappakasini par l'Achar Him de l'Institut Bouddhique (suite) .......... 25

IV. Causerie de M. Marchal sur l'Art Khmer .......... 33

V. Liste des livres et Manuscrits de la Bibliothèque Royale. 41

VI. Mœurs et coutumes cambodgiennes Règles pour conjurer les malheurs (suite) .......... 49

VII. Contes populaires cambodgiens inédits :

Conte de Thmègnchey Pandit (suite et fin) .......... 57


## HORS TEXTE :


Ruines brahmaniques Khmers aux bords du Tonlé-Sap à Kompong-Préas Kompong-Chhnang (Cliché dalet) ....... 1



ប្រាសាទកំពង់ព្រះ នៅឆ្នេរទន្លេសាប (កំពង់ឆ្នាំង)

# ព្រហ្មចរិយគាថា

## របស់ព្រះមហាសែស ក្រុមពុទ្ធសាសនបណ្ឌិត្យ

## រៀបរៀង (គ)

# ព្រហ្មចរិយកថា

ព្រហ្មចរិយទី ៣ គឺបញ្ចសីល បានដល់សីលទាំង ៥ មានមកក្នុងគម្ពីរជាតក ៗ មានរឿងក្នុងវិន័យបិដក សេនាសនក្ខន្ធក គម្ពីរចុល្លវគ្គថា មនុស្សទាំងឡាយមានសទ្ធាសាងសេនាសនប្រគេនភិក្ខុសង្ឃជាច្រើន ៗ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅជាសុខសប្បាយ ក្នុងនគរវេសាលី ហើយទ្រង់យាងអំពីនគរវេសាលីសំដៅទៅនគរសាវត្ថី មានភិក្ខុសង្ឃច្រើនជាបរិវារ ៗ ពួកភិក្ខុជាសិស្សរបស់ឆព្វគ្គិយភិក្ខុ នាំគ្នាដើរស្រូតរូតទៅមុនភិក្ខុសង្ឃមានព្រះពុទ្ធអង្គជាប្រធាន ដណ្តើមយកសេនាសនតាមគាប់ចិត្តថា សេនាសននេះគួរបានឧបជ្ឈាយ៍យើង នេះគួរបានអាចារ្យយើង នេះគួរបានយើង ៗ ព្រះសារីបុត្រនិមន្តទៅក្រោយគេបង្អស់ មិនបានសេនាសនសោះ លោកក៏និមន្តទៅគង់ក្រោមម្លប់ឈើ ១ ដើម ៗ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ក្រោកឡើងក្នុងបច្ចូសសម័យនៃរាត្រី ហើយទ្រង់គ្រហែម ៗ ព្រះសារីបុត្រ ក៏គ្រហែមតទឹងព្រះអង្គ ៗ ព្រះអង្គសួរថា នរណានេះ ៗ ព្រះសារីបុត្រក្រាបទូលថា ខ្ញុំព្រះករុណាឈ្មោះសារីបុត្រ ៗ ព្រះអង្គសួរថា ចុះហេតុអ្វីបានជាមកអង្គុយក្នុងទីនេះ ៗ ព្រះសារីបុត្រក្រាបបង្គំទូលថា គ្មានសេនាសនៈ ព្រោះគេដណ្តើមយកមុនអស់ទៅ ៗ ព្រះអង្គទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ ហើយទ្រង់សួរបញ្ជាក់រឿងនោះជ្រាបសព្វគ្រប់ហើយ

ទ្រង់សួរភិក្ខុទាំងឡាយតទៅទៀតថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុយ៉ាងណា គួរបានអាសនប្រសើរ ទឹកប្រសើរ ដុំបាយប្រសើរ ។ ភិក្ខុខ្លះក្រាបទូលថា អ្នកចេញចាកត្រកូលក្សត្រទៅបួស គួរបានអាសនប្រសើរ ទឹកប្រសើរ ដុំបាយប្រសើរ ខ្លះថា អ្នកចេញចាកត្រកូលព្រាហ្មណ៍ទៅបួសគួរ ខ្លះថា អ្នកចេញចាកត្រកូលគហបតីទៅបួសគួរ ខ្លះថា ភិក្ខុជាវិនយធរគួរ ។ល។ ព្រះអង្គទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកហើយ ទ្រង់សំដែងតិត្តិរជាតកថា ភូតបុព្វំ ភិក្ខវេ ហិមវន្តប្បទេសេ មហា និគ្រោធោ អហោសិ ។ ម្នាលភិក្ខុទាំងឡាយ រឿងមានមកពីដើមថា មានដើមជ្រៃធំ ១ ដើម ដុះនៅក្បែរព្រៃហិមពាន្ត ។ មានសត្វទាំង ៣ គឺសត្វទទា ១ សត្វស្វា ១ សត្វដំរី ១ ជាសំឡាញ់នឹងគ្នា ។ សត្វទាំង ៣ នោះ ឥតមានសេចក្ដីគោរពកោតក្រែងដល់គ្នានឹងគ្នាឡើយ ។ គ្រាក្រោយមក សត្វទាំង ៣ ក៏មានសេចក្ដីត្រិះរិះថា យើងគួរឲ្យដឹងច្បាស់ថា នរណាចាស់ជាងគេ បើដឹងថានរណាចាស់ជាងគេហើយ គួរគោរពបូជាដល់អ្នកនោះ គួរស្ថិតនៅក្នុងឱវាទអ្នកនោះ ។ ទើបសត្វស្វានឹងសត្វទទាសួរទៅសត្វដំរីថា សំឡាញ់ឯងរឭកឃើញរឿងពីដើមឬទេ ដំរីឆ្លើយថា កាលយើងជាកូនដំរីនៅឡើយ យើងដើរកន្លងដើមជ្រៃនេះដាក់ក្នុងចន្លោះភ្លៅទាំង ២ ដើរកន្លងទៅបាន ចុង

ត្រួយកូនជ្រៃគ្រាន់តែប៉ះពាល់ក្បាលពោះរបស់យើង ម្នាលសំឡាញ់ យើងទើកឃើញរឿងពីដើមដូច្នេះបាន ។

គ្រានោះ សត្វទទានឹងដំរីសួរទៅសត្វស្វាថា សំឡាញ់ឯងរឭកឃើញរឿងពីដើមបានដែរឬ ។ សត្វស្វាឆ្លើយថា កាលយើងជាកូនស្វានៅឡើយ អង្គុយលើផែនដី យកចាត់ធ្មេញខាំចុងត្រួយដើមជ្រៃនេះបាន ម្នាលសំឡាញ់ យើងរឭកឃើញរឿងពីដើមដូច្នេះបាន ។ គ្រានោះ សត្វស្វានឹងដំរីសួរទៅសត្វទទាថា សំឡាញ់ឯងរឭកឃើញរឿងពីដើមបានដែរឬ ។ សត្វទទាឆ្លើយថា មានដើមជ្រៃធំ ១ ដើម ដុះនៅត្រង់កន្លែងឯនោះ អាត្មាអញស៊ីផ្លែជ្រៃនោះ ហើយយកមកជុះដាក់ត្រង់កន្លែងនេះ ទើបដើមជ្រៃនេះដុះឡើង ម្នាលសំឡាញ់ ហេតុនោះ អាត្មាអញចាស់ជាងគេបង្អស់ដោយជាតិ ។ គ្រានោះ សត្វស្វានឹងដំរីនិយាយទៅនឹងសត្វទទាថា សំឡាញ់ឯងចាស់ជាងគេដោយជាតិហើយ យើងនឹងគោរពបូជាកោតក្រែងដល់សំឡាញ់ឯង ហើយស្ថិតនៅក្នុងឱវាទសំឡាញ់ឯងផង ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ សត្វទទាញ៉ាំងសត្វស្វានឹងដំរីឲ្យសមាទានសីល ៥ ហើយសមាទានប្រព្រឹត្តក្នុងសីល ៥ ដោយខ្លួនឯង សត្វទាំង ៣ នោះ ប្រកបដោយសេចក្តីគោរពកោតក្រែងដល់គ្នានឹងគ្នា លុះមានកាយបែកធ្លាយទៅហើយ ខាងមុខអំពីសេចក្តីស្លាប់ ក៏ចូល

ទៅកាន់លោកគឺស្ថានសួគ៌ជាសុគតិ ។ ឯតំ ខោ ភិក្ខវេ តិត្តិរិយំ នាម ព្រហ្មចរិយំ អហោសិ ។ ម្នាលភិក្ខុទាំង-ឡាយ សីលទាំង៥នេះឯង ហៅថា តិត្តិរិយព្រហ្មចរិយ គឺការប្រព្រឹត្តយ៉ាងប្រសើររបស់សត្វទ៣ ។ ព្រះអង្គទ្រង់សំដែងធម៌ដោយគាថាថា

យេ វុឌ្ឍមបចាយន្តិ នរា ធម្មស្ស កោវិទា
ទិដ្ឋេ ធម្មេ ច បាសំសា សម្បរាយេ ច សុគតិ ។

ជនទាំងឡាយឯណា ជាអ្នកឈ្លាសក្នុងធម៌ ប្រព្រឹត្តកោតក្រែងបុគ្គលដែលចាស់ជាងខ្លួន ជនទាំងឡាយនោះ អ្នកប្រាជ្ញតែងសរសើរក្នុងបច្ចុប្បន្ន លោកខាងមុខរបស់ជនទាំងនោះ ក៏ជាសុគតិ ។ ព្រះអង្គសំដែងគាថាដូច្នេះហើយ ទ្រង់មានព្រះបន្ទូលតទៅទៀតថា ម្នាលភិក្ខុទាំងឡាយ សត្វតិរច្ឆានទាំងនោះ ប្រកបដោយសេចក្តីគោរពកោតក្រែងដល់គ្នានឹងគ្នា អ្នកទាំងឡាយដែលចូលមកបួសក្នុងធម្មវិន័យ ដែលតថាគតសំដែងដោយល្អយ៉ាងនេះហើយ គួរណាស់តែមានសេចក្តីគោរពកោតក្រែងដល់គ្នានឹងគ្នាដូច្នោះឯង ។ ពាក្យថាព្រហ្មចរិយក្នុងតិត្តិរជាតកនេះ ជាពុទ្ធភាសិត សំដៅយកសីលទាំង ៥ ឬថាជាឈ្មោះរបស់សីលទាំង ៥ ព្រោះហេតុនោះបានជាព្រះអដ្ឋកថាចារ្យ អាងពុទ្ធភាសិតនេះហើយ អធិប្បាយថាសីលទាំង ៥ ហៅថាព្រហ្មចរិយធម៌ ១ ដែរ ។

ម្យ៉ាងទៀត ពាក្យថាសីល ៥ គឺសិក្ខាបទទាំង ៥ ដូចមានក្នុងបាលី សង្គីតិសូត្រ គម្ពីរទីឃនិកាយ បាដិកវគ្គថា បញ្ច សិក្ខាបទានិ បាណាតិបាតា វេរមណី អទិន្នាទានា វេរមណី កាមេសុ មិច្ឆាចារា វេរមណី មុសាវាទា វេរមណី សុរាមេរយ-មជ្ជប្បមាទដ្ឋានា វេរមណី ។ សិក្ខាបទទាំងឡាយមាន ៥ គឺ ការវៀរសំឡាប់សត្វ ១ ការវៀរលួចទ្រព្យគេ ១ ការវៀរប្រព្រឹត្តខុសក្នុងកាម គឺសេពមេថុនធម្មនឹងស្ត្រី ២០ ពួក ១ ការវៀរនិយាយពាក្យកុហក ១ ការវៀរហេតុជាទីតាំងនៃសេចក្ដីប្រមាទ ព្រោះផឹកទឹកស្រវឹង គឺសុរានិងមេរ័យ ១ ។

បើនឹងសំដែងដោយសេចក្ដី ពាក្យថាវៀរនោះ បានដល់វិរតិ គឺការវៀរដែលប្រកបដោយកុសលចិត្ត ។ ក៏វិរតិនោះមាន ៣ ប្រការ គឺ សម្បត្តវិរតិ ១ សមាទានវិរតិ ១ សមុច្ឆេទវិរតិ ១ ។ សម្បត្តវិរតិ បានដល់ការវៀរដែលកើតឡើងដល់បុគ្គល ដែលមិនបានសមាទានសិក្ខាបទ ហើយមិនប្រព្រឹត្តកន្លងនូវវត្ថុ ដែលមកដល់ក្នុងទីចំពោះមុខ គឺ ចួបប្រទះនឹងសត្វគួរសម្លាប់មិនសម្លាប់ ទ្រព្យគេគួរលួចមិនលួចជាដើម ដោយពិចារណាឃើញនូវជាតិនឹងវ័យ និងសេចក្ដីចេះដឹងរបស់ខ្លួនជាដើម មួយទៀត គិតឃើញថា អំពើសំឡាប់ជាដើមនេះ មិនសមគួរដល់

អាត្មាអញឡើយ ដូចរឿងរបស់ចក្កនឧបាសក អ្នកនៅក្នុងលង្កាទ្វីប ៗ មានរឿងនិទានថា កាលឧបាសកនោះនៅក្មេងនៅឡើយ រោគក៏កើតមានឡើងដល់មាតារបស់ឧបាសកនោះ ៗ យកពេទ្យមកព្យាបាល រក្សាមើលរោគមាតានោះ ពេទ្យគេនិយាយថា រោគនេះត្រូវនឹងថ្នាំសាច់ទន្សាយស្រស់ ៗ ទើបបងក៏ប្រើចក្កនឧបាសកនោះ ឲ្យទៅរកសាច់ទន្សាយស្រស់ឯប្រទេសស្រែ ៗ ចក្កនឧបាសកក៏ដើរទៅឯប្រទេសស្រែនោះ ៗ ក្នុងសម័យនោះ មានសត្វទន្សាយ ១ ដើរផកដើម្បីទំពាស៊ីសន្ទូង ៗ ទន្សាយនោះបានឃើញចក្កនឧបាសកនោះហើយ ក៏រត់ទៅប្រញាប់ទៅពន្ធព័ន្ធនឹងវល្លិទៅណាពុំរួច ប្រឹងស្រែកបម្រះនៅទៀលនៅទីនោះ ៗ ចក្កនឧបាសកបានឮសំឡេងនោះហើយ ក៏ស្ទុះទៅចាប់បានយកមកដោយគិតថា នឹងធ្វើថ្នាំដល់មាតារបស់ខ្លួន ក៏គិតម្ដងទៀតថា អាត្មាអញមិនគួរនឹងសំឡាប់ជីវិតគេ ព្រោះជីវិតមាតារបស់ខ្លួនដូច្នេះឡើយ ៗ ទើបចក្កនឧបាសក លែងទន្សាយនោះទៅនិយាយថា ទន្សាយឯង ចូរទៅបរិភោគស្មៅនឹងទឹកជាមួយនឹងទន្សាយឯទៀតចុះ ៗ លុះចក្កនឧបាសកត្រឡប់មកផ្ទះវិញ បងក៏សួរថា បានទន្សាយឬទេ ក៏ឆ្លើយប្រាប់ដំណើរនោះសព្វគ្រប់ដល់បង ៗ បងក៏គម្រាមចក្កនឧបាសកនោះតាមអំពើចិត្ត ៗ ចក្កនឧបាសកនោះក៏ទៅកាន់សំណាក់មាតារបស់

ខ្លួន ហើយពោលសប្បាយថា អាត្មាអញតាំងពីកើតមក មិនដែលមានចិត្តគិតញ៉ាំងសត្វឲ្យធ្លាក់ចុះចាកជីវិតឡើយ ៗ មាតាបិតានឧបាសកនោះ ក៏ជាកេតភ្ជាមមួយរំពេច ៗ សម្បត្តិវិរតិ មានសេចក្តីសង្ខេបយ៉ាងនេះ ៗ

ឯសមាទានវិរតិ គឺវិរតិដែលកើតឡើងដល់បុគ្គល ដែលបានសមាទានសិក្ខាបទហើយ ស៊ូលះបង់ជីវិតខ្លួន មិនហ៊ានប្រព្រឹត្តឲ្យកន្លងវត្ថុ គឺសត្វគួរសម្លាប់ និងទ្រព្យគួរលួចជាដើម ដូចវិរតិរបស់ឧបាសកម្នាក់ នៅក្នុងឧត្តរវឌ្ឍមានគ្រាម ៗ មានវត្ថុនិទានថា ឧបាសកនោះ បានសមាទានសិក្ខាបទ ក្នុងសំណាក់ព្រះបិង្គលពុទ្ធរក្ខិតត្ថេរ ហើយក៏ទៅភ្ជួរស្រែ ៗ លុះកាលជាខាងក្រោយ គោរបស់ឧបាសកនោះក៏បាត់ទៅ ៗ ឧបាសកនោះ ដើរស្វែងរកគោនោះ ឡើងទៅរកលើភ្នំឈ្មោះឧត្តរវឌ្ឍមាន ៗ មានពស់ថ្លាន់ធំ ១ រឹបរឹតឧបាសកនោះនៅលើភ្នំនោះឯង ៗ ឯឧបាសកនោះគិតថា អាត្មាអញកាត់ក្បាលពស់ថ្លាន់ដោយកាំបិតព្រាដ៏មុតនេះ ក៏គិតមួងទៀតថា អាត្មាអញបានសមាទានសិក្ខាបទ ក្នុងសំណាក់គ្រូដែលមានកេរ្តិ៍ឈ្មោះប្រសើរហើយ មិនគួរនឹងទំលាយសិក្ខាបទនោះសោះ លុះគិតដូច្នេះ ៣ ដងហើយ ក៏គិតមួងទៀតថា អាត្មាអញលះបង់ជីវិតខ្លួនចុះ មិនគួរលះបង់សិក្ខាបទទេ ហើយក៏បោះកាំបិតព្រាដែលលីនៅលើស្មាចោលទៅក្នុងព្រៃ ៗ ឯពស់

ប្រាំក៏លែងខុចាសកនោះ ហើយលូនចេញទៅមួយរំពេច ៗ សមាទានវិរតិ មានសេចក្ដីសង្ខេបយ៉ាងនេះ ៗ

ឯសមុច្ឆេទវិរតិ បានដល់វិរតិដែលប្រកបដោយអរិយមគ្គរបស់ព្រះអរិយបុគ្គល ចាប់ដើមតាំងអំពីកើតសមុច្ឆេទវិរតិនោះឡើង សន្ដានចិត្តរបស់ព្រះអរិយបុគ្គលនោះ មិនបានគិតទីងសំឡាប់សត្វឡើយ ៗ

ចប់វិរតិ ៣ ប្រការដោយសង្ខេបតែប៉ុណ្ណោះ ។

# សិលាចារិកនគរវត្ត

នឹង

# បទានុក្រម

# ពាក្យនាំ

លោកសាស្ត្រាចារ្យ ស៊ិក-សេដេស ចាងហ្វាងសាលាស្រាវជ្រាវប្រវត្តិសាស្ត្រនៃប្រទេសឥណ្ឌូស៊ីននៅហាណូយ មានប្រាថ្នាទីងផ្សាយរឿងសិលាចារិកនេះ ឲ្យមហាជនជ្រាបរឿងរ៉ាវ ទីងជ្រាបទំនៀមទម្លាប់ ប្រើអក្សរក្នុងជាន់នោះ ជាដូចម្តេចខ្លះ តែឃើញថា បើបោះពុម្ពតាំងស្រេចដូច្នោះទៅ ដោយមិនមានធ្វើសេចក្តីអធិប្បាយនូវពាក្យដែលជ្រៅ ៗ អមផង ឃើញមិនមានប្រយោជន៍ដល់អ្នកមើលប៉ុន្មានណាស់ ទើបបញ្ជូនរឿងនោះមកដល់លោកស្រីការប៉ឺឡែសចាងហ្វាងព្រះរាជបណ្ណាល័យកម្ពុជា ដើម្បីឲ្យរើសរកអ្នកប្រាជ្ញណាមួយដែលជំនាញភាសាខ្មែរ ឲ្យស្រង់ពាក្យទាំងឡាយដែលមានសេចក្តីជ្រៅសុខុម ដែលមនុស្សសាមញ្ញមើលទៅហើយមិនយល់បានដោយងាយ មកធ្វើសេចក្តីអធិប្បាយពន្យល់ បែបជាកែជើងអត្ថ ដែលហៅក្នុងទីនេះថា "បទានុក្រម" ឲ្យងាយទៀងអមផង ដូចមានសំបុត្រលេខ ២៣ ចុះថ្ងៃ ៣ ខែយ៉ាំងវីយេ ឆ្នាំ ១៩៣៥ នោះស្រាប់ ។

លោកស្រីការប៉ឺឡែស បានទទួលហើយ ក៏ជ្រះថ្លាទីងផ្សាយដូច្នោះដែរ ទើបដាក់រឿងនោះឲ្យខ្ញុំធ្វើវចនាធិប្បាយ ។ ខ្ញុំទទួលមកមើល ១ ចប់ទៅហើយ ឲ្យនឹកធុនចិត្ត ធុនគំនិតជាយ៉ាងក្រៃពេក ដោយឃើញសិលាចារិកនោះដេរដាសពាសពេញទៅដោយពាក្យដែលក្រ ៗ សឹងប្លែកក្នែក

បែកគ្រះចៀកខ្ញុំជាច្រើនអន្លើ តែក៏បំពេញមិនទាន់ទេ ត្រឡប់ជាមានបានៈទឹងសេចក្តីព្យាយាមដ៏ក្លាឡើងវិញ បានខ្មីឃ្មាតធ្វើទាល់តែហើយស្រេច ដោយនឹកគិតថា បើមិនសព្វគ្រប់គង់ពាក្យឯណាទីមួយ ក៏នឹងបានប្រតិបត្តិសួរលោកសាស្ត្រាចារ្យ សេដេស ជាអ្នកម្ចាស់ដើម ឲ្យលោកបំពេញឲ្យ ។ លុះសរសេររួចហើយ ខ្ញុំក៏បញ្ជូនទាំងច្បាប់សិលាចារិកទាំងសេចក្តីអធិប្បាយ ទៅសុំឲ្យលោកពិនិត្យផ្ទៀងផ្ទាត់ឲ្យ លោកក៏មេត្តាកែតម្រង់ឲ្យបាន តាមដែលនៅមានឃ្លៀងឃ្លាតនោះជាច្រើនអន្លើ ខ្ញុំសូមអំណរព្រះតេជព្រះគុណលោកជាយ៉ាងក្រៃពេកក្នុងទីនេះ ។

ក៏ឯសិលាចារិកអំបាលនេះ គេចារិកទុកនៅប្រាសាទនគរវត្តជា ៣ អន្លើ គឺនៅទីដែលហៅថា "ព្រះពាន់" ត្រង់ដែលមានព្រះពុទ្ធរូបច្រើននោះខ្លះ នៅថ្នាក់លើបំផុតដែលហៅថា "បាកាណ" នោះខ្លះ មួយអន្លើទៀត គឺសិលាចារិកលេខ ៣៨ នៅព្រះរបៀងថ្នាក់ក្រោម ពីខាងកើត ត្រង់ដែលមានព្រះចេតិយកដោយថ្មបាយក្រៀម ។

សិលាចារិកទាំងនេះកើតឡើងក្នុងសម័យដែលប្រាសាទនគរវត្តត្រឡប់មកជាស្ថានទីក្នុងព្រះពុទ្ធសាសនាហើយ ។ សករាជដែលប្រើក្នុងសិលាចារិកនោះ គឺមហាសករាជ, ដំបូងឃើញមានតាំងពីមហាសករាជ ១៤៨៨ ឆ្នាំខាលនក្សត្រ (ព. ស. ២១០៩) ដល់ ១៦៦៩ ឆ្នាំថោះនក្សត្រ (ព. ស. ២២៩០) ជាទីបំផុត ។

សេចក្ដីក្នុងសិលាចារឹកនោះ និយាយពីរឿងធ្វើបុណ្យផ្សេង ៗ គឺប្រោសខ្ញុំឲ្យរួចជាអ្នកជា បំបួសមនុស្ស លាបំណន់ សាងព្រះ សាងពិតាន ទឹងថ្វាយរបស់ជាគ្រឿងបូជា ។ល។ ជារបស់ស្ដេចខ្លះ—មន្ត្រីខ្លះ—រាស្ត្រខ្លះ ។

## អំពីភាសា

ភាសាដែលចារឹកនោះ ជាភាសាខ្មែរធម្មតាក្នុងសម័យកណ្ដាលនោះឯង មិនមែនជាភាសាបុរាណចាស់ណាស់ណាទេ មានភាសាបុរាណលាយឡំខ្លះមួយៗ ភាសាបុរាណមែនទែនលំបាកមើល លំបាកយល់ជាងនេះទៅទៀត ។ សេចក្ដីដែលសំខាន់ គឺអក្សរដែលប្រើក្នុងសិលាចារឹកនោះ ឃើញប្លែកនឹងអក្សរដែលយើងប្រើក្នុងសម័យនេះខ្លះ គឺប្លែកស្រៈខ្លះ ប្លែកវិធីប្រើអក្សរប្រែកបខ្លះ ដូចយ៉ាង ស្រៈ អឹ អឺ ក្នុងសិលាចារឹកដំបូង ៗ មិនទាន់ឃើញមានប្រើនៅឡើយ លុះមកដល់ចារឹកលេខ ១៧ ទើបឃើញមានប្រើ ។ ស្រៈ អួ គ្មានសន្ទតរូបកង់ដូរប្ដូរមកពីដើម , គេប្រើដើង វ គឺ «+» ជំនួស ។ ស្រៈ អៃ ក្នុងជាន់ដើមក៏មិនឃើញមានប្រើដែរ គេប្រើតែស្រៈ អេ ដូចពាក្យថា កើត គេសរសេរជា កេត, លើកជា លេក, ប្រើនជា ប្រេន ។ល។ លុះមកដល់ចារឹកលេខ ១៣ បន្ទាត់ ៨ មហាសករាជ ១៥៥២ ជាដើមមក ទើបឃើញមានប្រើ ។

មកដល់ចារិកលេខ ១០ សង្កេតឃើញគេសរសេរ ១ យ៉ាងជាចំឡែក ដូចពាក្យថា "បើ" គេសរសេរជា ប្អោ ដូចគ្នានឹងសៀមប្រើសព្វថ្ងៃនេះ ។ លុះមកដល់ចារិកលេខ ២៧ ឃើញសរសេរដូចដែលប្រើសព្វថ្ងៃនេះ តែមានបុសិកទន្តពីក្រោម ដូចយ៉ាង "លើក" គេសរសេរជា ល្ញើគះ ។

ស្រៈ អៀ បុរាណគេប្រើជា ២ យ៉ាង គឺ ១ យ៉ាងគេប្រើស្រៈ អែ ដូចពាក្យថា "ស្លៀក" គេសរសេរជា ស្លែគះ ចូរមើលចារិកលេខ ១០ បន្ទាត់ ១៨ ។ ទៀង ជា ទែង ចារិកលេខ ១៩ ។ ទៀត ជា ទែត ចារិកលេខ ២៤ បន្ទាត់ ៣៣ ។ ១ យ៉ាងទៀត ប្រើស្រៈ អេ នឹងជើង +្យ ផ្សំគ្នា ដូចពាក្យថា "រៀន" ជា រេ្យន, បៀតបៀនជា បេ្យតបេ្យន ។ល។

ឃើញប្រើចំឡែក ១ យ៉ាងទៅទៀត ដូចពាក្យថា "សិង" សរសេរជា ស្យង, "ដិង" ជា ដ្យង, "ពីរ" ជា ព្យរ ជាដើម ។

## ពាក្យប្រកបដោយសញ្ញា

ពាក្យដែលគ្មានតួសង្កត់ ដូចយ៉ាង "ថ្ម" គេសរសេរជា ថ្មុំ ។ ក ជា កះ ។ ត ជា តះ ។ សំណ ជា សំណះ ។ ព ជា ព្បា ។ល។

រូប ៕ នេះដែលហៅ មូសិកទន្ត ឬកណាប្រើស្រៈ អ តែម្តង លុះយូរមកបាត់គូសកណ្តាល នៅតែ ៕ ដូចពាក្យថា ចៅន្អក ប្អូហ ឈ្អូហ ជាដើម ដល់ក្រោយមកសរសេរជា ចៅន្ទក ប្ទូហ ឈ្ទូហ ទៅវិញ សិនដូចគ្នានឹងបែបសៀមប្រើ ៗ

គ្រឿងសំគាល់ផាត់អាកាស (៸) ឃើញប្រើជា ២ យ៉ាង គឺ ១ យ៉ាងប្រើជំនួសគួ (ង) ដែលសង្កត់តែម្តង ដូចយ៉ាង ស៎ររ (សង្ឃរ) ស៎យ (សង្ឃ្យ) ទ៎ា (ទាំង) អ៎ (អង្គ) អាទិស៎រ (អាទិសង្ឃ្យ) ហ៎ា (ហោង) ៗ ១ យ៉ាងទៀត ប្រើកាត់សំឡេងវែងឲ្យខ្លីចុះ ដូចពាក្យថា ស៎ករ ប្រុង៎ប៎ត ឯ៎ករ ច៎ន្ទ្រ ស្ត៎ល ប្រ៎ករ ៗល ៗ

របៀបទាំងឡាយតាមដែលស្រង់មកដាក់ក្នុងទីនេះ ជាគតិ ១ យ៉ាងឲ្យដឹងមូលអក្សរសាស្ត្ររបស់ខ្មែរ សិនប្រែប្រួលមកដូចម្តេច ៗ

## អំពីសមណស័ក្តិ

សង្កេតមើលក្នុងសិលាចារិកអំបាលនោះ ឃើញថា ក្នុងសម័យនោះមានទំនៀមទម្លាប់តាំងព្រះសង្ឃឲ្យមានសមណស័ក្តិយ៉ាងសំបូណ៌ហូរហៀរណាស់មកហើយ ទាំងមានគោរមងារដ៏ប្លែក ៗ អំពីគោរមងារសព្វថ្ងៃនេះជាច្រើន ៗ

នៅមានប្លែកទៀត គឺ (១) ក្នុងសម័យមួយ ឃើញមានសម្តេចព្រះមហាសង្ឃរាជ ច្រើន ៗ អង្គ ដូចយ៉ាងក្នុងសិលាចារិកលេខ ៣៩ មាន

ដល់ទៅ ៩ អង្គ ចំនៀមទម្លាប់កាលគ្រានោះជាយ៉ាងដូចម្តេច ត្រូវឲ្យឆ្ងល់ណាស់ ឬអ្នកចារិកពេះតែជាក់ ៗ ទៅទេ ៗ (២) ឈ្មោះខ្ទះក្នុងសម័យនោះសំដៅណែនជាពួកជាគណៈ មកដល់សម័យនេះ ត្រឡប់ជាទីព្រះគ្រូ ទៅវិញក៏មាន ដូចយ៉ាងវិបញ្ញាវិន័យ ៗ ក្នុងគ្រានោះ ជាពួកជាគណៈជាន់ខ្ពស់ ហេតុដល់ទីសម្តេចពួកជាគណៈ មកដល់ឥឡូវនេះ ត្រឡប់ជាពួកជា-គណៈសាមញ្ញ ទៅវិញក៏មាន តែនេះមិនជាការប្លែកប៉ុន្មានទេ ស្រេចហើយដំដឹសន្ទតតាំង ៗ (៣) ក្នុងជាន់នោះមានឋានន្តរៈ ទីព្រះគ្រូបាលដ្ឋដូចមានប្រាកដក្នុងសិលាចារិកលេខ ២៨ មកក្នុងបច្ចុប្បន្ននេះមិនឃើញមានមានតែព្រះគ្រូសុទ្ធ បាលដ្ឋសុទ្ធតែម្តង ។ តែក្នុងស្រុកសៀមសព្វថ្ងៃនេះមានទីព្រះគ្រូបាលដ្ឋ គឺជាបាលដ្ឋរបស់ពួកជាគណៈជាន់ខ្ពស់ ដូចយ៉ាងបាលដ្ឋរបស់ព្រះមហាព្រហ្មមុនី ជាដើម ហៅថា ព្រះគ្រូបាលដ្ឋ យសសក្តិធំជាងព្រះគ្រូវិន័យធរ ព្រះគ្រូវិន័យធម្មទៅទៀត ៗ

គោរមងារព្រះបង្សុអំបាលនោះ ខ្ញុំបានស្រង់រួបរួមយកទៅដាក់ខាងចុងបន្តស់ក្នុងសៀវភៅនេះ ដើម្បីឲ្យងាយស្រួលដល់ការត្រួតមើលរបស់អ្នកដែលត្រូវការពិនិត្យមើល ៗ

១៣ សេបតម ១៩៣៦

ព្រះមហាពិទូរ ក្រសេម

គន្ថរបេទបណ្ឌិតនៃព្រះរាជបណ្ណាល័យកម្ពុជា

ហាណូយនៅថ្ងៃ ៣ ខែយ៉ាំងវីយេឆ្នាំ ១៩៣៥

ហាន់ហ្វាំងសាលាស្រាវជ្រាវប្រវត្តិសាស្ត្រ ក្នុងប្រទេសឥណ្ឌូស៊ីន របស់បារាំងសែសនៅហាណូយ ជំរាបមកលោកស្រីការបឺឡែស ជាអ្នកគ្រប់គ្រងព្រះរាជបណ្ណាល័យ ក្រុងភ្នំពេញ ។

ខ្ញុំបាទផ្ញើសៀវភៅភាសាខ្មែរពន្យល់អំពីសិលាចារឹកនៅនគរវត្ត បកជូនលោកស្រី ១ កញ្ចប់ដោយឡែក ឯការម្ដកថាសៀវភៅសិលាចារឹកដែលលោកស្រីឲ្យខ្ញុំផ្ញើមកជូននោះ ចាំដល់សៀវភៅខ្មែរពន្យល់មិនអក្ខរានុក្រមព្រមទាំងបទានុក្រមបោះពុម្ពហើយរាល់ការ ខ្ញុំនឹងផ្ញើមកជូនលោកស្រីមិនខាន ពីព្រោះអក្ខរានុក្រមនិងបទានុក្រមនេះជាការមានប្រយោជន៍ សម្រាប់បំភ្លឺដល់អ្នកដែលត្រូវការមើលសៀវភៅនេះ ។

ឯសិលាចារឹកនោះបានរៀបចំជាលំដាប់តាមឆ្នាំមុន-ក្រោយ ពីលេខ ១ ទៅដល់លេខ ២០ ឯលេខរៀងនោះជាលេខខ្មែរបុះលើសន្លឹកសៀវភៅជួងខាងឆ្វេងត្រង់ខាងលើ នៅក្រោមលេខនោះមានសរសេរលេខអារ៉ាប់ ទឹកក្រហមហើយដាក់អក្សរ "A ឬ B" ពីមុខ ឯលេខឬអក្សរដែលកត់សំគាល់តាមសៀវភៅស្រុកខ្មែរ ភាគទី ៣ របស់លោកអាអ៊ីមូនីយេរនេះ តាមសេចក្ដីដែលខ្ញុំយល់ឃើញថា មិនត្រូវយកមកចុះជាជីកង់សៀវភៅនេះទេ ប៉ុន្តែលេខអក្សរដែលកត់សំគាល់នោះមានប្រយោជន៍ សម្រាប់យកទៅចុះនៅហាត់ពោសិលាចារឹក ២ ដែលមាននៅ

ទំព័រខាងចុងសៀវភៅនេះ ១ ទៀតលេខនឹងអក្សរដែលគត់សំគាល់មាន ចុះក្នុងក្រាំងផែនទី ២ ដែលខ្ញុំផ្ញើមកជូនជាមួយនឹងសំបុត្រនេះ ៗ ឯក្រាំងផែនទីនេះត្រូវរើសរកជាងគំនូរខ្មែរ ១ អាចឲ្យយកក្រាំងផែនទីនេះទៅផ្ទឹម ហើយត្រូវកត់សំគាល់ត្រង់កន្លែងដែលចុះជាលេខអារ៉ាប់នោះហាត់ដោ ត្រូវឲ្យចុះជាលេខខ្មែរវិញ ដូចជាលេខអារ៉ាប់ 2 ត្រូវដាក់ជាលេខខ្មែរ ២ វិញ ត្រង់លេខអារ៉ាប់ 10 ឲ្យដាក់ជាលេខខ្មែរ ១០ វិញ ។ល។

១ ទៀតមុននឹងបោះពុម្ពសៀវភៅនេះ សូមប្រគល់បញ្ជូនហាត់ដោ ២ ព្រមទាំងសេចក្តីពន្យល់អក្សរខ្មែរទៅខ្ញុំវិញ ដើម្បីនឹងមើលពិនិត្យផ្ទៀងផ្ទាត់ឲ្យត្រឹមត្រូវក្រែងមានពាក្យខុសឆ្គង សំដីគាថា នឹងរបៀបប្រែអក្សរសិលាចារឹកទាំងប៉ុន្មាន នាំឲ្យអ្នកប្រាជ្ញប្រទេសខ្មែរ មានសេចក្តីងឿងឆ្ងល់ជាធំ ដោយហេតុមានសរសេរប្លែក ៗ ពីគ្នា ។ លុះដល់ពិនិត្យទៅឃើញមិនសមរម្យ ដូច្នោះហើយមុខជាពួកអ្នកប្រាជ្ញស្រុកខ្មែរនឹងពោលថាខ្ញុំមើលអក្សរសិលាចារឹកនោះពុំសូវច្បាស់ ហើយក៏មានសេចក្តីបំណងនឹងកែប្រែអក្សរនេះ សូមលោកស្រដីកបទៅលោកអ្នកប្រាជ្ញក្នុងស្រុកខ្មែរផងថា សូមកុំចង់កែប្រែអក្សរនោះជាការឥតប្រយោជន៍ទេ ពីព្រោះអក្សរទាំងប៉ុន្មាននេះ ខ្ញុំបានផ្ទៀងផ្ទាត់ដោយការម៉ត់ចត់ ៣ ឬ ៤ ដងហើយនឹងគំរូដែលថតពីសិលាចារឹកបុរាណនោះហើយ ។ ប៉ុន្តែសូមឲ្យលោកជាអ្នកប្រាជ្ញពិនិត្យត្រង់អក្សរចារឹកណាដែលមានទាស់ខុស អក្សរនេះ

សម្រាប់យកទៅដាក់បទានុក្រមខាងចុងសៀវភៅ កាលបើមានអក្សរត្រូវប្រែប្លែកយ៉ាងណា ៗ ឲ្យលោកអ្នកប្រាជ្ញស្រុកខ្មែរផ្ញើមកខ្ញុំ ៗ នឹងបានពិនិត្យផ្ទៀងផ្ទាត់អក្សរនោះឲ្យត្រឹមត្រូវឡើង ព្រោះខ្ញុំមិនចេះសព្វគ្រប់ ខ្ញុំនឹងរើសពាក្យណាដែលលោកអ្នកប្រាជ្ញបានកែប្រែត្រឹមត្រូវ ហើយនោះយកទៅដាក់បញ្ចូលជាមួយនឹងពាក្យដែលខ្ញុំបានសរសេរតាមច្បាប់ដើម ៗ

សេចក្ដីចុងបំផុតខ្ញុំសុំផ្ញើសេចក្ដីរាប់អានយ៉ាងខ្ពស់មកអ្នក

ស៊ីញេ: សេដេស

ំយ ប្យកា សិងី

របស់អាចារ្យ ហ៊ឹម ក្រុមពុទ្ធសាសនបណ្ឌិត្យ

រៀបរៀង (ត)

## ១៣ បំពើនប្រយោជន៍

តំបន់ណាមួយដែលឃើញទោសក្នុងការល្ងង់ខ្លៅហើយ ទំនុកបំរុងសាលារៀនតែងបញ្ជូនកុមារ ឲ្យចូលរៀនតាមបញ្ញត្តិរបស់រាជការ តែ ១ ដំណា ២ ដំណាទៅ តម្បន់នោះសឹងតែដេរដាសទៅដោយអ្នកចេះដឹង អ្នកចេះដឹងនេះហើយដែលជាអ្នកលើកវិជ្ជាឲ្យរុងរឿង ជាអ្នកលើកស្រុកទេសឲ្យថ្កុំថ្កើង ជាអ្នកលើកទ្រព្យសម្បត្តិឲ្យស្តុកស្តម្ភ ជាអ្នកលើកប្រ-យោជន៍ក្នុងឥធលោកនឹងបរលោកឲ្យវិសេសវិសាល ។

## ១៤ សប្បុរិសធម៌

អ្នកចេះដឹងជាអ្នកកាន់ធម៌ ៧ ប្រការដែលឈ្មោះថាសប្បុរិសធម៌ ។ នេះ បានរៀបរាប់ខាងដើមរួចហើយចំណែកខាងមិនដឹង ឥឡូវនេះនឹងពណ៌នា ចំណែកខាងដឹងដូចមានសេចក្តីតទៅនេះ, ១ ដឹងហេតុគឺដឹងថា អំពើនេះជាហេតុនាំយកសេចក្តីទុក្ខមកឲ្យ អំពើនេះជាហេតុនាំយកសេចក្តីសុខមកឲ្យ ដឹងយ៉ាងនេះហើយអាចនឹងឲ្យសន្សំយកតែហេតុដែលល្អៗ, ២ ដឹងផលគឺដឹងថា សេចក្តីទុក្ខមកពីផលទុច្ចរិត សេចក្តីសុខមកពីផលសុចរិត ដឹងយ៉ាងនេះហើយអាចនឹងឲ្យធ្វើតែអំពើសុចរិត ដើម្បីនឹងទទួលផលសុខ, ៣ ដឹងប្រមាណខ្លួនគឺដឹងថា ខ្លួនអញមានជាតិត្រកូលវ័យចំណេះវិជ្ជា ទ្រព្យសម្បត្តិនឹងកេរ្តិ៍ឈ្មោះយសស័ក្តិត្រឹមប៉ុណ្ណេះ ដឹងយ៉ាងនេះហើយ

អាចនឹងឲ្យមានសណ្ដាប់ធ្នាប់ចេះទុនលំនេះនគរពេញស្រស់ ទាំងលោកអ្នកប្រាជ្ញ លោកអ្នកធំ, ៤ ដឹងប្រមាណភោជនាហារ គឺដឹងថា ស្វែងរកអាហារបានមកយ៉ាងនេះ បរិភោគទៅប្រកបដោយទុក្ខ បានមកយ៉ាងនេះបរិភោគទៅប្រកបដោយសុខ ដឹងយ៉ាងនេះហើយអាចនឹងឲ្យស្វែងរករបរដោយត្រឹមត្រូវ វៀរការចិញ្ចឹមជីវិតខុស, ៥ ដឹងកាលគឺដឹងវេលាពេលថា ពីក្មេងខំរៀនចំណេះវិជ្ជាទៅទល់នឹងអាយុ ២៥ ឆ្នាំ ដល់កណ្ដាលអាយុខំសន្សំទ្រព្យសម្បត្តិដែលគួរនឹងគន្លងធម៌ ដល់ខ្លួនចាស់ខំស្រមរៈរកធម៌អាថ៌ជាគ្រឿងទ្រទ្រង់របស់ខ្លួន ដឹងពេលយ៉ាងនេះហើយខំប្រកបឲ្យត្រឹមត្រូវតាមដឹង ដើម្បីចំរើនខ្លួនតាំងពីលោកនេះរហូតទៅលោកខាងមុខ, ៦ ដឹងបុគ្គលគឺដឹងថា នេះជាមនុស្សពាល នេះជាបណ្ឌិត ការសេពគប់នឹងមនុស្សពាលជាការនាំខ្លួនឲ្យវិនាស សេពគប់នឹងបណ្ឌិតរមែងនាំខ្លួនឲ្យបានសេចក្ដីសុខចំរើនគ្រប់យ៉ាង ដឹងយ៉ាងនេះហើយអាចនឹងឲ្យគិតជ្រើសរើសរកសេពគប់តែនឹងពួកបណ្ឌិត ដើម្បីផលប្រយោជន៍ ២ ប្រការ គឺឥធលោកនឹងបរលោក. ៧ ដឹងបរិសទ្យគឺដឹងថា ប្រជុំជននេះកាលអញចូលទៅរកនឹងប្រព្រឹត្តដោយកាយដូច្នេះ ដោយវាចាដូច្នេះ ដោយចិត្តដូច្នេះជាដើម ដឹងយ៉ាងនេះហើយអាចនឹងធ្វើខ្លួនឲ្យមានជំនឿក្នុងទីប្រជុំជន ចៀសចាកសំណើចនឹងដំណេះដំនៀលគ្រប់យ៉ាងទៅបាន ។

## ១៥ សុភាសិត

អ្នកចេះដឹងដូចអណ្ដាតអាចដឹងរសជាតិ ចំណែកឯអណ្ដាតនោះទោះរសជាតិអ្វី ៗ មួយមកប៉ះពាល់ហើយ អាចនឹងដឹងបានថាសាបប្រៃជាដើមក្នុងមួយរំពេច ធម្មតាអ្នកចេះដឹងអាចដឹងនូវសប្បុរិសធម៌ ៧ ប្រការមានដឹងហេតុជាដើមដោយប្រាជ្ញា ៗ ម្យ៉ាងទៀតអ្នកចេះដឹងមិនសូវត្រេកត្រអាល ដោយអំពើដែលធ្វើទៅហើយរមែងឲ្យផលអាក្រក់ ដូចជាខ្សែចងរឹតរួតខ្លួនឲ្យជាប់នូវក្នុងសង្សារវដ្ដ ជាអ្នកមានស្មារតីភ្ញាក់រឭកកំណត់បណ្ដេញបង់នូវសេចក្ដីលោភនិងអាក់អន់ចិត្តក្នុងលោក ដូចសេះដ៏ចំរើនគឺនាយសារថីទូន្មានហើយ មានស្មារតីភ្ញាក់រឭកប្រុងខ្លួនការពារនូវរំពាត់ មិនឲ្យធ្លាក់ចុះលើខ្លួនបាន ៗ

## ១៦ ការចំរើនចំណេះវិជ្ជា

អ្នករៀនចំណេះវិជ្ជាចង់ចេះដឹងច្រើន គប្បីប្រកបអង្គ ៤ ប្រការឲ្យបាន អង្គ ៤ នោះ គឺ សុ. ចិ. បុ. លិ. ៗ សុ សុណេយ្យ គប្បីស្ដាប់ ចិ ចិន្ដេយ្យ គប្បីគិត បុ បុច្ឆេយ្យ គប្បីសួរ លិ លិខេយ្យ គប្បីកត់ត្រា អង្គទាំង ៤ នេះជាអង្គរបស់អ្នកប្រាជ្ញគឺថា អ្នករៀនសូត្រលុះ

តែប្រកបដោយអង្គ ៤ នេះទើបបានជាអ្នកបេះដូង បើប្រាសចាកអង្គ ៤ នេះហើយ ទោះរៀនតាំងពីក្មេងដល់ចាស់ផងក៏គ្មានបេះដូងឡើយ ។

## ១៣ គុណវិជ្ជា

អ្នកចេះចំណេះវិជ្ជាមានចេះបឋមវិជ្ជាជាដើម មិនដែលធ្លាក់ខ្លួនចុះទៅជាមនុស្សកាប់គាស់សែងការដោយកំឡាំង មិនដែលក្ខនថយទៅជាមនុស្សស្ទួយឈ្មោះឥតយសស័ក្តិ មិនដែលសៀបព្រៀបដល់ស្ពាយសំពាយដើរតាមក្រោយអ្នកដទៃ មិនដែលខ្វះខាតញាតិមិត្តខ្សត់អត់ឃ្លានឡើយ ។ អ្នកដែលចេះដឹងគឺចំណេះនេះឯងតែងយើតយោងអន្ទងដឹកនាំឲ្យណាសវែកង ទោះនៅក្នុងស្រុកស្រែចំការក៏តែងចេះធ្វើស្រែចំការដោយតំរិះប្រាជ្ញា ឲ្យកើតផលប្រយោជន៍បរិបូណ៌ទៅបានមិនទាល់ក្រ វែងមានកេរ្តិ៍ឈ្មោះក្រអូបជាអ្នកល្បីល្បាញខ្ចរខ្ចាយសព្វស្រុក ទោះដើរទៅកាន់ស្ថានណាមិនដាក់អន្ទក់ទៅផងក៏មិនដែលអត់ឃ្លានឡើយ វែងបានយសស័ក្តិអំពីសំណាក់ស្តេចនឹងនាហ្មឺនធំ ច្រើនរុងរឿងជាអ្នកដើរមុខអ្នកដទៃ ហើយជាអ្នកចិញ្ចឹមគេឯងផង តែងតែបរិបូណ៌ញាតិមិត្តចោមរោមពឹងពាក់ចំណេះ ច្រើនមានលាភមិនដែលខ្វះខ្នះ ច្រើនពេញលេញទៅដោយសេចក្តីអំណរ ទោះស្រុកអំណត់អត់ឃ្លានយ៉ាងណា គង់មានញាតិមិត្តជួយឧបត្ថម្ភគាំទ្រដោយអាហារនឹងសម្លៀកបំពាក់ ទោះមានគ្រោះ

ធ្លាក់ដល់ជាប់ទោសទុក្ខ គង់បានរួចជាសុខវិញក៏មាន ពាក្យដែលថាជាប់ទោសនោះជាពាក្យថាក្រែងទៅទេ តាមពិតនោះមិនដែលមានទោសអ្វីដូច្នោះ ព្រោះអ្នកចេះដឹងជាអ្នកមានភ្នែកភ្លឺសព្វសាយ វិស័យអ្នកមានភ្នែកភ្លឺមិនដែលដើរទៅជាន់បន្លា ដែលខ្លួនមើលឃើញច្បាស់នោះទេ ដូចព្រះសម្មាសម្ពុទ្ធព្រះអង្គជាអ្នកប្រាជ្ញធំក្នុងលោក ព្រះអង្គមានចក្ខុភ្លឺក្រៃលែងលោកហើយនៅពីលើ ដូចនៅលើកំពូលភ្នំអាចក្រឡេកមើលឃើញគ្រប់ទិសឥតកំបាំង អំណាចមិនកំបាំងដូច្នោះ បានជាព្រះអង្គជម្រុះចោលអាក្រក់ទុកតែល្អ ចោលខុសទុកតែត្រូវ បន្សាត់បង់ទុក្ខយកតែសុខម្យ៉ាង អ្នករៀនសូត្រតាមពាក្យប្រៀនប្រដៅរបស់ព្រះអង្គរមែងគ្មានជាប់ទោសដូច្នោះទេ កុំថាដល់ទោសធ្ងន់សូម្បីគ្រាន់តែឈ្មោះប្រកែក ឬកើតក្ដីក្ដាំជាប់កំណោះបន្តិចបន្តួចក៏មិនគប្បីមានដល់អ្នកភ្នែកភ្លឺនោះឡើយ ។

## ១៨ ផលប្រយោជន៍វិជ្ជា

មានទ្រព្យពុំស្មើនឹងមានវិជ្ជា ទ្រព្យសម្បត្តិតែងវិនាសទៅដោយហេតុផ្សេង ៗ ឯវិជ្ជាដែលចេះដឹងហើយឥតមានវិនាសចោរលួចយកពុំបាន អ្នកមានចំណេះវិជ្ជារមែងមានលាភ អំពីមហាក្សត្រិយ៍ពីនាហ្មឺនសព្វមុខមន្ត្រីពីសេដ្ឋីគហបតីទឹងអំពីអ្នកស្រុកផងគ្នាតែងបូជា មិនតែប៉ុណ្ណោះទោះ

ទេវតាក៏តែងជួយទំនុកបំរុងមិនស្វះមើលចំណាំ ។ អ្នកដែលចេះចំណេះវិជ្ជាមិនមែនមានផលប្រយោជន៍តែប៉ុណ្ណោះទេ នៅមានច្រើនជាអនេកទៅទៀត មិនអាចនឹងនាំយកមករៀបរាប់ឲ្យអស់បាន នាំមកដំណាលប៉ុណ្ណោះនេះ គ្រាន់តែនឹងពន្យល់អស់លោក-អ្នកឲ្យពេញចិត្ត ឲ្យមានគំនិតគិតប្រាថ្នាចំណេះវិជ្ជាដល់ខ្លួននឹងកូនចៅចៅសន្តាន ឲ្យចេះដឹងគ្រប់ ៗ គ្នាទៅ ។

វ័យបឋម ត្រូវរៀនវិជ្ជា សង្ខេបតែប៉ុណ្ណោះ ។

អធិប្បាយអំពីរចនាខ្មែរ

ដោយលោកម៉ារសាល ហាងហ្សាង់ គ្រប់គ្រងបុរាណស្ថាន

នៅអង្គរ

# សុន្ទរកថា

## របស់លោកម៉ាសាលចាងហ្វាងគ្រប់គ្រងបុរាណស្ថាន នៅអង្គរ
## សំដែងនៅមន្ទីរព្រះរាជបណ្ណាល័យ កម្ពុជា

កាលនៅថ្ងៃ ១ ឧកត្តូប ឆ្នាំ ១៩៣៧

ឱកាសនេះ ខ្ញុំមានសេចក្ដីសោមនស្សសាទរនឹងអំណរគុណអ្នកស្រីការប៉ឺឡែស ជាច្រើន ក្នុងការដែលអ្នកស្រីដឹកនាំខ្ញុំ ឲ្យបានមកជួបជុំនឹងបណ្ដាអស់លោកខេមរជាតិទាំងឡាយនៅក្នុងមន្ទីរនេះ ក្នុងវេលាមុនដែលខ្ញុំនឹងចេញចាកជាដាច់ខាតអំពីប្រទេសឥណ្ឌូស៊ីននេះទៅ ។

ខ្ញុំមានបីតិរីករាយពន់ពេកណាស់ ដែលខ្ញុំបានឱកាសមកថ្លែងសេចក្ដីមេត្រីចំពោះអស់លោកខេមរជាតិទាំងពួង ខ្ញុំសូមឱកាសនេះ ដើម្បីនឹងថ្លែងសេចក្ដីនឹករលឹក នឹងអារម្មណ៍ដែលខ្ញុំបានទទួលដ៏ជោកជាំមកយូរហើយ ដោយខ្ញុំបានមកប្រសព្វនឹងជនជាតិខ្មែរ តាំងពី ២០ ឆ្នាំមុននេះ ៗ

កាលខ្ញុំនៅក្មេង គ្រាដែលនៅជាកូនសិស្សនៅឡើយ ខ្ញុំបានសិក្សាទៅឃើញលក្ខណៈក្បាច់ចនារបស់ឡាតាំង ក្រិក អេស៊ីប ស៊ីយោង សាលដេអាង នឹងចនាឥណ្ឌាខ្លះដែរ តែខ្ញុំសង្កេតមើលទៅឃើញថា ចនាអំពាលនោះ មិនទាន់ចូលក្នុងចំពូកចនាដ៏ប្រសើរថ្លៃថ្លាទៅឡើយ ៗ ចំណែកឯចនាខ្មែរវិញ ខ្ញុំមិនដែលប្រទះឃើញ មិន

ដែលបានស្គាល់សោះឡើយ ដោយហេតុនៅប្រទេសបារាំងគេទុកជារចនាបន្ទាប់បន្សំសិនត្រាប់តាមយ៉ាងរចនាឥណ្ឌា ។

លុះខ្ញុំមកដល់ភ្នំពេញហើយ បានទទួលមុខក្រសួងគ្រប់គ្រងបុរាណ-ស្ថានអង្គរ អំពីនោះមកខ្ញុំក៏ផ្ដើមសិក្សា ស្រាវជ្រាវដោយពិស្ដារឆ្ងាយទូលាយទៅហើយ ទើបបានយល់ច្បាស់ថា រចនាខ្មែរជារចនា ១ ដោយឡែកផ្សេង សិងមានអានុភាពនឹងគុណសម្បត្តិដ៏ប្រសើរស្មើនឹងរចនាតាំងប៉ុន្មាន ដែលពួកអ្នកប្រាជ្ញបានរុករានរកទៅឃើញហើយ លោកទុកជាគោលរចនានៅលោកនេះ គឺថា កម្ពុជរចនាមិនមែនជារចនា ១ ដ៏នៅក្នុងអាណាខែត្រឥណ្ឌានោះទេ ទាំងមិនមែនជាជាងឥណ្ឌាមកធ្វើប្រាសាទនគរវត្ត បាយ័ន តាកែវ បន្ទាយស្រី ។ល។ នោះទេ គឺជារចនារបស់ជាតិខ្មែរស្មោះតែម្ដង បើមិនទេសោតសុំឲ្យយករចនារបស់ជាតិទាំងពីរមកផ្ទៀបគ្នាមើល ក៏នឹងអាចឃើញបានថា ទទៃពីគ្នាតែម្ដង ខ្ញុំបានតាំងចិត្តចង់ចាំមើលមកយូរហើយឲ្យតែមានអ្នកណាមួយដែលអាចយករចនាយ៉ាងឯណានីមួយដែលជារបស់ឥណ្ឌាសុទ្ធ មកផ្គូឲ្យឃើញដូចគ្នាសុទ្ធសួននឹងរចនាខ្មែរនៅបុរាណស្ថានតាំងប៉ុន្មាននៅតំបន់អង្គរ តែជាការទទេដោយពុំដែលបានឃើញអ្នកដែលអាចដូច្នោះសោះឡើយ ។

បើនឹងពោលឲ្យច្បាស់លាស់ទៅទៀត គឺថារចនាខ្មែរចេញមកពីរចនាឥណ្ឌា ដូចគ្នានឹងរចនាបារាំងសែសចេញមកពីរចនាឡាតាំង ក្រិក នោះឯងដែរ ក៏ប៉ុន្តែមិនដែលមានអ្នកប្រាជ្ញរចនាណា មកថារចនាបារាំងសែសជារចនាឡាតាំងឬក្រិកនោះទេ ដ្បិតរចនាបារាំងសែសនេះដូចរចនាខ្មែរ ដែលចេះប្រែទៅរកអានុភាពនឹងសេចក្តីលំអក្នុងខ្លួនរបស់ជាតិបានដោយងាយ ៗ

នៅមានពាក្យគេពោលមួយកន្លែងទៀតថា "ខ្មែរគ្មានចេះក្នុងក្បួនចម្លាក់រចនាទេ" ត្រង់នេះខ្ញុំសូមអស់លោកចូរមើលចម្លាក់រចនាដែលឆ្លាក់នៅលើរូបទាំងប៉ុន្មាន ដែលគេទើបនឹងគាស់រកឃើញនៅភ្នំគូលេន នឹងបណ្តាចម្លាក់បណ្តែតនៅលើប្រាសាទនៅលើផែនថ្ម សឹងគេឆ្លាក់ទុកនៅបុរាណស្ថានទាំងប៉ុន្មានក្នុងក្រុងកម្ពុជា ក៏អាចឃើញបានថាចម្លាក់អំបាលនោះជារបស់ខ្មែរ ឬមិនមែនរបស់ខ្មែរហើយ ៗ

កាលនឹងពោលដោយសង្ខេប ត្រូវយល់ថា សេចក្តីចេះដឹងទាំងពួងនឹងសេចក្តីស៊ីវិល្សរបស់ខ្មែរ មានមកជាអន្លើហើយ គឺមានមកមុនសម័យអារ្យធម្មឥណ្ឌាផ្សាយមកដល់កម្ពុជានោះទៅទៀត រចនាឥណ្ឌាដែលផ្សាយចូលមកក៏ពិត តែត្រឡប់លាយចូលគ្នាក្នុងអារ្យធម្មបុរាណរបស់ខ្មែរទៅវិញទេ មិនមែនខ្មែរចំឡងយកបែបឥណ្ឌាមកទាំងស្រុង ឬក្រាប់តាមទាំងមូលដោយឥតគំនិតនោះទេ ៗ

ត្រង់ដែលខ្ញុំថា «ខ្មែរមានអក្សរធម្មមកមុនហើយ ក្រោយនោះទើបមានអក្សរធម្មឥណ្ឌាផ្សាយចូលមកដល់» ត្រង់នេះសូមឲ្យអស់លោកពិចារណាមើលគ្រឿងប្រើប្រាស់ គ្រឿងសស្ត្រាវុធ និងគ្រឿងសំ-លៀកបំពាក់របស់ខ្មែរដែលគេឆ្លាក់ជារូបភាពនៅជញ្ជាំងប្រាសាទនៅអង្គរ និងគ្រឿងប្រដាប់ដែលខ្មែរប្រើតាំងពីនោះមកដល់សម័យឥឡូវនេះក៏អាចឃើញនឹងភ្នែកជ្រាបបានហើយ ។

ឯត្រង់ពាក្យដែលអ្នកខ្លះគេថា «ខ្មែរសព្វថ្ងៃនេះជាខ្មែរ១ យ៉ាង មិនមែនជាប់ពូជពង្សវង្សសាលោហិតអំពីខ្មែរបុរាណក្នុងសម័យអង្គរនេះទេ» ត្រង់នេះ សូមឲ្យអស់លោកត្រួតមើលក្នុងសៀវភៅរបស់លោក ល្វី-ហ្វីណូត៍ នឹងសៀវភៅលោកសេដេស ក៏អាចនឹងភ្នែកជ្រាបបានដោយច្បាស់លាស់ ។

រីឯខ្មែរមាននៅឯណា ? លោកទាំងឡាយគង់ជ្រាបច្បាស់ហើយថា ប្រទេសកម្ពុជាមានបុរាណស្ថានដ៏ហើយដោយថ្ម សិងដេរដាសពាសពេញក្នុងព្រៃនគរនេះហើយ តែកុំថាឡើយមានច្រើនដល់ម្លោះ សូម្បីមានតែប្រាសាទនគរវត្ត និងប្រាសាទបាយ័នប៉ុណ្ណោះ ក៏ល្មមជាក័ស្តុតាងឲ្យខេមរៈជនាមានជីវិតរស់នៅអស់កាលដ៏យូរទៅបានហើយ ។

ក្នុងទីបំផុតនេះ ខ្ញុំសូមអស់លោកខេមរជាតិគប្បីជ្រាបថា ខេមរៈជ[...]
សព្វថ្ងៃនេះបានជាប់ពូជពង្សសាច់សាលោហិតមកអំពីពួកខ្មែរ ដែលសា[...]

បូរាណស្ថាន (សឹងជាស្ថានដែលមហាជនក្នុងនានាប្រទេសនៅលោកនេះទាំងមូល បានខ្មីឃ្មាតកាត់វាលចូលព្រៃឆ្លងភ្នំឆ្លងសមុទ្រឆ្លងទ្វីបមកសិក្សាមកមើលជុំទិស លុះបានឃើញហើយ ក៏មានសេចក្តីស្ងើចនឹងទឹក ស្ញែងកោតឫទ្ធិកោតប្រាជ្ញាយោបល់ជាយ៉ាងក្រៃពេក ) ប្រទេសកម្ពុជាមានអារ្យធម៌ចំរើនដោយចំណេះវិជ្ជាច្រើន រាប់តាំងអំពីវិជ្ជាធ្វើសំពត់ក្រមា កាព្យឃ្លោង ល្ខោន ចម្រៀង គ្រឿងប្រដាប់ប្រើប្រាស់ដរាបទាំងផ្ទះសំបែងជាដើមទៅ ។ ខ្ញុំសូមខេមរជនទាំងឡាយគប្បីយកចិត្តទុកដាក់ខិតខំសង្កេតសិក្សាមើលឲ្យឃើញច្បាស់លាស់នូវពង្សាវតារ រចនារបស់ជាតិ ឲ្យឃើញយល់ពិតប្រាកដឡើង ដើម្បីនឹងបានរក្សាកេរ្តិ៍ដំណែលនៃអារ្យធម៌របស់ជាតិ ដែលលោកបុព្វបុរសបានរិះរកហើយបងទុកមកនោះឲ្យស្ថិតស្ថេរគង់វង្សរហូតកល្បាវសាន ។

ចំណែកឯខ្លួនខ្ញុំវិញ ក៏នៅតែរករកសិក្សាក្នុងក្បួនខេមររចនានោះតទៅទៀតដែរ ដ្បិតការសិក្សានេះ អាចនឹងធ្វើឲ្យខ្ញុំមានអារម្មណ៍ចាំជាប់ថា ខ្ញុំនៅតែបានកប់ប្រសព្វនឹងជនជាតិខ្មែរជានិច្ចដោយមិនមានភ្លេចតទៅលុះអស់ជីវិត ។

## បញ្ជីសៀវភៅផ្សេងៗ

# របស់នានាជាតិ សិងនៅក្នុងព្រះរាជបណ្ណាល័យ

តាមទំនៀមរបស់ប្រទេសទាំងឡាយដែលចំរើនហើយ កាលនៅក្មេងគេទៅសិក្សាឯសាលារៀនផ្សេងៗ កាលធំឬចាស់ហើយ គេទៅសិក្សាឯបណ្ណាល័យ គឺមន្ទីរធំដែលប្រមូលនូវគម្ពីរក្បួនខ្នាតផ្សេងៗ ទុកសម្រាប់ព្រះនគរ ដូច្នេះលោកអ្នកទាំងឡាយ ប្រហែលជាជ្រាបហើយថា ព្រះរាជបណ្ណាល័យកម្ពុជា ជាទីឃ្លាំងប្រមូលនូវក្បួនខ្នាតគ្រប់មុខ ទុកសម្រាប់ព្រះនគរខ្មែរ ជារបស់ដែលព្រះរាជបណ្ណាល័យ ទិញដូរមកខ្លះក៏មាន គេធ្វើអំណោយមកខ្លះក៏មាន កាលចាត់ចូទាត់ដោយមុខៗ ឬដោយពួកៗទៅ ឃើញមានជាច្រើនយ៉ាង ស្ទើរតែគ្មានខ្វះអ្វី សៀវភៅទាំងនេះប្រមូលមកទុកជាតម្រាឲ្យអ្នកនគរសិក្សា កាលអ្នកណាមួយត្រូវការសៀវភៅអ្វីដែលមាននៅទីនោះ អាចនឹងខ្ចីមកមើលបាន ឬអាចចូលទៅមើលនៅទីនោះក៏បាន ដូចដែលធ្លាប់ធ្វើជាយូរឆ្នាំហើយ ក៏ប៉ុន្តែមើលទៅឃើញដូចជាមិនទាន់ជ្រួតជ្រាបទូទៅ ថាមានសៀវភៅអ្វីខ្លះ ស្ដាយណាស់ដែលមិនសូវមានឱកាសនឹងធ្វើសេចក្ដីកយការឲ្យល្អិតគ្រប់ៗសៀវភៅ ឲ្យបានសព្វគ្រប់ដោយពិស្ដារ ឱកាសនេះទើបចាត់កយការដោយពួកៗ តាមដែលមាននៅ ជូនជាដំណឹងដល់អស់លោក-អ្នកទាំងឡាយ

បានផ្សាបជាំទំនងៗ ប៉ុណ្ណោះ ដើម្បីថា បើលោក-អ្នកណាត្រូវការ សៀវភៅអ្វីទៅកន្លែងអ្វី អាចនឹងស៊ើបសួរតាមពួកនោះៗទៅ បើបានគន់ជាន់នឹងឲ្យខ្លីបាន តាមដែលត្រូវការ ។

## សៀវភៅជាភាសារបស់ជាតិផ្សេង ៗ

| | | | |
|---|---|---|---|
| ១ | ភាសា | បាលី ឬ មគធៈ | |
| ២ | — | សំស្ក្រឹត | |
| ៣ | — | ខ្មែរ | |
| ៤ | — | សៀម | |
| ៥ | — | លាវ | |
| ៦ | — | បារាំងសែស | |
| ៧ | — | អង់គ្លេស | |
| ៨ | — | អាមេរិកាំង មានតិច | |
| ៩ | — | អាលឺម៉ង់ មានតិច | |
| ១០ | — | លង្កា | — |
| ១១ | — | ចិន | — |
| ១២ | — | យ៉ាពុន | — |
| ១៣ | — | យួន | — |

# ១ ផ្នែកភាសាបាលី

## ពួកសៀវភៅព្រះត្រៃបិដក

(ក) ជាអក្សរខ្មែរ ពួកសៀវភៅព្រះត្រៃបិដកគង់ ១០០ ភាគបោះបាន ៤៣ ភាគហើយ ចំណែកគម្ពីរស្ទឹករិត តួព្រះត្រៃបិដកមានចប់ អដ្ឋកថា ដីកា មានដោយច្រើន តែមិនគ្រប់បរិបូណ៌ នៅមាន ពួកគម្ពីរសទ្ទាវិសេស សម្រាប់សិក្សាភាសាបាលីទាំងគម្ពីរបក-រណវិសេសផ្សេងៗ ខ្លះទៀត ។

រួមប្រមាណ ៥០០ គម្ពីរ ។

(ខ) ជាអក្សរសៀម ផ្នែកបាឡីព្រះត្រៃបិដកមានគ្រប់ទាំងចប់ ផ្នែក អដ្ឋកថា មានដោយច្រើន ខ្លះខ្វះមិនគ្រប់បរិបូណ៌ ។

(គ) ជាអក្សរភូមា ផ្នែកបាឡីព្រះត្រៃបិដក មានគ្រប់ទាំងចប់ ផ្នែក អដ្ឋកថាទាំងដទៃទៀត មានមិនគ្រប់ ។

(ឃ) ជាអក្សរឡាតាំង (ព្រះត្រៃបិដកប្រទេសអ៊ឺរុប) ទាំងបាឡីទាំង អដ្ឋកថា មានក្រៃលដែរ តែមិនចប់ ។

(ង) ជាអក្សរលង្កា ទាំងបាឡីទាំងអដ្ឋកថា មានដោយច្រើន តែមិន គ្រប់ ។

(ច) គម្ពីរដំពូកដីកាយោជនា មានតិចណាស់ ដោយមិនទាន់មានគេ បោះពុម្ពឡើង ។

## ២ ផ្នែកសៀវភៅខ្មែរ

(ក) ពួកសៀវភៅធម៌អថ៌ផ្សេង ៗ

(ខ) " ប្រវត្តិសាសនា

(គ) " សុភាសិត ពាក្យកាព្យ

(ឃ) សៀវភៅ វចនានុក្រម

រួមទាំងអស់ប្រមាណ ៣០ រឿង ។

## ពួកសាស្ត្រាគម្ពីរសម្រាយ

(ក) ពួកគម្ពីរ ព្រះសូត្រផ្សេង ៗ

(ខ) " ព្រះអភិធម្ម

(គ) " ទេសនាផ្សេង ៗ

(ឃ) " ជាតក មានទសជាតិជាដើម

(ង) " បឋមសម្ពោធិកថា

(ច) " សុភាសិតផ្សេង ៗ មានច្បាប់ក្រមជាដើម

(ឆ) " អានិសង្សផ្សេង ៗ

(ជ) " រឿងល្ខោនបែបបូរាណ មានរឿងរវង្សសូរវង្សជាដើម
មានច្រើនរឿង

(ឈ) " និទានផ្សេង ៗ ។

រួមប្រមាណ៣០០រឿង ។

## ពួកក្រាំង

(ក) ក្បួនមើលផ្សេង ៗ មានច្រើនយ៉ាង មានក្បួនអត្តជាដើម

(ខ) រឿងល្ខោន មានព្រះជិនវង្ស នឹងភមកេរ្តិ៍ខុះ

(គ) រឿងបុប្ផាខន្ធ

(ឃ) អភិធម្ម គិរីមានន្ទ សតិបដ្ឋានសូត្រ សម្រាប់សូត្រឲ្យអ្នកឈឺស្តាប់ ។

រួមប្រមាណ ៣០ ក្រាំង ។

## ៣ ផ្នែកភាសាសៀម

(ក) ពួកធម៌អាថ៌ផ្សេង ៗ សំដៅសំដែងអំពីកិច្ចបដិបត្តិក្នុងព្រះពុទ្ធសាសនា ទាំងមូល ទាំងជាន់ទាប កណ្តាល ខ្ពស់ មានច្រើនយ៉ាង ។

(ខ) ពួកសៀវភៅធម្មសិក្សា គឺវិន័យ ធម្ម សុភាសិត ពុទ្ធប្រវត្តិ នឹងមហាអសីតិសាវកប្រវត្តិ ។

(គ) ពួកសៀវភៅទស្សនាវដ្តី ចេញពល់ខែ មាន៦គឺ: ធម្មចក្សុ ថ្លែងការណ៍គណៈសង្ឃ វជិរញាណ ពុទ្ធសាសនចក្រ វិទ្យាចារ្យ សិល្បាករ ។

(ឃ) ពួកសៀវភៅពង្សាវតារ គឺពង្សាវតារខ្មែរ ពង្សាវតារសៀម ពង្សាវតារលាវ ពង្សាវតារចិន (សាមកុក) ពង្សាវតារយួន នឹងប្រវត្តិសាស្ត្រសាកល (ពង្សាវតារលោកទាំងមូល) ។

(ង) ពួកសៀវភៅលទ្ធិទំនៀមផ្សេងៗ (មានតិច) ។

(ច) ពួកសៀវភៅវចនានុក្រម មានជាភាសាសៀមសុទ្ធ បាឡីនឹងសៀម សំស្ក្រឹតនឹងសៀម បារាំងនឹងសៀម ។

(ឆ) ពួកសៀវភៅរឿងល្ខោន ជាពាក្យកាព្យខ្លះ ជាពាក្យរាយធម្មតា តាមបែបល្ខោននិយាយទំនើបថ្មីខ្លះ នឹងសៀវភៅកាព្យឃ្លោងរាយ រាយខ្លះទៀតគួរច្រើនយ៉ាង ។

(ជ) សារពត៌មាន (កាសែត) រាយសប្តាហ មាន ២ ច្បាប់ ។

បូករួមមានប្រមាណ ៧០០ រឿង ។

## ៤ ពួកសៀវភៅលាវ

(ក) ពួកសៀវភៅ ធម្មវិន័យផ្សេងៗ ។

(ខ) " រឿងទសជាតិ ។

(គ) " សិក្សារបស់ក្រសួងសិក្សាធិការ ។

(ឃ) " ច្បាប់ព្រហ្មទណ្ឌ រដ្ឋប្បវេណី ។

(ង) " ពង្សាវតារ ។

បូករួមមានប្រមាណ ១៥ រឿង ។

## ៥ សៀវភៅបារាំងសែស

(ក) ពួកសៀវភៅ ពង្សាវតារ បារាំងសែស ។

(ខ) " ពង្សាវតារ ខ្មែរ ។

(គ) " វចនាបុរាណ របស់ជាតិផ្សេង ៗ ។

(ឃ) " សិក្សាថែបជាន់ចាស់ របស់បារាំងសែស ។

(ង) " ទស្សនាវដ្ដី របស់សាលាបារាំងសែសនៅចុងបូព៌ាប្រទេស មាននិយាយពីពង្សាវតារឥណ្ឌា ជាដើម ។

(ច) " ទស្សនាវដ្ដី ចេញរាល់ខែ និយាយពីសាសនានិងវចនា ។

(ឆ) " សព្វវចនាធិប្បាយ និងវចនានុក្រម ។

បូករួមមានច្រើនពាន់សៀវភៅ ។

## ៦ សៀវភៅអង់គ្លេស

(ក) " និយាយពីព្រះពុទ្ធសាសនា ។

(ខ) " ទស្សនាវដ្ដីរាល់ខែនិងសារពត៌មាន ។

បូករួមមានប្រមាណ ២០០ រឿង ។

ចំណែកឯសៀវភៅរបស់សាសន៍ឯទៀត មានបន្តិចបន្តួច ហើយ មិនបាច់រៀបរាប់ ។

# ក្បួនជុំឧទ្យាន៍

# របស់បុរាណ

# (៣)

## បទពំនោល

សាស្ត្រាពីព្រះឥន្ទ្រា ទុកតជាតិជា សណ្ដាប់ទម្លាប់ច្បាស់ច្បង ៗ សិទ្ធិការ្យពិស្ដារគន្លង ទោះបីអ្នកផង បង់ដឹងអស់បូពិនិមិត្រ ។ ព្រះចន្ទ្រនូវព្រះអាទិត្យ កេតុកហូស្ថិត តាពពកមឃា ៗ រន្ទះសូរសព្ទមហិមា ផ្គរបន្ទោរលោហាស៍ មហាឥន្ទធនូបរបុះ ៗ គិរីបពាតិធ្លាយធ្លុះ ធ្លាក់បែករលុះ រលំរណ្ដំរូរខ្ចារ ៗ ប្រថពីប្រែះបែកអស្ចារ្យ ទ្រោមទ្រុឌស្រុតស្រាល រលំរលាយខ្ទេចខ្ទាត ៗ ទោះសត្វទ្វេបាទចតុប្បាទ ឃើញពុំត្រូវខ្វាត កស្រូវហើយត្រូវកាចក្រៃ ៗ ទក្សិណនិរតីឯងវិញ បស្ចិមសោតនៃ ទុត្តរពុំបរិបូណ៌ឡើយ ៗ ទិសបូពាយីនយូរឯងហើយ អគ្នេយ៍ជាត្រើយ ពឹងពាក់សំណាក់ថ្កើងថ្កល់ ៗ ទិសទក្ខៀសានសោតសល់ចំរើនមង្គល មកដល់កូនចៅផងជា ៗ ឯទិសពាយ័ព្យនោះណា ពុំសូវកាចជា មើលនាល់នៅក្នុងក្រៅ ៗ លក្ខណាចរិយាឥតសៅ ចរចូលមុកនៅ ពុំមានភ័យកិតឡើយណា ៗ ត្រូវបុក្យ មពារវេលា មើលមុខមាត់ព ប្រែប្រាណព្ពោះថ្កាននៅឯណា ៗ ឲ្យរៀបប្រដាប់បូជាគ្រឿងគន្ធមាលា ប្រដាប់នូវផ្កាប្រាលស [1] ៗ សំពត់ទាំងផ្គត់សឹងល្អឆ្វេងស្ដាំហើយយក គណ្ឌីអប់ទឹកពិរផង ៗ មាសប្រាក់ឆ្ងៅឆ្លាក់កែវកងចង់ស្មាចង់រង គោកពានសឹងមានធូបទៀន ៗ ចំណីបន្ថែមទៅសែន

---

១ ផ្កាប្រាលស គឺផ្កាព័ណ៌ក្រហម នឹងព័ណ៌ស ។

នៅទីនៅដែន ជុំញាតិសន្ដានទាស់ទុំ ។ ឲ្យសែនបូជាទឹកឃ្មុំ ស្រ្ត
សែកកោគម បន្សំប្រណម្យសំរិទ្ធិសាយ ។ (ឲមព្រះត់ទ្រូនាកយណ៍
ស្រីគន្ធពូបកាយ សូបញ្ចូញ្ចនទ្ធិសុកហាយ) ។ គោះនិមិត្រស្បូគ្រោះហ៍
តាំងឡាយ ព្រះពហូខ្លល់ខ្វាយ ទៅចាប់ព្រះស្បូលេបណា ។
ងងឹតទាំងផ្ដូមេឃា ដូចយប់សោះសោ អ្នកដំកែត្រៃក្រោធផកិត្តា ។
ជាទោសទាស់ទែងកបា នឹងបង់នគរ ឲ្យរៀបូជាជាធំ ។ កេ្សងក្លាត់
សោតស្អាត់ប្រតំ ឲ្យសង់អស្រែម សោតសមបូជានូវពិណ ។ ស្រ្ត
ហោមពិធីអាចិណ្ណ ធ្មួសតិដិន ពិធីតបៈភារបុរាណ ។ ឲ្យបន្ទក់អស់
ហោមសូត្រ ហើយសង្ឃការ និមន្ដអស់គ្រៃន្ទុំសង្ឃ ។ គ្រប់ត្តសោត
ស្អាត់ផ្ចិតផ្ចង់ ធ្វានបួសគ្រប់អង្គ ចំរើនទំពូមន្តរម្យាប់ ។ និមិត្រ
បេលផ្កាយពុំតាប់ ដុះកន្ទុយធាប់ ប្រញាប់កន្ទុយខ្ពស់ឡើង ។ ក្រហម
ដូចរងើកភ្លើង ក្បែតពីជើងទ្រូង ចរបើងជណ្តើមគេដដៃ ។ គោះ
កន្ទុយចុះក្រោមទូប្រល័យ ខុនណាងលៅទៃ ប្រុសស្រីទំងមរណ៍ពុំ
លែង ។ ទឹងកើតកង្វល់ទាស់ទែង ឧត្បាទនោះឯង ឲ្យរៀបបូជា
ហោងណា ។ គោះផ្កាយនៅបូពិទិសា រស្មីជ្រះថ្លា ប្ញក្សល្អប្រសើរ
ប្រាយប្រុះ ។ សិងមានកជទូតពីរក្បោះ ថ្ងៃប្រាំបំពោះ នោះទឹងមក
ដលនឹងផាប់ ។ គោះផ្កាយព្រោងព្រាយគួរគាប់ នៅទិសពាយ័ព្យ រស្មី
ល្អ ៗ ជ្រះភ្លឺ ។ ប្រាំថ្ងៃនោះនៃទឹងត្ដ ពណ៌ដ៏មាះអឹងអឺ ឃានកេ្សងអ្នក

ប្រាជ្ញពន្ទក ។ ពុំនោះរាជទូតចូលមក ប្រះសើរទើងរក ស្រដីពីគេះ
សោះសា ។ គោះផ្កាយនៅទិសទក្ខិណា មានភ័យមហិមា ឲ្យរៀប
បូជាសូត្រ ។ សូត្រព្រះទិព្យមន្តមេត្រី[1] ប្រជាប់សោតក្តី តាមក្បួន
បង្គាប់នេះហោង ។ គោះផ្កាយនិរតីនោះផង ទើងកើតទោសធ្ងន់ មានក្តី
មានទោសហៀបស្លាប់ ។ គោះផ្កាយនៅទិសពាយ័ព្យ មានគេឲ្យ
ទ្រព្យ ពុំនោះនូវសុខសាទរ ។ គោះផ្កាយនៅទិសឧត្តរ មានលាភ
បវរ ទើងអរក្រៃគត់ប្រមាណ ។ គោះផ្កាយនៅទិសឦសាន នោះនៃ
ទើងមាន បង្អួនឲ្យលាភសប្បាយ ។ ហើយឲ្យមើលនិមិត្តផ្កាយ
ទិសទីពណ៌កាយ ទក្សិណបស្ចិមឧត្តរ ។ ល្អិតដូចផ្សែងភ្លើងអម្ពរ ពស្រ្ត
ផងទើងមរណ៍ ទើងបានគ្រោះព្រាត់ព្រាយ ។ គោះភ្លៀងអុរបុះព្រះពាយ
បក់មកខ្លាត់ខ្លាយ ទទិសទាំងបួនប្រើយ ។ ទិសទីបស្ចិមផងក្តី ឧត្តរ
គោះបី រលីមទូរទឹមបម្លែក ។ ទឹកដំក្រៅក្នុងតពន់ពេក ល្អិតល្អន់គ្គ
ឯក អនេកទើងស្លាប់ប្រើនផង ។ គោះភ្លៀងអុរដូចព្យុះហោង ក្សិណ
ស្រកអើងកង ហៅមហាកំណាចក្រៃក ។ គោះភ្លៀងអុរធ្លាក់នោ នៃ
ប្រសើរប្រពៃ ទើងជាមង្គលសួស្តី ។ គោះភ្លៀងអុរដូចមេឃាវៃ ប្រ-
សើរឥតបី ទីស្ថានលំនៅពណ៌កាយ ។ គោះភ្លៀងសៀងស្លូតសព្វសាយ
គុក ៗ ខ្ទរខ្ទាយ ទើងគេប្រសកលជួរទ្រូង ។ គោះភ្លៀងអុរឡើដូចជ្រូង

---

១ មេត្រី ជាឈ្មោះទិព្យមន្ត គឺមហាមេត្រី ។

ទិសបូព៌ាឯត្បូង បស្ចិមឧត្តរពុំជា ។ ទីដ៏ខូចទីដ៏បង់ទគក ឲ្យរៀបបូជា
តាមដោយបង្គាប់ទេះណា ។ នោះគ្រឿងស្រគ្នាក់ធាក ដូចទឹកដោះជា
គុណា ប្រសើរពេកពន់ ។ ស្រុកទេសពិសេសក្រៀមលន់ ដោយសត្វ
តម្បូន ទីដ៏កើតដំណាំគោជនា ។ គ្រឿងទៅដូចអាចម៍គោណា ប្រ-
សើរថ្លៃថ្លា សិរីជាមង្គលសួស្តី ។ ព្រះរាហូចាប់ព្រះចន្ទ្រី អាប់អស់
រស្មី ឲ្យព្រះចក្រីស្អាងអង្គ ។ កក់ជ្រះដំរះស្រួចស្រង់ ហើយទើប
ស្ដេចទ្រង់ ព្រះពស្ត្រសុទ្ធហើយណា ។ ទ្រង់គ្រឿងរុងរឿងជា ។
ប្រេងម្សៅអប់ផ្កា លំអាទៅថ្វាយចន្ទ ។ ព្រះស្រីត្នត្រ័យសោភសម
សួស្តិឧត្តម បង្កក់ដំរីសេះពេង ។ ព្រះរាហូចាប់ព្រះសូរ្យផង ដូច
គ្នាឯងហោង ឲ្យបូររៀបចំដូចគ្នា ។ ឥន្ទធនូចុះទិសបូព៌ា ឲ្យរៀបបូជា
នោះណាទឹងសុខឯងឯង ។ ឥន្ទធនូចុះទិសអគ្នេយ៍ ប្រសើរលើសគេ
រាប់បូជាព្រះឥន្ទ ។ ឥន្ទធនូចុះទិសទក្សិណ ទិសនោះកាចលន់ ឲ្យរៀប
បូជាថ្លៃវិ ។ ឥន្ទធនូចុះទិសនិរតី ទឹងកើតអប្រិយ ឲ្យរៀបបូជា
សន្ទិប ។ ឥន្ទធនូចុះទិសបស្ចិម កាចក្រៃគ្រគតថ្ងួយ ឲ្យរៀបបូជាឲ្យ
ធាប់ ។ ឥន្ទធនូចុះទិសពាយ័ព្យ ពុំកាចពុំគាប់ ឲ្យរៀបបូជាត្រែកអរ ។
ឥន្ទធនូចុះទិសឧត្តរ មានលាភសោះសារ អំណរបូជាទើបបាន ។
ឥន្ទធនូចុះទិសឦសាន ពលជងទឹងមាន ជម្ងឺជម្ងាត់ស្លាប់ហោង ។
ពុំនោះមានរនុកធំផង ធ្វើទោសឲ្យគ្នង ហេតុទុក្ខពុំសុខភិតភ័យ ។

ទោះផ្ទះបន្ទាលនោះនៃ ប្រាក់ដោយព្យ គម្ពុទទិសបូព៌ពេកពន់ ។
ផ្ទះបន្ទាលទិសបូព៌ទក្សិណ បស្ចិមគ្រប់គ្រាន់ ឧត្តរកុះករពុំជា ។
និមិត្របណ្ដាលនោះណា កាចក្រៃមហិមា ឲ្យរៀបបូជាតាមផ្កាយ ។
ទើបព្រះឥសូរសិល្បសាយ ប្រើគ្នាតទាំងឡាយ មកទំដំបូលផ្ទះគេ ។
និមិត្រទាំងនេះឯងឯង ទិសបូព៌អគ្នេយ៍ វារឲ្យសសក្ដា ។ បើបាន
ផ្ទះក្អុតផងណា ប្រែមុខទិសជា ឲ្យសាធុការស្រេចបាន ។ ទោះគ្នាត
ទំទិសក្ដៀសាន នោះសោតនឹងមាន កូនចៅផៅពង្សត្រូវគាប់ ។ ទោះ
គ្នាតទំទិសពាយ័ព្យ ពុំខុសពុំគាប់ ពុំជាពុំកាចឡើយទៃ ។ ទោះគ្នាត
ទំទិសនិរតី ទក្សិណនោះក្ដី បស្ចិមឧត្តរពុំជា ។ ទោះគ្នាតដេះក្លើងចឹក
គ្នា ចូលក្នុងព្រះពន្លា ជ័យឲ្យបូជាឲ្យទាន ។ បើពុំបានធ្វើដោយដាន
ទំនងបុរាណ ឡើយនឹងព្រាត់ប្រាសដល់អគ្គ ។ ទោះគ្នាតចូលក្រោមផ្ទះ
ត្រង់ កណ្ដាលកំឡុង ឲ្យរៀបបូជាពៃថែង ។ សូនរូបស្នងខ្ទឯកឯង
ប្រដាប់តាក់តែង យកផ្ទះប្រគេនសង្ឃបាន ។ ទោះគ្នាតចូលក្នុងគ្រឹះ
ស្ថាន នោះសោតនឹងបាន ក្របីគោសេះដំរី ។ នឹងបានខ្ញុំប្រុសខ្ញុំស្រី
មានជ័យសួស្ដី ឲ្យរៀបបូជាកុំយូរ ។ ទោះគ្នាតទំត្រង់ដំបូល ឯកើត
ពុំយូរ មានលាភនូវបានស៊ីស្រុក ។ ហើយបានមាសប្រាក់ផងទុក
នូវបានក្សេមសុខ ស្រណុកសប្បាយសព្វកាល ។ គ្នាតទំដំបូល
កណ្ដាល ម្ចាស់ផ្ទះអសារ បណ្ដាលនូវក្ស័យផន្ទា ។ តែប្រាំពីរថ្ងៃ

ឯណា ឲ្យរៀបបូជា ទេស្នាកំសាន្តកំសាយ ។ ងដុះឲ្យទ្រខ្វាត់ក្លាយ
យកទៅថ្វាត់ថ្វាយ ព្រះពុទ្ធព្រះធម៌ព្រះសង្ឃ ។ ទោះគ្នាតទំងំបូល
គ្រប់ ឯលិចពុំលង់ ដូចកល់កណ្តាលពុំរួច ។ ទោះគ្នាតបួលដោយ
បង្អួច បុជាឲ្យរួច កើតក្នុងមាសប្រាក់ច្រើនណា ។ ឯរបៀបឲ្យ
រៀបបូជា មាសប្រាក់នូវផ្កា គ្រប់ពណ៌ដោតជា ប្រាយផង ។ សំពត់
សទៅវៃគង ប្រាយទឹកសោតហោង ប្រដាប់គ្រឿសាច់ញាំភ្លា ។
ទៀនធូបគន្ធៈមាលា ថង់ហិបដាក់ស្លា រៀបចំតែតែងឲ្យគ្រប់ ។ បំពង់
ទឹកស្រាឲ្យស្រព្វ ដគ្រឿងដំបានដប់ ប្រិសប់សូនរូបស្អង់ខ្លួន ។ ឲ្យរៀប
សង់ពេធាមួន ឲ្យភ្លាប់ឲ្យល្អួន កម្រាលព្រែព្រំឲ្យស្រព្វ ។ មានទាំង
តាំងយូឬជាំងម្ជប់ បង្អួមផងគ្រប់ នូវស្រែអន្ទ្រដាក់ដង ។ នូវល្អ
សណ្តែកគ្រប់ហោង ប្រដាប់ឥតគ្គង់ បង្អួមសព្វហើយរៀបដាក់ ។
(ទមព្រះឥសូរនាកយណ៍ តន្ទ្រីបរិពាកយ សូបញ្ញាឡានទិស្វាហាយ) ។

## រឿងធនញ្ជ័យបណ្ឌិត

## (តបប់)

ស្តេចស្តាប់ហើយក៏មិនមានព្រះបន្ទូលឡើយ ទ្រង់ស្ងៀម ធនញ្ជ័យ ាបថ្វាយបង្គំហើយ ទៅទារប្រាក់អំពីអស់នាហ្មឺនដែលខ្ចីហើយ ានសំបុត្របោះត្រាយកប្រាក់ច្រើនប្រមាណទឹងយកមិនរួច ហើយយក ាឲ្យប្រពន្ធទូវអាពុកក្មេកម្តាយក្មេក ហើយនៅជាសុខសប្បាយទៅ ។

ឯអស់នាហ្មឺនដែលធនញ្ជ័យយកប្រាក់នោះកើតទំងទឹងធនញ្ជ័យខាំង ស់ ខាំងស្តេចក៏ខ្វល់ណាស់ ស្តេចឲ្យហៅអស់នាហ្មឺន ធំតូច ឃុនហ្មឺន រហាឡឹកមកឲ្យគិតជំនុំ ទឹងបំបរបង់ធនញ្ជ័យចេញហើយ ដ្បិតវាបង្កើត ទាសច្រើនណាស់ ឯអស់នាហ្មឺនស្តាប់ព្រះបន្ទូលបង្គាប់ដូច្នោះហើយ ក៏ ំកគិតជំនុំគ្នាឃើញថា ទឹងបណ្តេញវាឲ្យចុះសំពៅទៅស្រុកចិន ដ្បិត ស្រុកនោះធំហើយគេស្អប់វា តែឃើញវាទៅៈគេគង់សម្លាប់ចោល យើង បានសុខសប្បាយក្នុងនគរ ឯព្រះមហាក្សត្រក៏សប្បាយក្នុងព្រះរាជ-ហឫទ័យ គិតឃើញដូច្នោះហើយយកសេចក្តីទៅក្រាបទូលដោយ ដំណើរដែលបានជំនុំឃើញ ព្រះមហាក្សត្រស្តាប់ហើយក៏ព្រមនឹងឲ្យ ទៅហៅធនញ្ជ័យមកប្រាប់ថា អាជ័យអញនឹងឲ្យឯងទៅនៅស្រុកចិន នឹងគេឯណោះ ដ្បិតស្រុកគេធំ នៅក្នុងស្រុកខ្មែរនេះមិនបានទេ មាន ព្រះបន្ទូលបង្គាប់ឲ្យយកសំពៅ ១ មក ឲ្យធនញ្ជ័យចុះទៅក្នុងសំពៅ ហើយឲ្យយកទៅប្រាសចោលឯស្រុកចិន ឲ្យស្តេចក្រុងចិនសម្លាប់ កាលធនញ្ជ័យទៅដល់ស្រុកចិនហើយ ផ្តាំអស់អ្នកសំពៅដែលគេវិលមក

ស្រុកខ្មែរវិញថា អញផ្តាំទៅប្រពន្ធអញផង កុំឲ្យគិតទុក្ខនឹងអញឡើយ អញនឹងទៅវិញឆាប់ទេ អញសន្មតតែ ៣ ខែ ត្រូវគង់អញទៅវិញ កុំបីព្រួយចិត្តឡើយ ឯអ្នកសំពៅថា អើសិនអញប្រាប់ឲ្យបានទេ ថាហើយចេញសំពៅមកស្រុកវិញ ។

ឯធនញ្ជ័យក៏ដើរទៅកេដ្ឋនាហ្មឺនធំ ចូលទៅដួលឲ្យគេប្រើធ្វើការ ដើរតាមនាហ្មឺននោះទៅគាល់ស្តេចនោះ ឯនាហ្មឺននោះនឹងបានដឹងថា ជាធនញ្ជ័យក៏ទេ ក៏គិតថា ខ្មែរតែផ្កាសមិនបានសួរដណ្តឹងឡើយ ឯធនញ្ជ័យគិតថា បើអញបានប្រាក់ឈ្នួលច្រើន អញនឹងគិតទិញអង្ករ ហើយគិតធ្វើនំកោយនឹងប៉ែនឲ្យមានសរសៃអង្ករឡើងវែង ៗ ហើយនឹងលក់ទិញស៊ីមិនឲ្យក្រពីបាកឡើយ គិតហើយធ្វើនំដូចចិត្តគិតនោះឯង ហើយលក់ឲ្យចិនទិញស៊ី កាលនោះស្រុកចិនមិនទាន់ចេះធ្វើនំទេ ដល់ឃើញធនញ្ជ័យធ្វើដូច្នោះហើយ ក៏បបួលគ្នាមកទិញនំស៊ីៗហើយនិយាយថា អ្នកនេះចេះធ្វើនំល្អណាស់ ឮទៅដល់ស្តេចក្រុងចិន ៗ ឲ្យហៅធនញ្ជ័យ ៗ ទៅដល់ហើយមានព្រះបន្ទូលដណ្តឹងថា ឯងធ្វើនំវែង ៗ មែនឬ ទើបធនញ្ជ័យក្រាបទូលថាមែន ទើបស្តេចមានព្រះបន្ទូលថា នាំយកមកឲ្យអញមើលផង ទើបធនញ្ជ័យវិលមកយកនំនោះទៅថ្វាយ ទើបស្តេចដណ្តឹងថា នំនេះឈ្មោះនំអី ធនញ្ជ័យក្រាបទូលថា នេះហៅនំបញ្ចុក បើនឹងស៊ីឲ្យងើយហើយហាមាត់លើកដៃឲ្យខ្ពស់ទើបបានស៊ីជាពិសារ ឯនំនេះបានជា

ធនញ្ជ័យថាដូច្នោះដ្បិតចង់ឃើញមុខស្តេចក្រុងចិន ដ្បិតឮតែព្រះបន្ទូល ឯព្រះភក្ត្រពុំដែលឃើញ ហើយចង់នឹងវិលមកស្រុកវិញ ឯស្តេចក្រុងចិនឮដូច្នោះហើយឲ្យយកនំនោះមកថ្វាយ ហើយធ្វើដូចជាពាក្យធនញ្ជ័យថានោះឯង ឯធនញ្ជ័យកាលបើស្តេចសោយទំនើបឡើងហើយ ក៏មើលទៅឃើញមុខស្តេចក្រុងចិនហើយថា អញមើលទៅមុខស្តេចក្រុងចិននោះដូចជាមុខឆ្កែ មើលមុខស្តេចស្រុកខ្មែរដូចជាខែពេញបូណ៌មី ឯមហាក្សត្រក្រុងចិនឮធនញ្ជ័យដៀលថា មុខដូចឆ្កែដូច្នោះហើយ ក៏ទ្រង់នូវព្រះក្រោធខ្លាំងណាស់ហើយត្រាស់ថា ឲ្យអស់នាហ្មឺនចាប់យកទៅដាក់គុក ឲ្យដល់ស្លាប់កុំលែងវា ៗ

ឯគុកនោះឯងត្រជាក់ណាស់ បើមនុស្សណាតែទៅដល់ហើយ ក៏ស្លាប់មិនរស់ឡើយ កាលថ្ងៃដែលយកធនញ្ជ័យទៅដាក់គុកនោះមានចិន ១ នោះខុស គេក៏យកទៅដាក់គុកត្រជាក់នោះឲ្យស្លាប់ដែរ គេយកទៅដាក់ជាមួយនឹងធនញ្ជ័យ បានជាពីរនាក់នឹងចិននោះ ឯគុកនោះតែដាក់ហើយមិនបាច់ដាក់ច្រវាក់ដាក់ឃ្នាងទេ តែទៅដល់ហើយដោះចេញអស់ ទើបបញ្ចូលទៅក្នុងគុកនោះឯង ហើយទើបបាំងទ្វារទៅទុកឲ្យស្លាប់ ឯធនញ្ជ័យដឹងជារងាត្រជាក់ណាស់ ហើយបបួលចិនទៅប្រដាល់ចំបាប់ឲ្យក្តៅបែកញើសស្រួលខ្លួន ហើយវិលមកឈប់វិញ បើកាលណាត្រជាក់ណាស់ ក៏បបួលគ្នាទៅដាល់ៗ តែសព្វថ្ងៃឥតមានរងាសោះឡើយ

លុះបានពីថ្ងៃបីថ្ងៃ អស់នាហ្មឺនឲ្យទៅមើលឃើញនៅរស់ ហើយវិលមក ប្រាប់ថា អស់ទាំងអ្នកទោសចិញ្ចឹមទីនខ្លានោះមិនស្លាប់ទេ បើដូច្នោះតើទីងធ្វើដូចម្តេច ទើបអស់នាហ្មឺនថា បើគេមិនស្លាប់ក៏កំហិចុះ ឯចទង្គ័យហើយ ទីងពិនិត្យគិតថា យើងនឹងគិតធ្វើខ្ទង់បង្ហើរ ធ្វើអែកឲ្យត្រូតែយប់ ថ្ងៃដាក់ចេញ គិតឃើញធ្វើខ្ទង់បានហើយបង្ហើរសព្វយប់ បានត្រូទៅដល់ស្តេចៗត្រាស់សំឡេងអែកនោះ ជាប្លែកនឹងសំឡេងសត្វយំ ស្តេចមិនដែលត្រាដូច្នោះហើយស្តេចទូលគន្ធព្រះពជហង្ស័យថា ថ្ងៃមិនដែលត្រាស់យំ តែយប់ត្រអន្ទើត ៗ តែសព្វយប់ ហើយស្តេចហៅនាហ្មឺនមកគិតថា មានវេណាទីងជំជាសត្វអ្វីរាយំនោះ ហើយស្តេចឲ្យហៅហោរមកគូរមើល ឯហោរគូរមើលទៅឃើញហើយក្រាបទូលថា បានជាសត្វនេះរាយំដូច្នោះនេះ ដ្បិតកើតហេតុកង្វន់នគរ បើកើតហេតុឧត្បាតនេះមិនឃើញ សត្វនោះរានឹងស៊ីអស់ទាំងក្រុងនគរនេះមិនខានឡើយ ស្តេចស្តាប់ហើយក៏មានព្រះបន្ទូលថា បើដូច្នោះតើឧត្បាតពីព្រោះអ្វី ហោរគួរមើលឲ្យបានដឹងក៏នឹងធ្វើឲ្យបាំ កុំឲ្យសត្វនោះរាយំស៊ីមនុស្សក្រុងប្រជាជនទាំង-ឡាយ ទើបហោរក្រាបទូលថា ខ្ញុំបង្គំគិតទៅឃើញថា ដ្បិតមានអ្នកប្រាជ្ញ ១ គេយកពីស្រុកខ្មែរមកប្រោសកុំស្រុកយើង ឥឡូវនេះព្រះអង្គដាក់គុកនោះឯង បានជាកើតហេតុដូច្នេះ ឥឡូវនេះមានតែនឹងនិមន្តឲ្យទៅស្រុកខ្មែរវិញទើបបាន ឯព្រះមហាក្សត្រស្តេចក្រុងចិនត្រូវហោរ

ទូលដូច្នោះហើយ ស្តេចភ្ញាក់ព្រះអង្គថា អញមិនដឹងជាអ្នកប្រាជ្ញស្រុកខ្មែរទេ មនុស្សស្រុកខ្មែរមិនដែលមកនៅកេស៊ីផ្តេសផ្តាសទេ បើដូច្នោះឲ្យទៅយកមកនឹងអង្វរសុំទោស កុំឲ្យខឹងនឹងអញឡើយ ឯអមាត្យក៏រត់ទៅរកធនញ្ជ័យដែលនៅក្នុងគុកនោះឯងនាំមកថ្វាយស្តេចហើយ ឯព្រះមហាក្សត្រស្តេចទតទៅឃើញធនញ្ជ័យមកដល់ហើយ ស្តេចមានព្រះបន្ទូលថា អញមិនដឹងជាខ្លួនឯងជាអ្នកប្រាជ្ញស្រុកខ្មែរទេ ឥឡូវនេះឯងកុំខឹងនឹងអញឡើយ អញនឹងយកមនុស្សចិនទាំងស្រីទាំងប្រុសបាន ១០០ អញសែនឯង ហើយឲ្យជូនឯងទៅស្រុកវិញ ឯធនញ្ជ័យក្រាបថ្វាយបង្គំទូលថា ខ្ញុំមិនខឹងនឹងម្ចាស់ទេ សត្វដែលវាថានឹងស៊ុកស្ត្រនោះ ខ្ញុំម្ចាស់ឲ្យវាទៅវិញហើយ ឯមហាក្សត្រស្រុកចិនដណ្តឹងថា ឈ្មោះសត្វអីដែលវាយំព្រូតែអទ្តើត ៗ នោះ ទើបធនញ្ជ័យក្រាបទូលថា សត្វនោះឈ្មោះសត្វខ្លែងពួង ទើបស្តេចសួរថា រូបវាដូចម្តេចក៏វាយំព្រូខ្លាំងម៉្លេះ ទើបធនញ្ជ័យក្រាបទូលថា ខ្ញុំទូលបង្គំនឹងធ្វើរូបខ្លែងពួងមកថ្វាយ ហើយធនញ្ជ័យទៅយកខ្លែងដែលបង្ហើរនោះមកថ្វាយថា សត្វនេះវាយំនឹងស្នែងវា មិនបានយំនឹងមាត់វាដូចអស់ទាំងសត្វឯទៀតក៏ទេ ឯមហាក្សត្រស្តាប់ធនញ្ជ័យក្រាបទូលដូច្នោះហើយក៏មានព្រះបន្ទូលថា ប្លែកមិនដែលឃើញដូច្នេះ ទើបនឹងឃើញឥឡូវនេះ បើដូច្នេះយើងធ្វើបង្ហើរឲ្យវាយំនឹងមើលលេង រួចហើយឲ្យយកសំពៅ ១ ធំបំណុះមនុស្ស ២០០ ហើយនឹងជូន

ធនញ្ជ័យទៅស្រុកខ្មែរវិញ ហើយឲ្យយកមនុស្សចិនបាន ១០០ ដាក់ក្នុងសំពៅហើយទឹងស្បៀងដាក់ឲ្យជូនទៅជាសំណែនធនញ្ជ័យ ជូនមកស្រុកលុះដល់ហើយធនញ្ជ័យឡើងទៅសួរម្ដាយឪពុកកូនប្រពន្ធ ហើយជញ្ជូនអស់ទ្រព្យរបស់ ដែលស្ដេចក្រុងចិនព្រះរាជទានសែនជូនមកទាំងអស់នោះឲ្យឡើងមកហើយឲ្យសង់ផ្ទះនៅជាសុខសប្បាយ បានជាមានចិននៅស្រុកខ្មែរនេះ គេហៅថាចិនសំណែនធនញ្ជ័យតាល់តែឥឡូវនេះ ។

ឯព្រះមហាក្សត្រក្នុងស្រុកខ្មែរឮថា ធនញ្ជ័យវិលមកវិញហើយបាននាំចិនមកផង ហើយស្ដេចនូវនាហ្មឺនកោតខ្លាចប្រាជ្ញាធនញ្ជ័យ មិនហ៊ានធ្វើសេចក្ដីអ្វីឲ្យទាស់ទឹងគំនិតធនញ្ជ័យឡើយ ព្រះមហាក្សត្រឲ្យទៅហៅធនញ្ជ័យមកសួរដំណើរអំពីស្រុកចិន ដ្បិតគាត់បានទៅ ធនញ្ជ័យក៏ក្រាបទូលតាមដំណើរដែលបានទៅឃើញហើយនិយាយថា កាលខ្លួនខ្ញុំបានទៅដល់ហើយគិតឲ្យបានមកវិញនោះ ព្រោះធ្វើខ្លែងពួងបង្ហើរស្ដេចបានឮសូរអែកខ្លែង បានជាខ្ញុំបានមកវិញ ឯព្រះមហាក្សត្រឲ្យធ្វើខ្លែងនោះបង្ហើរទឹងមើលលេង ធនញ្ជ័យក៏ធ្វើខ្លែងទៅថ្វាយឲ្យស្ដេចទតដូច្នេះឯងហៅខ្លែងពួង បានជាយើងចេះធ្វើខ្លែងដល់ឥឡូវនេះឯង ។

ឯធនញ្ជ័យដល់មានជម្ងឺឈឺខ្លាំងណាស់ហើយផ្ដាំប្រពន្ធថា បើអញទឹងស្លាប់ទៅហើយឲ្យយកទៅកប់នោះឲ្យធ្វើចំរុងបោះលើផ្នូរនោះឲ្យច្រើនកុំឲ្យខាន ហើយឲ្យទៅទូលហ្លួងថា អញឈឺខ្លាំងណាស់ហើយ ឯប្រពន្ធ

នោះទៅទូលហ្លួនដូចពាក្យធនញ្ជ័យ ស្តេចដឹងដូច្នោះហើយក៏ស្តេចទៅ សួរធនញ្ជ័យ ដល់ហើយស្តេចចូលទៅសួរធនញ្ជ័យថា ឯងឈឺតើដូចម្តេច ធនញ្ជ័យទូលថា សូមទ្រង់ចូលមកឲ្យជិតខ្ញុំៗនឹងខ្សឹបផ្តាំទុក ខ្ញុំទូលឲ្យខ្លាំងមិនបានទេ ស្តេចស្តាប់ហើយចូលទៅជិត ធនញ្ជ័យទូលថា សូមទ្រង់ឱនព្រះកេសមកឲ្យជិតនឹងមាត់ខ្ញុំ ស្តេចក៏ឱនត្រចៀកទៅជិតមាត់ធនញ្ជ័យៗក៏ផ្តាំថា បើស៊ីត្រីព្រលកុំបោលស្រកា បើស៊ីត្រីប្រាកុំបោលស្រកី ឲ្យស្ងួតក្បាលត្រីប្រានឹងម្ទេសណ្តាន់ ឲ្យស្តេចចាំទុកកុំឲ្យភ្លេច ស្តេចស្តាប់ហើយស្តេចវិលមកដំណាក់វិញ ឯអស់នាហ្មឺនសួរហ្លួនថា ធនញ្ជ័យក៏ផ្តាំថាដូចម្តេច ព្រះមហាក្សត្រស្តេចស្តាប់ហើយ ក៏ប្រាប់អស់នាហ្មឺនថាតាមពាក្យធនញ្ជ័យថា ស៊ីត្រីព្រលកុំបោលស្រកា ស៊ីត្រីប្រាកុំបោលស្រកី ឲ្យស្ងួតក្បាលត្រីប្រានឹងម្ទេសណ្តាន់ ក៏ថាជាពេលក៏ទេ ស្តេចមានព្រះបន្ទូលដូច្នោះ ក៏អស់នាហ្មឺនមិនជឿឡើយ គិតថាធនញ្ជ័យនេះជាអ្នកប្រាជ្ញធំណាស់ ដឹងជាគេថាដូចម្តេចនឹងព្រះមហាក្សត្រ ឯអស់យើងទុកចិត្តថា ស្តេចជាៗមិនបានទេ បានជាស្រុកខ្មែរនេះខ្លាចស្តេច ខ្លាចនាហ្មឺនលុតជង្គង់ដូច្នោះ ដ្បិតតែធនញ្ជ័យខ្សឹបនឹងស្តេចនោះឯង ឯធនញ្ជ័យក៏ស្លាប់ទៅគេយកទៅកប់ ហើយធ្វើបុណ្យដាក់ដារនោះឯងតាមពាក្យធនញ្ជ័យផ្តាំនោះឯង អស់នាហ្មឺនទូវអ្នកកងកំរែដែលខឹងស្អប់ធនញ្ជ័យ ថាធនញ្ជ័យធ្វើបាតយកប្រាក់ ព្វថាធនញ្ជ័យស្លាប់ហើយគេ

យកទៅកប់នៅត្រង់ទីពលា ក៏ប្រើឲ្យមនុស្សផ្ទះអាចម៍ផាក់ផ្សារ ឯអស់មនុស្សទាំងនោះក៏ទៅដល់ផ្សារ ហើយក៏សើយសំពត់ពាក់គួរជនីផ្ទះមិនបានដឹងជាមានចំរើកមុតគួរពកល់គ្នា ពន្ធមិនហានទៅផ្ទះទៀតឡើយ ហើយខាងខាងចងទញ្ញយ ស្រដីប្រាប់គ្នាវៀងទៅ នេះប្រាកដជាអ្នកមានប្រាជ្ញ ដល់ស្លាប់ទៅហើយ ក៏គងគិតទុកឲ្យបាន គាត់ដឹងជាឯងទៅផ្ទះអាចម៍ផាក់ផ្សារគាត់ បានជាគាត់ផ្តាំគេឲ្យទៅដោតចំរុងទុកឲ្យមុតគូថឯង ។

ឯរឿងអំពីធនញ្ជ័យបុរសប្រាជ្ញក្នុងស្រុកឥន្ទ្របត្តនគរនេះ ចប់តែប៉ុណ្ណេះឯង ។

# បញ្ជីរឿង


ទំព័រ

១ ព្រហ្មចរិយកថា របស់ព្រះមហាសែស ក្រុមពុទ្ធសាសនបណ្ឌិត្យ ប្រែនិងរៀបរៀង (ត) . . . . . . . . . . . . . . . . . . . . ៧៣

២ ចាតុរង្គបទ របស់ព្រះមហាពិទូរ ក្រសេម (ត) . . . . . . . . . . . . ៧៩

៣ សិលាចារិកនគរវត្ត និងបទានុក្រម . . . . . . . . . . . . . . . . ៨៧

៤ សុភាសិតភាជកថា របស់ព្រះគ្រូញាណសំវរ ញាណ-ឈឹម ក្រុមពុទ្ធសាសនបណ្ឌិត្យ ប្រែនិងរៀបរៀង (ត) . . . . . . . . . . . . . . . . . ១២៣

៥ ហិតោបទេស ភាគទី ១ របស់ព្រះមហាពិទូរ ក្រសេម (ត) . . . . . . . . ១២៩

៦ លោកន័យ ពាក្យកាព្យរបស់ឧកញ៉ាវង្សាសពេជ្ញនង (ត) . . . . . . . . ១៣៧

៧ ការសិក្សានៅស្រុកបើពុន . . . . . . . . . . . . . . . . . . . . ១៤៥

៨ លទ្ធិទំនៀមទម្លាប់ខ្មែរ ក្បួនដំរះឧត្បាទ របស់ប្លូកណា (ត) . . . . . . . ១៥៥


# រូបក្រៅរឿង


ប្រាសាទនគរវត្ត ភាពខាងមុខ មុនដែលរាជការទៅកាប់ឆ្ការ . . . . . . . ៧១

# TABLE DES MATIÈRES

| | | Pages. |
|---|---|---|
| I. | BRAHMACARIYAKATHĀ par Préas Maha Sès de l'Institut Bouddhique (suite) | 73 |
| II. | CATURANGAPADA par Préas Maha Pitou Krasém (à suivre). | 79 |
| III. | Les inscriptions de Nokor Vat (suite) | 87 |
| IV. | SUBHASITAVĀCAKATHĀ par Préas Krou Nhéan Sangvara Chheun de l'Institut Bouddhique (suite) | 123 |
| V. | Hitopadés 1re partie par Préas MahaPitou Krasém (à suivre) | 129 |
| VI. | LOKANAYA par l'Oknhā Vongsāsarapéch Nong (suite)... | 137 |
| VII. | Enseignement primaire au Japon | 145 |
| VIII. | Mœurs et coutumes cambodgiennes Règles pour conjurer les malheurs (suite) | 155 |

## HORS TEXTE:

Angkor Vat avant le débroussaillement ........ 71



ប្រាសាទនគរវត្ត ភាគខាងមុខ មុនដែលរាជការទៅកាប់ឆ្ការ ។

# ព្រហ្មចរិយគាថា

## របស់ព្រះមហាសែស ក្រុមពុទ្ធសាសនបណ្ឌិត្យ

## រៀបរៀង (គ)

ម្យ៉ាងទៀត ជនជាសប្បុរសប្រកបដោយបញ្ញាល្អ គួររក្សាសីល ៥ កាលបើបានរក្សាហើយ ត្រូវប្រព្រឹត្តឲ្យល្អក្នុងសីលនោះ កុំឲ្យដាច់ដាចធ្លុះធ្លាយ កាលទទួលបរិភោគអាហារ គួរបរិភោគឲ្យបរិសុទ្ធដោយទីបំផុតទាំង ៣ គឺមិនបានឃើញ ១ មិនបានឮ ១ មិនបានរង្កៀស ១ គួរតែលះបង់ជីវិតខ្លួន មិនគួរប្រព្រឹត្តឲ្យកន្ទួងសីលនោះឡើយ ដូចមានវត្ថុនិទានថា ព្រះរាជាមួយព្រះអង្គ សោយរាជ្យក្នុងលង្កាទ្វីប ទ្រង់ព្រះនាមថា ធម្មិក-តិស្សមហារាជ ព្រះរាជានោះ ទ្រង់មានព្រះរាជហឫទ័យ ចង់សោយសាច់សត្វទាគាំង តែទ្រង់ព្រះចិន្តាថា បើអញនិយាយប្រាប់គេថា ចង់ស៊ីសាច់សត្វទាគាំងហើយ មុខជាជនទាំងឡាយនឹងធ្វើសត្វទាឲ្យវិនាសក្នុងទីប្រមាណជាមួយយោជន៍ជុំវិញ ។ ព្រះរាជានោះ ក៏ទ្រង់អត់ទ្រាំសេចក្តីស្រេកឃ្លានអស់ ៣ ឆ្នាំ មានរោគខ្ទុះកើតក្នុងព្រះកណ្ណ ។ ព្រះរាជានោះ ក៏មិនអាចនឹងអត់ទ្រាំសេចក្តីស្រេកឃ្លានបាន ក៏មានព្រះបន្ទូលសួរថា មនុស្សណាមួយជាខ្ញុំបំរើរបស់អញ ហើយជាអ្នករក្សាសីលដោយត្រឹមត្រូវមានដែរឬ ។ ជនទាំងឡាយក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស មានឧបាសកម្នាក់ឈ្មោះតិស្សឧបាសក រក្សាសីលត្រឹមត្រូវមិនឲ្យដាច់ដាចធ្លុះធ្លាយឡើយ ។ ព្រះរាជាទ្រង់ប្រាថ្នានឹងល្បងឧបាសកនោះមើល ទ្រង់បង្គាប់ឲ្យហៅឧបាសកនោះមក ។ ឧបាសកនោះក៏មកតាមព្រះរាជអាជ្ញា ដល់ហើយក៏ក្រាបបង្គំ ស្ថិតនៅក្នុងទីដ៏

សមគួរ ៗ ព្រះរាជាទ្រង់សួរថា អ្នកឯងឈ្មោះតិស្សឧបាសកឬ ៗ ឧបាសកក្រាបទូលថា ព្រះករុណាថ្លៃវិសេស ៗ ព្រះរាជាទ្រង់ត្រាស់ថា អ្នកឯងចូរត្រឡប់ទៅវិញចុះ ៗ លុះឧបាសកនោះត្រឡប់ទៅវិញហើយ ព្រះរាជាទ្រង់បង្គាប់បុរសម្នាក់ ឲ្យយកមាន់រស់ ១ ទៅឲ្យឧបាសកនោះបំពងក្រយាស្ងោយ ៣ មុខយកមកថ្វាយព្រះអង្គ ៗ បុរសនោះក៏ទៅតាមព្រះរាជបង្គាប់ ៗ ឧបាសកនិយាយទៅនឹងព្រះរាជបំរើនោះថា បើមាន់នេះស្លាប់ស្រាប់ យើងអាចនឹងចាត់ចែងក្រយាស្ងោយថ្វាយតាមព្រះរាជហឫទ័យ ឥឡូវមាន់នេះនៅរស់ យើងធ្វើមិនបានឡើយ ព្រោះយើងមិនសម្លាប់សត្វ ៗ រាជបំរើក៏ត្រឡប់មកក្រាបបង្គំទូលព្រះរាជាវិញ ៗ ព្រះរាជាក៏ទ្រង់បង្គាប់ឲ្យរាជបំរើទៅប្រាប់ដូច្នោះម្តងទៀត រាជបំរើក៏ទៅប្រាប់ឧបាសកនោះម្តងទៀតថា ការបំរើព្រះរាជាជាការធ្ងន់ពេកណាស់ អ្នកឯងកុំធ្វើដូច្នេះឡើយ កាលបើសីលដាច់ទៅហើយ អ្នកឯងអាចនឹងសមាទានវិញទៀតបាន អ្នកឯងចូរបំពងមាន់នេះប្រគេនព្រះរាជាកុំខាន ៗ គ្រានោះ តិស្សឧបាសកនិយាយទៅនឹងរាជបំរើថា កុំអត្តភាពមួយមានសេចក្តីស្លាប់ម្តងជាទៀងឥតឃ្លៀងឃ្លាតឡើយ ហេតុនោះយើងមិនធ្វើបាណាតិបាតទេ ៗ រាជបំរើក៏ត្រឡប់មកក្រាបបង្គំទូលព្រះរាជាវិញ ៗ ព្រះរាជាក៏ប្រើរាជបំរើទៅដូច្នោះជាគំរប់ ៣ ដង ឧបាសកនោះក៏នៅតែ

មិនព្រមទទួលធ្វើតាមព្រះរាជអាជ្ញា ទើបទ្រង់ឲ្យហៅឧបាសកនោះមក ទ្រង់សួរដោយព្រះអង្គឯង ។ ឧបាសកនោះ ក៏នៅតែរឹងទទឹងនឹងព្រះរាជអាជ្ញាដូច្នោះដដែល ។ ព្រះរាជាទ្រង់បង្គាប់រាជបុរសថា ឧបាសកនេះ វាមិនទទួលធ្វើតាមព្រះរាជអាជ្ញា អ្នកទាំងឡាយចូរនាំវាទៅដាក់ត្រង់កន្លែងសម្លាប់មនុស្ស ហើយកាត់ក្បាលវាចោលចេញ តែទ្រង់ឲ្យសញ្ញាដល់រាជបុរសក្នុងទីស្ងាត់ថា អ្នកទាំងឡាយកុំអាលសម្លាប់វា ត្រាន់តែគម្រាមឲ្យវាខ្លាចហើយនាំវាទៅ យកក្បាលវាដាក់ផ្ទុកលើជ្រញ់កន្លែងសម្លាប់មនុស្ស ហើយត្រឡប់មកប្រាប់អញវិញ ។ ពួករាជបុរសនាំឧបាសកនោះទៅឲ្យដេកលើជ្រញ់កន្លែងសម្លាប់មនុស្ស ហើយយកមាន់នោះទៅដាក់លើដៃឧបាសក ។ ឧបាសកក៏យកមាន់ដាក់លើដើមទ្រូងនិយាយថា ម្នាលមាន់ អញឲ្យជីវិតអញដល់ឯង យកជីវិតឯងមកជាជីវិតអញវិញ មាន់ឯងកុំគិតភ័យអ្វី ចូរឯងទៅចុះ ថាដូច្នេះហើយក៏លែងមាន់នោះទៅ ។ មាន់ក៏ទះស្លាបហើរទៅទំលើដើមជ្រៃ ១ ។ កន្លែងនេះជាកន្លែងឲ្យអភ័យដល់សត្វមាន់ មានឈ្មោះប្រាកដថា កុក្កុដគិរី ។

ឯព្រះរាជា ទ្រង់ព្រះសណ្ដាប់ដំណើរនោះហើយ ទ្រង់បង្គាប់បុត្រនៃអមាត្យម្នាក់ឲ្យហៅឧបាសកនោះមកវិញ ហើយទ្រង់ព្រះរាជទានបំពាក់គ្រឿងប្រដាប់តាំងពួងដល់ឧបាសក ហើយទ្រង់មានព្រះបន្ទូលថា យើង

មិនបានធ្វើទុក្ខទោសអ្វីដល់អ្នកឯងទេ យើងគ្រាន់តែល្បងលអ្នកឯងមើលទេ ព្រោះយើងមានប្រាថ្នាចង់សោយសាច់សត្វទាកន្ទង់ ៣ ឆ្នាំមកហើយ អ្នកឯងអាចចាត់ចែងសាច់សត្វទាដែលបរិសុទ្ធដោយទីបំផុតទាំង ៣ ឲ្យយើងបានឬទេ ។ ឧបាសកទទួលព្រះបន្ទូលរួចហើយ ក៏ចេញទៅឈរទៀបមាត់ទ្វារ ក៏ស្រាប់តែឃើញបុរសម្នាក់ នាំយកសត្វទាស្លាប់ស្រាប់ ៣ ដើរចូលមកអំពីព្រឹក បានឲ្យថ្លៃពីរកហាបណ ទិញយកទទាះនោះមកចាត់ចែងធ្វើបង់គ្រឿងប្រហើរមានជីរជាដើម អាំងឆ្អិនស្រេចក៏នាំយកមកថ្វាយព្រះរាជា ។ រឿងនេះមានមកក្នុងអដ្ឋកថាអាសិវិសវគ្គ ក្នុងសំយុត្តនិកាយ សឡាយតនវគ្គ ។

# ចាតុរង្គប់ន ភាគទី ២

## របស់ព្រះមហាពិទូរ ក្រសេម គន្ធរបទបណ្ឌិត

## រៀបរៀង

# បទទី ២ សមត្ថភាព

## សមត្ថភាព ស្ទួយជីវិតសម្បត្តិ

សមត្ថភាព (សេចក្ដីអាច) នេះ កាលជីវិតសម្បត្តិនៅមានទៅដោយល្អហើយ រមែងធ្វើការជ្រោមជ្រែងជីវិតឲ្យឡើងថ្លៃបាន តែបើដាច់ជីវិតសម្បត្តិកាលណា កាលនោះ សមត្ថភាពក៏គង់ឈប់អំពីមុខការមួយ ព្រោះហេតុនោះ ជីវិតសម្បត្តិនិងសមត្ថភាព ទើបតោងអាស្រ័យគ្នានឹងគ្នាប្រព្រឹត្តទៅ ៗ ជីវិតសម្បត្តិនឹងមានដំឡៃតិចច្រើនយ៉ាងណា ស្រេចហើយតែកំលាំងសមត្ថភាពរឹងប៉ឹងឬទន់ទាប បើសមត្ថភាពមានកំលាំងក្លាក៏ជួយស្ទួយជីវិតសម្បត្តិឲ្យអណ្ដែតឡើង បើសមត្ថភាពមានកំលាំងទុព្វលភាព ជីវិតសម្បត្តិក៏គង់អាប់ឱនអន់ចុះតាមគ្នា ។ ជីវិតសម្បត្តិប្រៀបដូចទារកដែលកើតអំពីមាតាបិតា សមត្ថភាពប្រៀបដូចមាតាបិតា ឬពហ៍លៀងជាអ្នកប្រកបដោយសេចក្ដីចេះដឹង និងសេចក្ដីប្រព្រឹត្តល្អចាប់ដើមតាំងពីយល់ក្នុងវិធីព្យាបាលក្មេងត្រូវតាមអនាម័យនិងសុខវិទ្យា ក៏អាចនឹងទំនុកបម្រុងទារកនោះឲ្យមានកំលាំងកាយមាំមួន ទំធាត់ធំសមប្រកបចំរើនវ័យឡើងដោយលំដាប់កាល ៗ បើមាតាបិតាចេះដឹងទំនៀមទម្លាប់របៀបបែបផែនដែលល្អៗទៅ ឬចំពោះតែក្នុងវង្សត្រកូលរបស់ខ្លួន តាំង

ជាអ្នកមានកិរិយាមារយាទរៀបរយល្អ មុខគួរស្រឡាញ់ មុខគួររាប់អានសោត ក៏អាចនឹងបង្ហ្វឹកបង្ហាត់ទារកនោះឲ្យទៅជាក្មេងល្អ រហូតដល់ទៅអាចគ្រប់គ្រងខ្លួនឯងបានទៅថ្ងៃក្រោយ ។

## សមត្ថភាពកើតអំពីការសិក្សានិងធ្វើតាម

ដែរពិត សមត្ថភាពនេះមាននៅសព្វខ្លួនទៅក្នុងជីវិតកើតជាគូសាងមកជាមួយគ្នា នឹងចំរើនឡើងតាមសេចក្ដីចំរើននៃជីវិត រហូតដល់ទៅសំដែងអាការចេញមកឲ្យឃើញជាក់ស្ដែង ដូចយ៉ាងអាចចាត់ចែងធ្វើអ្វីៗ បានវិសេសជាងរបស់ដែលធម្មតាគាត់តែងមក នឹងអាចនិយាយរំលឹកដាស់តឿនក្រើនប្រដៅតតបប្រកបដោយតឹកតាង អាងមកជាគោលឲ្យអ្នកស្ដាប់ឃើញសមពិត កើតចិត្តក្លាហានទទួលជឿស្ដាប់កាន់យកធ្វើតាមពាក្យនោះៗ គ្រប់ប្រការ តែគ្មានការសិក្សាការបង្ហ្វឹកពត់ផ្សំក្នុងខាងដើម ក៏ដូចជាអាហារដែលគ្មានអ្នកផ្សំគ្រឿង នឹងសម្រេចជាអាហារដ៏ត្រកាលមានប្រភេទផ្សេងៗ ដូចម្ដេចបាន ឬដូចជាភ្នែក តាមធម្មតា ភ្នែកតែងឃើញរូប បើគ្មានភ្នែកនឹងឃើញអ្វីបាន ហេតុនេះសមត្ថភាពនឹងលោតលេចចេញមកឲ្យឃើញ លុះតែបានសន្សំបន្ទុំមកដោយការសិក្សា ការសិក្សានោះនិយាយដោយន័យម្យ៉ាងមាន ២ គឺ :

១ ការសិក្សាអំពីគ្រូ

២ ការសិក្សាអំពីធម្មតា ។

១ ការសិក្សាអំពីគ្រូ គឺការរៀនសូត្រតាមស្ថានទីរៀនសូត្រទាំងឡាយ ដូចយ៉ាង សាលារៀន វត្ត ភូមិ ផ្ទះជាដើម ។ ការសិក្សាជាន់នេះ ជាហេតុឲ្យបុគ្គលបាននូវសេចក្តីចេះដឹងនិងសេចក្តីអាចក្នុងករណីយៈតាមកំលាំង ។

២ ការសិក្សាអំពីធម្មតា គឺការរៀនចេះដឹងរឿងធម្មតារបស់លោកខាងក្រៅ និងលោកខាងក្នុងគឺកាយនិងចិត្តរបស់យើងនេះ ដោយវិធីស្រាវជ្រាវរកហេតុផលគឺស្រាវជ្រាវរកដើមហេតុចុងហេតុរបស់ធម្មតា ដែលបានឃើញបានស្តាប់ បានធុំក្លិន បានបរិភោគ បានប៉ះពាល់ត្រូវ បានដឹងមកដូចម្តេច, ការសិក្សាជាន់នេះជាហេតុធ្វើបុគ្គលអ្នកសិក្សាឲ្យបានជ្រួតជ្រាបសព្វគ្រប់ដល់រឿងធម្មតាទាំងឡាយទាំងខាងក្នុងខាងក្រៅថាមានហេតុផលទាក់ទងគ្នាទៅមកដូចម្តេច ជួយជ្រោមជ្រែងឲ្យកើតសេចក្តីចេះដឹងឆ្លៀវឆ្លាស ទាល់តែអាចបង្អោនមកគិតចាត់ធ្វើ ឲ្យសម្រេចជាទ្រព្យមាសប្រាក់ របស់ផ្សេងៗជាច្រើនយ៉ាង ច្រើនប្រភេទតាមត្រូវការនិងអាចនាំមកជាគតិប្រដៅចិត្ត បង្វឹកសន្តានខ្លួនឲ្យប្រព្រឹត្តទៅតាម ទាល់តែបានជាអ្នកសម្បូណ៌ស្តុកស្តម្ភសមតាមភូមិ ។ មានរឿងដំណាលថាមនុស្សសម័យព្រេងនាយឯណោះ ឃើញជាងពាក់កូនសរ អាចបង្អោនមកពាក់ខ្លួនឲ្យស្លូតត្រង់សុចរិតទៅក៏បាន ឃើញភ្លើងឆេះព្រៃ - ព្រិញថ្ងៃ ពពុះទឹកជាដើម ហើយនាំមកពិចារណាប្រៀបធៀបនឹងកាយ - ចិត្តនេះ

ទាល់តែអាចទំលាយគ្រឿងសៅហ្មងចិត្ត គ្រឿងរុំរឹតចិត្តឲ្យជាប់នៅក្នុងលោកសង្គ្រាំនៅក្នុងចិត្តឲ្យរលត់សូន្យសោះទៅ បានសុខកាយសប្បាយចិត្តស្ងោះស្ងាន គ្មានទុក្ខលាយឡំផង ទើបជាអ្នកមានអំណាចធំក្រៃលែងលើលោក លោកមិនអាចនឹងរួបរឹតឲ្យជាប់នៅបាន ។ ឧទាហរណ៍អម្បាលនេះលើកមកឲ្យឃើញថា លោកខាងក្នុង ខាងក្រៅ ជាស្ថានទីរៀនសិក្សាដ៏ធំទូលាយ ពេញទៅដោយវិជ្ជាសព្វសារពើ ហើយជាគោលសំខាន់យ៉ាងណាក បើត្រូវការចេះដឹងក៏គ្មានអ្នកណាហាមប្រាមឡើយ វៀរតែខ្លួនឯងមិនត្រូវការប៉ុណ្ណោះ ។

ហេតុនោះ សេចក្ដីចេះដឹងដែលកើតអំពីការសិក្សា បើមិនធ្វើតាមដែលចេះដឹងហើយ សេចក្ដីចេះដឹងនោះក៏មិនជាការអស្ចារ្យអ្វី ចូលបែបពាក្យបុរាណថា "មនុស្សក្បាលទំពែក បានក្រាស, មនុស្សកំបុតម្រាមដៃបានចិញ្ចៀន" ដូច្នេះ ជាបើយកសេចក្ដីចេះដឹងទៅប្រើក្នុងផ្លូវដែលខុស ដែលមិនជាប្រយោជន៍ផងហើយ ក៏នឹងប្រព្រឹត្តទៅដើម្បីទុក្ខទោសភ័យមួយយ៉ាង ហេតុនោះ ក្នុងព្រះពុទ្ធសាសនា ព្រះបរមសាស្ដាទ្រង់សំដែងបរិយត្តិ គឺការសិក្សា ព្រោះអត្ថថា ត្រូវរៀនសូត្រជាខាងដើម ទើបទ្រង់សំដែងបដិបត្តិ គឺការដំណើរតាម ជាសេចក្ដីរៀងលំដាប់គ្នា, ដោយមានព្រះពុទ្ធបំណងឲ្យប្រព្រឹត្តទៅ ទាំងដើម្បីរៀនចេះដឹង ទាំងដើម្បីធ្វើតាមឲ្យសមគួរ អំពីនោះក៏នឹងបានទទួលផលសម្រេច

តាមបំណងដែលធ្វើមក ទើបទ្រង់សំដែងបដិវេធជាឧបរិយោសាន រួម
គោលធម៌ដែលត្រឹមត្រូវមាន ៣ ប្រការដូច្នេះ ដោយន័យនេះ ការ
សិក្សាដែលអាចឲ្យកើតសេចក្ដីចេះដឹង សេចក្ដីយល់ចូលចិត្តនោះទុកដូច
ជាមនុស្សនាំផ្លូវ ការធ្វើតាមទុកដូចជាមនុស្សដើរតាមផ្លូវដែលខ្លួនបំណង
នឹងទៅ កាលដើរទៅតាមផ្លូវនោះមិនត្រឡប់ក្រោយ ក៏នឹងបានលុះ
ដល់ស្ថានទីនោះ តែនឹងអស់វេលាតិចឬច្រើន ស្រេចហើយតែថ្វីជើង
ដើរលឿនឬយឺត ព្រោះហេតុនោះ សេចក្ដីចេះដឹងដែលកើតអំពីការ
សិក្សា នឹងបានសម្រេចផលដូចបំណង ក៏ត្រូវតែធ្វើតាមឲ្យសមគួរ
កាលរួមទាំងសេចក្ដីចេះដឹង ទាំងសេចក្ដីធ្វើតាមចូលផងគ្នា ក៏ជាកំលាំង
ដ៏មហិមាក្នុងការដែលនឹងឲ្យកើតសមត្ថភាព គឺអង់អាចក្លាហានគ្រប់គ្រាន់
ដល់ករណីយកិច្ចតូចធំបានគ្រប់ផ្លូវជាប្រាកដ ។


ឧត្តរ
បស្ចិម
បូព៌
ទក្សិណ
០ ១ ២ ៣ ៤ ៥



# សិលាចារឹកនគរវត្ត

និង

# បទានុក្រម

# សិលាចារិក

## លេខ ១

(១) រត្នមហាពោធិនាមេន RATNAMAHĀBODHINĀMENA

(២) មយាសម្ពោធិមិច្ឆតា MAYĀSAMBODHIMICCHATĀ

(៣) ពោធិរុក្ខាតិរោបេត្វា BODHIRUKKHĀTIROPETVĀ

(៤) សជិនប្បដិមំតមំ[១] SAJINAPPAṬIMAṂ IMAṂ

(៥) សមត្ថញ្ញាយោមយ្ហំ SAMATTHAÑÑĀYO MAYHAṂ

(៦) ចាបេតុំសព្វសម្បទំ CĀPETUṂ SABBASAMPADAṂ

(៧) បសន្នបនសាសាធូ PASANNAPANASĀ SĀDHŪ

(៨) សាធុវោអនុមោទថ SĀDHUVO ANUMODATHA

(៩) ត្រិពិទ្ធ ត្រៃយសរវន្ទនា ៣ (១០) ហុល ឌុត (ល) អត្ថិរេកឯកបិតាតិ (១១) ទ្ធសុបរិតសាទរករទសន (១២) ក្វអករាង្គលិគ្រិបាទារពិទ្ធអ (១៣) បិន អត្ថិរេកអនេកពៃបុល ទ្ទុ (១៤) តុលបេស្មាទិពលតិ-កលហុ (១៥) ទៃរតោយ បុត្វិពោធិសត្វរោ (១៦) ង ស្យង្គរំពិងនានុប្រាបិនាសូម (១៧) ជាព្រះពុទ្ធគិបិសំតេបព្រះម (១៨) ហាប្រេរត្រិរត្នមហាពោធិ

---

១ តម់ ។

ប្រ (១៩) តំស្ពាព្រះមហាពោធិព្រក្សអង្គប្រ (២០) មួយ ពៅនិស្រែយមុនិ អង្គមួ (២១) យ ពៅស្រាមនេរវត្នលង្ការអង្គ (២២) មួយ ពៅស្រាមនេរឥន្ទមោ (២៣) លិអង្គមួយ ពៅស្រាមនេរប (២៤) ន្ទបូលាអង្គមួយ ពៅស្រាម (២៥) នេរ-ធម្មិមង្គល នុពៅស្រាមនេ (២៦) រខ្មោអង្គមួយ ពៅស្រាមនេរទេ (២៧) ពបូលាអង្គមួយ នុបណ្ឌិ (ត) ព្រហ្ម (២៨) ក្រៀហ ឧរ សាគរប្រស្នាព្រះ (២៩) អង្គមួយ . . និញ៉ាន . . ៣០....

### លេខ ២

(១) នេះតគិត្រិពិតសុបិរិតសទ្ធាំនៃខ្ញុំអ៊ិបស្បេសំតេ (២) បព្រះរាជមាតាមហាកល្យាណវត្តិស្រីសុជាតា (៣) ឪត្តមជាតិក្សត្រិព្រះមហាឪបាសិការត្នបតិ (៤) ត្របា្វយបង្គំមប្រគំម្រទូលតព្រះវរបាទារុពិន្ទុ (៥) នៃសំតេចព្រះមហាស្រីរត្នត្រៃកម្រតែងយេង (៦) តជាតំ្ពុនកត្រៃយត្រាណ ប្រាណរុស៊ំពោជា (៧) រត-រួងឪត្តុង្គជានុនាំឆ្លោងរំលែងស្រមទ្ធពោល (៨) មនគិកក្តាជាតកត្តារសារតា ខ្ញុំអ៊ិបស្បមានសទ្ធាំ (៩) តំលាបិត្រប្រព្រទ្ធិសាងសព្វកុសលរៀងមោក លុះ (១០) ជាតផល្លនេះ បន្តិលុះត ១៤៩៩

សក ឆ្នកក្សត្រ (១១) បត្តុំគិកេតអាសាធ្យៈសោរពារ ខ្ញុំអំបស្ស
យល (១២) ស្តួបព្រះរាជបុត្រមានសទ្ធាសាងព្រះពិស្នុលោក
(១៣) កុម្ពុជបុរាណនេះឱ្យបរិបូររបុរាណរឹង ខ្ញុំម (១៤) អំបស្ស
ត្រៀកអរអនុមោទនានុស្តួបព្រះរាជបុត្រ (១៥) ពេគហោង ខ្ញុំអំ-
បស្សមានសុចរិតសទ្ធាពួត (១៦) ព្រះសាស្នាព្រះតថាគតស្រ-
គតតាលអនិច្ចារំពឹង (១៧) យលតាមរុបធម្មនេះពុំទៀងស្បង្គ
ពុំជួអាត្មា (១៨) គុះ គិបិខ្ញុំអំបស្សតាកព្រះកេសមោលីតាមាន
បេ (១៩) ស្តាធិការអំពលនុមុទ្ធាភិសេកគោះបងព្វតស្នា (២០)
នព្រះពិស្នុលោកនេះ សុរេបតុតជាក្នុកសាងព្រះ (២១) ពុទ្ធរូប
ព្វតស្នានបាការោ (រ៉) ឥះ សោតមានសប្ចាទី (២២) វ្នៀកនុ
ជាឱបាសករត្នបាំបញ្ចសិលវីយ៉ៀភ្យាយាម (២៣) ហាំអស្តាង្គ
សិលពួតថ្ងៃអដ្ឋមីបុន់មីអំមាពិស្យាជា (២៤) ប្រក្រតិពរុះ
អាយុក្ខយ្យេតជាបន្តិស្សហោង បពិត្រ (២៥) គោតេជះផលា
និសង្សនោះ គោកាល្នាបងបញ្ចខន្ធ (២៦) អំពិជាតបិអន្ទោល
ទោមោកពួតស័សារភព្តតអ (២៧) នេកជាតិអនាគតកាល
សូមជាមហាបុរុសសប្បុ ៗ ជាតកំនេត ស្សូមកោប្រនុធញ្ញបុញ្ញ

លក្ខណ សំ (២៨) យក្សព្រួតព្រះសាស្តាព្រះតេជ្រាគតប្រាកដ តួបសំនួម (២៩) សាតប្រណីធានមុហ្នីរឹងហោង ឆោតាល្ហាបិ សំតេប (៣០) ព្រះគ្រីអាយ៉្យមែត្រីស្តបបុះមោកត្រីស្បស្រពុំជ្ឈ តាញាន (៣១) ពួតលោកនេះ សុំខ្ញុំអឹបស្បព្រានបំរេហជាឱ បាសក (៣២) វត្ថុនៃសំតេបព្រះគ្រីអាយ៉្យមែត្រី សុំមខ្ញុំបាន ស្តាប្ប (៣៣) ខ្ញុំងធម្មាំម្រត គិសត្តតិស័រិរពោធិបក្ខិឱ្ឋ បិញប្បួស (៣៤) បានឱប្បសម្បូរខ្ញុំឯហិភិក្ខុ មានព្រះកេសកោរខ្សូន (៣៥) ត្បៀងប្រាកតពួតកក្តាលជំនុំនៃបតុពិធបរសតូសុ (៣៦) រេប ផ្គិតគេរសធុតង្គផ្ទឹងភាវណា (៣៧) បក្ខាទ្បិសក់អហ៊េន ហ៊េន អរហត្ត (៣៨) ផលអំពលនុបតុបិតិសម្ភិទា (៣៩) ញាណ សូមបួលនិញ៉ាន (៤០) មួយអន្លេនុព្រះគ្រីអា (៤១) យ៉្យមែត្រី បពិត្រហោង

លេ១ ៣

(១) នែះគិរោះត្រីពិធសុបរិតសន្តាមហា (២) វិបុល អតុល្យអតិរេកឯកគ្គតាប្រា (៣) មោទ្យជោតិបង្កជ្ញវត្ថុវេណ្យ ពិន្ទុអបិ (៤) អបិន្ត្យនិយប្រិតិមានោជ្យពៃរោជ្យ (៥) សុគន្ធ

បវរសរមនស្សាភិលង្កិត រី (៦) កសិតសោត្ថរ បរមបទុម្មាភា ប្រិកា (៧) សយ្យ សមយ្យសមុត្តិមហុតិមហោ (៨) ត្ថិ សមគ្គ អសទាំរិកបិត សុបរិតវិប្ជាសប្ជាទិ (៩) ឆ្នានប្រិនិធាននៃសំតេច ព្រះជៃយ្យជេដ្ឋាធិរា (១០) ជនុង្ការបរមរាជាធិរាជរាមាធិបតិ គ្រិត្រិភវនាទិត្យពម្ម (១១) ធម្មិករាជ មនុរិវង្សាត្ថរ មហាបរម បក្រិពត្តិរាជកម្ពុជ្ជេ (១២) សូរ សុរិន្ទតេជោជេយ្យ ត្រៃរត្នមកុដ វិសុទ្ធ ជិន (១៣) សាស្នធរបរមត្របថម្ភករាជសំតេចព្រះមហា - ឪ (១៤) បាសកមហារាជបពិត្រ ឋ្វាបង្គំប្រិនម្យទូលត់ (១៥) ព្រះ វរបាទារុពិន្ទនៃសំតេចព្រះមហាគ្រិរត្នត្រៃយ (១៦) បរមបពិត្រ មគ្គិអំពិកាលជាប្រិបំមសំតេចព្រះមហា (១៧) ឪបាសកបាន ថ្លែងស្មោយរាជសម្បត្តិគ្រោងរាជ (១៨) ប្រិវេណីនោះ ស្ដុប ម៉ានព្រះរាជបំពោះប្រាជ្ញាន្ន (១៩) លេកសាស្នាព្រះតថាគត ប្រាកដសាងមហាប្រា (២០) សាទូព្រះពិស្នុលោកប្រាការ លេកប្ញុំកំពូល ន (២១) ព្ទូលប្រាសាទ្ធ សំអាតពិបិត្របិត មាសសុវេប (២២) ស្នាបណាព្រះមហាសារិកធាតុឆ្លង បំរេនព្រះ (២៣) រាជកុសលនេះ កល្បនាប្ញាយទោត់សំតេច

ព្រះ (២៤) ជីតប្អូនព្រះអង្គ នុំសំតេចព្រះវរបិតាធិរាជស្ដោង (២៥) គុណព្រះកន្លោងបពិត្រជាអាទិ នុព្រះញាតិវោង (២៦) កំលុងសប្ដសន្ដានត់សមុទាយឱយពន្លាយពួត (២៧) ត្រិពិធសំម្បត្តហោង អន្តាប៉្បនោះសំតេចព្រះមហោ (២៨) ឱបាសកមហារាជបពិត្រ រំពឹងបូព្វប្រាថ្នាតេម្បិន (២៩) សាងសាស្នាព្រះតថាគតឱយប្រាកដពួតកំម្ពុជទេស (៣០) នេះ លោកយសព្រះរាជសន្តានឱយសំបូណ្ណ៌ រោះ (៣១) បូព្វកាលវឹង កុំម្បិអានធម្មន្ត្រាយលេយ សូម (៣២) ខ្សែមសំមទ្ធិស្មិរស្នាពរហោង ១ មួយឃ្មិនាប្រថំមកាល (៣៣) សំតេចព្រះភគវតិត្រិប-ក្រុពត្តិអគ្គិរាជមហេសិព្រះ (៣៤) ពំធរណិទ្រូដេយ្យរាជទេពិត្រធម្មធិតាបពិត្រទ្វង (៣៥) គព្ភណិ នោះសំតេចព្រះមហាឱបាសកមហារាជប (៣៦) ពិត្រមានព្រះបរិតចិន្តាប្រាថ្នាចាំតាំព្រះរាជបុត្រនេះ (៣៧) ទោះបុរុសលោះទោះស្រី -តំណាព្រះរាជអទិស្ឋានន្តប្ថា (៣៨) យជាឱបាសកឱបាសិកាឱប្បថាកត់សំតេចព្រះ (៣៩) មហាត្រិរត្នត្រៃបរមបពិត្រ សុំសំយក្សភក្តីត់ព្រះ (៤០) សាស្នាព្រះតថាគតហោង កុម្បិហាកលែង

ព្រះ (៤១) សាស្នាលេយ ទោះព្រះរាជបុត្របុរុសព្រះរាជអទិ
ស្ឋាន (៤២) ថ្វាយជាពុទ្ធបុត្រពុំតាក់ព្រះមហាគិរត្នត្រៃបរម
បពិ (៤៣) ត្រជាប្រធាននៃព្រះអង្គ លុះតាបានបួសសឹក្កព្រះ
(៤៤) សាស្នាពោង លុះកាល្ហាបិលាផ្លូសបព្ជាកម្មរឹង (៤៥)
មោក សុំបានគ្រោងព្រះរាជប្រវេណិមហាខ្សត្ររឹង (៤៦) សុំសំ
យក្សភក្តិត់ព្រះមហាគិរត្នត្រៃបរមបពិត្រជា (៤៧) ប្រជាណា
ពុំតាក់ត់ព្រះរាជបុត្រនេះពោង ហេតុតេ (៤៨) ជះដលហេតិសង្ឃ
សំតេចព្រះអហោឱបាសកមហា (៤៩) រាជបពិត្រស្មោះពុំតាក់
ឮតព្រះមហាគិរត្នត្រៃបរ (៥០) មបពិត្រព្យិតអ្សុតបិស្សៀង
លេយ ទេបទេព្វប្យុត (៥១) មោកឱត្សត្តឮតមាត្រោទរផែសំ
តេចព្រះរាជទេ (៥២) ពិទិព្យ ត់មានបុន្យភុលព្រះរាជបុត្រកោ
ប្រនុលក្ស (៥៣) ឱត្តិសំនុព្រះលគ្នារាសីតំបី ស្បិង្គអនុក្កូល
បរិបូណ្ណ៍ ឱ (៥៤) ត្សត្តនា ១៥០១ សក ហោះនក្សត្រចតុទ្ទិគី
រាជអ៊ា (៥៥) សាទ្ធ ពុទ្ធពារ សារតាប្រថមអទ្ធាត លគ្នាស្ថិត
ឮតប្រ(៥៦)ថមរាសីស្កុលព្រះអង្គបរិសុទ្ធ លុះត់អាទិត្យពារគំរប្ប
(៥៧) ទ្វាទសទិន មានជុំនុំសំតេចព្រះរាជមាតាបពិត្រ ឆ្ន (៥៨)

រាជគ្រូហោរព្រាហ្មណាចារ្យផងថ្វាយផាតិកម្ម គិរិ (៥៩) ព្រះ
បាទតាំតេចព្រះរាជបិតាបពិត្រមានព្រះរាជទយា (៦០) ប្រកា
ប្រព្រះតាមករពារប្រសិទ្ធិត់សំតេចព្រះរាជឱរស (៦១) ហោ
សំតេចព្រះបរមរាជាធិរាជបពិត្រ សុរេបស្តួបនាំសំ (៦២) តេច
ព្រះបរមរាជាធិរាជព្រះរាជឱរសមោកនាព្រះពិស្នុ (៦៣) លោក
ត់ជាស្ពានជុំនុំនៃទេព្វតាមហាខេត្រមហាព្រហ្ម (៦៤) រសីហ
សិទ្ធិសក្តិនុទេព្វរក្សបិត្តរគណផងស្បង្គជុំនុំស (៦៥) មុគ្គតា
ទោគិបស្តួបមានព្រះរាជសទ្ធានាំសំតេចព្រះបរម (៦៦) រាជា
ធិរាជថ្វាយដាឱបាសការត្នបត្តិបត្តសំតេចព្រះម (៦៧) ហាគ្រី
រត្នត្រៃបរមបពិត្រ សុរេបស្តួបឱយរត្តាប្បក្រិយា (៦៨) បូជា
សរប្បសរាទកាល គឺបិនិមនព្រះសឃ៍ផងតអស្វារ (៦៩) សឃ៍
ត់ទ្រង់បតុបារិសុទ្ធសិល នុរាជគ្រូអាចារ្យផងមោ (៧០) ក
ថ្វេពិធិតប្បណ្ណទ្វាទសបិណ្ឌ នុអស្មោត្តរសតមង្គល អំ (៧១)
ពលនុសព្វផ្លែឈេហនុភ្ញិគន្ធក្រយាបញ្ចុយផ្សផង តោយ (៧២)
នុយហិសាស្ត្រ តេម្បីបន្ទះទោតព្រះញាតបិត្តរផោងកំលុង (៧៣)
សប្តសត្តាន នុសព្វសត្វជោង្គលន្បៀងទោច្ឆតបតុរាបាយ (៧៤)

ភូម ដោយលេហរូបតលអក្ខនិដ្ឋព្រហ្ម ដោយក្រោមរូប (៧៥) ត លអរបិ ដោយខាងរូបតលទសលហាស្សប្រក្រាភឡនេះ (៧៦) សុំផលានិសង្សនៃសំតេចព្រះមហាឧបាសកមហារាជប (៧៧) ពិត្រមានកត្តញ្ញុកត្តវេទិឱ្យជូនកុសលផលបុណ្យនេះបំរេន (៧៨) អ្នកដោង្គអំបាល់នេះ ទោះបិអ្នកដោង្គអំបាល់នេះវង្វេង (៧៩) ទៅ លូត្សៀងពួតបតុរាបាយភូមគុះ ដោតេជះផលានិសង្ស (៨០) នេះ សំលំតោះឱយរូបភែបតុរាបាយទោពន្ធរាយ (៨១) ពួតត្រីពិធ សំប្បត្តសំបូណ្ណរឹង ទោះបិអ្នកដោងតអំបាល (៨២) នេះបាន ស្មោះផ្តោះទៅស្មោយទិព្យសម្បត្តសំបូណ្ណហោយ

(១) ដោតេជះផលានិសង្សនេះសុំទោះបំរេនទិព្យសំម្បត្ត រឹង (២) សំបូណ្ណពិពទ្ធិមួយសារ លុះបាទបូលតបទមោក្សមហោ (៣) នគរនិព្វានដាបនតិលហោង ១ បពិត្រដោតេជះនៃ (៤) សំ តេចព្រះមហាគិរន្ទត្រៃបរមបពិត្រគុតេជះសិទ្ធិសក្តិ (៥) នៃទេ ព្វតាមហាខេត្រដោងតាគ្រោងប្រទិបត្តព្រះសាស្នា (៦) នេះសុំ

ជ្រោមរក្សាព្រះអង្គសំតេចព្រះបរមរាជាធិរាជព្រះ (៧) រាជឱរស
នេះ សុំបំរេនព្រះពរមង្គលស្កុលតេមសម្រិទ្ធិ (៨) ស្ថិរទិឃាយុះ
លុះតសុក្ខសួស្ឋាធិការពិពទ្ធិមួយសារលៃ (៩) ឯបានបួសសំ
នក្កតព្រះសាស្នាឱត្បាប្រនិបាត្តកិតតោយ (១០) ព្រះបន្ទូល
ហោង នោកាលតាបិលាបព្វជ្ជាកម្មរឹងមោក (១១) សុំទេព្វតា
ផោងជ្រោមរក្សាព្រះអង្គសំតេចព្រះបរមរា (១២) ជាធិរាជឱយ
ល្មោះលែងសព្វទុក្ខសព្វសោកសព្វ (១៣) រោគសព្វភៃសព្វ
បង្រៃឱប្បទ្រព្យអន្តរាយផោងតនា (១៤) នាប្រាកាយ្យ សុំបំរេន
ព្រះជន្មាពិធិទិឃាយុះ លែងបាន (១៥) គ្រោងព្រះរាជប្រវេណិ
ទ្ធិ បានជាធម្មិរាជអាបលេកព្រះ (១៦) សាស្នាព្រះតប៉ាគត
ប្រាកដព្វតកម្ពុជរាស្ត្រនេះ ឱយ (១៧) ខេមខ្សាន្តភព្វមណ្ឌល
ស្កុលបរិបូណ្ណិត្តបព្រះរាជស (១៨) ន្តានប្ចូរាននាំបានសាង
ព្រះមហានគរផន្ទ្រប្រព្រៃ នព្រះ (១៩) ពិស្នុលោក នុសព្វប្រាការ
ផោង សប្បអន្លេហកំលុងកំ (២០) ពុជ្ជទេសនេះ លែងស្ថិតស្ថិរ
ផសកាលតលង្ស រោះ (២១) ព្រះរាជបំនងប្រាថ្នានៃសំតេចព្រះ

មហាឧបាសកមហា (២២) រាជបពិត្រហោង ១ បពិត្រនោ តេជះផលាទិសង្សគិ សំ (២៣) តេបព្រះមហាឧបាសកមហា រាជបពិត្រឱទិសកុសល (២៤) ផលដោងទៅ គឺទេព្វតាមហា ខ្សេត្រ ឲុបិត្តុរគណាដោង (២៥) អំបាល់នេះត់លោកនេះ សុំទេព្វតាដោងជ្រោមលំនោះ (២៦) សំតេបព្រះមហាឧបាសកមហោ រាជបពិត្រ ឲុសំតេប (២៧) ព្រះរាជទេពិបពិត្រព្យេរព្រះអង្គ ឲុព្រះរាជបុត្រ ឲុសំតេប (២៨) ព្រះរាជមាតាបពិត្រ ឲុគ្រិគ្រិង្គារបរិវារ ឲុរាជគុរុព្រាហ្ម (២៩) ណាបាយ៉្យមន្ត្រីមុក្ខបតុស្តំអ្នក្រមការ សប្តប្រក្រតិកិរិ (៣០) បណ្ឌិតឲុរាជបរសត្វដោង សុំស្តោះលែង សត្វទុក្ខសត្វ (៣១) សោកសត្វរោគសត្វភែសត្វបង្រៃសត្វ ឱប្បទ្រុព្យ (៣២) អន្តរាយដោងតនានាប្រាកាយ៉្យ សុំបំរេនសត្វ សុក្ខស្វ (៣៣) ស្តាធិការពិពទ្ធិមួយសារឥសកាលត់លង្ឃ ហោង សុំម (៣៤) ឈ្នះសត្វសត្រូដោងតសំមុទាយ ទោះបិមាន រាជសត្រូ (៣៥) ដោងសប្បទិសបិមានបិតគិតឲុមោកប្បេត ប្បេន (៣៦) កំម្ពុជទេសនេះ ឲុមោករំលាងព្រះសាស្នាព្រះមហា

(៣៧) សារិកជាតុគុះ នោះតេជះផលានិសង្សនេះសូំទេព្តា (៣៨) ផោងបន្តួនបិត្រាជសត្រូវនោះកុំម្បីឱយមោកបៀត (៣៩) បៀនកម្ពុជទេសនេះ គុព្រះសាស្នា ព្រះមហាសារិកជាតុ (៤០) លេយ សូំរាស្ត្រផោងអំបាលកំលុងកម្ពុជទេសនេះ (៤១) នោសុក្ខខ្សេមខ្សាន្តកុំម្បីមានបលាបល្មិលេយ ៙ (៤២) បពិត្រ សូំធុត ៗ ពោះសាធុប្រណិធាននេះ ពោះព្រះ (៤៣) មហាសព្វិជ្ញ ពុទ្ធកម្រែតេងយេងស្តុបបន្ទូលហោង ។

ប ទា នុ ក្រ ម

# អធិប្បាយសព្ទក្នុងសិលាចារឹក

ឥគរវត្ត

# បទានុក្រម

## លេខ ១

(៩) ត្រិពិធ សំ. ដែលត្រូវជា ត្រិពិធ = មាន ៣ ប្រការ ។ តទៅមានពាក្យដូច្នេះជាច្រើនទៀតឲ្យគប្បីដឹងដូចគ្នានេះ ។

(៩) ត្រៃយសរណគមនា សំ. គឺ ត្រយសរណាគមនា = ថ្វាយបង្គំដល់ប្រជុំ ៣ នៃសរណវត្ថុ (គឺព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ) ។

(១០) ឧតុល សំ. ម. គឺ អតុល ឬ អតុល្យ = រកវត្ថុដទៃទីផ្ទឹមឲ្យស្មើពុំបាន - ថ្លឹងគ្នាពុំបាន ។

(១២) ករទសនក្ខអករាង្គុលិ សំ. ម. គឺ ករ-ទស-នខ-អាករង្គុលិ = ម្រាមដែលជាទីកើតនៃក្រចកទាំង ១០ ។ ឬថា ម្រាមដៃព្រមទាំងក្រចកទាំង ១០ ។

(១២) ត្រិបាទារពិន្ទ សំ. គឺ ត្រិបាទរពិន្ទ = ព្រះបាទដ៏មានសិរី សិងមានលាយលំក្ខណ៍ជាផ្កាឈូក ។ ដូនកាលគេសរសេរជា បាទារពិន្ទ ក៏ដូចគ្នានេះ ។

(១៣) អបិន ម. គឺ អចិណ្ណ = មិនដេចក្រសែ, ហូរហែ, ជានិច្ច ។ ពាក្យនេះហើយដែលខ្មែរយើងប្រែក្លាយទៅជា "អចិន្ទ្រៃយ"

សំនៅប្រែថាមិនគប្បីគិត, គិតមិនឃើញ, គិតមិនយល់, ហួសវិស័យនឹងគិត ។

(១៣) អនេកពៃបុល សំ. បរិបូណ៌ជាអនេក, ដំរូលាយជាច្រើន ។

(១៤) ឧតុលបេស្សាទិពល សំ. គឺ អតុលវេស្ជាទិពល = មានកំលាំងមានព្រះវេស្ជាជាដើមរកទីប្រៀបគ្មាន ។

(១៥) ហ្ឫទៃ សំ. គឺហ្ឫទ័យ = ទឹកចិត្ត ។

(១៥) បុត្រពោធិសត្វផោង សំ. ១ គឺ បុត្រពោធិសត្វ·ផង = ពោធិសត្វអំពីដើមផង ។ ពាក្យថា ផង បូកណាសារសោជា ផោង តទៅមានច្រើនអន្លើឲ្យគប្បីដឹងដូចគ្នានេះ ។

(១៦) ស្បង្ដរំពឹង ខ. ឲ្យមើលថា "សៀងដំរំពឹង" គឺសិងដំរពិង ។

(១៦) នានុ-ប្រាបិតា ខ. សំ. គឺ នានូវ-ប្រាថ្នា ។ ពាក្យថា នុ តទៅមានច្រើនអន្លើ គប្បីដឹងដូចគ្នានេះ ។

(១៧) ព្រះតុ្ឋ-គិបិ ខ. ព្រះតុ្ឋ-គីប៉េ ។

(១៩) មហាពោធិ-ព្រក្ស សំ. មហាពោធិ-ព្រឹក្ស ឬ មហាពោធិ-ព្រួក្ស ។

(២០) ប្រមូយ ខ. ប្រាមួយ (៦) ។

(២១) ស្រាមណេរ សំ. ក្លាយ គឺ ស្រាមណេរ ។ ម. សាមណេរ ។

(២៨) ប្រ-សាព្រះ សំ. ប្រតិស្ឋាព្រះ ។ គឺ រលុបបាត់ អក្សរ តិ និងជើង ឋ ។

## លេខ ២

(១) នេះតតិ-ត្រិពិត ខ. សំ. នេះដ៏ គឺ ត្រីពិធ ។

(១) អំបស្ស ខ. អម្ចាស់ ។

(២) ត្រីសុជាតា សំ. សម័យនេះសរសេរជា ស្រីសុជាតា តែឲ្យត្រូវតាមសំស្ក្រឹតស្មោះជា ត្រីសុជាតា ។

(៤) ប្រំម្រ សំ. គឺ ប្រណាម្យ = ប្រណាម្យដៃ ។

(៥) កម្រតែង-យេង ខ. ។ អ. សព្វថ្ងៃនេះប្រែជា "គម្ដែងយើង" ប្រែថា ជាអម្ចាស់របស់យើង ។ ក្នុងទីខ្លះឃើញសរសេរជា កម្រតែងយេងក៏មាន កម្រតេងយេងក៏មាន សេចក្ដីដូចគ្នា ។ ពាក្យថា យេង ត្រូវនឹងពាក្យសម័យនេះថា យើង ព្រោះបុរាណគ្មានស្រៈ អើ ។ នេះទើបនឹងបង្កើតឡើងជាន់ក្រោយ ។

(៦) ពុំនកត្រើយ-ត្រាណ ខ. សំ. ពុំនាក់ត្រើយ-ត្រាណ ។ អ. មិនពឹងទៅខាងមុខ, ឬមិនដល់ត្រើយ ដូចកោះ ។ សំ. ត្រាណ ម. ជា តាណ = ទីជ្រកកោន ។

(៦) រុ-សំពៅ ខ. រូ-សំពៅ = បីដូច-សំពៅ ។

(៧) រត-រុង សំ. ខ. រត្ន-រុង ។ រត្ន=កែវ, រុង=រុងរឿង ។ ម្យ៉ាងទៀត រុង=ធំ (ម. រតន) ។

(៨) មន-គិ ខ. ពាក្យនេះក្នុងទីនេះមានច្រើនអន្លើ គេសរសេរ ជា មន-គិ ក៏មាន មុន-គិ ក៏មាន មន្គិ ឬ មុន្គិ ក៏មាន ដែលត្រូវជា ម័ន-គី ត្រូវទំនងពាក្យសព្វថ្ងៃនេះថា "ដ៏-គី" ឬ "នេះ-គី" ។

(៨) ភក្ត-ជាត-កន្តារ សំ. គឺ កត-ជាតិ-កន្តារ ប្រែថា ភពនឹងជាតិដ៏ជាឆ្មជាតិឆ្ងាយដាច់ស្រយាល ។

(៩) ប្រពទ្ធិ សំ. ប្រព្វត្ត ឬ ប្រព្រឹត្ត ។

(៩) រៀងមោក ខ. គឺ រៀងមក ។ ស្រៈ េ នឹងដើង យ គឺ ្យ) ជា ៀ មកសម័យនេះ ប្រែក់ចុងវែងចេញទៅ ដែលពិត ដើង ្យ នេះឯង ។ មក បុរាណសរសេរ ជា មោក គេទៅមានច្រើន ធ្វើឲ្យគេប្រដឹងដូចគ្នានេះ ។

(១១) ចតុទ្ទសិ-កេត សំ.-ខ. គឺ ចតុទ្ទសី-កើត គឺថ្ងៃ១៤ កើត ។

(១១) សៅរពារ សំ.ម. ប្រែថា ថ្ងៃសៅរ៍ ។

(១២) ប្រះពិស្ណុលោក ពាក្យនេះជាឈ្មោះហៅប្រាសាទនគរវត្តសព្វថ្ងៃនេះ ព្រោះប្រាសាទនេះ ព្រះបាទសូរ្យវរ្ម័នទី ២ ទ្រង់សាងនឹងឧទ្ទិសថ្វាយព្រះវិស្ណុ គឺប្រាសាទធំកណ្ដាលនោះជាទីប្រតិស្ឋានព្រះរូបរបស់ព្រះអង្គ ដល់សុគតហើយគេថ្វាយព្រះនាមជា "បរមវិស្ណុលោក" ដោយហេតុនេះគេទើបឲ្យឈ្មោះប្រាសាទនោះ ជាប់ដោយព្រះនាមរបស់ព្រះអង្គផង ដោយអធិប្បាយថា ព្រះអង្គគង់បានទៅឧបត្តិរូបលោកជាមួយគ្នានឹងព្រះវិស្ណុ ។

(១៣) រុ-បុរាណ-វិង ខ.ម. រូ-បូរាណ-វិង=ដូចបូរាណឡើងវិញ ។

(១៤) ត្រៀកអរ ខ. គឺ ត្រេក-អរ ។ ត្រៀក ឲ្យមើលថា ត្រេក ដោយយកស្រៈ េ ជា ៀ ទើបជា ត្រៀ ។ ពាក្យបែបនេះគេនៅមានច្រើនទៀតប្រើដូចគ្នានេះ ។

(១៤) ស្ដប ឬ ស្ដាប ខ. គឺ ស្ដាប ។

(១៦) តាលអនិច្ចា ខ.ម. ដាល-អនិច្ចា=បែរគិតដល់អនិច្ចា ។

(១៧) ពុំទៀង គឺ ពុំទៀន ។

(១៧) ពុំជូ-អាត្មា-គុះ ១. សំ គឺ ពុំជារបស់អាត្មា-សោត,- ពុំមែនជា-អាត្មា-សោត ។

(១៨) គិបិ ឲ្យមើល ទំព័រ ១០៤ លេខ ១៧ ។

(១៨) កេស-មោលី ម. ប្រែថាក្ពនសក់ ។

(១៩) ចេស្តាធិការ សំ. ប្រែថា កសាងក្រៃពេកដើម្បី ចេស្តា ។ បើជាចេស្តាធិកា ប្រែថា មានចេស្តាក្រៃពេក ឬជា ដ៏ក្រៃ ដោយចេស្តា, ធំទៅដោយចេស្តា ។

(១៩) អំពល ខ. អំពល់= ព្រមទៅដោយ... ប្រដាប់ទៅ ដោយ... ម្យ៉ាងទៀតថា រវល់ ។

(១៩) មុទ្ធាភិសេក សំ. មុធាភិសេក= ពិធីស្រោចក្បាល (ដោយទឹកមន្ត) ។

(២០) តុតជាក្ខុកសាង ១. ស្តុតជាខ្ទុកសាង (គឺគេដុតសក់ ដែលកោរហើយខ្ទុកសាងជាព្រះពុទ្ធរូប) ។

(២១) បាកាណ ជាឈ្មោះហៅប្រាសាទអង្គរវត្តត្រង់ថ្នាក់លើ បង្អស់ ។

(២២) សញ្ចទិដ្ឋោន ម. គឺសច្ចាធិដ្ឋាន (សំ. សត្យាធិស្ឋាន)= តាំងចិត្តចុះដោយសេចក្ដីសត្យ ។

(២២) វីយ៉្យព្យាយាម សំ. វីរ្យព្យាយាម (ម. វិរិយ ព្យាយាម)= សេចក្ដីព្យាយាមដ៏ក្លា ។

(២៣) អស្ដាង្គសិល សំ. គឺអស្ដាង្គសីល (ម. អដ្ឋង្គសីល) សីលដ៏ប្រកបដោយអង្គ ៨ ។

(២៣) អដ្ឋមី-បុណ៌មី-អំមាពិស្យា សំ. គឺអដ្ឋមី-បុណ៌មី-អមាវសី; អដ្ឋមី ថ្ងៃទី ៨, បុណ៌មី ថ្ងៃពេញបូណ៌, អមាវសី ថ្ងៃខេដច ។

(២៤) ប្រក្ឫតិ សំ. បក្ឫតិ ទម្លាប់ប្រើសព្វថ្ងៃនេះជាប្រក្រតី ។

(២៤) ជាបន្ដុស្ស ខ. ជាបន្តុស= ជាបង្អស់ ។

(២៦) អន្លោលទៅមោក ខ. អន្ទោលទៅមក ។

(២៦) សំសារភព្ទ ម. សំ. សំសារភព= ភពដែលតែងអន្ទោលកើត-ស្លាប់ ។

(២៧) សព្វៗជាតកំនេត ខ. សព្វៗ ជាតិកំណើត ។

(២៧) កោប្រគុ—ធញ្ញបុញ្ញ-លក្សណ ខ. ម. សំ. គឺកប ឬប្រកបនូវធញ្ញបុញ្ញលក្សណ ។ ធញ្ញបុញ្ញលក្សណ ប្រែថា លក្សណៈ ជាអ្នកមានសម្បត្តិមានបុណ្យ ។

(២៨) សំយក្សព្លត ខ. សំណាក់ឮដ៏..... ។

(២៩) សាតប្រណីធាន សំ. សាត្យប្រណិធាន ឬសត្យប្រណិធាន ប្រែថា សេចក្ដីតាំងចិត្តដោយទៀងត្រង់ ។

(២៩) មុហ្ចរិងហោង ខ. គឺមួយនិវិញហោង = មួយវិញទៀតហោង ។

(៣០) ត្រីអាយ៉ុមៃត្រិ សំ. ត្រិអាយុមៃត្រី ឬត្រិអាយុមៅត្រយ ។

(៣៣) ខ្ញុំង – ធម្មាំម្រឹត ខ. សំ. ខ្ញុំង – ធម្មាម្រឹត ខ្ញុំងអម្រឹតធម៌ = ខ្ញុំងធម៌ដែលមិនចេះស្លាប់ ។

(៣៣) គិ – សត្តតិស័ររពោធិបក្ខិ ខ. ម. គឺ – សត្តតិសររពោធិបក្ខិ (យ) = ធម៌ប៉ែកខាងត្រាស់ដឹងមានចំនួន ៣៧ ប្រការ ។

(៣៤) ព្រះកេសកោរ – ខ្សណ ខ. សំ. ព្រះកេសកោរក្សណ = ព្រះកេសកោរស្រេចក្នុងខណៈនោះ ។

(៣៥) ត្បិង – ប្រាកត ខ. សំ. មើលថា "ដៀងប្រាកដ" គឺ ដឹងប្រាកដ ឬ ទៀងប្រាកដ ។

(៣៥) បតុពិធបរសត្វ សំ. ចតុពិធបរិស័ទ្យ = បរិស័ទ្យមានប្រភេទ ៤ ។

(៣៦) គេរសធុតង្គ ម. ប្រែថា ធុតង្គ ១៣ ។

(៣៦) ផ្លង—ភាវណា ខ. ម. ផ្ទន់—ការនា ។

(៣៧) បត្តាឡិសកំមដ្ឋាន ម. ចត្តាឡីសកម្មដ្ឋាន = កម្មដ្ឋាន ៤០ ។

(៣៨) បតុបិតិសម្ភិទាញាណ ម. ចតុបដិសម្ភិទា-ញាណ = ញាណដ៏បែក ស៊ិនមានចំនួន ៤ ប្រការ ។

(៤០) មួយអន្លេ ខ. មួយអន្ទើ ។

លេខ ៣

(១) នែះគិពោះត្រិពិធសុបរិត ខ. សំ. នេះគឺពេះ–ត្រិពិធ–សុចរិត ... ។

(១០) គ្រិត្រិភវិនាទិត្យពម្ម ស. ប្រែថា អ្នកមានព្រះអាទិត្យជាគ្រោះសិនផ្សាយអំណាចទៅក្នុងភពទាំងបីដ៏មានសិរី ។ ពាក្យថា ពម្មនេះក្នុងសិលាចារឹកខ្លះសរសេរជា វម្ម ពាក្យនេះហើយដែលប្រើក្នុងព្រះកជពង្សាវតារក្នុងជាន់ក្រោយ ជា ពាក់ បុពាណ ដូចយ៉ាងព្រះនាមស្តេច ១ អង្គថា សុរិយោពាណ នេះគឺ សុរិយវម្ម ឬក៏ សុរិយពម្ម ដល់មកសម័យនេះ សរសេរជាវរម័ន ទាំងអស់ នេះឲ្យគប្បីដឹងថា

ដើមជា ក្ដិ ប្រែថា គ្រោះ គឺគ្រោះដែលគេពាក់ព្យាំង ជាពាក្យសំស្ក្រឹត មិនមែនជាពាក្យចិន តាម យ៉ាងណា ដូចជាអ្នកខ្លះយល់នោះទេ ។

(១៦) មគ្គិកាលជា-ប្រឋម ១. សំ. ម័ន គឺ កាលជា-ប្រថម = ដ៏គឺកាលជាប្រថម ។ ឬ នេះគឺកាលជាបឋម ។

(១៧) ប្លែងស្មោយរាជសម្បត្ត ១. ម. ថ្លើងស្មោយរាជ-សម្បត្តិ = ឡើងស្មោយរាជសម្បត្តិ ។ ពាក្យថ្លើងនេះសៀមយកទៅប្រើសព្វថ្ងៃនេះ ។

(១៩) ឆុលេក-សាស្នា ១. នូវលើកសាសនា ឬ នឹងលើកសាសនា ។

(២០) ព្រះពិស្នុលោកប្រាការ សំ. ប្រែថា កំពែងនៃប្រា-សាទព្រះពិស្ណុលោក (គឺនគរវត្តសព្វថ្ងៃនេះ) ។

(២០) លេកថ្នក់កំពូល ១. លើកថ្នកកំពូល ។

(២១) ឆព្វស្វូល សំ. ម. ខពស្វូល ឬ ឧស្វូល ប្រែថា កំពូល ៩ ។

(២២) ស្ថាបណា សំ. ស្ថាបនា = ការកសាងឡើង ។

(២៣) ឆ្លោងបំរេគ ១. ឆ្លងចំរើន ។

(២៣) ក័ល្បនា  សំ. កល្បនា = ការសម្រេច, សេចក្ដីសម្រេច ។

(២៣) ព្រះជិតប្អូនព្រះអង្គ  ខ. ព្រះជីដូនព្រះអង្គ ។

(២៦) សប្ដសន្ដាន  សំ. ប្រែថា ញាតិទាំង ៧ សន្ដាន ។ គេពោលមានពាក្យបែបនេះជាច្រើន ឲ្យគប្បីដឹងដូចគ្នានេះ ។

(២៦) ត់សំមុទាយ  ខ. សម័យនេះប្រើជា "ដ៏សម្ពាយ" ជាពហុវចនៈគួនឹងពាក្យថា "ទាំងឡាយ" ។

(២៦) ឱ្យពន្លាយ  ខ. សំ. ឲ្យពណ៌ក៌យ=ឲ្យរុងរឿង ។

(២៨) បុត្រប្រាថ្នា  សំ. បុព៌ប្រាថ្នា, ម. បុព្វបត្ថនា=ប្រាថ្នាអំពីមុនមក, ប្រាថ្នាជាប់ពីដើមមក ។

(២៩) កំម្ពុជទេស  ម. កម្ពុជទេស=ប្រទេសកម្ពុជា ។

(៣០) ឱ្យ-សំបូណ៌  ខ. សំ. ឲ្យសំបូណ៌; ដូនកាលសារសេរជា សម្បូណ៌ ។

(៣១) រោះ-បូព៌កាលរឹង  ខ. សំ. រូ-បុព៌កាលវ៉ង (ម. បុព្វ-កាល)=ដូចកាលដើមវិញ ។

(៣១) ធម៌ន្ដរាយ  សំ. ធម៌ន្ដរាយ=អន្ដរាយធម៌ ។

(៣២) ខ្សេម-សម្ឫទ្ធិ សំ. ក្សេម-សម្ឫទ្ធិ ឬក៏ក្សេមសម្រឹទ្ធិ = សម្រេចនូវសេចក្ដីក្សេម (ប្រាសចាកទុក្ខ) ។

(៣២) ស្ថិរ-ស្ថាពរ សំ. ស្ថិរ ស្ថាវរ (ម. ថិរ-ថាវរ) មាំមួន ខ្ជាប់ខ្ជួន, ឋិតថេរ ។

(៣២) មួយ្ឃ-នាប្រឋមកាល ១. សំ. មួយទី-នាប្រថម-កាល = មួយវិញទៀតនាប្រថមកាល ។

(៣៤) ព្រះពី-ធរណិន្ទ្រ ១. សំ. សរសេរខ្វាត់ ដែលត្រូវ ជា "ព្រះត្រី–ធរណិន្ទ្រ" ។

(៣៤) ត្រិធម្មិធិតា សំ. ត្រិធមិធីតា = ជាធីតាព្រះធមិដ៏ មានសិរី ។ ត្រ នេះគឺលុបបាត់ស្រៈអិ ។

(៣៥) ទ្រង់-គត្តិណិ សំ. ទ្រង់-គត៌ណី = ទ្រង់-គតិ (គតិណី ស្រីមានគតិ) ។

(៣៧) ទោះបុរុស-ឈោះ-ទោះស្ត្រី ១. ទោះបុរស-ឬ-ទោះស្រី ។

(៣៧) គីណា-ព្រះរាជអទិស្ឋាន ១. សំ. សិទព្រះរាជអធិ-ស្ឋាន គឺក្សេណព្រះរាជអធិស្ឋាន ។

(៣៨) ឱប្បហិក ម. ឧបដ្ឋាក ប្រែថា បំរើ-ចំនុកបម្រើ ។

(៣៩) ស៊ុំសំយ៉ក្ស-ភក្តី ១. សំ. សូមសំណាក់-ភក្តិ ។ គទៅមានពាក្យបែបនេះជាច្រើនអន្លើ គប្បីដឹងដូចគ្នានេះ ។

(៥០) ព្យិតអ្យតបំល្អ្យង ១. ឲ្យមើលថា "ពៀត-អៀត-បំល្អៀង" គឺ ពិត-ឥត-បំល្អៀង ។ ពាក្យបែបនេះមានច្រើន គប្បីដឹងដូចគ្នានេះ ។

(៥១) មោក-ឱត្បត្តិ ១. សំ. មក-ឧត្បត្តិ (ម. ឧបត្តិ) = មកកើត ។

(៥១) មាត្រោទរ សំ. (ម. មាតុ-ឧទរ) = ផ្ទៃនៃមាតា ។

(៥២) ភុល-ព្រះរាជបុត្រ ១. កុល-ព្រះរាជបុត្រ គឺ ប្រសូតព្រះរាជបុត្រ ។ ពាក្យថា កុល សម័យនេះច្រើនប្រើថា ផុល ដូចយ៉ាងថា ផុលផុស ។

(៥២) កោប្រ-ទុ-ល័ក្ស ១. សំ. កបទូវ-លក្សណ៍ គឺប្រកបទូវលក្ខណៈ ។

(៥៣) ឱត្តំ-សំ-ទុព្រះលក្ខារាសី-តំបី ម. ១. ឧត្តម-សម-ទូវព្រះលក្ខណា-រាសី-តិត្ថី ។ (តិត្ថី = ថ្ងៃ) ។

(៥៣) ស្បិង្គ-អនុកូល-បរិបូណ្ណ៌ ១. សំ. ស្យន្ទ-អនុកូល បរិបូណ៌ គឺ សិងដ៏អនុកូលបរិបូណ៌ ។

(៥៤) បតុទ្ទិតី-ពោធិ សំ. ខ. បតុទ្ទសី ឬ ចាតុទ្ទសី កេច គឺ ១៤ កេច ។

(៥៥) អាសាឍ្ហ-ពុទ្ធ ពារ-សារទា សំ. អាសាឍ-ពុធ-ពារ សារទា ប្រែថា ខែអាសាឍ-ថ្ងៃពុធ ។ ពាក្យថា សារទា ដែលភ្ជាប់ខាងចុង ដូចកាលឃើញសរសេរជាសារទា ដូចកាលជាសារណ៍, ជាប្រែដូចម្ដេច មិនប្រាកដក្នុងចិត្ត សុំស្ទើរទុកសិន ។

(៥៥) ទា-ប្រឋម-អទ្ធាំត សំ. ទា-ប្រថម-អាធ្រាត ។ វេលានេះប្រើជាអាធ្រាត ។

(៥៥) លគ្នា-ស្ថិត ម. សំ. លក្ខណា-ស្ថិត ។

(៥៧) គំរប្ប-ទ្វាទសទិន ខ. ម. ឬ ខ. សំ. គំរប់-ទ្វាទសទិន = គំរប់ថ្ងៃ ១២ ។

(៥៨) ធ្វើ-ជាតិកម្ម ខ. សំ. ធ្វើ-ជាតិកម៌ ។ ជាតិកម៌ ឬ ជាតិកម្ម ប្រែថា ធ្វើឲ្យចំរើន ដូចយ៉ាងទិញរបស់សង្ឃ ឲ្យថ្លៃលើសថ្លៃដើម តាំងពី ១ សេនឡើងទៅហៅថា ជាតិកម៌ ។

(៦៣) មហាខេត្រ សំ. មហាក្សេត្រ ។ ជាឈ្មោះហៅទេវតាធំៗ គឺព្រះព្រហ្ម ព្រះឥសូរ ព្រះនារាយណ៍ ប្រែថា អ្នកជាខេត្រស្រែបុណ្យដ៏ធំ ឬជាអ្នកមានខេត្រដ៏ធំ ។ តែតាមទំនៀមនៅស្រុកខ្មែរ

ក្នុងវេលានេះ ហៅ ព្រះព្រហ្ម ព្រះឥសូរ ព្រះនារាយណ៍ ព្រះពិឃណេស និងព្រះចន្ទ្រ រួមទាំង ៥ អង្គនេះថា បញ្ចក្សត្រ ។

(៦៤) មហាព្រហ្មឫសី សំ. មហាព្រហ្មឫសី = ឫសីដ៏ប្រសើរធំ ។ ឫសីក្នុងសាសនាព្រាហ្មណ៍ចំណែកជា ៤ ប្រភេទ គឺ ១ ព្រហ្មឫសី, ២ ទេពឫសី, ៣ រាជឫសី, ៤ មុនី មានយសស័ក្តិធំជាងគ្នា ដោយលំដាប់ចុះមក ។

(៦៤) សិទ្ធិសក្តិ សំ. មានអំណាចដ៏ឲ្យសម្រេចបានធុតឆាប់ពិត ។

(៦៤) នុ-ទេពរក្ស-បិត្តរគណា-ផោង ខ. សំ. នូ-ទេព-រក្ស-បិតរគណ:ផោង ។ ទេពរក្សបិតរគណ: ប្រែថា ពួកព្រះបិតរ ដែលកើតជាទេពរក្ស ឬថា ពួកទេពរក្សដ៏ជាព្រះបិតរ ។ បិតរជាស័ព្ទ ដែលប្រកបឡើងសម្រាប់ជាឈ្មោះហៅព្រលឹង ឬវិញ្ញាណព្រះអយ្យកោ ព្រះអយ្យិកា ព្រះជនក ព្រះជននី ។ល។ របស់ព្រះមហាក្សត្រ ត្រូវនឹងពាក្យព្រស្តាយើងថា ខ្មោចដីដូនតា ខ្មោចឪពុកម្តាយ ដូចយ៉ាងការសែនថ្វាយទៅខ្មោចទាំងនោះ ហៅថា ថ្វាយព្រះបិតរ ។

(៦៥) សមុគតា ម. ប្រែថា ជួបជុំព្រម — ប្រជុំព្រម ។ ពាក្យនេះប្រែហលក្លាយមកពីពាក្យថា សាមគ្គិតា = សេចក្តីជាអ្នកព្រមព្រៀង ។

(៦៥) ទោគិបិស្តុប ខ. ទោះគីបីស្តេច ។

(៦៨) សរប្ប-សរាទ-កាល សំ. សរុប្ប-សរទ-កាល គឺត្រង់បញ្ចប់ សរទៈរដូវ ។ ក្នុងកន្លែងអស្សុជ ទៅខែកត្តិកជា សរទៈរដូវ ។

(៦៨) គីបិ-តិមនព្រះសយិដោង ខ. សំ. គីបី-ទិមន្ត ព្រះសង្ឃផង ។

(៦៨) ត-អស្សារ ខ. សំ. ដ៏-អស្សារ្យ ។

(៧០) ពិធិ-តប្បិណា-ទ្វាទសបិណ្ឌ សំ. ពិធី-តបិណា-ទ្វាទសបិណ្ឌ ប្រែថា ពិធីប្រួចទឹកក្នុងឱកាសបុណ្យដាក់បិណ្ឌទាំង ១២ ។

(៧០) ឥ-អស្សោត្តរសតមង្គល សំ. អស្សោត្តរសតមង្គល គឺមង្គល ១០៨ ។ ចូរមើលក្នុងជីវទាន ។

(៧២) យថាសាស្ត្រ សំ. ប្រែថា តាមតម្រាសាស្ត្រ ។

(៧៣) សព្វសត្វ-ដោង្គលល្បងនោ សំ. ខ. សព្វសត្វ-ផង ដ៏លទ្ធិនៅ... ។ លទ្ធិនត្រូវទឹងពាក្យថា កើតនៅ ឬស្ថិតនៅ ។

(៧៤) រូបដល់-អក្ខនិដ្ឋព្រហ្ម ខ. ម. រូបដល់-អកនិដ្ឋ-ព្រហ្ម ។

(៧៩) ឰត-បតុរាបាយភូម-គុះ ខ. សំ. ឰត-បតុរាបាយ-ភូមិ-គុះ ។ គុះ ត្រូវនឹងពាក្យថា សោត? ។

(២) សំបូណ៌-ពិពទ្ធិ-មួយសារ សំ. សំបូណ៌-ពិពទ្រ-មួយសារ គឺ សំបូណ៌ចំរើនវិសេសមួយយ៉ាងទៀត ។

(២-៣) បទមោក្ស-មហានគរ-និញ្វាន សំ. បទមោក្ស-មហានគរនិព្វាន ។ បទមោក្ស នេះក៏ជាឈ្មោះនៃព្រះនិព្វានដែរ ប្រែថា ផ្លូវដែលរួចចាកកិលេសទឹងកងទុក្ខ ។

(៣) ជាបឥតសហោង ខ. ជាបដ្ឋស់ហោង ។

(៧) ព្រះពរមង្គលស្កល សំ. ម. ព្រះពរមង្គលសកល = ព្រះពរមង្គលទាំងអស់ ឬថា ព្រះពរមង្គលគ្រប់មុខគ្រប់យ៉ាង ។

(៧-៨) តេម-សម្ពទ្ធិ-ស្មិរ-ទិឃ៉ាយុះ ខ. សំ. តើម-សម្ពទ្ធិ-ស្ថិរទីឃាយុ គឺ ថែមឲ្យបានអាយុវែងខ្ជាប់ខ្ជួន ។ តើម ប្រែថា ថែម ។

(៨) សុក្ខ-សួស្តាធិការ សំ. សុខ-សួស្តាធិការ ប្រែថា ចំរើនសុខសួស្តីក្រៃលែងទៅ ។

(៩) ឱត្យាប្រែនិបាត្ត ក្រិត សំ. ឧត្យាហ-ប្រណិប័តន៍-ក្ឫត ឬ ឧត្យាហ-ប្រតិប័ទ-ក្ឫត ។ ក្ឫត ទឹងសរសេរជាក្រឹត ជំនួសក៏បាន តែបរសេរដូចមុនត្រូវជាង ។ ដែលសរសេរ ក្រិត នេះគឺលើសស្រៈ អិ ១ ។

(១៥) ត-ណាណាប្រាកាយៀ សំ. ដ៏-នានាប្រការ = ដ៏មាន ប្រការផ្សេង ៗ ។

(១៦) កំម្ពុជិរាស្ត្រ សំ. កម្ពុជរាស្ត្រ = រាស្ត្រខ្មែរ ឬ រាស្ត្រ ដែលនៅក្នុងប្រទេសកម្ពុជា ជាគូគ្នានឹងពាក្យថា កម្ពុជេស្វរ ដែលប្រែថា ស្តេចខ្មែរ ឬស្តេចក្នុងប្រទេសកម្ពុជា ។

(១៧) ខ្សេមខ្សានភព្វមណ្ឌលស្កុល សំ. ក្សេមក្សានកព មណ្ឌលស្កុល ។

(១៨) បូរាន- តាបានសាង ម. ខ. បូរាណ—នាបាន សាង ។

(១៩) ធុ-សព្វិប្រាការផោង សប្បេអន្ទេហ ខ. សំ. ទូវ—សព្វប្រការផង សព្វអន្ទើ ។

(២០) ឥសកាលតលង្ឃ ខ. អស់កាលដ៏លុង = អស់ កាលដ៏យូរ ។

(២១) ពោះព្រះរាជបំណង ខ. ពោះព្រះរាជចំណង់ ឬព្រះរាជចំណង់ គឺដូចព្រះរាជចំណង់ ។

(២៧) ព្យេរព្រះអង្គ ខ. ពីរព្រះអង្គ ។ ប្រហែលប្រុងនឹងសរសេរជា ព្យេរ ដែលអាទេសមកពី ពីរ បើដូច្នេះមិនឃើញលើសអី១ ។

(២៩) សប្តប្រក្រតិ សំ. សប្តប្រក្ឫតិ គឺប្រក្ឫតិ ៧ យ៉ាង ។ បាននឹង ព្រះរាជា, អាមាត្យ, នគរ, ប្រទេស, ទ្រព្យ, ពល, មិត្រ, ហៅថា សប្តប្រក្ឫតិ ។

(៣០) កវីបណ្ឌិតនុរាជបរសត្វ សំ. កវី-បណ្ឌិត-នូរាជបរិស័ទ្យ ។

(៣៤) សប្បុទិសបិមានចិត សំ. សពិទិស-បីមានចិត្ត ។

(៣៤) មោកបៀតបៀន ខ. មកបៀតបៀន ។ គទៅមានពាក្យបែបនេះច្រើន ឲ្យគប្បីដឹងដូចគ្នា ។

(៣៧) ព្រះមហាសារិកធាតុ គុះ ម. ខ. ព្រះមហាសារី-រិកធាតុ គុះ ។

(៣៨) បន្ទនបិត្រាជសត្រូ ខ. សំ. បណ្តាន់ចិត្តកផសត្រូ ។ សត្រូតាមទម្លាប់សរសេរជាសត្រូវ តែយ៉ាងដើមត្រូវជាង ។

(៤១) បលាបល្អិលេយ ម. ១. ចលាចល នី លើយ = ចលាចលនីមួយ ៗ ។

(៤២) សុំធុត ៗ ពោះសាធុប្រណិធាន ខ. សំ. សូមធុត ៗ ស្រាធុប្រណិធាន គឺសូមធុត ធុតដូចសេចក្ដីតាំងចិត្តដ៏ប្រពៃ ។ (សាត្យ. ប្រណិធាន?) ។

(៤៣) ព្រះមហាសត្វជិពុទ្ធ សំ. (ម. មហាសត្វញ្ញពុទ្ធ) តាមទម្លាប់កន្លងសម័យនេះ សរសេរជា មហាសាពេជ្ញ តែសរសេរយ៉ាងនុំនោះត្រូវស្ទះតាមសំស្ក្រឹត ។

# សុភាសិតកចាំគាថា

របស់

# ព្រះគ្រូញាណសំវរ ញាន - ឈឹន

## មានរឿងដទៃទៀតក្នុងគម្ពីរតិក្កនិបាត

មានសេចក្ដីដំណាលថា ក្នុងអតីតកាលកន្លងទៅយូរហើយមាន សេដ្ឋីបុត្របីនាក់ជាសំឡាញ់នឹងគ្នា នៅក្នុងក្រុងពារាណសី ឯក្នុងក្រុងនោះមានស្រះឈូកមួយ មានបុរសម្នាក់អ្នករក្សាស្រះឈូកជាមនុស្សកំបុតច្រមុះ ។ ថ្ងៃមួយសេដ្ឋីបុត្រទាំងបីនាក់ចង់ប្រដាប់តែងខ្លួនដោយកម្រងផ្កា ទើបនាំគ្នាដើរចូលទៅកាន់សំណាក់អ្នករក្សាស្រះឈូកដោយប៉ិនថា យើងទាំងអស់គ្នានឹងពោលពាក្យមិនពិតសរសើរគុណបុរសកំបុតច្រមុះនេះ ហើយនឹងសូមផ្កាគាត់ លុះគិតហើយទើបចូលទៅឈរជិតបុរសនោះ សេដ្ឋីបុត្រជាបឋម (ទី ១) កាលរៀបនឹងសូមផ្កាក៏សូត្រជាបទគាថាថាៈ

យថា កេសា ច មស្សូ ច ឆិន្នំ ឆិន្នំ វិរូហតិ
ឯវំ រូហតុ តេ នាសា បទុមំ ទេហិ យាចិតោ

ប្រែថា សក់នឹងពុកចង្កាគេកោរកាត់ហើយគង់ដុះឡើងវិញបាន យ៉ាងណា ច្រមុះរបស់អ្នកចូរឲ្យដុះឡើងដូចសក់នឹងពុកចង្កានោះចុះ ឯខ្ញុំត្រូវការសូមផ្កាអ្នក អ្នកចូរឲ្យផ្កាដល់ខ្ញុំ ។

សេដ្ឋីបុត្រជាគំរប់ពីរ កាលរៀបនឹងសូមផ្កាក៏សូត្រជាបទគាថា ថា

យថា សារទិកំ ពីជំ ខេត្តេ វុត្តំ វិរូហតិ
ឯវំ រូហតុ តេ នាសា បទុមំ ទេហិ យាចិតោ

ប្រែថា ធម្មតាពូជដែលបុគ្គលសាបព្រោះ ក្នុងស្រែឬក្នុងចំការ ក្នុងរដូវសរទកាល គឺរដូវសម្រកតែងលូតលាស់ដុះឡើងផុនយ៉ាងណា ច្រមុះរបស់អ្នកចូរឲ្យលូតលាស់ដុះឡើងដូចពូជទាំងនោះចុះ ឯខ្ញុំត្រូវការសូមផ្កាអ្នក អ្នកចូរឲ្យផ្កាដល់ខ្ញុំ ។

បុរសអ្នករក្សាស្រះឈូកក៏ខឹងអន់ចិត្តមិនឲ្យផ្កាឈូកដល់សេដ្ឋីបុត្រទាំងពីរនាក់នោះឡើយ ព្រោះសេដ្ឋីបុត្រទាំងពីរនាក់នោះពោលពាក្យមុសាវាទ ។

ឯសេដ្ឋីបុត្រជាគំរប់បី កាលរៀបនឹងសូមផ្កាក៏ពោលពាក្យពិតសូត្រជាបទគាថាថា

ឧកោចំ បលបន្តេ តេ អបិ បទុមានិ ទស្សតិ
វឌ្ឍំ វា តេ ន វា វឌ្ឍំ នត្ថិ ឆាតកាយ រូហាជា
ទេហិ សម្ម បទុមានិ តស្ស មេ សម្ម យាចិតោ

ប្រែថា សេដ្ឋីបុត្រទាំងពីរនាក់នោះ ពោលពាក្យមិនពិតចំពោះអ្នកដោយគំនិតគិតថា អ្នកនឹងឲ្យផ្កាមិនខាន ក៏នាំគ្នាពោលពាក្យប្រៀបធៀបក្តី មិនពោលក្តី ពាក្យនោះមិនជាប្រមាណដល់ចិត្តអ្នក ឯចំណែកខ្ញុំ ៗ គិតថា ធម្មតាច្រមុះបើកំបុតហើយក៏មិនដែលដុះវិញទេ តែពាក្យនេះខ្ញុំមិនពោលសំដៅដល់ច្រមុះអ្នកទេ ខ្ញុំមកនេះមានបំណងតែនឹងសូមផ្កាប៉ុណ្ណោះ បើសំឡាញ់ខ្ញុំត្រូវការសូមផ្កាអ្នក ចូរសំឡាញ់អ្នកឲ្យផ្កាដល់ខ្ញុំ

ដោយស្រួលចុះ បុរសអ្នកក្រស្រះឈូកក៏តបថា អ្នកទាំងពីរនាក់នោះពោលពាក្យមុសាវាទ ឯអ្នកនេះពោលពាក្យតាមសភាវពិត ខ្ញុំនឹងឲ្យផ្កាដល់អ្នក ថាហើយក៏កាច់ផ្កាយកមកបង់ជាបាច់ហុចឲ្យទៅ ។

បុគ្គលអ្នកប្រព្រឹត្តពោលពាក្យមុសាវាទ ហើយ នឹងខាតលាភដូចរឿងសេដ្ឋីបុត្រទាំងពីរនាក់នោះឯង អ្នកលះពោលមិនពោលពាក្យមុសាវាទហើយ នឹងបានលាភបវរមិនដូចសេដ្ឋីបុត្រជាគំរប់បី ដែលនាំមកក្នុងរឿងជាមួយគ្នានេះ ។

ចប់រឿងសេដ្ឋីបុត្រ ៣ នាក់

## ទោសបិសុណវាចា

មានរឿងក្នុងគម្ពីរធម្មបទ បឋមភាគ

សេចក្តីថា កាលក្នុងសាសនាព្រះសម្ពុទ្ធព្រះនាមកស្សប មានព្រះថេរពីរអង្គជាសំឡាញ់នឹងគ្នា មានព្រះទ័យស្មើដូចជាបងប្អូនកើតក្នុងផ្ទៃមាតាជាមួយគ្នា ។ ថ្ងៃមួយមានភិក្ខុជាធម្មកថិកមួយរូប នៅពោលពាក្យញុះញង់បំបែកព្រះថេរទាំងពីរ[១]អង្គឲ្យបែកបាក់សេចក្តីរាប់អាន លុះភិក្ខុធម្មកថិកនោះធ្វើកាលកិរិយាស្លាប់ទៅ ក៏ទៅកើតក្នុងអវិចីនរកអស់

---

១ ព្រះថេរ ១ អង្គដែលជាមហាថេរលោកមានវស្សា ៦០ ព្រះថេរ ១ អង្គដែលជាអនុថេរលោកមានវស្សា ៥៩ ។

កាលដ៏យូរកន្លងមួយពុទ្ធន្តរ លុះរួចពីនរកមកទៅកើតជាសូករប្រេត គឺប្រេតមានសណ្ឋានដូចជាជ្រូក មានខ្លួនជាមនុស្ស ក្បាលជាជ្រូក រងទុក្ខលើភ្នំគិជ្ឈកូដក្នុងពុទ្ធកាលនេះ ទោសទាំងនេះជាទោសព្រោះពោលបិសុណវាចានោះឯង ។

ព្រះវង្គីសត្ថេរលោកដឹងសេចក្តីនេះពិតហើយ ទើបលោកសំដែងជាបទគាថាដែលរាប់បញ្ចូលមកក្នុងសុភាសិតសូត្រដូច្នេះថា

តមេវ វាចំ ភាសេយ្យ យាយត្តានំ ន តាបយេ
បរេ ច ន វិហឹសេយ្យ សា វេ វាចា សុភាសិតា ។

ប្រែថា បុគ្គលមិនគប្បីធ្វើខ្លួនឲ្យក្តៅក្រោយផង មិនគប្បីបៀតបៀនអ្នកដទៃផង ដោយវាចាណា គប្បីពោលតែវាចានោះចុះ វាចានោះឯងហើយជាសុភាសិត ។

ចប់រឿងសូករប្រេត

ហិតោបទេស ភាគទី ១

# ការបងមិត្រ

តពីកម្ពុជសុរិយា ឆ្នាំគំរប់ ៥ ខែ ៧ — ១២ (១៩៣៣)

ព្រះមហាពិទូរ ក្រសេម គន្ថរចនបណ្ឌិត

ប្រែនិងរៀបរៀង

ខណៈកំពុងផញ្ញើងដូច្នេះ អ្នកដំណើរនោះក៏ត្រូវខ្លាស្ទុះមកចាប់កអូសយកទៅស៊ី ហេតុនោះ យើង (ស្តេចព្រាប) ទើបនិយាយថា អ្នកដំណើរនោះមានសេចក្ដីលោភ ចង់បានកងមាស ពាល់តែធ្លាក់ក្នុងកក់ផុង មិនអាចនឹងរើខ្លួនរួច ក៏ត្រូវខ្លាកញ្ចាស់អូសយកទៅស៊ីបាត់ ហេតុនេះ កិច្ចការអ្វី ៗ ក៏ដោយ ដែលមិនទាន់បានពិចារណាឲ្យល្អិតសព្វគ្រប់សិន ទោះបីដូចម្ដេច មិនគួរនឹងធ្វើទៅដោយស្រពាន់ឡើយ ព្រោះ —

២១ អាហារដែលធាតុរំលាយល្អិតល្អ បុត្រដែលឆ្លៀវឆ្លាស ភរិយាដែលនៅក្នុងគភ៌ ព្រះនរបតីដែលក្រសួមានសេចក្ដីស្វាមីភក្ដិដោយល្អ វាចាដែលនិយាយចេញទៅដោយបានគិតល្អិតល្អស្រេចហើយ និងការងារដែលត្រិះរិះសព្វគ្រប់ហើយទើបធ្វើ (អំបាលនេះ) នឹងមិនប្រែប្រួល (ជាអាក្រក់ទៅក្នុងអនាគត) អស់កាលជាអង្វែង ។

ព្រាបដែលជាបរិវារ ១ បានឮដូច្នោះ ទើបនិយាយដោយសេចក្ដីក្រែងថា អើ ដែលលោកពោលដូច្នេះតើដើម្បីប្រយោជន៍អ្វី ព្រោះ —

២២ ពាក្យអ្នកចាស់ទាំងឡាយ គួរនឹងកាន់យកក្នុងវេលាមានក្ដីវិបត្តិមកដល់ហើយ បើអំពាល់តែពិចារណាគ្រប់មុខទៅដូច្នេះ ក៏នឹងទៅស្វែងរកអ្វីបាន? សូម្បីតែអាហារក៏ក្រមនឹងទៅរកស៊ីបាន ។

២៣ សត្វបើការស្វែងរកអាហារបាយទឹកក្នុងលោកនេះ បើចេះតែរអែងសង្ស័យគិតភ័យជាប្រក្រតីហើយ តើនឹងប្រកបការរកស៊ីដោយស្ថានណា នឹងញ៉ាំងជីវិតឲ្យប្រព្រឹត្តទៅ ដូចម្ដេចបាន? ។

២៤ អ្នកឥត្ថាឈ្លាទំនះគេ អ្នកប្រើខនិន្ទាគេ អ្នកមិនសារភាពទោស អ្នកមានទោសៈខ្លាំង អ្នកច្រើនសន្ទេះសង្ស័យ អ្នកអាស្រ័យមិច្ឆាជីវិតនឹងអ្នកដទៃ ៦ ពួកនេះជាអ្នកដែលត្រូវបានទទួលទុក្ខវេទនាដ៏ចំហុត ។

កាលព្រាបទាំងឡាយបានឮដូច្នោះ ក៏នាំគ្នាហើរចុះទៅ ព្រោះថា—

២៥ អ្នកជាបណ្ឌិត ពហុស្សូត្រ ចេះចាំវិជ្ជាមហាសាស្ត្របាន អាចរាយសេចក្តីកំបាំងផ្សេងៗ ឲ្យបែកត្រចះទៅបាន តែលុះត្រូវសេចក្តីលោភមកគ្របមុខឲ្យងងឹតហើយ រមែងបានទទួលទុក្ខវេទនា ដូចគ្នានឹងអ្នកល្ងង់ដែរ ។

២៦ សេចក្តីលោភធ្វើឲ្យកើតទោសៈ សេចក្តីលោភធ្វើឲ្យកើតសេចក្តីដក្រែក សេចក្តីលោភធ្វើឲ្យកើតសេចក្តីវង្វេង នឹងសេចក្តីវិនាស ព្រោះហេតុនោះ សេចក្តីលោភទើបជាអណ្តូងទីកើតនៃសេចក្តីមន្ទិលទាំងពួង ។

២៧ ធម្មតាប្រើស នឹងមានប្រើសមាសឲ្យខុសវិស័យទៅមិនបាន ទោះបីដូច្នោះ ព្រះកមក៏នៅតែលោភចង់បានប្រើសប្រភេទនេះ ហេតុនោះ សេចក្តីវិនាសដែលនឹងមានមកដល់ សូម្បីបញ្ញារបស់បុរសដែលធ្លាប់តែភ្លឺរុងរឿង ក៏ត្រឡប់ជាងងឹតងងល់ទៅវិញជាញយ ៗ ។

គ្រានោះ ព្រាបទាំងឡាយក៏ជាប់លប់អស់ ទើបនាំគ្នាបន្ទោសព្រាបដែលជាមេនាំចុះទៅនោះ ៗ លោកតែងថា —

២៨ (បើមិនល្មមការទេ) បុគ្គលមិនគួរខឹងរនេះរនោតបញ្ចេញមុខគេ កាលការនោះសម្រេចទៅ ក៏បានទទួលផលស្មើនឹងគេឯង តែបើការនោះខូចខាតទៅអ្នកមេនាំដើរមុន ក៏តោងវិនាសខូចក្នុងទីនោះ ។

២៩ ការដែលទប់ឥន្ទ្រិយទុកមិនបាន លោកថាជាផ្លូវនៃសេចក្តីវិបត្តិ, ការក្រោបឥន្ទ្រិយបាន ជាផ្លូវមកនៃសម្បត្តិ, ខនេះនឹងចង់ដើរផ្លូវណា ក៏ស្រេចហើយនូវចិត្តចុះ ។

ចិត្រគ្រីវៈ បានឮបរិវារបន្ទោសព្រាបអ្នកនាំអាទិ៍ ទើបនិយាយដោះសាថា ការរឿងនេះ មិនមែនជាសេចក្តីខុសរបស់គេទេ ព្រោះ —

៣០ សូម្បីមិត្រ ក៏នៅមានជាដើមហេតុនៃសេចក្តីអន្តរាយដែលមានមក ដើងមេគោអាចធ្វើជាបង្គោលចងកូនគោក៏បាន ។

៣១ អ្នកណាអាចដោះក្តីវិបត្តិ របស់អ្នកទទួលគ្រោះថ្នាក់ឲ្យរបូតរលូតទៅបាន អ្នកនោះឈ្មោះថា មិត្រ អ្នកដែលបានតែមាត់ពាក្យ ចាំបន្ទោសចាំនិន្ទាចាប់ខុស ក្នុងទំនងហាក់ដូចជានឹងជួយដោះទុក្ខភ័យ អ្នកនោះមិនមែនជាមិត្រទេ ។

នាកាលសេចក្តីវិបត្តិមកដល់ នាំគ្នាភ្ញាំងភ្លេចស្មារតីអស់ នេះជាលក្ខណៈនៃអ្នកខ្លាច ព្រោះហេតុនោះ ឱកាសនេះ ត្រូវសង្កត់ចិត្តទុកឲ្យនឹងហើយត្រិះរិះរកឧបាយតទៅ ព្រោះ —

៣២ ក្នុងយាមទុក្ខ មានចិត្តខ្ជាប់ខ្ជួន, ក្នុងយាមសុខ មានចិត្តស្ងប់ស្រគត់ស្រគំ, ក្នុងវេលាចូលទីប្រជុំ និយាយហាក់ហានច្បាស់លាស់, ក្នុងគ្រាចូលរណរង្គ មានចិត្តក្លាហាន, ក្នុងសម័យមានយស មានបីតិនិយម, ក្នុងការសិក្សា មានសេចក្តីព្យាយាម, ៦ អំពាលនេះ ជាគុណសម្បត្តិ ប្រចាំនៅក្នុងសន្តាននៃមហាបុរស (អ្នកមានចិត្តធំទូលាយ) គ្រប់រូប ។

៣៣ មិនជ្រើមក្នុងសម័យសុខ, មិនស្រប់ស្រុលក្នុងសម័យទុក្ខ, ទឹងដឹងក្នុងវេលាចូលសង្គ្រាម, មាតាអ្នកសម្រាលបុត្រ នឹងរកអ្នកដែលប្រកបដោយគុណតិលកទាំង ៣ នេះបានដោយក្រណាស់ ។

៣៤ ក្នុងលោកនេះ បុរសអ្នកបំណងសេចក្តីចំរើន គប្បីចៀសចាកទោស ៦ ប្រការ គឺមមីរងោកងក់, ងុយមុយមិនរៀវរៅ, ខ្លាចច្រើន, ខឹងច្រើន, ខ្ជិលច្រអូស, បណ្តោះបណ្តាយវេលា ។

ឥឡូវគួរយើងធ្វើដូច្នេះ គឺឲ្យព្រមកាយ ព្រមចិត្តគ្នាទាំងអស់ ហើយនាំយកទាំងលប់ទៅ ព្រោះថា :

៣៥ "សេចក្តីសាមគ្គីរួមកំឡាំងគ្នា សូម្បីតែវត្ថុដែលតូចឆ្មារ ក៏នៅអាចញ៉ាំងការងារដែលនឹងធ្វើឲ្យសម្រេចផលបាន ; សរសៃស្មៅក្រញ្ញវេញជាខ្សែ ហើយអាចចងដំរីសារដែលចុះប្រេងឲ្យជាប់បាន ។ សេចក្តី

សាមគ្គីក្នុងវង់ពួកញាតិរបស់ខ្លួន សូម្បីតិចក្តី ក៏រមែងជាការចំរើនដល់មនុស្ស ៖ គ្រាប់ស្រូវដែលបកសំបកចេញហើយ នឹងដុះឡើងពុំបាន” ។

កាលបានត្រិះរិះដូច្នេះហើយ ព្រាបទាំងអស់នោះក៏ព្រមគ្នាហើរព្រឹបនាំយកលប់ទៅ ឯនាយព្រានឃើញព្រាបហើរហ៊ុងយកទាំងលប់ទៅដូច្នោះអំពីចម្ងាយ ក៏រត់តាមភ្លាងគិតភ្លាងថា -

៣៧ “ ហ្វូងបក្សីនេះព្រមចិត្តគ្នា បង្អាចនាំយកលប់របស់អញទៅបាន តែថាកាលណាធ្លាក់ចុះ ក៏នឹងនៅក្នុងកណ្តាប់ដៃអញកាលនោះ” ។

កាលព្រាបទាំងឡាយនាំលប់ហើរទៅឆ្ងាយផុតកន្ទុយភ្នែកហើយនាយព្រានក៏លែងដេញតទៅ ហ្វូងព្រាបឃើញនាយព្រានដើរត្រឡប់ទៅវិញហើយ ទើបសួរព្រាបមេហ្វូងថា “ ស្វាមិន ! ឥឡូវនេះគួរធ្វើដូចម្តេចតទៅ ? ចិត្រគ្រីវៈតបថា ៖

៣៨ “មាតា បិតា មិត្រ ទាំង ៣ នេះជាអ្នកជ្រោមជ្រែងដោយសភាពឯង, អ្នកដទៃ (ដែលមិនមានមុខការប្រចាំដូច្នេះ) អាស្រ័យហេតុដោយឡែកផ្សេង ក៏អាចទៅជាមិត្តជួយជ្រោមជ្រែងបានដែរ ។

កាលបើដូច្នេះ សំឡាញ់របស់យើងឈ្មោះ ហិរណ្យកៈ ជាស្តេចកណ្តុរ អាស្រ័យនៅក្នុងព្រៃចិត្ររ័ទ នៅឆ្នេរស្ទឹងគណ្ឌកី នឹងជួយកាត់លប់ដែលរួបរឹតយើងឲ្យដាច់ដោយអំណាចធ្មេញដ៏មុត” កាលគិតឃើញ

ដូច្នេះហើយ ទើបព្រមគ្នាហើរទៅជិតព្រង់(១)ដែលជាទីនៅនៃហិរណ្យកៈ, ឯហិរណ្យកៈក៏មិនបានប្រទាខក្នុងហេតុភ័យអន្តរាយ (ដែលនឹងតាមមក) បានសាងព្រង់ មានបង្អួយសម្រាប់ចូលចេញបានទាំងរយផ្លូវ ជាទីអាស្រ័យនៅ ។

៣៩ · ស្តេចកណ្តុរអ្នកស្ទាញស្ទាត់ក្នុងនីតិសាស្ត្រឃើញភ័យដែលនឹងមានមកក្នុងខាងមុខបានអំពីចម្ងាយ អាស្រ័យនៅក្នុងរន្ធដ៏មានបង្អួយចេញទាំងរយផ្លូវ ។

ហិរណ្យកៈ បានឮសំឡេងព្រាបស្រែកសានក្នុងវេលាហើរចុះក៏ភ័យ ពួនសំងំឈឹងក្នុងរន្ធ ។

ចិត្រគ្រីវៈ ស្រែកហៅថា ម្នាលសំឡាញ់ហិរណ្យកៈ ម្តេចអ្នកមិនចេញមកទទួលខ្ញុំ ? ។

ហិរណ្យកៈឮសំឡេងក៏ចាំបាន (ថាចិត្រគ្រីវៈ ដ៏ជាសំឡាញ់) ក៏រត់ចេញមកប្រាស្រ័យថា ខ្ញុំមានបុណ្យ សំឡាញ់ចិត្រគ្រីវៈមករកខ្ញុំ ។

៤០ ក្នុងលោកនេះគ្មានអ្នកណាដែលនឹងមានបុណ្យជាងអ្នកដែលបានសន្ទនាជាមួយនឹងមិត្ត, មានទីអាស្រ័យនៅរួមជាមួយមិត្ត, ហើយនឹងរួមសុខទុក្ខផងគ្នា ។

---

១ ព្រង់ គឺរន្ធ ។

# លោកន័យ

របស់មិកញ៉ាវង្សាសារពេជ្រ ទន

(ត)

បពិត្រមហាពជ ទ្រើសទ្រង់អំណាច អ្នកណាបេះកល គិចដឹងតបះ
ាបលះអំពល់ ត្រង់ក្តីអកុសល កើតសុខពេកក្រៃ ៗ ក្នុងលោកនេះណា
ងបានទ្រព្យ ធនធានប្រពៃ ដល់បរលោកនាយ ពណ៌ាកយពេកក្រៃ
ានសោយសួគ៌ថ្ងៃ ហេតុមានប្រាជ្ញា ៗ ព្រាហ្មណ៍សោតធ្លល់ ពុំ
ប្អាល់មង្គល គប់ះនេះណា ដុតមែកខ្នុរល្មៅ សន្ទៅបូជា អគ្គីនោះណា
ានពាក្យករផង ៗ ហើយយកអាត្មា ឯងមកបូជា អគ្គីជាមួង ឲ្យ
ទ្គាយ ពុំស្តាយរូបផង ស្លាប់ធ្លាក់ទៅរង ទុក្ខនៅអវិចី ។ នេះទឹង
ះបមា ប្រដូចកល់អា- ម្នាក់នោះអប្រិយ កើតដំបៅជើង ចបើង
ភ្នុំ មិនយកថ្នាំពី- ព្រៃមកលាបឡើយ ៗ យកក្របាប់ដែក មក
ាក់ជាស្បែក ជើងទៅព្រៃឆើយ កម្មតជាប់ជើង រហាមពុំស្បើយ
ឥតឯល្ហែល្ហើយ ទល់ទុក្ខនិត្យនៅ ៗ រិលោកនានា យកស្បែកជើង
ាក់ ការពារដំបៅ បំរូងបំរះ ក្រែងលះឡើងទៅ ត្រូវបាទាគ្រូ
រយះរយាយ ៗ នេះមិនបោះឡើយ ខ្ពូនទៀតតតើយ លើសលោក
ទាំងឡាយ យកក្របាប់ដែក ជាស្បែកជើងស៊ាយ ទឹងជាប់ជុះធ្លាយ
ជើងឈាមប្រាលផ្សៅ ៗ ស្តេចស្តាប់ពាក្យពោ- ធិសត្វសង្ហា ត្រាស់
ថាឥឡូវ អញតែងឲ្យសា- ធុការទេគ្រូ ដ្បិតយប់អញនៅ ពុំបានបូជា ៗ
ព្រឹកបាឡើងមក ហើយអញទឹងយក ជនធានទ្រព្យ អញបូជាឲ្យ
តាមដោយចិន្តា បន្ទូលព្រោះណា ចូលក្នុងប្រាសាទ ៗ ឯអស់មន្ត្រី

សេនាបតី នូវកងអាមាត្យ បង្គំក្រាបលា ក្សត្រានរនាថ វិលទៅផ្ទះគេ-
ហាដោយទីទៃ ៗ កិច្ចមិត្តបរក្កោ ប ទិដ្ឋិគោ សូមប ប្រពៃ រីប្រស្នាល្បែង
យើងថ្លែងសេចក្តី អស់អាទិស្រ័យ បែនចប់ម៉្យាងណា ៗ

នេះបទកំណាត់ប្រែជា ក្បួនគ្គលីលា ថ្ងៃរាត្រីក្រៃថ្លៃ ៗ ចូល
ជួបមេសុខសេយ្យន៍ គិតក្នុងព្រះទ័យ រំពឹងឯងថា ៗ ធនញ្ជ័យហានក្រៃ
ចេះចេះ លេងផងសេនា- បតីបុរោហិត ៗ ជាល្បែងពុំក្រែងពុំគិត
ពុំគាត់ខាងចត្ត ក្អឹកប៉ុនកេសី ៗ ហានម៉្យាងនេះពីងអ្វី គន់ឯសំដី
សឹងធម៌ចំពោះ ៗ ចេះថ្លែងសំដែងពីកេះ គិតអម្បាលនោះ ហើយស្តេច
ដំណើរទៅ ៗ លុះស្រានព្រឹកព្រានព្រះចៅ គេងចេញគង់នៅ ក្រឡា-
គំនាល់ ៗ សេនាយោធាផងគាល់ អង្គុយរៀងកាល់ ក្រាស់ក្រៃជុំ
ជិត ៗ អ្នកប្រាជ្ញនូវកងបណ្ឌិត ទាំងបីបុរោហិត សេនាបតី ៗ គាល់
មហាក្សត្រាធិបតី ខាងតែពោធិ- សត្វពុំទៀងទេ ៗ ព្រះបាទ
នរនាថចមចៅ បើកបង្គូលទៅ ថាអ្នកទាំងឡាយ ៗ ធនញ្ជ័យហាន
ក្រៃអំបាយ ម៉្យាងតើអ្នកឃ្លាយ ពេះនេះពីងអ្វី ៗ ឯងបានសេនាបតី ក្រាញ
ក្រាបទូល ប្រណម្យទូលថា ៗ បពិត្រទ្រង់គិតយល់ជា ធនញ្ជ័យនេះ
ដែលថ្លង់ពេកក្រាត់ ៗ អាងមានឧបនិស្ស័យ ជាព្រះមហាក្សត្រ ក្តីរ្វី
ប្រើនវង់ ៗ ប្រើនគេអំណាត់ខាងគាន់ ទូលថាត់បើបុណ្យ ប្រយោជន៍
ក្សត្រា ៗ បុរោហិតព្រាហ្មណ៍ក្រឹមទូលថា អ្នកនេះពុំមា- នន័យ

ធនធាន ។ ហាក់នេះដ្បិតចេះហើយមាន ប្រាជ្ញាដ្បិតបាន ធម៌ស្ងប់ ក្នុងចិត្ត ។ បេះដូងសំដែងធម៌ក្លាត់ ពីពេះចូលចិត្ត នៃនរអ្នកផង ។ សូមមានក្សត្រក្សាន្តបរាស់បង្ស អត់ទ្រាំនបានម្ដង ទេះកុំបូជា ។ ថ្លែង ពីរពាធិសត្វមហា បុរសរតនា កាលអ្នកចុះទៅ ។ អ្នកគិតក្នុងចិត្ត ដោយទូរ ប្រាជ្ញាជ្រាបជ្រៅ ថាអ្នកទាំងបួន ។ រាគុំគំទុំគង់ក្នុង ស្វែងរកទោសខ្លួន អញឯងសព្វថ្ងៃ ។ ពោធិសត្វរំសេសថ្ងៃ គិត ដូច្នោះនៃ ទើបអ្នកឡើងទៅ ។ គាល់មហាក្សត្រាចមចៅ បង្គំទូលទៅ ទើបស្ដេចត្រាស់ថា ។ ដ្បិតអ្វីអំពីព្រឹកបា មិនមកលុះថ្ងៃ- ណោះទើប មកវិញ ។ អញទឹករពុកបាមិញ បាពុំទឹករញ ដល់តិចឡើយណា ។ ពោធិវន្ទីទូលថា បពិត្រព្រះមហា រាជក្សត្រជស្លជ័យ ។ ខ្ញុំទឹករលឹក ម្ចាស់ថ្ងៃ ដ្បិតដេកដល់ថ្ងៃ ត្រង់ទើបរលឹក ។ ទោរទន់អស់មន្ទិលផឹក ពុរមាត់ង្វិតទឹក ទើបទទួលមាន ។ គិតផាល្មាបថានទឹងខាន ថ្ងៃនេះពុំ បាន មកគាល់អម្ចាស់ ។ ហេតុរពុកអម្ចាស់ណាស់ ទើបខ្ញុំអម្ចាស់ មក ថ្កានេះណា ។ ស្ដេចស្ដាប់សាស័ព្ទវាចា ហើយបន្ទូលថា បើដូច្នោះ មិញ ។ ចូរបាចរោធឲ្យអញ ពាក្យអ្វីមួយមិញ ទៀតទឹងស្ដាប់ក៏ ។ ពោធិវន្ទីទូលថា ម្ចាស់ឲ្យនរណា ដណ្ដឹងអញខ្ញុំ ។ ស្ដេចថាកុំបា អារម្មណ៍ អញឲ្យតាស់ទុំ គឺបុរោហិតា ។ ឲ្យចោទចំណោទទឹងបា ទើប អ្នកឆ្លើយថា ហៃព្រាហ្មណ៍ព្រឹទ្ធ ។ ចូរចោទចំណោទនោះខ្ញុំ ឲ្យដាប់

កុំបី យូរលង់ឡើយហោង ។ បុរោហិតព្រាហ្មណ៍ព្រឺរន្ធើយស្ងួន ថា ទៅឲ្យលង់ ដណ្ដឹងត្រង់ណា ។ អ្នកឆ្លើយព្រាហ្មណ៍ម៉ឺយបារោ ដណ្ដឹង ត្រង់ណា អញសឹងចេះឆ្លើយ ។ អ្នកកុំបារម្ភអញឡើយ ព្រាហ្មណ៍ ថាទៅហើយ ទៅនៅក្មេងណាស់ ។ គាចដឹងដំណឹងឲ្យច្បាស់ ឡើយ នឹងអញចាស់ នោះពុំបានឡើយ ។ កុំអួតអំនួតទៅហើយ អ្នកថា ព្រាហ្មណ៍មើយ បំណាច់ចាស់ទុំ ។ តែប៉ុនចំណេះក្រិត្យក្រម តែ ហូបបាយកុំ ឲ្យដល់ច្រើនសោត ។ ព្រាហ្មណ៍ស្ដាប់សាសព្ទហើយ ក្រោធ ថាឈ្មោះខ្ញុំឆោត មិនចេះហូបបាយ ។ ថាហៃធនញ្ជ័យទៅ ក់យ មិនស្គាល់ហូបបាយ ឈ្មោះគួរទៅស្ដាប់ ។ អញថ្លែងសំដែង ប្រាយប្រាប់ តាមដោយក្បួនច្បាប់ ជាបទគាថា ។ បុព្វេ កុញ្ចេ អា- យុតិលោកថា បើប្រាថ្នាចង់ ។ បានអាយុបាឲ្យអង់- គុយហូបបាយ ជួង មុខទៅទិសបូព៌ា ៖ លោកថាមានអាយុយូរ យឺនវែងបរិបូណ៌ ដល់ចាស់ឯងឯង ។ ធនត្តិ ទក្ខិណេ- ន ច បវៃទ្ធ ថាបើប្រាថ្នា ។ ចង់បានធនធានទ្រព្យា ហូបបាយកាលណា ឲ្យបែរមុខថ្កាន ។ ទិសទក្សិណអ្នកនោះបាន មាសប្រាក់ធនធាន ផងអស់ទឹងគេ ។ យសត្ថិ បច្ឆិមេ- ន ច បវៃទ្ធ ថាបើប្រាថ្នា ។ យសស័ក្តិបែកក្ដកោក្កា ទៅបច្ឆិមា មានយសស្ដួស្ដី ។ ឥធ កុទ្ហេយ្យាតិ- បេក្ខោស្រដី លក្ខណា ហូបបាយ ។ អ្នកថាហៃមហាព្រាហ្មណ៍ហ្នុយ ដៀតអ៊ីពុំ

ក្រោយ ត្រង់ទិសឧត្តរ ។ ទិសពីស្រដីគ្រប់គួ នៅទិសឧត្តរ តើ
ទោសដូចម្ដេច ។ ព្រាហ្មណ៍ឆ្លើយទៅហើយមានកិច្ច កលហេតុបានតិច
ស្ដាប់អញចុះហា ។ មានយក្សសំណាក់នៅនា ទិសទីបូព៌ា ឈ្មោះទីឃា
យក្ស ។ ហេតុនោះហូបផ្ដោះប្រែក្រ្ត ទៅទិសបូព៌ាអ្នក នោះមានជន្មា ។
មានយក្សនៅទក្ខិណា ឈ្មោះកាឡយក្សា ហូបបាយផ្ដោះឆ្កាន ។
ទិសនោះចំពោះនូវបាន មាសប្រាក់ធនធាន ដូចចិត្តប្រាថ្នា ។ មាន
យក្សសំណាក់នៅនា ទិសបច្ឆិមា ឈ្មោះវិរយក្ស ។ ហេតុនោះហូប
ផ្ដោះប្រែក្រ្ត ទិសនោះមានស័ក្តិ បុណ្យដូចចិន្តា ។ យក្សនិត្យនៅ
ឧត្តរា នោះសោតនាមា ឈ្មោះវិរុឡបក្ខ ។ លោកថាអ្នកណាប្រែក្រ្ត
ហូបបាយផ្ដោះយក្ស នោះឯងឥតការ ។ ទិសនោះសូន្យសោះអសារ
ហេតុនោះអាចារ្យ លោកពុំសំដែង ។ អ្នកស្ដាប់សាសព្ទព្រាហ្មណ៍ថ្លែង
អ្នកទះដៃឯង ហើយសើចក្អាកក្អាយ ។ អ្នកថាហៃអាចារ្យក៏យ នាអ្នក
ហូបបាយ ប្រែទៅបូព៌ា ។ ខ្មួតវិឯទីឃោមហា. យក្សនោះហើយក៏
ធ្វើអ្វីឲ្យអ្នក ។ នោះមានជន្មបានវែងក្អាត់ ព្រាហ្មណ៍ឆ្លើយថាៈយក្ស
នោះឲ្យពរក៏ ។ អ្នកឆ្លើយបំឡើយទៅថា បើអ្នកឯណា ហូបបាយ
ប្រែខ្លួន ។ ឲ្យតើយក្សធ្វើម្ដេចដង ទើបព្រាហ្មណ៍ឆ្លើយស្នួង ថាយក្ស
នោះណា ។ ខេវឹងកំហឹងផ្ដាសា មិនឲ្យជន្មា នៃអ្នកនោះឡើយ ។

អ្នកស្តាប់ព្រាហ្មណ៍ប្រាប់ដូច្នោះហើយ អ្នកនឹងគ្នាសរឆ្លើយ ផ្ទាញ់ផ្ទាល
ទៅថា ៗ ហៃព្រាហ្មណ៍បើតាមកថា ពាក្យអ្នកហើយណា កុំហូប
បាយឡើយ ៗ ទើបគាប់ទឹងច្បាប់ជាត្រើយ ទិស ៤ នោះហើយ
សឹងលំនៅយក្ខ ៗ ទិសប្រែទៅឯកើតជាក់ យក្ខឯលិចអាក់ ចិត្តបាប
កំហឹង ៗ ទិសប្រែទៅឯលិចវិញ យក្ខឯកើតខឹង ជាផ្សិតប្រែខ្លួន ៗ
ទិសប្រែទៅឯត្បូងហោង ឯជើងទិសផង ជាផ្សិតប្រែក្រោយ ៗ ទិសប្រែ
ទៅឯជើងដោយ ឯត្បូងថាឲ្យ ខ្លួនទិសផងគួរ ៗ ផ្គាប់ក្រកម្រែតឡូវ
គិតគាប់គួរសួរ អត់កុំហូបបាយ ៗ ព្រាហ្មណ៍ស្តាប់សាសព្ទអភិប្រាយ
ពាល់ដូចទឹងថ្លាយ ទ្រង់ឥតបើឆ្លើយ ៗ អ្នកថាហៃមាតាព្រះរុំយ ស្ងៀម
ប៉ុមិនឆ្លើយ មកឲ្យឆាប់ពា ៗ

# សាលាបឋមសិក្សាក្នុងប្រទេសយីពុន

ព្រះមហាពិទូរ ក្រសេម

ក្នុងប្រទេសយីពុន កាលដល់រដូវស្ព្រីង ទើបឃើញដើមឆើរី ស្គួយផ្ការីកស្គុះស្គាយទូទៅគ្រប់អន្លើ សេចក្ដីល្អរបស់ផ្កាឆើរីក្នុងរដូវនេះ ជាទីរីករាយចិត្តរបស់អ្នកដែលបានទៅឃើញយ៉ាងណា នោះមិនអាចនឹងរៀបរាប់ឲ្យសព្វគ្រប់បាន ៗ ក្នុងខែពិសាខ (មេ) ដែលជាខែដំបូងរបស់រដូវស្ព្រីងនោះ នូវមានទស្សនីយភាពដែលគួរទស្សនាការជាងផ្កាឆើរី ផ្កាសួគ៌របស់ប្រទេសយីពុន ១ យ៉ាងទៀត គឺតាមសាលារៀនផ្សេងៗ ដែលជាសាលារៀនជាន់បឋម ក៏បានបើករៀនព្រមគ្នាទាំងអស់ ក្នុងខែនេះ ហេតុនោះ វេលាព្រឹក កាលព្រះអាទិត្យឧទ័យរឿងរះឡើងបែងចាំងទៅព្វជនភាកាស ផ្កាឆើរីសឹងមានពណ៌ស្រស់ល្អ ក៏រីកស្គុះស្គាយទទួលរស្មីព្រះអាទិត្យ ក្នុងយាមអរុណសម័យ បន្ទើរក្លិនពីដោះឲ្យខ្ជរខ្ជាយសាយភាយទៅតាមខ្យល់ សឹងបក់ទៅតាមភូមិទីផ្ទល់តូចផ្ទល់ធំគ្រប់អន្លើ វេលានោះ គេនឹងឃើញកុមារ-កុមារីយីពុនទាំងឡាយ នាំគ្នាដើរត្រសងទៅកាន់សាលារៀនជាពួកៗ ដោយទឹកចិត្តដ៏ជ្រះថ្លារីករាយ ដើម្បីចាប់សិក្សាជាដំបូងក្នុងខែនោះ តាមសាលាបឋមផ្សេងៗ ដ៏ច្រើនដេរដាសក្នុងប្រទេសនេះ ៗ ផ្សំគ្នាដោយអាកាសព្រឹកព្រហាម ភូមិប្រទេសទាំងផ្កាឈើដ៏ក្រអូបផ្អែម រួមទាំងកូនក្មេងតូចៗ ដ៏មានមុខមាត់ស្រស់បស់

របស់គេនោះហើយ រមែងជាវិស័យចិត្តនៃអ្នកដែលបានឈានទៅកាន់ឧទ័យប្រទេសនេះឡើងកើតមិតរីកកយយ៉ាងអស្ចារ្យក្រៃពន់ ។

ក្មេងយើពុនគ្រប់ៗរូប កាលអាយុគ្រប់ ៦ ឆ្នាំហើយក៏ជាមុខងាររបស់អ្នកគ្រប់គ្រងត្រូវបញ្ជូនឲ្យចូលសាលារៀនភ្លាម លើកលែងតែមានហេតុសំខាន់ដូចយ៉ាងកាយពិការ ឬវិកលចរិតខុសប្រក្រតីជាដើម ។

តាមស្ថិតិការសិក្សាសាលាបឋមក្នុងប្រទេសយើពុន ក្មេងដែលមិនអាចចូលរៀនមានត្រឹម ៤២% របស់ចំនួនទាំងអស់ប៉ុណ្ណោះ ឯក្មេងដែលបានចូលរៀន មានចំនួនដល់ទៅ ៩៩.៥៨% នេះសំដែងឲ្យឃើញថាការសិក្សាថ្នាក់បឋមរបស់ប្រទេសយើពុន មានបរិមាណយ៉ាងខ្ពស់ដល់ម្ល៉េះ ។ ការសំខាន់ដែលគួរពោល ១ យ៉ាងទៀត គឺក្នុងការសិក្សាដ៏ជាដំណើរកាំជំបូងរបស់កុមារយើពុន គ្មានកំណត់ខណ្ឌប្រកាន់គេប្រកាន់យើងក្នុងរឿងសេចក្ដីមាន – សេចក្ដីក្រ ស្រុកក្រៅឬក្នុងក្រុងឡើយ គេកាន់ថាជាមុខងារសំខាន់បំផុតរបស់អ្នកគ្រប់គ្រងកុមារ គល់ៗរូបត្រូវតែធ្វើក៏គឺបញ្ជូនក្មេងដែលនៅក្នុងសេចក្ដីគ្រប់គ្រងរបស់ខ្លួនទៅចូលសាលារៀនតាមព្រះរាជបញ្ញត្តិ ដោយព្រមព្រៀងគ្នា ។

ប្រទេសយើពុន បានចាប់ផ្ដើមកេណ្ឌក្មេងឲ្យចូលរៀនតាមព្រះរាជបញ្ញត្តិបឋមសិក្សា ក្នុងឆ្នាំទី ១២ នៃរជ្ជកាលព្រះបាទ "មេជី" គឺក្នុង គ.ស. ១៨៧៩ ក្នុងជាន់ដំបូងកំណត់វេលាដែលត្រូវសិក្សាត្រឹម ៤ ឆ្នាំ

ប៉ុណ្ណោះ តមកពង្រីកវេលាចេញទៅទៀតជា ៦ ឆ្នាំ មកក្នុងបច្ចុប្បន្ននេះ ដើម្បីនឹងឲ្យការសិក្សា នឹងការបណ្តុះនិស្ស័យសីលធម៌ក្មេង ឲ្យបានផលបរិបូណ៌ថែមទៀត ទើបកំណត់វេលាត្រូវសិក្សាដល់ទៅ ៨ ឆ្នាំ គឺផ្ដើមតាំងពីអាយុ ៦ – ១៤ ឆ្នាំ ។

ចំនួនសាលារៀនក្នុងប្រទេសយ៉េពុន រួមតាំងពោសេន Chasen នឹងហ្វ៊ែរមោសា Formasa ផង ប្រមាណ ២៥,៧០០ សាលា ក្នុងចំនួននេះមានត្រឹម ៤ សាលាប៉ុណ្ណោះជារបស់ដែលរដ្ឋបាលកាត់ការពេញទី ក្រៅអំពីនេះ ១០០ សាលាជារបស់ព្រស្ត តែចំនួនសាលាដែលច្រើនបំផុតនោះ ជាសាលារៀនរបស់ទេសបាលមាននៅក្នុងនិគមជនបទផ្សេង ៗ មាតាបិតារបស់កុមារយ៉េពុនគ្រប់ ៗ រូប តែងគាន់ថា ជាមុខងាររបស់ខ្លួនដោយពិត ដែលនឹងឲ្យការសិក្សាដល់កូនចៅរបស់ខ្លួន ឲ្យល្អជាបំផុត ចំណែកឯក្នុងខេត្ត ខណ្ឌ ស្រុក និគម ឃុំតាំងអស់ សុទ្ធសឹងតែរួមកាយរួមចិត្តគ្នាជាយ៉ាងស្រួល ក្នុងការដែលនឹងរៀបចំឲ្យការសិក្សាតាមគម្រោងទីលំនៅរបស់ខ្លួនឈោងឈានទៅកាន់សេចក្តីចំរើនជាយ៉ាងក្រៃពេកទៀងដូច្នេះ ការសិក្សាក្នុងជាន់បឋមរបស់ប្រទេសយ៉េពុន ទើបបានទទួលសេចក្តីយកចិត្តទុកដាក់ទាំងខាងរាជការ ទាំងខាងគ្រួសាររបស់ក្មេងជាយ៉ាងល្អ ។

ការដែលយីពុនមានចំនួនមនុស្សកើតច្រើនឡើង ៗ ដោយលំដាប់នោះ ធ្វើឱ្យយីពុនត្រូវមានសាលាបឋមសិក្សាបន្ថែមឡើងទៀតឲ្យគ្រប់គ្រាន់រៀនសូត្រ មិនត្រឹមតែបានសាលារៀនឲ្យច្រើនប៉ុណ្ណោះ ក្នុងសាលានីមួយ ៗ សុទ្ធសឹងតែចំប្រឹងប្រណាំងគ្នាក្នុងការល្អការចំរើន ឲ្យបានប្រយោជន៍ដល់ក្មេងមែន ៗ រហូតដល់ទៅចាត់ចែងរកគ្រឿងឧប-ករណ៍ក្នុងការសិក្សា ដូចយ៉ាងគម្រោងរៀនជាដើមដែលល្អទាន់សម័យសម្រាប់សាលារៀនទៀតផង ។ ពួកតាងប្រទេសដែលមានឱកាសផ្លាត់ទៅដល់ប្រទេសនោះ នឹងមានសេចក្ដីស្ងើចអស្ចារ្យ ដែលបានឃើញសាលារៀនយីពុនត្រឹមថ្នាក់បឋមទេ ក៏អធិកអាធំហើយមានគ្រឿងឧប-ករណ៍សម្រាប់សាលារៀនយ៉ាងគ្រប់គ្រាន់ សូម្បីតែសាលារៀនដែលនៅក្នុងស្រុកតូច ៗ ក៏ដោយ ចំណែកឯសាលារៀនដែលនៅក្នុងស្រុកធំ ៗ ដូចយ៉ាង តូក្យូ និងឱសាកា ក៏រឹតតែរុងរឿងយ៉ាងក្រៃពេកតែម្ដង ។

តាមប្រក្រតី សាលាបឋមដែលជាសាធារណៈទូទៅនោះ មិនបានយកថ្លៃឈ្នួលសាលាពីអ្នករៀនឡើយ ចំណែកឯសាលាបឋមឯទៀត ៗ ប្រសិនជាមានយកថ្លៃឈ្នួលខ្លះ ក៏យកយ៉ាងថោកបំផុត ទាំងនេះមិនមែនដទៃឆ្ងាយឡើយ គឺយីពុនមានសេចក្ដីបំណងនឹងបើកឱកាស ឲ្យក្មេងកល់ ៗ រូប បានចូលរៀនទូទៅគ្រប់គ្នាទាំងអស់ ដើម្បីជាបង្ការពារប្រទេសទៅថ្ងៃមុខនុ៎ះឯង ។

ឯសាលាបឋម ៤ ដែលរដ្ឋបាលចាត់ការខ្លួនឯងនោះ ក៏ដើម្បីជាស្ពានស័ក្យរបស់ក្មេងប្រុសស្រីដែលត្រូវទៅរៀនបន្ថែមចំណេះវិជ្ជា នៅសាលាបង្ហាត់ជាគ្រូជាន់ខ្ពស់ ក្នុងក្រុងតូកៀវ ហិរោដីម៉ា ទីងណាក សាលារៀនដូច្នេះ ក្រៅអំពីសាលារៀនទាំង ៤ ដែលពោលហើយ ក៏នៅមានទៀតជាច្រើន តែច្រើនតែជាសាលារបស់ទេសបាល ប្រាក់ចាយសម្រាប់ជាប្រាក់ខែគ្រូបង្រៀននោះរដ្ឋបាលចេញឲ្យ តែប្រាក់សម្រាប់ចាយរាយយ៉ាងដទៃជារបស់ទេសបាលឯង ៗ ឯសាលារៀនរបស់ក្រស្តមានឯកជនអ្នកចាត់ការ ឬជួនកាលបានទទួលសេចក្តីទំនុកបម្រុងអំពីរដ្ឋបាលក៏មាន សាលារៀនរបស់ក្រស្តដែលពោលមនេះមានទាំងអស់ប្រមាណ ១០០ សាលា សុទ្ធតែជាសាលាមានកេរ្តិ៍ឈ្មោះល្អច្រើន មិនថាសាលាបឋមណា ទោះជាសាលារបស់រដ្ឋបាល របស់ក្រស្តឬរបស់ទេសបាលក៏ដោយ រមែងនៅក្រោមរបៀបច្បាប់បង្គាប់ជាមួយគ្នាទាំងអស់ ដោយហេតុនេះ បណ្តាសាលាបឋមផ្សេងៗក្នុងយីពុន ទើបមានលក្ខណៈនឹងរូបការប្រហែល ៗ គ្នាដោយច្រើន របៀបច្បាប់បង្គាប់ផ្សេងៗ ដំតាក់ទាមដោយសាលារៀនបឋមនោះ គ្រប់ ៗ សាលាកាន់យកទឹងប្រតិបត្តិតាមដោយម៉ឹងម៉ាត់ មិនតែប៉ុណ្ណោះ សូម្បីក្នុងរបៀបបែបផែនយ៉ាងដទៃ ដែលល្អប្រពៃហើយ ពួកយីពុនរមែងនិងខ្ទួលបះគារពនឹងប្រតិបត្តិដោយរីករាយតែម្តង គុណលក្ខណៈដែលល្អមួយយ៉ាងសិង

ជួយស្ទួយឱ្យការសិក្សារបស់ក្មេងយីពុនលេចអណ្តែតឡើង ជាទីនិយមដ៏ក្រៃពេក ក៏គឺការដែលប្រជាជាតិយីពុនបានទទួលការហ្វឹកហ្វឺនប្រសើរមកជាយ៉ាងល្អ ក្នុងរឿងរបៀបវិន័យយ៉ាងដាច់ខាត និងតឹងម៉ឹងម៉ាត់មកអំពីសាលាបឋមផ្សេង ៗ អំបាលនេះគេទុកជាសំខាន់បំផុត ។

កាលរូបមានអំណាចនឹងទៅទស្សនាការសាលារៀនអំបាលនេះបានដោយសុំអនុញ្ញាតអំពីគ្រូធំរបស់សាលារៀនសិន ហើយលោកនឹងបានទទួលការបដិសណ្ឋារយ៉ាងម៉ាំមួន ដោយសុភាពនិងទន់ភ្លន់ជាបំផុត សេចក្តីសំខាន់របស់សាលារៀនបឋមអំបាលនេះ គេកាន់ថាជាសេចក្តីសំខាន់របស់ជាតិយីពុនទៅថ្ងៃមុខផង ព្រោះកុមារដែលបានបណ្តុះបណ្តាលដោយការសិក្សាជាខាងដើមដូច្នោះហើយ នឹងបានជាកំលាំងរបស់ជាតិក្នុងអនាគត ហេតុនេះ គេទើបទំនុកបម្រុងការបឋមសិក្សារបស់ក្មេង ឱ្យចំរើនឡើងជាដរាប មានការប្រួមគ្នា និងមេផ្ទះរបស់ក្មេងផង ដើម្បីជួយជ្រោមជ្រែងសាងសេចក្តីល្អ សេចក្តីចំរើនឱ្យក្មេងគ្រប់ ៗ ដូរជាយ៉ាងល្អ ៗ នៅសាលាអំបាលនេះ មានការបង្ហាត់កាយបរិហាររាល់ ៗ ថ្ងៃ មានការលេងកីឡាផ្សេង ៗ ជាប្រយោជន៍ក្នុងការទំនុកបម្រុងកាយនិងចិត្តផ្ទឹម ចំណែកឯសុខភាពរបស់ក្មេង ក៏បានទទួលសេចក្តីសង្គ្រោះក្នុងរឿងដែលទាក់ទាមដោយក្អក ធ្មេញ និងរោគឈឺថ្កាត់ផ្សេង ៗ អំពីពេទ្យរបស់សាលាជាយ៉ាងល្អ ។ សាលានេះមានទាំងគ្រឿងលេងសប្បាយ ក្នុង

វេលាក្រោយដែលចេញរៀនហើយ ដូចយ៉ាងអរកេស្រួសម្រាប់សាលា មានការច្រៀងក្លងលេងតន្ត្រីផ្សេង ៗ មើលទៅជាការគ្រឹកគ្រេង នឹងដាស់ចិត្តលោមចិត្តក្មេងឲ្យកើតបីតិ នឹងស្រឡាញ់សាលារៀនបាន ល្អណាស់ យើងអាចឃើញបានថា ការបឋមសិក្សារបស់គេចំរើន ជាយ៉ាងឆ្ងាយតែម្តង ៗ ពួកក្មេងមិនត្រឹមតែបានទទួលការបង្វឹកបង្ហាត់ ក្នុងចំណែកចំណេះវិជ្ជា សេចក្តីស្ទាញស្ទាត់ក្នុងការធ្វើដៃផ្សេង ៗ នឹង មានឧបនិស្ស័យដ៏មុខគួរនិយមប៉ុណ្ណោះ នៅមានការបង្វឹកក្មេងឲ្យមាន ជីវិតចិត្តថ្មីដ៏ជ្រះថ្លា សមជាពួកឧទ័យប្រទេសដ៏ពិតប្រាកដទៀតផង ៗ

បណ្តាក្បួនខ្នាតនិងបែបរៀនផ្សេង ៗ របស់សាលាបឋមសិក្សា អំបាលនេះ ក្រុមសិក្សាធិការរបស់ប្រទេសយីពុន ជាអ្នកចាត់ការធ្វើនឹង បោះពុម្ពចំណាយខ្លួនឯងទាំងអស់ រហូតដល់ទៅរឿងដទៃ ៗ ដែលទាក់ ទាមដោយការសិក្សា ការបណ្តុះបណ្តាលក្មេង ការចិញ្ចឹមជីវិត ការ អនាម័យ ការរៀបទរៀនផ្សេង ៗ នឹងការប្រណិប័តន៍ទាំងពួងផង ឯថ្នាក់ នឹងវិជ្ជារបៀបប្រព្រឹត្តទៅតាមគោលក្បួនរបស់សាលាបឋមសិក្សា ដែល រដ្ឋបាលកំណត់ទុកឲ្យ របស់សំខាន់ផ្សេង ៗ បានកំណត់ទុកក្នុងគោល យ៉ាងទូលាយ សមនឹងសេចក្តីត្រូវការរបស់ប្រទេស នឹងដើម្បីស្រួល ដល់ការកែប្រែផ្លាស់ផ្តូរឲ្យសមដល់កាលសម័យ ក្នុងកាលតទៅ ៗ

វិជ្ជាផ្សេង ៗ ក្នុងជាន់បឋមរបស់គេមានដូច្នេះ សីលធម៌និងបរិយា ភាសាជប៉ុន គណិតសាស្ត្រ ប្រវត្តិសាស្ត្រ ភូមិសាស្ត្រ វិទ្យាសាស្ត្រ ការងារដៃ គំនូរ តន្ត្រី និងកាយបរិហារ ក្រៅអំពីនេះ សាលារៀននៅមានចាត់ការផ្នែកថ្វីដៃហត្ថកម្មផ្សេង ៗ សម្រាប់ក្មេងប្រុស និងការដេរប៉ាក់សម្រាប់ក្មេងស្រី វិជ្ជាផ្សេងៗដែលគេដាក់ឲ្យក្មេងរៀនមានទាំងសាមញ្ញ-វិជ្ជា ទាំងវិជ្ជាពិសេសដោយឡែក ដែលទាក់ទាញដោយរស់រវើក Activity របស់ក្មេង ថែមឡើងទៀតដើម្បីជាការជួយឲ្យក្មេងបានប្រើសេចក្ដីហើសហួសរបស់វា ឲ្យជាប្រយោជន៍ក្នុងការសិក្សា ឲ្យមានសេចក្ដីសប្បាយរីករាយជ្រះថ្លាឲ្យច្រើនជាបំផុត ដូចយ៉ាងមានការនាំទៅប្រជុំសន្ទនាគ្នាកណ្ដាលវាល មានការទៅដើរលេងទំនងដើរលេងព្រៃ Picnic និងមើលស្ថានសំខាន់ផ្សេង ៗ ដែលនៅជិត ៗ ដែនជាងនោះទៅទៀត ជួនកាលសាលាខ្លះមានចាត់ឲ្យមានគ្រឿងឧបករណ៍ការសិក្សា ដែលជាន់សម័យផ្សេង ៗ ដូចយ៉ាងវិទ្យុ កុន ។ល។ ដែលជាប្រយោជន៍ទុកឲ្យកំសាន្តផង ក្នុងមួយថ្ងៃៗ ក្មេងក៏បានសេចក្ដីរីករាយទូទៅគ្រប់គ្នា សម្រាប់របៀបក្រិត្យវិន័យផ្សេង ៗ របស់សាលានោះ គេកាន់ហ៊ឹងម៉ឹងម៉ាត់មែនទែន តែមិនមែនតឹងរ៉ឹងដល់ទៅប្រើអំណាចពេកផង ហេតុនេះ ទើបមិនគួរឆ្ងល់ឡើយ ថាម្ដេច កុមារជប៉ុន ទើបសប្បាយរីករាយនិងស្រឡាញ់សាលារៀនណាស់ម៉្លេះ ។

និយាយអំពីគ្រូបង្រៀនវិញ គ្រូរបស់គេរមែងមានអំណាចស័ក្តិក្នុងការប្រដៅនិងការគ្រប់គ្រងក្មេងបានល្អប្រពៃ ពួកគ្រូទាំងប្រុសទាំងស្រីដែលសម្រេចកិច្ចអំពីសាលាបង្រៀនជាគ្រូមកហើយ រាល់ៗរូប មានសមត្ថភាពក្នុងការប្រដៅនិងការបណ្ដុះបណ្ដាលក្មេងបានយ៉ាងល្អ ចំនួនគ្រូ គ្រូស្រីមានតិចជាងគ្រូប្រុសឆ្ងាយ ធៀបចំនួនក្នុងគ្រូប្រុស ៩ នាក់ គ្រូស្រីមានត្រឹម ១ នាក់ ទោះបីដូចម្ដេចក៏ គ្រូអំបាលនោះទាំងប្រុសទាំងស្រីសុទ្ធសឹងតែមានកិរិយាសុភាពរាបសា មានមេត្តាករុណា និងមានសេចក្ដីតាំងចិត្តប្រឹងប្រែងមែនទែនយ៉ាងខ្លាំងក្លា ក្នុងការដែលនឹងបណ្ដុះប្រជាមជួយក្មេងឲ្យរោកស្ដដ៏ល្អ គ្រូទាំងនោះមើលទៅដូចជាមិនចេះនឿយណាយ ឬធុញទ្រាន់ក្នុងមុខការរបស់ខ្លួនសោះ មានដួងចិត្តដ៏ពេញព្រៀបទៅដោយសេចក្ដីប្រាថ្នាល្អក្នុងការងារដែលខ្លួនបានទទួលបន្ទុកមកហើយ ។ អ្នកដែលបានឱកាសទៅឯស្រុកឱសាកា (Osaka) នឹងឃើញអនុស្សាវរីយ៍ ទីរលឹកដល់គ្រូបង្រៀនម្នាក់ជាគ្រូបង្រៀនបឋម ១ កន្លែងនៅក្នុងស្រុកនោះ ដែលផ្ដូរជីវិតរបស់ខ្លួន ដើម្បីការពារជីវិតក្មេងអ្នករៀនរបស់គេឲ្យរួចអំពីគ្រោះអន្តរាយ ក្នុងកាលដែលកើតព្យុះធំក្នុងកាល ២-៣ ឆ្នាំ មកនេះ នេះជាគំរូយ៉ាងដ៏ល្អ ដែលសំដែងដល់ចរិយវត្តគ្រូ ដែលគេនិយមទៅក្រោក គ្រូដូច្នេះរមែងជាកំឡាំងនាំប្រទេសឲ្យចំរើន ។

របស់សំខាន់ ១ យ៉ាងទៀត ដែលហាក់ដូចជាជីវិតរបស់ការសិក្សាជាតិ នឹងរបស់សាលាបឋមទាំងឡាយក្នុងប្រទេសយើង គឺព្រះបរមឆាយាលក្ខណៈរបស់ព្រះរាជាធិរាជនៃឧទ័យប្រទេស នឹងព្រះរាជផ្ទុកទុកក្នុងផ្សសិក្សា ទាំងពីរយ៉ាងនេះមាននៅគ្រប់សាលារៀនក្នុងប្រទេសយើង គេកាន់ថាជារបស់គួរសក្ការៈនិងគោរពយ៉ាងខ្ពស់ រាល់ ៗ ឆ្នាំ កាលដល់ថ្ងៃដែលកំណត់ពិធី នៅបន្ទប់ប្រជុំធំរបស់សាលា នឹងមានការប្រដាប់ប្រដាតាក់តែងដោយទង់ជាតិយ៉ាងត្រកាលក្រែក ក្នុងខណៈនោះ សំពត់យ៉ាងល្អដែលគ្របព្រះបរមឆាយាលក្ខណ៍ ក៏សន្សឹម ៗ បើកបញ្ចេញ ខណៈជាមួយគ្នានេះ គ្រូធំក៏អញ្ជើញក្រសែព្រះរាជដំបរសាស់ជាស់តៀនដ៏ទាក់ទាមដោយការសិក្សា បញ្ចេញមកសូត្រពណ៌នាលទ្ធប្រជុំគ្រូនិងអ្នករៀនប្រមាណពាន់នាក់ក្នុងទីនោះ ចប់ហើយក៏ចាប់ច្រៀងភ្លេងជាតិយើងឡើងយ៉ាងព្រមព្រៀង ទាំងទំនងទាំងទំនុកភ្លេងជាតិនោះក៏នាំឲ្យជក់ចិត្ត ដាស់ចិត្តនិងគ្រើនចិត្តឲ្យពួកឧទ័យប្រទេសជាប់ខ្លួននៅក្នុងជាតិ - សាសនា ព្រះមហាក្សត្រ និងរដ្ឋធម្មនុញ្ញ ជាបណ្ដូលចិត្តជីវិតរបស់គេតែម្ដង ។ អំបាលនេះឯង ដែលជាគូជីវិតរបស់សាលាបឋមយើង ជនជាតិយើង និងប្រទេសយើងដ៏ជានុទ្យានរបស់អក្សរគតិធីរ ដែលត្រូវផ្ដើមបញ្ចេញតន្ត្រីដោយត្រូវប្រាសខ្យល់ទៅសព្វពេលវេលា ។

(ហាកវិជ្ជាបារូ)

ក្បួនដំរះឧត្សាហ៍

របស់បូរាណ

(ត)

ទោះខ្លែងទូរកុកសម្លាយ នាំគ្នាវើទក់យ ចុះជាកណ្តាលភូមិស្រុក ៗ
គឺថ្ងៃនោះនៃកើតទុក្ខ រត់ចេញចោលស្រុក ពុំសុខភ្លើងឆេះផងណា ៗ
ទោះខ្លែងទូរក្អែកជាន់គ្នា ពុំត្រូវកាសា ពុំជាថ្ងៃភរខែពីរ ៗ ទូរបង់
អស់ស្រុកគល់កេរ្តិ៍ ពុំនោះចង់ចោរ មានភ្លើងទូរឆេះផ្ទះសុះ ៗ ទោះ
ខ្លែងធាបស្មៅធ្លាក់ចុះ ក្នុងអាងទឹកនោះ ចំពោះខុនណាងប្រស្បា ៗ ប្រាំ
ខែកើតទោសផងគ្នា ឲ្យរៀបបូជា ដូចគ្នាអស់ខ្លែងស្រឡះ ៗ ទោះ
ខ្លែងមកទំលើផ្ទះ មានចោរមានៈ ទីងលួចទីងប្លន់ពុំលែង ៗ តែជប់បួន
ថ្ងៃជាក់ស្តែង ភ្លើងឆេះពុំលែង ឲ្យរៀបបូជាដូចគ្នា ៗ ទោះខ្លែងស្វះ
ស្វែងហើយណា ធាបធក់ម្ជ្ញា កូនមាន់ទៅជាអាហារ ៗ បរិភោគទីង
ប្បារត្រអាល ទីងកើតកំស្តារ អ្នកផងឲ្យទ្រព្យស្រឡះ ៗ ទោះខ្លែង
គូកបូលក្រោមផ្ទះ ឥតជ័យជំនះ ទីងកើតកង្វល់ផងគ្នា ៗ ទូរកើតជម្ងឺ
ពេគា ពុំនោះសោកណា ទីងមរណាដល់ខ្លួន ៗ ឲ្យរៀបធ្វើបុណ្យ
បញ្ចូន ឲ្យមាំឲ្យមួន បូជាតាមក្បួននេះណា ៗ ខ្លែងស្រាកទំផ្ទះពុំជា
ទីងកើតទោសា អាត្មាទីងក្សយពុំលែង ៗ ទូរបាត់ទ្រព្យធនជាក់ស្តែង
ឲ្យអ្នកនោះឯង គិតក្រែងប្រយ័ត្នបូជា ៗ ទោះក្អែកយំបេបជុំគ្នា ស្រុក
ទេសនោះណា ឲ្យជាកង្វល់មានហ្វូង ៗ ទោះក្អែកយំថ្ងៃអើងកង ចឹក
គ្នារំពង នោះហោងនិមិត្តមានសឹក ៗ ទោះក្អែកកាចក្រែកពន្ទឹក ផុះ
ស្រោចទទឹក ពន្ទឹកត្រូវអង្គអាត្មា ៗ ដូច្នេះចង្រៃមហិមា បើពុំបូជ

ត្រាត់ត្រាសទិសឯងហោង ។ នោះក្នុងក្រុលក្នុងផ្ទះផង គេត្រូវរៀសៅ-ហ្មង បានបង់ខ្ទប់មួនទឹងស្លាប់ ។ ពីថ្ងៃនោះនៃប្រញាប់ បើពុំចេញទាប់ រក្តាប់ប្ដាស់សូត្រមន្ត ។ នោះនឹងមានទុក្ខទោសធ្ងន់ ឲ្យកេតម្បូន លំនៅឯទៀតទើបជា នោះក្នុកទូមាន់ជាន់គ្នា ឆ្នាំបិទវា នឹងខូបខឹង ខាតបង់ស្រុក ។ នឹងកើតកន្លក់កលិយុគ ហើយនឹងកើតទុក្ខ ពុំសុខ សប្បាយបរិបូណ៌ ។ នោះក្នុកនាំក្នុកមួយចូល ក្នុងស្រុកពុំយូរ នឹង ច្រាសលំនៅទីស្ថាន ឲ្យម្ចាប់សូត្រកំសាន្ត សូត្រមន្តឲ្យបាន ធ្វើបុណ្យ រម្ងាប់ទើបជា ។ នោះក្នុកខ្ទូវត្រលែងរកណា ត្រេកសោមនស្សា ស្នា គ្នាក្នុងភូមិក្នុងស្រុក ។ ពីថ្ងៃនោះនៃកើតទុក្ខ ហើយនឹងបង់ស្រុក ពុំសុខ ក្មេងនេះត្រឹះហោ ។ នោះក្នុកខ្ទូវកុកផងគ្នា នឹងមានអ្នកឯណា ច្រាថ្នា អំពីចម្ងាយ ។ ទិសបូព៌ាពុំយូរមិនឆាយ យកស្រុកអន្តរាយ ឲ្យរៀប បូជាស្រឡះ ។ នោះកុកខ្ទូវតួមទំផ្ទះ ចឹកគ្នាតតះ ម្ចាស់ផ្ទះឲ្យរៀបបូជា ។ ធ្វើបុណ្យឲ្យបានផងណា ហោលផ្ទះទើបជា ម្ទាយកទៅប្ចាយព្រះ ។ នោះនុឡូរចូលភូមិដីស្រឡះ ឲ្យគិតដំរះ ធ្វើបុណ្យឲ្យបានបូជា ។ បើពុំធ្វើជូហោះណា នឹងនាំអាគ្នា បង់ស្រុកកើតទុក្ខក្មេងនេះ ។ នោះ ទោមគ្មាដក់ទោល នោះជុំគ្នាក់ ដោយស្រែសត្វថ្ងៃឯណា ។ នោះនឹង កើតហេតុកោលា ហលហើយពុំជា ថាឲ្យសូត្រមន្តដំរះ ។ នោះ ខ្នងក្នុងទឹកទំផ្ទះ អន្ទ្រយ៍គេហៈ និរតីអប្រិយសិង្គាប ។ បសុម

ទក្សិណគួរខ្លាច ទិស ៤ ឯងអាថ ឲ្យរៀបឲ្យមានបូជា ។ ទោះទុំងចុះ
ទន្លេណា មានទូកធ្លាក់ មានធាលំនៅត្រើះស្រែក ។ មានហេតុប្រាកត់
អ្នកឡុក គ្នាហើយពុំសុខ ខុនណាងនូវក្រ្បិតប្រាំងណា ។ ទោះមាន
មានកូនហើយណា ពុំស្រឡាញ់គ្នា តែពេលកូនឯងសាត់ព្រាត់ ។
តែប្រាំពីរថ្ងៃទៀងទាត់ បើពុំប្រយ័ត្ន នូវពុំបូជាទឹងប្រាស ។ អំពីលំនៅ
ផ្ទះផ្សារ ទឹកភ្នែកពេញពាស ពេលភូមិលំនៅឃ្លាតឆ្ងាយ ។ ទោះ
មានព្រៃត់ព្រាត់ព្រាយ ចូលភូមិខ្វល់ខ្វាយ ពុំមពញាមស្ងើតស្ងួត ។
មកពីទិសទីអាក្រក់ នោះទឹងមានទុក្ខ ពុំសុខសប្បាយឡើយហោង ។
ឲ្យប្រដាប់គ្រប់គ្រឿងផង បូជាចម្លង ព្រះគ្រោះបង្កក់ទើបជា ។
ទោះមានពងអស់ហើយណា ក្រាបយូរលុងជា ខាប់ខះគ្នានកូន
ចៅចីរ ។ ទោះមានថ្ងៃ ១ ពងពីរ ពុំលុងចុងចីរ នូវស្លាប់កូនចៅ
ផៅពណ៌ ។ ឲ្យរៀបបូជាអស់អាថ៌ បង្គាប់អំបាល ជូនអស់សត្វស្លាប
នោះណា ។ មានញីរងាវពុំជា ចង្រៃមហិមា ឲ្យរៀបបូជាវិង្វ ។
ទោះមានចិកកូនឯងក្តី ឧត្បាទអប្រិយ ព្រាត់គ្នាឃ្លាតឆ្ងាយបង់ស្រុក ។
ឲ្យរៀបបូជាទើបសុខ គ្រាន់បើគ្មានទុក្ខ ហើយទឹងស្រណុកវិញណា ។
ទោះលលកទំផ្ទះពុំជា ទឹងបង់ទ្រព្យា ឲ្យរៀបបូជាកុំយូរ ។ ទោះឃ្មុំ
ទំផ្ទះទិសបូព៌ា ព្រះកប៍បន្ទូល ឲ្យមកធ្វើទោសធ្វើគុណ ។ បើអ្នក
ឯណាដឹងបុណ្យ ឲ្យរៀបសូត្រមន្ត បង្កក់បូជាឲ្យថៃ ។ ទោះឃ្មុំទំនៅ

អគ្នេយ៍ គេដៀលគេជេរ ទីងកើតជំលោះពេកក្រៃ ។ ព្រួយចិត្តតែង គិតសព្វថ្ងៃ ប៉ាម្តៃម ៗ សរៃទ្ធសន្ធឹកកុំជា ។ ទោះឃ្មុំទំផ្ទះទក្ខិណា ឆ្ងូវមានលាភា លាភោប្រសើរឥតបី ។ ទោះឃ្មុំទំផ្ទះនិរតី ទីងកើត អប្រិយ ដូចដល់អំពល់អាត្មា ។ ទោះឃ្មុំទំផ្ទះបច្ចិមា ទីងកើតទោសា ឲ្យរៀបបូជាទើបបាន ។ ហើយឲ្យប្រយ័ត្នខ្លួនប្រាណ ធ្វើបុណ្យឲ្យទាន ប្រគេនផ្ទះនោះទៅឆាប់ ។ ទោះឃ្មុំទំផ្ទះពាយ័ព្យ ប្រសើរគួរគាប់ ឲ្យរៀបបូជាមង្គល ។ គេយកទ្រព្យធនមកដល់ នោះពុំអម្ពល់ មង្គល សិរីតែត្រេកអរ ។ ទោះឃ្មុំទំផ្ទះឧត្តរ មង្គលដ៏បវរ អរឲ្យតែជះ ក្រេមក្សាន្ត ។ ទោះឃ្មុំទំផ្ទះឦសាន នោះសោតទីងបាន ខ្ញុំប្រុស ខ្ញុំស្រីកែវកង ។ ឯរបៀបឲ្យរៀបសោតហោង តាមដោយគន្លង អស់ សត្វហានស្លាបឯងបាន ។ ទោះឃ្មុំហើរពីឦសាន ទំក្រោមផ្ទះប្រាណ នូវបានជោគជ័យជំនះ ។ ទោះឃ្មុំទ្រហឹងទំផ្ទះ ហើរចេញស្រឡះ នោះ គាថឲ្យរៀបបូជា ។ ព្រះពហ៊ុំប្រើមកម្ម៉ា បើពុំបូជា នោះណាមាន ភ័យតាំព្រដះ ។ ទោះឃ្មុំចូលទាំកន្ទផ្ទះ បូជាជំរះ នូវបានមាសប្រាក់ ទ្រព្យធន ។ ទោះឃ្មុំផ្តិតទំផ្ទះហោង វិសទីទំនង ជំណើរហើរចូល ទិសណា ។ តាំងបួនបីមានគាថា មើលលំនាំ ឲ្យរៀបបូជាស្នាន នោះ ។ ទោះឃ្មុំទំដោយច្បាប់នោះ ព្រះពហ៊ុំបំពោះ ប្រើមកធ្វើ ទោសឯងណា ។ ឲ្យរៀបប្រដាប់ប្រដា សត្វស្លាបដូចគ្នា បូជាបង្គាប់

ដូច្នេះ ។ ទៀនធូបលាជផ្កានូវក្រេះ ប្រេងម្សៅសំណោះ ចំអាប
បង្អែមផ្លែឈើ ។ ចង់វេងសិងមានដាក់លើ គោករេងហើយធ្វើ ស្លាធម៌
ពីរពណ៌ពីសី ។ ប្រដាប់មាសប្រាក់រ័តន៍មណី សំពត់អាវថ្មី នូវស្បៃ
កាសាយមនា ។ ស្លាបពានមែនមានដាក់ផ្កា ប្រដាប់ផង្គា នូវលាជ
បាចសាចព្រមផង ។ នូវប្រេងព្រះគោសោតហោង បូជាដោយគន្ធ
កន្ទង់លំនៅខាងជិត ។ ទោះត្រូវចំផ្ទះឯងសិទ្ធ ឲ្យរិះគន់គិត ឲ្យ
រៀបបូជាសព្វសាយ ។ (ឲមព្រះព្រហ្មទេវតា អាគច្ឆន្តុ ភុញ្ជន្តុ
ស្វាហាយ) ។ ព្រោះត្រូវចំផ្ទះមិនឆ្ងាយ នូវព្រាត់ខ្ចាត់ខ្ចាយ អន្តរាយ
ខ្លួនឯងកូនចៅ ។ ឲ្យរៀបបូជាប្រេងម្សៅ ប្រដាប់ទេះទូរ ដូចកល់
សត្វស្លាបឯងណា ទោះសេកផ្អើលយប់សន្និយោ ព្រាត់ប្រាសពីគ្នា ឲ្យ
រៀបបូជាសន្ទីយ៍[1] ។ បើពុំបូជាសូត្រ ហើយទឹងអប្រិយ ហោលភូមិ
ហោលស្រុកជាមួន ។ ទោះពស់ពិសពន់ដ៏កន្លង ទៀងផ្ទះឥតគង់ ទិស
បូពិអគ្នេយ៍មង្គល ។ ទៀងមកពេទព័ន្ធដកល់ សុខសប្បាយសល់ ផល់
ឲ្យទាំងសំណាកផង ។ ទឹងបានកូនចៅតបស្នង មាសប្រាក់កែវកង
សម្បត្តិសម្បូណ៌សួស្ដី ។ ចូលទិសទក្សិណនិរតី បស្ចិមអប្រិយ ទុក្ខ
នោះសោតពុំជា ។ ឲ្យរៀបធ្វើបុណ្យទេសនា ប្រដាប់ប្រដា ឲ្យមាន
សូត្រមន្តលំដោះ ។ ឲ្យបៀសពីលំនៅនោះ ទឹងស្បើយអស់គ្រោះ
ទឹងសុខសប្បាយសព្វគ្រា ។ ហើយឲ្យសូត្រមន្តបូជា ព្រះឥន្ទ្របស្កា

---

១ សន្ទីយ ប្រែថា យប់ ។

ទូវមន្ទគាថាពស់ពាយ ។ (ទេមព្រះឥន្ទ្រា សហបរិវារកាយ សព្វព្យញ្ជនំ
កុញ្ជរ ស្វាហាយ) ។ គោរពសំបូលក្នុងឆ្នាំងបាយ ព្យាធិទាំងឡាយ
កោតាបៀតៈបៀនដល់អគ្គ ។ ឲ្យរៀបបូជាម្ជិតជូន កុំខុកបង្អង់ ឲ្យជ្រះ
ស្រឡះលំហែ ។ គោរពសំបូលទិសបូព៌ាអាគ្នេយ៍ ក្បៀសានឯងឯង សឹង
តែប្រសើរថ្លាថ្លៃ ។ ទក្សិណនិរតីបែ្រ បស្ចិមសោតនៃ ឧត្តរទិសបូព៌ា
ដូចគ្នា ។ ឯទិសពាយ័ព្យសោតណា ពុំសូវគាបជា ចន្ទោះលផ្ញែក
តែឯង ។ ឲ្យរៀបបូជាតាក់តែង ប្រយ័ត្នគិតក្រែង និមិត្តដូចមាត់
គេថា ។ គោះថ្ងាន់គោមភ្ញក្តិណា ឡើងលើទាក់ លេលាលើផ្ទះសត្វ
ថ្ងៃ ។ បូជាព្រះកេតុនោះនៃ ស្បៀកខ្មៅប្រៃព រៀបប្រដាប់ដូចគ្នា ។
ទូវមានមាសប្រាក់នានា បើផ្ទុះហើយណា ឲ្យទាំងសំណាកនោះផង ។
បើត្រូវទិសបូព៌ាឯងហោង អគ្នេយ៍ទំនង ដំណើរទិសតីសើងជា ។ ឲ្យ
យកខុកដាក់ក្បែរ បំរើនសុខា ឲ្យរៀបបូជាសាទរ ។ បូលទិសទក្សិណ
ឧត្តរ បូលតុំស្នោះសរ និមិត្តបស្ចិមបើងកាច ។ ឯទិសពាយ័ព្យឯងអាច
តុំផាតុំកាច បូជាដូចគ្នារៀងកាយ ។ (ទិមស្រីគន្ធវ្វ បរិវារគ្រប់
សព្វព្យញ្ជនំ កុញ្ជរ ស្វាហាយ) ។ ពស់ព្រៃះលើងពស់ក្រោយ ឡើង
ផ្ទះគយ្លាយ ឲ្យរៀបបូជាឆាប់ៗ សំភាត់សព្រាសរខ្មៅញាប់ ឲ្យរៀប
ប្រដាប់ ដង្វាយព្រះឥន្ទ្រាថ្មី ។ បំភាបផ្ទះឈើចំណី ទាសប្រាក់
ផងគ្គី ទៀនធូបភ្ញីព្រាលប្រេងម្សៅ ។ គោរពសំពត់តក់ក្នុងបោះ គង់គួប

លំនៅ ថ្ងៃ៤ បង់ស្រុកគល់គេក្តី ៗ ពស់ចូលក្នុងរម្មូកខ្នល ទីង
កើតចុងចេរ គេនូវធ្វើទោសកាចក្តាត់ ៗ ឲ្យរៀបបូជាប្រសិទ្ធិ ហើយ
ឲ្យគន់គិត តាមដោយបង្គាប់សព្វសាយ ៗ ទោះបព្រឹលផងភាំងឡាយ
ប្រសូតកូនក្លាយ ជាពស់ឆ្នាំ១ បង់ស្រុក ៗ ទោះកូនជាក្អែឲ្យទុក ឆ្នាំ២
បង់ស្រុក បង់ភូមិលំនៅទីស្ថាន ៗ ទោះបុរសនោះសោតមែនមាន
កូនចៅពីព្រាណ នោះជាត្រមោចវិញហោង ៗ ចាំផ្ទៃនូវកើត
សៅហ្មង ឧត្បាទនេះហោង ថានៅបង់ស្រុកពុំលែង ៗ លាញើ
ទៅចូលស្រុកស្តែង ឲ្យរះគាក់តែង បូជាប្រាក់មាសនូវសេះ ៗ ឯមន្ត
ប្រដាប់នៅនេះ កុំបង្អង់ទុកស្ទេះ សិងរៀបប្រដាប់ដូចគ្នា ៗ ទោះ
ស្វាចូលស្រុកនោះណា ឲ្យរៀបបូជា មានស្រូវនូវអង្ករផង ៗ ទោះ
ទោចចូលស្រុកឯងហោង បង់ស្រុកតែម្តង ពុំនោះមានភ្លើងនូវឆេះ ៗ
ឲ្យរៀបបូជារួសរិះ តាមដោយក្បួននេះ តាមមនុស្សតាមសត្វស្រឡះ ៗ
ទោះក្អែឡើងដំបូលផ្ទះ ចិត្តនោះមនោមានះ ម្ចាស់ផ្ទះទីងស្លាប់បង់
ស្ថាន ៗ ឲ្យរៀបបូជាកុំខាន ទើបទីងក្រមកព្វត្ត ល្ហោះលែងទុក្ខ
ភ័យា ៗ ទោះពពែនូវក្អែជាន់គ្នា ឆ្នាំ១ ពុំជា ទោះណាទីងបង់ស្រុក
ស្រែ ឧត្បាទមួយមិញជាក្អែ ពុំត្រូវដូវខែ ស្លាគ្នាពុំចាំហោមន្ត ៗ

(មានតទៀត)

# បញ្ជីរឿង


ទំព័រ

១ ព្រហ្មចរិយកថា របស់ព្រះមហាសែសក្រុមពុទ្ធសាសនបណ្ឌិត្យ ប្រែនិងរៀបរៀង (ត) . . . . . . . . . . . . . . . . . . ១៧៦

២ បញ្ហាស្មុគស្មាញក្នុងសាសនា . . . . . . . . . . . . . . . . . . . . ១៨៦

៣ ធាតុវង្គបទ របស់ព្រះមហាពិទូរ ក្រសេម (ត) . . . . . . . . . . . . ២០៣

៤ សិលាចារិកនគរវត្ត និងបទានុក្រម (ត) . . . . . . . . . . . . . . ២០៩

៥ លោកន័យ (ត) . . . . . . . . . . . . . . . . . . . . ២៤១

៦ លទ្ធិទំនៀមទម្លាប់ខ្មែរ ក្បួនដំរះឧត្បាទ របស់បួកណា (ត) . . . . . . . ២៤៩

៧ រឿងព្រេងខ្មែរៈ រឿងសុភាទន្សាយ របស់បួកណា (ត) . . . . . . . . ២៥៩


# រូបក្រៅរឿង


រូបនាងរបាំ នៅជញ្ជាំងប្រាសាទនគរវត្ត . . . . . . . . . . . . . . . ១៦៩

# TABLE DES MATIÈRES


| | Pages. |
|---|---|
| I. BRAHMACARIYAKATHĀ par Préas Maha Sès de l'Institut Bouddhique (suite) | 171 |
| II. Diverses doctrines Bouddhique par Préas Maha Pitou Krasém | 181 |
| III. CATURAṄGAPADA par Préas Maha Pitou Krasém (suite) | 203 |
| IV. Les inscriptions de Nokor Vat (suite) | 209 |
| V. LOKANAYA (suite) | 241 |
| VI. Mœurs et coutumes cambodgiennes Règles pour conjurer les malheurs (suite) | 249 |
| VII. Contes populaires cambodgiens inédits : Le juge lièvre (à suivre) | 259 |


## HORS TEXTE :


Nokor Vat : une danseuse .......... 169



រូបនាងរបាំ នៅផ្ទាំងប្រាសាទនគរវត្ត ។

## សិលាចារិក

### លេខ ១

(១) រត្នមហាពោធិនាមេន RATNAMAHĀBODHINĀMENA

(២) មយាសម្ពោធិមិច្ឆតា MAYĀSAMBODHIMICCHATĀ

(៣) ពោធិរុក្ខាតិរោបេត្វា BODHIRUKKHĀTIROPETVĀ

(៤) សជិនប្បដិមំឥមំ[១] SAJINAPPAṬIMAṂ IMAṂ

(៥) សមត្ថញ្ញាយោមយ្ហំ SAMATTHAÑÑĀYO MAYHAṂ

(៦) ចាបេតុំសព្វសម្បទំ CĀPETUṂ SABBASAMPADAṂ

(៧) បសន្នបនសាសាធូ PASANNAPANASĀ SĀDHŪ

(៨) សាធុវោអនុមោទថ SĀDHUVO ANUMODATHA

(៩) ត្រិពិទ្ធ ត្រៃយសរវិន្ទនា ៣ (១០) ហុល ឌុតុ (ល) អត្តិរេកឯកបិតាតិ (១១) ទ្ធស្មុបរិតឈាទរករទសន (១២) ក្វអករាង្គ្លិគ្រិបាទារពិន្ធអ (១៣) បិន អត្តិរេកអនេកពៃបុល ឌ្វ (១៤) តុលបេស្មាទិពលតិ – កលហុ (១៥) ទៃតោយ បុត្វពោធិសត្វផោ (១៦) ង ស្បង្គ្តរំពិងនាន្ទុប្រាបិនាស្ចម (១៧) ជាព្រះពុទ្ធគិបិសំគេចព្រះម (១៨) ហាប្រេរត្រិរត្នមហាពោធិ

---

១ ឥមំ ។

# ព្រហ្មចរិយគាថា

## របស់ព្រះមហាសែស ក្រុមពុទ្ធសាសនបណ្ឌិត្យ

រៀបរៀង (ត)

ម្យ៉ាងទៀត សីល ៥ បើបុគ្គលឯណាបានរក្សាដោយប្រពៃហើយ បុគ្គលនោះបានឈ្មោះថាជាអ្នកមានសីល ហើយរមែងទៅកើតក្នុងសុគតិ-ភព សមតាមពុទ្ធភាសិតដែលព្រះអង្គទ្រង់ប្រោសព្រះរាជទានធម៌ទេសនាដល់អនាថបិណ្ឌិកសេដ្ឋី ក្នុងគម្ពីរអង្គុត្តរនិកាយបញ្ចកនិបាតថា

យោ បាណំ នាតិបាតេតិ   មុសាវាទំ ន ភាសតិ
លោកេ អទិន្នំ នាទិយតិ   បរទារំ ន គច្ឆតិ
សុរាមេរយបានញ្ច   យោ នរោ នានុយុញ្ជតិ
បហាយ បញ្ច វេរានិ   សីលវា ឥតិ វុច្ចតិ
កាយភេទា សប្បញ្ញោ   សុគតឹ សោបបជ្ជតិ ។

ជនឯណាមិនសំឡាប់សត្វ មិននិយាយពាក្យកុហក មិនកាន់យកទ្រព្យដែលគេមិនបានឲ្យ ក្នុងលោក មិនសេពគប់នឹងភរិយារបស់អ្នកដទៃ ម្យ៉ាងទៀត ជនឯណាមិនប្រកបខ្លួនការផឹកទឹកស្រវឹងគឺសុរានឹងមេរ័យ ជននោះឈ្មោះថាបានលះបង់វៀរទាំង៥ហើយ អ្នកប្រាជ្ញឲ្យឈ្មោះថា ជាអ្នកមានសីល ជននោះប្រកបដោយបញ្ញា លុះរលាងបញ្ចខន្ធទៅហើយ រមែងចូលទៅកាន់សុគតិភព ។

អ្នកមានបញ្ញាគួរពិចារណាតាមពុទ្ធភាសិតនេះ ឲ្យឃើញថា សីល ៥ នេះ មានអានិសង្សអាចឲ្យទៅកើតក្នុងសុគតិភពបាន សូម្បីតែបុគ្គលរក្សាតែមួយរំពេច ក៏អាចឲ្យទៅបង្កើតក្នុងស្ថានសួគ៌ក៏មានខ្លះដែរ ដូច

មានវត្ថុនិទានថា សម្ពហុលា តិរ សមុទ្ទកលភិជា នាកាយ
សមុទ្ទំ បក្ខន្ទិសុ ។ បានឮថា ពួកឈ្មួញសមុទ្រច្រើននាក់ នាំ
គ្នាស្ទុះទៅកាន់សមុទ្រដោយសំពៅ ។ ពួកឈ្មួញទាំងនោះបើកសំពៅ
ទៅ សំពៅក៏លឿនរហ័សឆាប់ប្រៀបដូចសរដែលគេបាញ់ទៅ បាន ៧
ថ្ងៃក៏កើតឧត្បាតធំក្នុងកណ្តាលសមុទ្រ មានរលកធំតាំងឡើងទឹកចូល
ពេញសំពៅ ។ កាលបើសំពៅទៀបនឹងលិចហើយ មហាជនក៏នឹក
រឭកដល់ឈ្មោះទេវតាពល់ៗខ្លួន បានធ្វើកិច្ចបន់ស្រន់ជាដើម ហើយ
ក៏នាំគ្នាយំ ។ មានបុរសម្នាក់គិតពិចារណាថា អាត្មាអញមានទីពឹង
ក្នុងភ័យនេះឬទេ ក៏នឹកឃើញដល់សរណគមន៍និងសីលដ៏បរិសុទ្ធរបស់
ខ្លួន ហើយក៏អង្គុយតែនក្នុងនាកណ្តាលជនទាំងនោះ ប្រៀបដូចជាព្រះ
យោគីធ្វើកម្មដ្ឋាន ។ ពួកជនដទៃក៏សួរដល់ហេតុដែលមិនបានខ្លាចនឹង
បុរសនោះ ។ បុរសក៏ប្រាប់ថា ម្នាលអ្នកទាំងឡាយ ថ្ងៃដែលយើង
ឡើងជិះសំពៅមក យើងបានឲ្យទានដល់ភិក្ខុសង្ឃ បានសមាទាន
សរណគមន៍និងសីលរួចជាស្រេច ព្រោះហេតុនោះបានជាយើងមិន
ភ័យ ។ ជនទាំងឡាយសួរថា អ្នកជាម្ចាស់ សរណគមន៍និងសីលនោះ
គួរដល់អ្នកដទៃដែរឬទេ ។ បុរសប្រាប់ថា គួរដល់អ្នកដទៃដែរ ។ ជន
ទាំងឡាយនិយាយថា បើដូច្នោះ អ្នកចូរឲ្យដល់យើងកល់គ្នាផង ។
បុរសនោះធ្វើមនុស្សទាំងអស់នោះឲ្យជា ៧ ចំណែក ក្នុងមួយចំណែក ៗ

៧០០ នាក់ៗ ។ ទើបបុរសនោះឲ្យសីល ៥ ដល់មនុស្សទាំងអស់ ៗ បណ្តាជនទាំងនោះ ជន ១០០ នាក់ទី ១ សមាទានសីលក្នុងវេលាទឹកត្រឹមកជើង ៗ ពួកជន ១០០ នាក់ទី ២ សមាទានសីលក្នុងវេលាទឹកត្រឹមជង្គង់ ទី ៣ ទឹកត្រឹមចង្កេះ ទី ៤ ត្រឹមផ្ចិត ទី ៥ ត្រឹមដោះ ទី ៦ ត្រឹមក ទី ៧ សមាទានសីលក្នុងវេលាទឹកប្រែចូលមាត់ ៗ បុរសនោះបានឲ្យសីលដល់មនុស្សទាំងអស់នោះរួចហើយ ស្រែកប្រកាសឃោស្នាឡើងថា អ្នកពល់គ្នាគ្មានទីពឹងអ្វីដទៃក្រៅអំពីសីល ៖ ចូរពិចារណាសីលតែម្យ៉ាងចុះ ៗ ពួកជនទាំង ៧០០ នាក់ក៏ធ្វើមរណកាលក្នុងសមុទ្រទាំងអស់ ក៏បានទៅកើតក្នុងពិភពតាវត្តិង្សទេវលោក ព្រោះអាស្រ័យសីលដែលខ្លួនបានសមាទានក្នុងសម័យជិតស្លាប់ ៗ វិមានទាំងឡាយក៏កើតមានដល់ទេវតាទាំងនោះដោយពួកដោយដុំ ៗ វិមានមាសប្រមាណជា ១០០ យោជន៍ កើតឡើងដល់ទេវតាជាអាចារ្យ នាកណ្តាលវិមានទាំងអស់ ៗ វិមានក្រៅអំពីនោះជាបរិវារនៃវិមាននោះ វិមានយ៉ាងតូចជាងគេបង្អស់ត្រឹម ១២ យោជន៍ ៗ ទេវតាទាំងឡាយនោះ ក៏រំពឹងបុញ្ញកម្មក្នុងខណៈដែលខ្លួនបានទៅកើតរួចហើយ ក៏ដឹងច្បាស់ថា សម្បត្តិដែលខ្លួនបាននោះ បានព្រោះអាស្រ័យទេវតាជាអាចារ្យ ហើយក៏នាំគ្នាទៅនិយាយសរសើរគុណអាចារ្យក្នុងសំណាក់ព្រះឧសភពល ៗ រឿងនេះមានក្នុងអដ្ឋកថាទេវតាសំយុត្ត ៗ

មានរឿងក្នុងបាឡី សព្ភិសូត្រ ទេវតាសំយុត្ត ក្នុងគម្ពីរសំយុត្តនិកាយថា ទេវតាទាំងអស់នោះ ឈ្មោះថា "សតុល្លបកាយិកាទេវតា" មានរស្មីគឺព្រោងព្រាយញ៉ាំងវិហារជេតពន ឲ្យភ្លឺស្វាងជុំវិញទាំងអស់ ក្នុងវេលាពាក់កណ្ដាលរាត្រី ហើយក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយស្ថិតនៅក្នុងទីដ៏សមគួរ ។ ទេវតាមួយ លុះស្ថិតនៅក្នុងទីដ៏សមគួរ ហើយក៏ពោលគាថានេះ ក្នុងសំណាក់ព្រះដ៏មានព្រះភាគថា

សព្ភិរេវ សមាសេថ  សព្ភិ កុព្វេថ សន្ថវំ
សតំ សទ្ធម្មមញ្ញាយ  សេយ្យោ ហោតិ ន បាបិយោ ។

បុគ្គលគប្បីអង្គុយ(១)ជាមួយនឹងសប្បុរស គប្បីធ្វើសេចក្ដីរីករាយជាមួយនឹងសប្បុរស សេចក្ដីល្អចំរើននឹងមានដល់បុគ្គលនោះ សេចក្ដីអាក្រក់មិនមានដល់បុគ្គលនោះឡើយ ព្រោះបុគ្គលនោះបានដឹងច្បាស់នូវព្រះសទ្ធម្មគឺសីល ៥ របស់សប្បុរសទាំងឡាយ ។

លំដាប់នោះ ទេវតាដទៃទៀត បានពោលគាថានេះក្នុងសំណាក់ព្រះដ៏មានព្រះភាគថា

សព្ភិរេវ សមាសេថ  សព្ភិ កុព្វេថ សន្ថវំ
សតំ សទ្ធម្មមញ្ញាយ  បញ្ញា លព្ភតិ នាញ្ញតោ ។

---

១ គប្បី ដេក ដើរ ឈរ អង្គុយ ។

បុគ្គលគប្បីអង្គុយជាមួយនឹងសប្បុរស គប្បីធ្វើសេចក្តីរាក់ទាក់ជាមួយនឹងសប្បុរស បុគ្គលនោះរមែងបានបញ្ញា ព្រោះដឹងច្បាស់នូវព្រះសទ្ធម្មគឺសីល ៥ របស់សប្បុរសទាំងឡាយ មិនមែនបានអំពីសំណាក់បុគ្គលដទៃឡើយ ។

លំដាប់នោះ ទេវតាដទៃទៀត បានពោលគាថានេះក្នុងសំណាក់ព្រះដ៏មានព្រះភាគថា

សព្ភិរេវ សមាសេថ  សព្ភិ កុព្វេថ សន្ថវំ
សតំ សទ្ធម្មមញ្ញាយ  សោកមជ្ឈេ ន សោចតិ ។

បុគ្គលគប្បីអង្គុយជាមួយនឹងសប្បុរស គប្បីធ្វើសេចក្តីរាក់ទាក់ជាមួយនឹងសប្បុរស បុគ្គលនោះរមែងមិនសោយសោកក្នុងកណ្តាលនៃពួកជនដែលប្រកបដោយសេចក្តីសោយសោក ព្រោះដឹងច្បាស់នូវព្រះសទ្ធម្មគឺសីល ៥ របស់សប្បុរសទាំងឡាយ ។

លំដាប់នោះ ទេវតាដទៃទៀត បានពោលគាថានេះក្នុងសំណាក់ព្រះដ៏មានព្រះភាគថា

សព្ភិរេវ សមាសេថ  សព្ភិ កុព្វេថ សន្ថវំ
សតំ សទ្ធម្មមញ្ញាយ  ញាតិមជ្ឈេ វិរោចតិ ។

បុគ្គលគប្បីអង្គុយជាមួយនឹងសប្បុរស គប្បីធ្វើសេចក្តីរាក់ទាក់ជា

មួយនឹងសប្បុរស បុគ្គលនោះរមែងរុងរឿងក្នុងកណ្ដាលនៃញាតិ ព្រោះដឹងច្បាស់នូវព្រះសទ្ធម្មគឺសីល ៥ របស់សប្បុរសទាំងឡាយ ។

លំដាប់នោះ ទេវតាដទៃទៀត បានពោលគាថានេះ ក្នុងសំណាក់ព្រះដ៏មានព្រះភាគថា

សព្ភិរេវ សមាសេថ សព្ភិ កុព្វេថ សន្ថវំ
សតំ សទ្ធម្មមញ្ញាយ សត្តា គច្ឆន្តិ សុគតឹ ។

បុគ្គលគប្បីអង្គុយជាមួយនឹងសប្បុរស គប្បីធ្វើសេចក្ដីរករាយជាមួយនឹងសប្បុរស សត្វទាំងឡាយបានដឹងច្បាស់នូវព្រះសទ្ធម្មគឺសីល ៥ របស់សប្បុរសទាំងឡាយហើយ រមែងទៅកាន់សុគតិភព ។

លំដាប់នោះ ទេវតាដទៃទៀត បានពោលគាថានេះ ក្នុងសំណាក់ព្រះដ៏មានព្រះភាគថា

សព្ភិរេវ សមាសេថ សព្ភិ កុព្វេថ សន្ថវំ
សតំ សទ្ធម្មមញ្ញាយ សត្តា តិដ្ឋន្តិ សាតតំ ។

បុគ្គលគប្បីអង្គុយជាមួយនឹងសប្បុរស គប្បីធ្វើសេចក្ដីរករាយជាមួយនឹងសប្បុរស សត្វទាំងឡាយបានដឹងច្បាស់នូវព្រះសទ្ធម្មគឺសីល ៥ របស់សប្បុរសទាំងឡាយហើយ រមែងស្ថិតនៅជាសុខអស់កាលយូរ ។

លំដាប់នោះ ទេវតាដទៃទៀត ក្រាបទូលសួរព្រះដ៏មានព្រះភាគជាម្ចាស់ថា សូមទ្រង់ព្រះមេត្តាប្រោស បណ្ដាពាក្យយើងខ្ញុំព្រះអង្គទាំង

អស់គ្នា ពាក្យទរណា ល្អពីរោះជាងគេ ៗ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ពាក្យអ្នកទាំងអស់គ្នា សុទ្ធតែជាពាក្យល្អពីរោះ ដោយបែបដោយយ៉ាង តែជាអ្នកទាំងឡាយចាំស្ដាប់ពាក្យតថាគតម្ដងវិញមើល ព្រះអង្គទ្រង់ត្រាស់ថា

សព្ភិរេវ សមាសេថ  សព្ភិ កុព្វេថ សន្ថវំ
សតំ សទ្ធម្មមញ្ញាយ  សព្វទុក្ខា បមុញ្ចតិ ៗ

បុគ្គលគប្បីអង្គុយជាមួយនឹងសប្បុរស គប្បីធ្វើសេចក្ដីរីករាយជាមួយនឹងសប្បុរស បុគ្គលបានដឹងច្បាស់នូវព្រះសទ្ធម្មគឺសីល ៥ របស់សប្បុរសទាំងឡាយហើយ រមែងរួចចាកទុក្ខទាំងពួង ៗ

(មានតទៅទៀត)

# បញ្ហាស្មុគស្មាញក្នុងរឿងសាសនា

## របស់ព្រះមហាពិទូរ ក្រសេម

# បញ្ហាស្មុគស្មាញក្នុងរឿងសាសនា

(ព្រះមហាពិទូរ ក្រសេម ប្រែចេញពីសៀវភៅ ពុទ្ធសាសនចក្រ របស់សៀម ដែលប្រែចេញពីសៀវភៅមហាពោធិសមាគម ព. ស. ២៤៧៧ នៅឥណ្ឌាជាច្បាប់ដើម) ។

សាសនានោះ បើទុកជាជារបស់ផ្តួចផ្តើមមានឡើងជាគូគ្នានឹងសេចក្តីគ្រប់គ្រងជីវិត ហើយនឹងសេចក្តីប្រព្រឹត្តទៅនៃមនុស្សតែម្តង ក៏សឹងថាបានដោយមិនប្រាកដថា ប្រជាជនជាតិណា ដែលមិនបានកាន់សាសនាយ៉ាងឯណានីមួយសោះនោះគ្មាន ទោះជាលទ្ធិដែលថោកទាបប្លែកៗ ដូចយ៉ាងការបូជា "តោតេម" របស់អមេរិកាំងឥណ្ឌា ឬលទ្ធិដែលគោរពរាប់អានបិសាចរបស់ពួកមនុស្សដែលនៅតាមកោះហ្វីជី គង់-គោ នឹងទីបេត៍ ក្នុងសម័យច្រើនរយឆ្នាំមកហើយ រហូតដល់លទ្ធិសាសនាដែលចំរើនក្នុងគោលសីលធម៌ និងប្រាជ្ញាយ៉ាងខ្ពស់ៗ រាប់តាំងពីសាសនាជិនគោ ដរាបដល់សាសនាធំៗ ដែលមានមនុស្សស្គាល់សព្វសាយក្នុងសម័យបច្ចុប្បន្ន ។

រឿងដែលមនុស្សលើកឡើងជជែកគ្នាច្រើន ក៏គឺរឿងដែលថា "មនុស្សយើងជាអ្នកមានសន្តានជ្រួតជ្រាបជាប់ក្នុងលទ្ធិសាសនាតាមនិស្ស័យ តាំងអំពីកំណើតមកឬទេ" តែពាក្យតបបញ្ហានេះស្រេចហើយតែសេចក្តីចូលចិត្តក្នុងការឲ្យសេចក្តីក្នុងពាក្យថា "សាសនា" អ្នកណានឹងឲ្យសេចក្តីសំដៅរបស់ "សាសនា" ដោយន័យកំណត់ត្រឹមត្រូវដូច

ថា "សាសនា" គឺសេចក្ដីជឿក្នុងអំណាចបង្គាប់របស់ព្រះដែលគេជឿស្ដាប់ ឬនឹងគិតតាមសេចក្ដីសំដៅយ៉ាងខ្លីហៅយថា "សាសនា" នោះជាលទ្ធិ ឬបែបផែននៃសេចក្ដីជឿគោរពរាប់អានក៏ដោយ នោះជារឿងកំណត់ភូមិនៃសេចក្ដីចេះដឹង សេចក្ដីយល់ឃើញ ក្នុងរឿងនោះរបស់ខ្លួន ៗ ដោយចំពោះ ព្រោះគោលសេចក្ដីប្រព្រឹត្តដែលនឹងនាំមកផលឲ្យដល់វត្តបដិបត្តិ ដែលយើងហៅថា "សាសនា" មួយ ៗ តាមដែលយើងឃើញនោះក៏មានផ្សេងគ្នាក្នុងចំណែកសេចក្ដីគិតឃើញ តាមកាលៈទេសៈទៀតផង ៗ

យើងអាចនឹងពោលដោយសង្ខេបថា លទ្ធិសាសនាដែលជឿក្នុងព្រះជាម្ចាស់មែនរុះរើកាយខ្លួនចេញ នឹងរុះរើកាយខ្លួនតៗទៅ ក្នុងជាន់ដំបូងប្រជាជនជាតិផ្សេង ៗ មានព្រះជាម្ចាស់ជាទីគោរពរាប់អានជាច្រើន ដូចយ៉ាងក្រុមទេវតា ធារទេវតា ព្រះម្ចាស់នៃធម្មជាតិ ព្រះម្ចាស់នៃគណជាតិនឹងពិជជាតិផ្សេង ៗ ជាព្រះដែលមិនសូវមានឫទ្ធិមុខគួរខ្លាចព្រឺព្រួចណាស់ទេ ចំណែកឯព្រះដែលកើតក្នុងជំនាន់ក្រោយ ៗ ច្រើនតែព្រះដែលចំរើនរុងរឿងគ្រាន់បើ សឹងបែកសាខាចេញអំពីព្រះក្នុងសម័យមុន ៗ នោះឯង មានទាំងអានុភាពមុខគួរខ្លាចជាងពួកមុន ដូចយ៉ាងព្រះអសុនិបាត ព្រះអគ្គី ព្រះពាយុ នឹងព្រះនៃសព្វធម្មជាតិដទៃ ៗ ទៀត សឹងមានអភិនិហារផ្សេង ៗ ចេញទៅ តាមកំឡាំងអាចនៃប្រាជ្ញា ឬសេចក្ដីចេះដឹងរបស់ជនអ្នកផ្ដើមឡើងនោះ ៗ យើងត្រូវយល់

ទឹងត្រូវកុំភ្លេចថា អសុរិបាត បិសាចរបស់ហ្ស៊ីណានោះ មានសេចក្តីពាក់ទងគ្នាយ៉ាងជិតនឹងព្រះសិវស៍ ដ៏ជាទេវាធិរាជរបស់ក្រិកបុរាណតែម្តង ។

មិនតែប៉ុណ្ណោះ នៅមានព្រះផ្សេងៗ ដែលកើតមានឡើងអំពីព្រះដែលពោលហើយខាងដើមនោះ មានចំនួនជាច្រើនទៀត ស្ទើរតែរាប់មិនអស់, ប្រព្រឹត្តទៅតាមអាការនៃធម្មជាតិនោះៗ គ្រប់បែប លុះសម័យតមក មានព្រះរបស់ពួក មោនោទីអ៊ីសត៍ កើតឡើង, ពួកនេះមានសេចក្តីឃើញថា ធម្មជាតិតែរបស់លោកមិនមានច្រើន គឺមានតែ ១ ប៉ុណ្ណោះ ទោះព្រះរបស់ពួកមោនោទីអ៊ីសត៍នេះ ក៏នៅផ្សេងគ្នាចេញទៅទៀត តាមសេចក្តីយល់ឃើញ នឹងសេចក្តីកាន់ក្នុងវង្សជាតិនឹងប្រជា-ជនផ្សេងៗ ការប្រៀបធៀបគុណសម្បត្តិនៃព្រះអំបាលនេះ មានផលមុខគួរពេញចិត្តច្រើន ព្រោះហេតុនេះ យើងនឹងនាំយកព្រះដែលចាត់ថា សំខាន់ៗ មកប្រៀបធៀបគ្នាមើលបាន ៥ អង្គ គឺ :

១ ព្រះដ៏ជាប្រធានរបស់ពួក "ពីរូ" បុរាណ ក្នុងសម័យនៃព្រះអង្គនេះ យើងនឹងឃើញបានថា ការយកមនុស្សមកធ្វើពិធីបូជាយញ្ញនោះ រាប់ថាគ្មានទៅហើយ តែមានពិធីសក្តិសិទ្ធិមួយយ៉ាង ហៅថាហោលី គមមិវយ៉ែន (ថ្ងៃធ្វើពិធីដ៏បរិសុទ្ធដ៏ទាក់ទាមដោយសេចក្តីលើក

ដល់មរណកាលរបស់ព្រះជាម្ចាស់[១] ឡើងជំនួស ហើយក្នុងពិធីនេះ មានការបរិភោគនំបុ័ងដែលហៅថា "សាន់សុ" ដែលប្រោះព្រំដោយឈាមចៀមដែលយកមកសម្រាប់ធ្វើការបូជាយញ្ញ ពួកអ្នកមកប្រជុំបានបរិភោគសាន់សុនៅវេលាក្រោយដែលបានប្រកាសថា "ពួកអ្នកទាំងឡាយចូរប្រយ័ត្នថា ពួកអ្នកដែលបរិភោគរបស់នេះ (សាន់សុ) នេះត្រូវធ្វើដូចម្ដេច ព្រោះថា អ្នកណាដែលបរិភោគសាន់សុនេះ ដោយចិត្តអកុសល នឹងមិនពិតក្នុងចិត្តនោះព្រះបិតា (ព្រះអាទិត្យ) របស់យើងនឹងដឹង–ឃើញហើយ ព្រះបិតារបស់យើង នឹងផ្ដន្ទាទោសឲ្យបានសេចក្ដីទុក្ខវេទនា" ។

ក្នុងរឿងនេះមុខគួរឲ្យសង្កេតថា កាលពួកគ្រីស្ទ័ញបានប្រទះការបដិបត្តិបែបនេះ ដែលប្រហែលគ្នានឹងលទ្ធិបដិបត្តិ ១ យ៉ាង ដែលពួកបុរិមប្រទេសគេដឹងស្គាល់ណាស់មកហើយ ទាំងឥឡូវនេះ ពួកបូព៌ាប្រទេសក៏ដឹងស្គាល់ដែរហើយ ហេតុដូចម្ដេចក៏បានជាគេបញ្ចេញមតិថា អាហារនេះលោកសេនត៍បាថោលោមិវ ជាអ្នកប្រតិស្ឋានឡើង? ។

២ យើងត្រឡប់មើលតាំងអំពីអមេរិកាភាគខាងត្បូងរៀងទៅដល់អាហ្វ្រិកាភាគខាងត្បៀសាន នឹងឃើញព្រះជាម្ចាស់ឈ្មោះ "ឧសិរិស" របស់ពួកឥយិបត៍ នឹងហោរ៉ស ជាឧរសរបស់ព្រះអង្គ ហើយជាអ្នកអាជ្ញាកណ្ដាល ឬជារាជទូតរបស់ព្រះអង្គ សម្រាប់នាំមនុស្សស្លាប់ទៅកេព្រះ

---

១ យ៉ាងថ្ងៃវិសាខបូជារបស់ពួកយើង ។

អង្គជាភាពសំដែងក្នុងវេលាក្រោយដែលបានចូលដួងចិត្ត (បេះដូង) របស់អ្នកស្លាប់អំបាលនោះហើយ ។

៣ ក្រៅអំពីនេះ គឺព្រះ "សិវ" របស់ពួកឥណ្ឌូ(*) ដែលគេជឿជ្រែកជ្រាបទូទៅក្នុងសកលលោកហើយ យើងត្រូវប្រៀបធៀបនឹងសង្កេតដល់ព្រះយាហ៉េហ៍ របស់ពួកហិបទ្រូ ដែលក្លាយនាមមកជា "យេហូវ៉ា" តាមព្រះគម្ពីរចាស់ (Old Testament) ដែរ ក្នុងទីបំផុតបានក្លាយមកជាព្រះដ៏ទ្រង់នូវអនន្តានុភាពរបស់ពួកគ្រិស្តិក (ពួកដែលកប់អានព្រះជាម្ចាស់ នឹងចំណេះដែលព្រះជាម្ចាស់បើកឲ្យ) តាមដែលពោលទុកក្នុងគម្ពីរថ្មី (New Testament) សឹងជាអ្នកដែលបានសាងទេវលោកនឹងមនុស្សលោក ព្រះឱរសរបស់ព្រះអង្គក៏ជាអាជ្ញាកណ្តាល ឬជាអ្នកនាំការរបស់ព្រះអង្គដូចគ្នានឹងបេរាស ក្រៅអំពីនេះនៅមានដំណែងជាអ្នកជួយលោក ហើយទៅក្នុងអនាគត ក្នុងសម័យមួយនោះ នឹងបានជាអ្នកវិនិច្ឆ័យអំពើកម្មរបស់មនុស្សទាំងអ្នកដែលរស់នៅ ទាំងអ្នកដែលស្លាប់ទៅហើយផង ។

១ អង្គទៀត គឺព្រះមហាម័ត របស់ពួកឥស្លាមសឹងជាព្រះសំខាន់ ១ អង្គដែរ ដែលគេបញ្ញត្តិថា "គ្មានព្រះអង្គឯទៀតក្រៅអំពី ១ អង្គនេះ ហើយព្រះមហាម័តជាអ្នកស្នងព្រះអង្គនៃព្រះនោះ" ។

---

១ ត្រង់នេះខ្ញុំព្រះមហាពិទូរ ក្រសេម សុំឲ្យមើលសេចក្ដីពិស្ដារក្នុងរឿងសាសនប្រវត្តិ ដែលព្រះរាជបណ្ណាល័យបោះពុម្ពហើយ ។

ទោះលទ្ធិសាសនាដែលជឿកាន់តាមព្រះជាម្ចាស់ មានច្រើនពួក ទាំងផ្សេងគ្នា ដោយប្រការខ្លះក្តី តែគល់ ៗ លទ្ធិទាំងនោះ សុទ្ធតែមានរបស់សំខាន់ទាំងបួនគល់រួមជាមួយគ្នា បួនគល់ដ៏សំខាន់ សុទ្ធតែប្រាថ្នានាំឲ្យចូលដល់ "ការរំដោះទុក្ខ និងកន្ទ្រងបង់ទុក្ខ" ៗ

លទ្ធិសាសនាគ្រិស្តាំង ប៉ុនប៉ងដើម្បីនឹង "ញុំាងចក្រពត្តិរបស់ព្រះជាម្ចាស់ឲ្យបង្កើតឡើង ក្នុងពិភពលោក" ហើយឲ្យបំណាច់ដល់អ្នកដែលតាំងនៅក្នុងគុណសេចក្តីល្អ ឲ្យបានទៅកើតក្នុងឋានសួគ៌ ដ៏ជាស្ថានសិងប្រាសចាកសេចក្តីទុក្ខសោក និងសេចក្តីអាក្រក់ សាសនាមហាម៉ត់ទទួលពាក់ព័ន្ធនឹងឲ្យឋានសួគ៌ដល់អ្នកដែលរាប់អាន ឋានសួគ៌របស់ពួកនេះងាយបាន សាវកអ្នកបដិបត្តិអាចនឹងដំណើរដើរតែបាន យ៉ាងសន្ធោហឹហាពេញនៅសេចក្តីសុខក្នុងកាមគុណ ទំនងប្រហែលគ្នានឹងលទ្ធិសាសនាក្នុងយុគដំបូង ៗ ក្នុងជាន់នេះឃើញថា ឋានសួគ៌បានចំរើនល្អឡើងក្នុងផ្លូវជាមួយគ្នាតែក៏មិនល្អទៅជាង "សេចក្តីល្អដែលចាត់ជាកំពូល" របស់មនុស្សក្នុងសម័យឬក្នុងយុគនោះ ៗ ព្រោះហេតុនោះ សាសនាទាំងអស់ក្នុងលោក ទោះជាមានសេចក្តីបែកផ្សេងគ្នាដោយភូមិ (ថ្នាក់ជាន់) ដូចម្តេចក្តី ក៏សុទ្ធតែមានសេចក្តីបំណង ដែលពិតតែមួយ គឺ តាំងចិត្តស្វែងរកស្ថាបនាសាន្តិភាព ភាតរភាព និងការុណ្យភាព ក្នុងរវាងមនុស្សជាតិដ៏ជាផ្លូវឲ្យលុះផលដែលប៉ុនប៉ងពិតប្រាកដ គឺការរំដោះទុក្ខសោក

ទាំងឡាយ តែសេចក្ដីប៉ុនប៉ងនេះនឹងបានសម្រេចដូចប្រាថ្នាឬទេ នៅក្នុងបញ្ហានៅឡើយ ព្រោះរាល់លទ្ធិសាសនាដែលអាស្រ័យសេចក្ដីជឿជាគោលមែនសម្រេចផលក្នុងរបស់មួយមុខប៉ុណ្ណោះ ផលនោះគឺសេចក្ដីសុខអាលទៅក្នុងផ្លូវសង្គ្រាម សេចក្ដីសុខអាលចិត្តឲ្យកើតគុំគួនព្យាបាទដែលកប់នៅខាងក្នុង ដល់ទៅញុំាងផលគឺសេចក្ដីជ្រួលច្របល់នឹងការចំលាយលាងគ្នាទូទៅឲ្យកើតឡើង ។

គ្មានសោះ "សង្គ្រាមដែលប្រសើរបរិសុទ្ធ" (សង្គ្រាមដើម្បីសាសនា) បែបណា ៗ ក៏ដោយ ដូចយ៉ាងសង្គ្រាមមេកសិកោ ក្នុងសម័យបុំរាណ, សង្គ្រាមគ្រិសេត ក្នុងសម័យកណ្ដាលឬសង្គ្រាមជីហាត (សង្គ្រាមសាសនារបស់មហាម៉ាត់ ទីងពួកដទៃ ៗ) ក្នុងសម័យក្រោយនោះមកទៀត កើតឡើងដោយប្រាសចាក "សេចក្ដីជឿក្នុងផ្លូវសាសនា" សង្គ្រាមអម្បាលនោះដែលកើតឡើង ក៏ព្រោះតាក់តាមដោយរឿងលទ្ធិសេចក្ដីជឿ ឬព្រោះសទ្ធាជ្រមុជនៅក្នុងលទ្ធិ ហើយពួកព្រះដែលជាម្ចាស់លទ្ធិនោះឯងជាអ្នកហោមភ្លើងនៃការសង្គ្រាម អម្បាលនោះឲ្យកើតឡើងដោយខ្លួនឯង ។

គ្រោះកាចរបស់ពួកអ្នកប្រាជ្ញវិទ្យាសាស្ត្រដែលប្រកាសថា "លោកមួល" នោះ រាល់ៗ គ្នាគង់ជ្រាបស្រេចហើយថាជាយ៉ាងដូចម្ដេច, សោ-គ្រឹស ត្រូវបំពុលថ្នាំពិស មិនមែនព្រោះហេតុថា គេបានះពាល

សេចក្ដីពិត តែព្រោះសេចក្ដីពិតដែលគេពោលនោះ មិនចុះសម្រុងគ្នានឹងសេចក្ដីជឿរបស់មនុស្សក្នុងសម័យនោះ មិនចាំបាច់វិលទៅមើលសេចក្ដីប្រព្រឹត្តទៅ ក្នុងសម័យដែលមានការបែកខ្ញែកគ្នាហើយតាំងនិកាយប្រូតិស្តង់តំឡើងថ្មី (មានការសង្គ្រាមសាសនា) ដែលធ្វើឲ្យកើតការបែកខ្ញែកគ្នាក្នុងរវាងត្រកូលនឹងត្រកូល បិតានឹងបុត្រ(១) នោះទេ ព្រោះសូម្បីក្នុងសម័យដែលរុងរឿងជាងនោះ ដូចយ៉ាងក្នុងបច្ចុប្បន្ននេះ យើងក៏នៅប្រទះបក្ខពួករបស់ត្រកូលមួយ ៗ ដែលប្រព្រឹត្តនឹងគិតផ្សេងគ្នាម្នាក់មួយផ្លូវ ដោយហេតុមកពីមានសេចក្ដីជឿសាសនាផ្សេងគ្នានៅឡើយដែរ ។

គ្រប់សាសនាបានប្រដៅក្នុងផ្លូវកោតគោរព (ជាបងប្អូននឹងគ្នា) តែសាវ័ករបស់លទ្ធិផ្សេង ៗ ដែលនឹងបដិបត្តិត្រង់តាមពាក្យប្រដៅនោះមានតិចណាស់ សូម្បីតែក្នុងលទ្ធិជាមួយគ្នា ក៏នៅមានផ្សេងពួកផ្សេងគណៈ ក្នុងគណៈនីមួយ ៗ ក៏នៅរកពន្ទោសរូសគណៈដទៃ ៗ តទៅទៀត តែងមានប្រកែកជាញយ ៗ ថា បើគណៈឯណាប្រៀបរបនឹងដំណើរសេចក្ដី

---

១ ក្នុងការដែលគ្រិស្តសាសនាបែកគ្នា មាននិកាយប្រូតិស្តង់តំឡើង មានកើតសង្គ្រាមសាមសិបឆ្នាំ ដោយហេតុមិនចុះសម្រុងគ្នាក្នុងរឿងសាសនា ពួកអ្នកបួសនឹងពួកអ្នកសទ្ធាមាំក្នុងសាសនានិកាយទ្វេ: ត្រូវបង្ខាប់ឲ្យប្រែចិត្ត ត្រូវផ្ដន្ទា ត្រូវដុតទាំងរស់ ជិតតែគ្រប់ប្រទេសក្នុងអ៊ឺរ៉ុបចលាចលដោយរឿងនេះ ។

សុចរិតស្អាតត្រង់ ហើយនឹងមានទឹកចិត្តទូលាយ កាលនោះឯងគេនឹងត្រូវទទួលគ្រោះដូចយ៉ាងសោក្រទីសដែលបានទទួលមកហើយ ។

ប្រវត្តិសាស្ត្របានសំដែងសេចក្តីពិត យ៉ាងឥតទីសង្ស័យសូម្បីបន្តិចបន្តួចឡើយថា សាសនា (ដែលជឿក្នុងព្រះជាម្ចាស់) នឹងនិកាយទាំងឡាយមានតែនាំឲ្យកើតបែកខ្ញែកពួកគណៈការឈ្លោះវិវាទ សេចក្តីចលាចលយ៉ាងធំទូទៅក្នុងលោក រាប់តាំងអំពីសម័យដំបូង ៗ មកតែម្តង ក្នុងសាសនានីមួយ ៗ ក្នុងនិកាយនីមួយ ៗ ដែលមានគោលដើមរួមជាមួយគ្នា (គឺប៉ុនប៉ងកំចាត់ទុក្ខ) តែគ្មានគោលដ៏ពិតប្រាកដនោះនៅក្នុងចិត្តសូម្បីបន្តិចឡើយ គង់មិនមានអ្នកណាក្បែរនៅឡើយ ត្រង់ពាក្យដែលថា "សាលាព្រះ" ដែលតាំងឡើងសម្រាប់វិនិច្ឆ័យប្តូរលាយសេចក្តីយល់ឃើញដែលផ្ទុយគ្នានឹងសេចក្តីជឿរបស់គ្រិស្តសាសនា និកាយរ៉ូម៉ង់កាថូលិកនោះ ទើបតែនឹងលើកលែងបង់ប្រមាណ ១០០ ឆ្នាំមកនេះឯង ដោយហេតុមានហេតុការណ៍ដទៃមកបង្គាប់ ។

១នេះគង់ជាការឲ្យហេតុផលយ៉ាងវិលវល់ទៅមក សឹងត្រូវនឹងពាក្យដែលយើងពោលថា លទ្ធិសាសនាផ្សេង ៗ ជាហេតុឲ្យកើតសេចក្តីទុក្ខសេចក្តីធំពាក់ស្អកស្អាញជាច្រើនដល់ពពួកមនុស្សមែន ៗ ទាល់តែមានពាក្យសំអាងថា បើគ្មានសេចក្តីទុក្ខស្អកស្អាញក្នុងលោកនេះទេ, សេចក្តីគិតសេចក្តីឃើញដោយរឿងព្រះជាម្ចាស់ ក៏គង់មិនបង្កើតឡើង កាល

បើដូច្នេះ លទ្ធិសាសនាដែលជឿក្នុងព្រះជាម្ចាស់ ក៏គង់ជាគ្មានពិត ដែលកើតជាមានថាឡើង ព្រោះមនុស្សជាតិកាលមិនទាន់បានសិក្សាជាមុតមាំ ហើយមានចំណេះវិជ្ជានោះនៅក្នុងថ្នាក់ទាបនៅឡើយ លទ្ធិសេចក្ដីជឿក្នុងព្រះជាម្ចាស់អំបាលនេះទើបគង់មាននៅបាន ព្រោះថា បើនិយាយគ្នាតាមពិតហើយ សេចក្ដីគិតទឹកក្នុងរឿងដែលថា "សភាវធម៌ទាំងពួងគ្មានសេចក្ដីកើតនៅដ៏ពិតប្រាកដ (អនត្តា)" នោះជាសេចក្ដីគិតដែលផុតអំណាច សេចក្ដីដឹងយល់របស់មនុស្សធម្មតាទៅហើយ ព្រោះធម្មតាអ្នកគិតគេរមែងដឹងថា "ខ្លួនគេមាន" គេទើបមិនអាចនឹងចាប់សេចក្ដីគិតឃើញខ្ពស់ជាងនោះទៅថា "ខ្លួនគេគ្មាន" ហេតុនោះលទ្ធិសាសនាដូចដែលពោលមកខាងលើនេះ ទើបចាត់ជាលទ្ធិសាសនាដ៏ទន់ទាបនៅឡើយ ។

ទោះបីដូចម្ដេចក្ដី ក្នុងមិនយូរនេះឯង យើងនឹងឃើញថា មនុស្សទោះមានសេចក្ដីទុក្ខយ៉ាងឯណា នីមួយ ក៏មិនបាច់ចាំមានសេចក្ដីគិតឃើញក្នុងរឿងព្រះជាម្ចាស់នឹងកើតអំពីហេតុនោះ ថាបើសេចក្ដីគិតដូច្នោះកើតឡើង វាក៏គង់ចូលក្នុងបទភាសិតដ៏ល្បីកេរ្តិ៍ឈ្មោះរបស់លោកទុងដូ ដែលថា ចូរថ្វាយបង្គំព្រះជាម្ចាស់ ហាក់ដូចជាមានព្រះជាម្ចាស់នៅចំពោះមុខ ការដែលនឹងជឿរឿងព្រះជាម្ចាស់នឹងកើតឡើងឬទេនោះ រមែងស្រេចហើយតែភូមិនៃសីលធម៌ នឹងសេចក្ដីជ្រួតជ្រាបរបស់បុគ្គល សេចក្ដីរស់

នៅ ការសិក្សា សេចក្ដីរៀបរយក្នុងចំណែកនៃសេចក្ដីប្រព្រឹត្ត ទាំងអធ្យាស្រ័យចិត្តថ្លើមសុភាពមុតដេបខាត ផ្ចិតផ្ចង់ របស់មនុស្សនេះរឹតតែខ្ពស់ឡើង ៗ ម្ល៉ោះហើយសេចក្ដីជឿរឿងព្រះម្ចាស់សួគ៌ ក៏ថយតិចចុះដោយលំដាប់ គួរឲ្យយើងសង្កេតដឹងថា វិទ្យាសាស្ត្រនោះនៅក្នុងឋានដែលកប់ថា "ធ្លាត" ព្រោះថា វិទ្យាសាស្ត្រមិនខ្វាស់តែត្រូវខ្ទងឯង ក្នុងផ្លូវឯណានីមួយ ក្នុងការដែលនឹងពិចារណារឿងព្រះជាម្ចាស់នេះ បានវិនិច្ឆ័យទុកជាកណ្ដាល ៗ ដូចយ៉ាងក្ដីរឿងខ្វះក្នុងសាលាយុត្តិធម៌នៃពួកសកខ · គឺនឹងទទួលថា "បាទ" ក៏មិនទទួល នឹងបដិសេធថា មិនមែនក៏មិនបដិសេធ តែថា "ជារឿងដែលមិនទាន់បានពិសោធ" កាលបើដូច្នោះ បញ្ហារឿងលទ្ធិសាសនាគង់មាននៅដូច្នេះ លទ្ធិសាសនាទាំងអស់សុទ្ធសឹងតែផ្ចិតផ្ចង់សំដៅទៅត្រង់ សន្តិសុខ តែតាមដែលប្រាកដមកដកបដល់ឥឡូវនេះ លទ្ធិសាសនាអំបាលនោះឲ្យផលក្រាស់តែការសង្គ្រាម និងការប្រជែងប្រឆាំងដណ្ដើមមុខគ្នាប៉ុណ្ណោះ ព្រោះហេតុនេះ ក្នុងទីបំផុត មហាជនអ្នកចូលចិត្តគិត (មិនសូវប្រាកដឈ្មោះក្នុងប្រវត្តិសាស្ត្រ) ទើបនាំគ្នាធ្វើសេចក្ដីយល់បួលចិត្តថា "មិនត្រឹមតែថាយើងមិនបាច់តោងមានសាសនាប៉ុណ្ណោះ គេអាចថា សាសនា ទាំងលទ្ធិសេចក្ដីជឿបែបនោះ ជាហេតុអន្តរាយនៃសេចក្ដីចំរើនរបស់លោកទៀតផង" ៗ

ទោះបីដូចម្ដេចក្ដី ក្នុងសម័យនេះមើលទៅព្រះជាម្ចាស់ នៅជារបស់ដែលត្រូវការនៅឡើយដោយច្រើន ដោយទាក់ទាម ដោយហេតុផលដូចពោលៈហើយខាងដើមអ្នកដែលមានភូមិនៃសេចក្ដីចេះដឹង សេចក្ដីយល់ផុតពីជាន់នោះ (ជាន់ដែលរកបានព្រះម្ចាស់សួគ៌) ទៅហើយនោះ មានចំនួនតិច ហើយពួកនេះឯង ដែលត្រូវពួកដែលកាន់លទ្ធិសាសនាព្រះជាម្ចាស់ ឲ្យឈ្មោះថា អធីអ៊ីសត៍នឹងពួកអេរ៉េទិក (គឺពួកដែលមិនជឿថា ព្រះជាម្ចាស់មាន នឹងពួកក្រៅត្រូ មិនជឿពាក្យប្រដៅរបស់ព្រះជាម្ចាស់) ។

តែបើយើងពិចារណាត្រិះរិះក្នុងរឿងនេះយ៉ាងស្រួម នឹងធ្វើសេចក្ដីកត់សំគាល់ទុកក្នុងចិត្តដល់ខសេចក្ដីផ្សេង ៗ ដែលពោលមកហើយខាងដើម ៗ នោះ យើងយល់ថា ចិត្តរបស់លោកទាំងឡាយគង់យល់ព្រមចុះសម្រុងនឹងយើងគ្រប់យ៉ាងថា អត្ថិមតិដែលបានពោលទុកថា "អំណាចរបស់សាសនាផ្សេង ៗ កឲ្យកើតសេចក្ដីមិនស្ងប់" នោះជាអត្ថិមតិដ៏ត្រឹមត្រូវ ។

មុនដែលយើងនឹងមកដល់ផលលេក្ខរបស់បញ្ហាដ៏ស្មុកស្មាញនេះ យើងនឹងលើកយកសុន្ទរកថារបស់សមាជិកនៃវិហារសេនត៍ផល់ នៅឡុង-ដុន បានពោលទុកជាច្រើនឆ្នាំមកហើយ សមាជិកនេះ គឺលោកកៃណនសកត ហលលៃនត៍ បាននិយាយតែនឹងសមាជិកពួក ដែលនិយម

កប់អានលទ្ធិជាមួយគ្នានឹងលោកប៉ុណ្ណោះ តែសំដីរបស់លោកអាចប្រើនិយាយបាននឹងពួកសាវកអ្នកលះបង់ចោលនូវលទ្ធិរបស់ខ្លួន ព្រោះហេតុផលដូចពោលហើយផងដែរ សំដីរបស់លោកមានសេចក្ដីដូច្នេះ ពួក អែកណោសទិក (ពួកមិនទទួលកប់អានថាព្រះជាម្ចាស់ជារបស់ដែលពិសោធ្យបានកាន់ថា សេចក្ដីមាននៅកើតនៅរបស់ព្រះជាម្ចាស់ ឬរបស់អ្វីដែលផុតអំពីធម្មជាតិវត្ថុ ជារបស់ដែលគ្មានអ្នកណាអាចនឹងដឹងបាន) មិនមែនជាក្មេងដែលប្រឆេងប្រឆាំងផ្ដេសផ្ដាស ដែលនឹងមកធ្វើការទទឹងទាស់ពាក្យប្រដៅដោយសេចក្ដីល្ងីល្ងើ យ៉ាងឯណានីមួយឡើយ គេជាបុរសដ៏ប្រកបដោយសេចក្ដីខ្ជាប់ខ្ជួន នឹងមានសេចក្ដីពិចារណាពិនិត្យយ៉ាងសុខុម ជាអ្នកប្រើតុល្យពិនិត្យជ្រៀងផ្ទាត់ត្រួតត្រា ហ៊ានផ្ដាញ់នឹងរបស់ដែលគេចូលចិត្តថាជាសេចក្ដីពិតនោះ ដោយមិនបាច់ដញ្ជឹងដល់សេចក្ដីទុក្ខនឹងសេចក្ដីខូចខាតដែលគេត្រូវបានទទួល រហូតដល់ទៅហ៊ានប្រកាសចេញខ្លាំងៗមកថា ខ្ញុំមិនមែនជាប៉ែកបក្ខនៃពួកនេះ ខ្ញុំទើបមានចំណែកការគ្រងជីវិតតាមប្រជាគមពួកនេះមិនបាន ដូច្នេះ បើយើងសំឡឹងមើលមនុស្សដូច្នោះ ក៏អាចនឹងសង្កេតបទដ្ឋាននៃសេចក្ដីប្រព្រឹត្ត ដ៏នាំគេទៅជួប អ្នកប្រទានសេចក្ដីផុតទុក្ខ សម្រាប់ខ្លួនគេបានយ៉ាងបរិបូណ៌ គេបានសំដែងខ្លួននឹងបើកអធ្យាស្រ័យដែលប្រសើរមែនៗឲ្យប្រាកដចេញមក ទើបចាត់ថា គេជាអ្នកបរិសុទ្ធសុភាពល្អ មិនឃើញ

តែដល់ខ្លួន បុរសដូច្នោះគេអាចនិយាយអ្វី ៗ តាមដែលគេគាប់ចិត្ត តែថា អ្នកប្រទានសេចក្ដីផុតទុក្ខរបស់គេមិនបានសំដែងដំណឹងទុកជាមុនឲ្យគេដឹងប៉ុណ្ណោះ មនុស្សបែបនេះមានជាច្រើនក្នុងកាលឥឡូវនេះ និងមានទៀតច្រើនទៅក្នុងអនាគត ដែលកំពុងតែដើរចេញអំពីសេចក្ដីពិតដូចគេនោះ ៗ

ឥឡូវនេះ សុំឲ្យយើងរកផលលព្ធឲ្យដល់បញ្ហាដ៏ស្មុគស្មាញរបស់យើងនេះ, មុនយើងនឹងថា ផលលព្ធនេះត្រឹមត្រូវពិតប្រាកដ, ដំបូងយើងត្រូវរកគំនិតខុសដែលគិតទកឃើញក្នុងរឿងព្រះជាម្ចាស់ ឲ្យបានជាមុនសិន យើងត្រូវដញ្ជឹងត្រិះរិះឲ្យល្អថា កាលពីយូរឆ្នាំមកហើយ មានអ្នកណាបានអធិប្បាយដល់សេចក្ដីឆ្លាយកំហុសនេះខ្លះហើយឬទេ យើងត្រូវពិចារណារកសេចក្ដីពិត, គួរឃើញផលលព្ធដែលព្រះពុទ្ធអង្គបានប្រកាសដោយព្រះពុទ្ធដីកានេះ "ម្នាលភិក្ខុទាំងឡាយ យើងប្រដៅធម៌ដល់អ្នកទាំងឡាយ ក៏ដើម្បីជាឧបករណ៍ជួយពួកអ្នកឲ្យឆ្លងផុតសង្សារទុក្ខ មិនមែនឲ្យអ្នកឱបក្រសោបយកទុកជារបស់ខ្លួន" ៗ

ត្រង់នេះហើយ យើងអាចនឹងឃើញខ្លះនៃគំនិតវិបល្លាសក្នុងលទ្ធិសាសនានោះ ៗ បានតែម្ដង គឺកាលដែលជឿកាន់ក្នុងលទ្ធិឯណា ៗ ក្នុងសម័យណា ៗ ក៏ដោយ មកប្ដេជ្ញាខ្លួនថា ខ្ញុំជាបក្ខពួកខាងសាសនា ១ យ៉ាងឬថា លទ្ធិសាសនារបស់ខ្ញុំយ៉ាងនោះ ៗ កាលសេចក្ដីញែកប្រភេទថា

'យើង' ថា 'ខ្ញុំ' កើតឡើងហើយ, លំដាប់នោះសេចក្ដីប្រជែងប្រណាំងគ្នា, សេចក្ដីដណ្ដើមយកឈ្នះគ្នា, សេចក្ដីបែកពួកគណៈ, សេចក្ដីខូចខាតបាត់គុណសារប្រយោជន៍នៃការគ្រងជីវិតយ៉ាងខ្ពស់តាមលទ្ធិរបស់ខ្លួន ក៏តោងកើតឡើងដែរ ។

កាលណាគេមកគិតឃើញថា "របស់យើងក៏ជារបស់យើង" "របស់គេក៏ជារបស់គេ" រួចក៏ក្លាយជារបស់យើងល្អជាងរបស់គេ" កើតឡើងរួបរិតសន្ដានចិត្តអ្នកកាន់លទ្ធិសាសនាឯណាទីមួយហើយ កាលនោះ សេចក្ដីសុខក្នុងអនាគតក៏នឹងរលាយសូន្យ ត្រឡប់ជាមានការឈ្លោះវិវាទគ្នាឡើងជំនួស សេចក្ដីបង្អៀតបង្អល់ស្មុគស្មាញក៏កើតឡើងតាមគ្នាមកដោយលំដាប់ អំពីនោះលទ្ធិសាសនាក៏ធ្លាក់ទៅក្នុងឋានៈថោកទាប ដូចគ្នានឹងរឿងប្រាក់ គឺគេចូលចិត្តថា លទ្ធិសាសនានឹងប្រាក់នោះសឹងមានទីបំផុតដោយសព្វខ្លួន ឬសេចក្ដីបំណងដ៏ជាផលបំផុតនៅក្នុងខ្លួនវាឯង ប្រាក់មិនមែនជាទ្រព្យពេញទី តែថាជារបស់សម្រាប់ប្រើផ្លាស់ប្ដូរ; លទ្ធិសាសនាមិនមែនថាជាផលបំណងចុងបំផុតត្រឹមនោះ តែថាជាបច្ច័យ ឬជាផ្លូវឲ្យលុះដល់ផលដ៏ជាសេចក្ដីបំណងចុងបំផុត មុខគួរឲ្យអាណោចណាស់ ដែលលោកសឹងមានចំនួនជាច្រើនមកក្រេបសេចក្ដីពិតខនេះសោះតែម្ដង អំពល់ទៅឱបក្រសោបយកចំណែកដែលជាក្ដីអន្តរាយមកជំនួសវិញ ។

ព្រះធម៌ជាគ្រឿងសម្រាប់យើងប្រើឆ្លងសមុទ្រទុក្ខ ក្នុងកាលណាព្រះធម៌គឺពាក្យប្រដៅក្លាយទៅជាសម្បត្តិដ៏មានម្ចាស់ ក្នុងកាលណាពាក្យប្រដៅបានក្លាយមកនៅត្រឹមជារឿងនៃសេចក្ដីជឿពប់គាន ដំនួសជារឿងរបស់ការធ្វើ កាលណាយើងមកអំពល់វង្វេងក្នុងពិធីដ៏មិនមានសារៈ មិនដំណើរគោដីរ: ក្នុងផ្លូវដ៏បរិសុទ្ធប្រកបដោយសារៈប្រយោជន៍ហើយ កាលនោះឯងយើងអាចថាបានថា យើងគ្រាន់តែជាម្ចាស់ធម៌ តែមិនមែនជាអ្នកប្រើធម៌ជាពាហនៈឆ្លងសមុទ្រសាគរ កាលបើដូច្នេះហើយ សាសនាក៏ឥតជំនឿអ្វីឡើយ ហើយថែមត្រឡប់ជាឧបសគ្គដ៏សំខាន់ទៅវិញទៀតផង ប្រៀបដូចពួកមនុស្សអ្នកឆ្លងទន្លេដោយក្បូន អ្នកម្នាក់ជំបូង កាលឆ្លងទៅដល់ត្រើយហើយ ក៏ច្រានចោលក្បូននោះបង់ ព្រោះប្រយោជន៍ដោយការប្រើក្បូននោះបានសម្រេចដល់ទីបំផុតហើយ អំពីនោះគេក៏ជាឥស្សរៈតាមទំនើងចិត្ត ឡើងដើរទៅតាមថ្នល់ដោយស្រួកន់ទាល់តែផុតកន្ទុយភ្នែកទៅ ចំណែកឯអ្នកផ្សេង ៗ មិនដូច្នោះ កាលឡើងលើក្បូនហើយក៏គិតថា ក្បូនរបស់យើងល្អអ្វីមាល្បាយ ម្នាក់ទៀតក៏និយាយខ្លាំង ៗ មកថា ក្បូនរបស់អ្នកនោះមុខគួរឲ្យវេទនាណាស់ ជំនួសដែលនឹងឡើងដើរទៅកាន់ទីបំណងដោយស្រួកន់ ក៏អំពល់បែរមកប្រកែកគ្នាដោយរឿង របស់យើងល្អ របស់យើងល្អជាងរបស់អ្នក របស់យើងល្អបំផុត ។ល។ ក្នុងទីបំផុតពាក្យអំពាលនោះបណ្ដាលទៅជាឈ្លូន នាំ

ឲ្យឈ្មោះវិវាទគ្នារហូតដល់ទៅវាយដំកាប់សម្លាប់គ្នាជាទីបំផុត សូម្បីក្បួនរបស់ខ្លួនក៏យកមកប្រើជំនួសអាវុធប្រហារគ្នា បាក់បែកវិនាសអស់ទៅដោយហេតុជំលោះនោះឯង ព្រោះហេតុនោះ ការធ្វើដូច្នេះជាសេចក្ដីខុសដ៏សំខាន់យើងរមែងឃើញផលនៃសេចក្ដីខុសដូច្នេះគ្រប់ៗទិស និតតែទាំងអស់ក្នុងខេត្រខណ្ឌនៃលោក ឯសេចក្ដីបំណងល្អតែហាក់ទាក់ទាមដោយសេចក្ដីកំហុសរបស់លទ្ធិសាសនាសិនមានទៅ ដោយប្រការដូចពោលនោះ តាមដែលប្រព្រឹត្តមកហើយ រមែងមិននាំទៅកាន់សេចក្ដីល្អប៉ុន្មានក្រៅពីការជំលោះគ្នាយ៉ាងធំ ។

នេះឯង គឺបញ្ហាស្មុគស្មាញក្នុងសាសនា ឥឡូវនេះយើងអាចនឹងឈានទៅកាន់ថ្នល់ខ្ពស់ ឬខាងមុខ ដោយឧបាយដូចម្ដេចបានឬទេ ? តាមពាក្យដែលមានតខាងក្រោមនេះ ឃើញថា ងាយជាបំផុត សមគួរសាវករបស់លទ្ធិសាសនានោះៗ នឹងបដិបត្តិតាមបាន ព្រោះមិនចាំបាច់នឹងប្រែប្រួលលទ្ធិរបស់ខ្លួន សូម្បីបន្តិចឡើយ គឺតបថា "មុនបង្អស់យើងតោងជាអ្នកផុតចាកប្រាថ្នា ចង់បានក្នុងផ្លូវលោកិយ តោងកំចាត់កិលេសគ្រឿងសៅហ្មងចិត្ត ទឹងសេចក្ដីលោភគ្មានទីបំផុត ដ៏ជាឫសគល់របស់សេចក្ដីទុក្ខសោកទាំងពួងបង់" មូលដ្ឋាននៃពាក្យប្រដៅក្នុងសាសនាទាំងពួង ជារបស់ងាយៗ ដូច្នេះមិនមែនមានផ្លូវយ៉ាងដទៃទៀតទេ ។

ទោះបីលោក-អ្នកនឹងសាងរូបបដិមាករឿងៗ តាមដែលលោក-អ្នកគាប់ចិត្ត ទុកជំនួសពាក្យប្រដៅរបស់អ្នករំដោះខ្លួន ឬអ្នកនាំផ្លូវរបស់លោក-អ្នក; ប្រដាប់ពាក្យប្រដៅដ៏ឆ្ងាយៗ នោះដោយពិធីដ៏ឧឡារិកផ្សេងៗ; អុជធូប ដុតគ្រឿងក្រអូប និងអុជប្រទីបតាមគ្រឿងយ៉ាងព្រេងព្រាយ, ឬនឹងធ្វើតាមពិធីដ្រូអ៊ិត *druid* អាសតិក *astec* ពុរីតាន *Puritan* ឬហោលីឈើដក៏ដោយ អំពើអំពាលនោះទាំងអស់ សុទ្ធសឹងតែបានផលដូចៗគ្នា គឺជាការធ្វើដូចគ្នានឹងការលេងណាំងតលុង ឬយ៉ាងល្បែងក្មេងលេងនោះឯង ។

ផ្លូវដ៏ត្រង់ដែលក្រៅអំពីនេះមិនធ្លាប់មានមកអំពីមុន, និងមិនមានសម្បីទៅក្នុងអនាគត, មិនអាចនឹងមានបានសោះឡើយ គ្មានអ្នកជួយធ្វើ ជួយបដិបត្តិឲ្យយើងបានសោះឡើយ លោក-អ្នកនឹងកាន់យកអ្នកណាជាសាស្តារបស់ខ្លួនក៏ដោយ សាស្តានោះអាចតែត្រឹមសំដែងផ្លូវឲ្យលោក-អ្នកប៉ុណ្ណោះ ការបំពេញសេចក្តីប្រព្រឹត្តបដិបត្តិរបស់យើងឲ្យផ្ចិតផ្ចង់វិសេសឡើង ជារបស់សំខាន់ ហើយតែ ១ យ៉ាងប៉ុណ្ណោះដែលយើងត្រូវធ្វើពីដំបូងគឺ យើងត្រូវជំរះចក្ខុរបស់យើងឲ្យជ្រះថ្លា ។

ពាក្យប្រដៅដូច្នេះ មិនមែនថាជាពាក្យប្រដៅដែលបដិបត្តិតាមមិនបាន ជាពាក្យប្រដៅដែលមានអ្នកខ្លះគេបដិបត្តិបានមកហើយ ទាំងជាពាក្យប្រដៅដែលអ្នកពល់គ្នា អាចបដិបត្តិបាន មិនថាអ្នកមានឬអ្នកក្រ

មិនថាគ្រហស្ថឬអ្នកបួស មិនថាស្ដេចឬកស្ត្រ សុទ្ធសឹងតែបដិបត្តិបានទាំងអស់គ្នា អ្នកបួសអាចនឹងគ្រងជីវិតរស់នៅដោយសេចក្ដីសំបូណ៌រុងរឿងជាងព្រះមហាក្សត្របាន ដូចម្ដេចមិញ, ព្រះមហាក្សត្រក៏អាចគ្រងជីពជន្មយ៉ាងឆ្ងាយ នឹងទុទ្ទថយទន់ទាបជាងអ្នកខ្ញុំរាជការរបស់ព្រះអង្គបានដូច្នេះ; សម្រាប់ស្ដេចឬអ្នកមានស្ដុកស្ដម្ភ សឹងជាអ្នកដែលភារៈផ្សេងៗមិនព្រមឲ្យគេចៀសចេញចាកជីវិតខាងប៉ែកលោកៗនេះបាន, សេចក្ដីស្ដុកស្ដាញផ្សេងៗ ចូលមកជាឧបសគ្គជំទាស់ផ្លូវរបស់គេបង់, តែសម្រាប់បុគ្គលអ្នកដែលលះសេចក្ដីសប្បាយរីករាយរបស់លោកបាន ដោយសេចក្ដីស្ម័គ្រចិត្តរបស់គេ, នោះផ្លូវរបស់គេមិនសូវជាមានអន្ទាក់នឹងរន្ធដៅបញ្ឆោតប៉ុន្មានណាស់ទេ ។

មានផ្លូវដ៏ឆ្ងាយសម្រាប់បុគ្គលដូច្នោះដែរ ព្រោះថាគោលសំខាន់សម្រាប់បុគ្គលគ្រប់រូបនឹងបដិបត្តិនោះដូចគ្នាទាំងអស់ គឺ សេចក្ដីអើពើរាក់ទាក់ដល់គ្នានឹងគ្នា, សេចក្ដីជាមិត្តភាពផងគ្នា, ការមិនប្រហារកាប់សម្លាប់គ្នា, ការមិនលួចទ្រព្យ, សេចក្ដីបរិសុទ្ធនៃវត្តាចារៈ, នឹងការធ្វើបុណ្យកុសលទាំងឡាយយ៉ាងដទៃ ៗ ទៀត អំពើអំបាលនេះឯង អាចជួយពួកយើងបានដោយពិត ។

យើងត្រូវចាំទុកជានិច្ចថា យើងអ្នកបដិបត្តិក្នុងផ្លូវដ៏ត្រឹមត្រូវនេះដើម្បីរបស់ ១ យ៉ាងប៉ុណ្ណោះ មិនមែនពីព្រោះថា យើងជាម្ចាស់លទ្ធិ

សាសនា ពុទ្ធសាសនាជាម្ចាស់របស់ខ្លួនយើង មិនមែនព្រោះជាសេចក្ដីពិតដែលអ្នកវិសេសបើកបង្ហើបបង្ហាញឲ្យ, ទឹងមិនមែនព្រះជាម្ចាស់អង្គឯណាទីមួយ ត្រូវប៉ុនប៉ងដើម្បីរបស់ ១ មុខប៉ុណ្ណោះ មិនចាំបាច់ស្វែងរកបំណាច់ផ្ទាន់យ៉ាងដទៃទៀត អំពីសេចក្ដីល្អដែលយើងប្រព្រឹត្តនោះប៉ុណ្ណោះក៏មានសេចក្ដីយុត្តិធម៌ក្នុងខ្លួនស្រាប់ហើយ, ព្រោះសេចក្ដីពិតខនេះដែលថា បណ្ដាមនុស្ស-សត្វ បុសត្វតែទាំងពួងដូចគ្នាទាំងអស់ ជាសេចក្ដីពិតដែលបានពិសោធរួចហើយ ជាការពិសោធដែលប្រព្រឹត្តទៅដើម្បីការលឿនថ្នាក់របស់មនុស្សជាតិឲ្យល្អវិសេសឡើង ទឹងប្រព្រឹត្តទៅដើម្បីប្រយោជន៍ជ្រោមផែនលោក គ្មានផលឯណាប្រាសចាកហេតុដែលកើតមកមុន, ព្រោះហេតុនោះ ចូរដំណើរជីវិតយ៉ាងប្រសើរ, ចូរធ្វើសេចក្ដីល្អដល់មនុស្សជាតិរាល់រូប, កុំប្រទុស្តរាយដល់សត្វតូចសត្វធំរហូតដល់សត្វមានពិសកំណាចទាំងពួង ព្រោះសត្វអំបាលនោះ ទោះជាមនុស្សក្ដី ជាទេវតាក្ដី សឹងត្រូវធម្មតាសាងឡើងដោយហេតុជាមួយគ្នា ព្រោះហេតុនោះ ចូរបដិបត្តិតាមច្បាប់ងាយៗ អំបាលនេះ ។

"សូមសាន្តិសុខចូរមានដល់សព្វសត្វសម្លាយ សត្វទាំងឡាយចូរបានសោយសាន្តិសុខចុះ" ផ្លូវដទៃក្រៅអំពីនេះ គ្មានទៀតទេ កុំអំពល់ទៅស្វែងរកឡើយ ។

ចាតុរង្គបទ បទទី ២

របស់ព្រះមហាពិទូរ ក្រសេម គន្ថរចនបណ្ឌិត

រៀបរៀង (ត)

# សមត្ថភាពនឹងជីវិតសម្បត្តិផ្សេងគ្នា

បានពោលមកហើយ ជីវិតសម្បត្តិនឹងសមត្ថភាពតែងអាស្រ័យគ្នានូវគ្នា តែមិនគួរនឹងចូលចិត្តថា មានសេចក្តីដូចគ្នា ៗ អាការដែលដៃលើកដាក់អ្វីបាន ភ្នែកឃើញរូប ត្រចៀកស្តាប់សំឡេងដូច្នោះជាដើម ដែលប្រព្រឹត្តទៅតាមហេតុរបស់ខ្លួនឯងដោយធម្មតា ឈ្មោះថា ជីវិតសម្បត្តិ មិនមែនសមត្ថភាព ៗ អាការដែលអាស្រ័យធម្មតានោះឯង គិតប្រកបធ្វើករណីយកិច្ចផ្សេង ៗ ឲ្យសម្រេចផលដែលល្អតាមត្រូវការ ឈ្មោះថា សមត្ថភាព តួយ៉ាងដែលនឹងលើកឲ្យឃើញ ដូចយ៉ាងដៃសម្រាប់ប្រើលើកដាក់អ្វីៗបានតាមធម្មតា កាលមានសេចក្តីចេះដឹងឡើង អាចប្រើសរសេរអក្សរក៏បាន ប្រើធ្វើការឯទៀតៗ ដែលទាក់ទាមដោយដៃក៏បាន ៗ ភ្នែកមានមុខការសម្រាប់មើលរូប ដែលមិនហួសវិស័យរបស់ភ្នែក កាលមានសេចក្តីចេះដឹងឡើង អាចនឹងធ្វើកែវឆ្លុះពង្រីកសម្រាប់ប្រើឆ្លុះមើលរូបដែលល្អិត សូម្បីហួសវិស័យភ្នែកទទេក៏បាន ត្រចៀកមានមុខការសម្រាប់ស្តាប់សំឡេង ដែលមិនហួសវិស័យរបស់ត្រចៀក លុះមានសេចក្តីចេះដឹងឡើង ក៏អាចនាំយកធាតុមកផ្សំបញ្ចូលគ្នា គិតបាត់ធ្វើវត្ថុផ្សេង ៗ ដូចយ៉ាងវិទ្យុជាដើម សម្រេចជាគ្រឿងកំចាយសំឡេងឲ្យបានឮទៅក្នុងទីឆ្ងាយ ៗ ខុសនឹងសំឡេងប្រក្រតីក៏បាន រហូតដល់ទៅចេះគិតធ្វើគ្រឿង ស្លៀកដណ្តប់ អាហារ ទីលំនៅ យានពាហន

ជាគ្រឿងបង្ហាញផ្លូវឆ្ងាយឲ្យដើរបាន ឲ្យសេចក្ដីស្រួលដល់អ្នកទៅមក ជាអាទិ ៗ

## សេចក្ដីបំណងនៃសមត្ថភាព

សម្មត្ថភាពនោះ ដោយសេចក្ដីក៏គឺ សេចក្ដីជាអ្នកអាចក្នុងករណីយកិច្ចតូចធំទាំងពួង គឺប្រកបដោយសេចក្ដីពិចារណា ស្ទង់មើលដោយឧបាយដ៏លៃបខាយ ហើយទើបចាត់ធ្វើដំណើរកិច្ចានុកិច្ចនោះ ៗ ឲ្យផុះផាលជាផលល្អ តាមដែលត្រូវការរបស់ខ្លួន របស់អ្នកដទៃរហូតដល់ទៅជាតិសាសនា ព្រះមហាក្សត្រិយ៍ ស្រុកទេសរបស់ខ្លួន ៗ បើនឹងពោលជាបុគ្គលាធិដ្ឋាន គួរលើកយកព្រះអានន្ទត្ថេរជាឧទាហរណ៍ មានរឿងដំណាលថា លោកបានគិតធ្វើតួយ៉ាងចីវរឡើង ត្រូវតាមព្រះបរមពុទ្ធាធិប្បាយ ហើយបានសេចក្ដីសរសើរអំពីព្រះបរមសាស្ដា, ចាប់ដើមអំពីនោះមក ព្រះអង្គបានទ្រង់អនុញ្ញាតត្រៃចីវរ គឺ សំឃាដិ ឧត្តរាសង្គ អន្តរវាសក ជាសំពត់កាត់តាមសណ្ឋាននោះ ឲ្យព្រះភិក្ខុសង្ឃប្រើដរាបមកដល់ឥឡូវនេះ នេះជាឧទាហរណ៍នៃសមត្ថភាពដោយឯកទេស ទោះនឹងលើកយកបុគ្គលដទៃ ៗ មកជាឧទាហរណ៍ ក៏គប្បីធៀបដោយន័យនេះ ៗ

គុណ៖នេះកាលមាននៅក្នុងបុគ្គលឯណា រមែងធ្វើបុគ្គលនោះឲ្យឧស្សាហ៍ខ្មីឃ្មាតអត់ធន់ ធ្ងន់ មិនស្រើបស្រាលហៅហាវ អង់អាច ក្លា

ហាន មិនខ្ជិលច្រអូសរួញរាក្នុងករណីយកិច្ចតូចធំទាំងពួង អាចញ៉ាំងកិច្ចការនោះៗ ឲ្យសម្រេចស្រេចទៅបាន ដោយមិនទើសទាក់ជំពាក់រីមរាម ឬស្រួបស្រែងក្នុងកិច្ចនោះ; ហេតុនោះ សមត្ថភាព ទើបជាគុណត្រូវតែប្រាថ្នាទាំងក្នុងផ្លូវលោក ទាំងក្នុងផ្លូវធម៌, បើមានសមត្ថភាពហើយ ខ្លាច ថ្វីរឿងការធ្ងន់ កុំថាតែធ្ងន់ម្យ៉ាងឡើយ ទោះក្រិក្រលំបាកយ៉ាងណា ក៏គង់មិនផុតវិស័យសមត្ថភាពទៅបាន គង់អាចពត់ធ្វើឲ្យសម្រេច រួមយកសេចក្ដីជ័យជំនះមកទុកក្នុងកណ្ដាប់ដៃពាល់តែបានជាប្រាកដ, តែសមត្ថភាពនេះមានសេចក្ដីទូលាយណាស់ ទើបគួររួបរួមកំណត់ទុក ឲ្យនៅក្នុងវង្វង់តាមដែលត្រូវការដូច្នេះ :

១ អាចសមតាមអត្តភាព

២ អាចសមតាម ដំណែងមុខការ

៣ អាចសមតាមពួកគណៈ

៤ អាចសមតាមធម៌ ៗ



ឧត្តរ
បស្ចិម
បូព៌
ទក្សិណា
០ ១ ២ ៣ ៤ ៥




ឧត្តរ
បស្ចិម
បូព៌ា
ទក្សិណា

សៃ១៤

(១) អ្នកម្ចាស់យ៉ារាជព្រះធម្មខេតជ្វយអ (២) នុមោន្ទាជាពេជញាន (៣) អ្នកម្ចាស់យ៉ារាជ្ជព្រះស្មេត្តជ្វយអនមោន្ទា (៤) សព្ទមស្តុ ១៤៨៨ សកខាលអ្នក្សត្របុរមី (៥) កេតខែហមាគ្គិសីរ ព្រហស្បតីពារ មគ្គិ (៦) អកហ្វាងអកែយរាជនុអ្នកអកធម្មិមា (៧) នបិត្រស់ទ្ធាសាងព្រះវិហារស្បាតនោះ (៨) អំពីឆ្នាំមហោះកាលអកញាឱង លុះត (៩) លឆ្នាមខាលអ្នកព្រះឱង្ការត្រីត្រីនីញ៉ (១០) នទេព្វស្រែប គាតលកខ្វណាទាងផ្តីយ (១១) ប្រពន្ធជាសុពណ្ណាវីលេប្បបីតព្រះអងអ (១២) ដ្ឋារស្ស នុព្រះប្ញហព្រះអង្គ៥ ព្រះមាស ១ (១៣) ព្រះប្រាក ១ សាងព្រះបៃយតីយព្រះស្រីយ (១៤) ម្ហាពោធី សាងព្រះអភិធម្ម ម្ហាជាតប (១៥) ប្បសុរេបទេព្វបញ្ចុះសេមាបប្វសអា (១៦) គ្នាសទ្ធាយោកទាសាទាសីខ្ញុំមគ្រីយ (១៧) ខ្ញុំមប្រុសឈ្មោះអាបាន ១ អាកែវ ១ (១៨) មេសុត ១ មេអន ១ មេគៃយ ១ មេសរ (១៩) ១ មេរស ១ មេសម ១ មេហង ១ មេគា (២០) ម ១ អាគោក ១ អា

កន ១ អាសែន (២១) អាស្រីយ ១ អាជោត ១ រីញោមទាងអំ (២២) បាលនេះស្បែងប៉ាយជាញោមព្រះពុទ្ធ (២៣) រុប្បនោរ សំមរាប្បព្រះវីហេរនេះ វិជី (២៤) ទាំង ៣ នេះគាតយោកជា ហោរអំពីយគ្រ (២៥) ហាសមោកបម្បស្បជាពណ្ណាំស្រមឱយ (២៦) នោរសំមរាប្បព្រះវីហារនេះ ឱយអ្នក (២៧) ម្ចាបេីរឱទៃយ កជាគ្រងរក្សាញោម (២៨) ទាងនេះ ទោះព្រះម្ចាបេីរឱទៃយក្ត ជា (២៩) ពុំប្ញូសសោតសំនេរទាង ៣ នេះ ទោះម្បី (៣០) សំ នេរនេះនាមួយបួសបរប្ញូរបានឱបស (៣១) ម្បាតឱយគ្រងតិស ញាតគាត (៣២) ទាងអំបាលនេះវឹងតាងព្រះម្ចា (៣៣) បេីរ ឱទៃយកជាវឹង រីបោ (៣៤) ប្ញាងវង្សាភិនេតន្ទូ (៣៥) ហោ ព្រំម្មឱយជួយ-

(១) រក្សាកុំម្បិឱយមានអ្នកនិនទាបៃ (២) តបែនវាឱយ អន្តរាយទានព្រះពុទ្ធរូព (៣) នោះលេយ ទោះប្បិមានពោងម្តុណ ក្ញូណ (៤) ក្ញូយប្រាំព្យលសន្តានកល្យានមិតស្រ (៥) លេញ មានទំនេប្បឃ្យត្រាធិរាជន្ញូរាជ (៦) ក្ញូលមន្ត្រីយបតុរងសេនាប

តិយសុភា (៧) សុហិនក្តិ ទោះប្បិគេហៅមោកអង្វ (៨) វគតិយ
ប្តេហេឱយអន្តរាយទានព្រះ (៩) ពុទ្ធនេះ អ្នកទាំងអំបាលនោះ
ឱយ (១០) ទាវនោវបតុភាបាយភ្វ (ម) គុះម្ហាអរិបិយន (១១) វក
កុំប្បិឱយព្រះពុទ្ធអំបាលខ្សែបកុំប្បិ (១២) ប្រោសអ្នកនោះបាន
លេយ តទំ មេវ ទានំ (១៣) សព្វញ្ញុតញ្ញាណ្ណំ បច្ចិវិធំ សបច្ច
យោ ហោតុ (១៤) អ្នកបោពិសតិគជ្ជ (យ) សាងស្លូមលោកសស្នា
(១៥) សព្តមាសតុ ១៥០២[៨] សក អ្នខ្សត្រនិទ្ធាមប្ចខែ (១៦)
ហបសបរមិរោបអាទិត ឱកហ្លងអភៃយរា (១៧) ជមានបិតសា
ទ្ធាំសាងប្រាសាត្រថ្ម ១ ត្រ (១៨) សែងកែងទ្វព្រះពុទ្ធរូបថ្ម
៤ ទុក្ខ ប (១៩) ញប្រាសាត្រ ពុទ្ធរូបសំរ្ឋ ១ ព្រះសម្រី (៣០)
តិ ១ ព្រះទោងតែង ១ ភិមព្រះពុទ្ធ (៣១) រូបតិ ១ ព្រះភ្លក ១
ព្រះបន ១ ព្រះមោគលានព្រះសារីបុតព្រះបទ្ធ ១ ប (៣២) ញ្ញ
បុះហព្រះទ្វាត ឱយទានបង្គន កតទង (៣៣) ប្វើឆាត ឱយទាន
បាយទឹកសំពូតមាសប្រា (៣៤) កន្ទស្លាហអំម្លូហក្រាយាបព្ច
ញេប ទ្វ (៣៥) តេជាះផលានិសងនេះប្អំរេនតិសព្ទ (៣៦) ក
ទេពតាផោងទាងហ្លាយតលេហាត (២៧) លអយនិសែព្រហ្ម

បំរេនទោរិក្ខស្បូត (២៨) ត្រធីរាជរាជកូលរាជមន្ត្រីបត (២៩) រង់សេនាបត្តីនូម្គាយអាត្ត (៣០) កនូបោងផ្ទុនកូណ ។

(១) អ្នូ (ក) ហៅរិភិក្ខុអំម អ្នកសិតជាសាក (២) សីពែជញានឱតំមជួយអនមោទ្ន (៣) កមួយប្រាមពិលសន្តានកលញាន (៤) នូមីតស្រិលេញនូអ្នកតមានគូនសប្ប (៥) រុសព្ធុពែងបញ្ញបិម ទោះអ្នកអំម្បា (៦) លនេះវង្វេងទៅព្វតបតរាបា (៧) យភូមគុះ ឱយអ្នកអំម្បាលនេះ(៨) ឱយព្រាបលៃ (ង) ភៃយបតុរាបាយ (៩) ពនរាយនូត្រិភិធសំម្បាតសម្បូររឹង (១០) ហោង នូតេជាះហាធិលាគិសង់នេះជួ (១១) ណាទោរិសតូនរកផោងទាងហ្លាយត (១២) លអរីបិនរកភូមគុះ នុតេជាះធិលាគិសង់ (១៣) នេះជូនទៅសតូនរកទាងហ្លាយតល៖ (១៤) លសហាសចក្រពាលហោង គាតសូមជាអ (១៥) បាលករតនៃយព្រះស្រិអារមៃត្រិពោធិស (១៦) ត លោកសាស្នាបិត្រសទ្វាបានបួសកានតោយ (១៧) ព្រះរីនៃយកេតទ្វេត្រិង្សម្ហាបរសលោកកុំម្បិឱយបយសំម្បាតលេយ សូមទោរិកេតអ្នក (១៩) តមានត្រ-កូល (១៨) សន្តានយសតិសូរ សូមមាន(២០)ហាត្តិរតអាជា

នៃយរត ស្ទូបកែវសព្វទីត់ (២១) វត សូមមានអាហារទិព្វ
សព្វតទិព្វព្រៃ (២២) មព្រាយ ៣ ជុំមជាយសបញ្ញតញ្ញា
(២៣) ណាំ បបេយោ ហោតុ

លេខ ៥

(១) នេះហអ្នកអកហ្លួងអប្ដេយរាជមានពាក (២) ស្យ
បាដដ្ឋា ទោះកូនអញឯងក្ដិយក្នុយ (៣) អញក្ដិទោះបោរអញជា
ព្រះសយ៏ក្ដិយ (៤) ជាគ្រហាសក្ដិ ឥសក្នុយកូនបោរទាង (៥)
នេះអញពុំមឱយតៀងលេយឱយ (៦) ពមព្វេញតួបក្រិស្នាជា
លិយតល (៧) បួលនិព្វាំនហោង ។

លេខ ៦

(១) អ្នកបោរភិក្ខុឥនជួយសាងហេយប្ហាឫក (២) ដោង
សុំបានស្មោ (យ) ទិព្វសំម្បាតហេយសុំបាន (៣) បួលនិព្វាន
ជាបនឥសហោង

៙ (៤) ស័ព្វមស្តុ ១៥២១ សក្ក កុរអ្នកខ្សត្របុរមិកេតខែ
(៥) ហមាត្យសិរព្រហស្សត្តិពារ មន្តិឱកហ្លួងអព្ដោរាជ (៦) ឆុ
អ្នកបោរភិក្ខុសរឱកបាកខារមោកនាស្នានព្រះពិស្ណុ (៧) លោក្ដ

ជាស្ថានជុំនុំមនៃយទេព្វតាមហាខេត្រ ម(៨)ហាព្រាហ្មរសិសិទ្ធិ
សក្តិនុទេព្វរក្សបិតរគណរោង (៩) ស្បៀងជុំនុំសុមុក្កតា យេងខ្ញុំម
មានបិត្តសាទ្ធាសា (១០) ងប្រាសាទ្ធប្អូនមុកនុព្រះបុំហាព្រះសំម
ឆហអទិស្ថានជា (១១) ព្រះពិស្ណុលោកសុរេបហេយទេព្វយេង
ខ្ញុំមរត្តាបក្រិយា (១២) បូជាសំរប គិបិនិមនព្រះសយ៍រោង គិអ
ស្មារសយ៍ (១៣) តទ្រេងបតុបារិសុទ្ធសិលមោកប្វេមង្គលអំ
ពលទុស (១៤) ព្យំផ្លែឈេហានុភ្ជិគន្ធក្រាយារោង តោ់យនយ
ហ៊ាសា (១៥) ស្រ្ដតេម្បិបន្ទះទោត្រព្រះញាតបិតរោងកំលុងស់
(១៦) បសន្តានទុសព្យំសត្វរោង្គលខ្លិងរោព្ទតបតុរាបា (១៧)
យភូម តោយលេហរ៉ិបតលអក្តុនិដ្ឋព្រហ្ម តោយក្រោ(១៨)មរ៉ូប
តលអរបិ តោយខាងរ៉ូបតលទសសហាស្សប្រក្រារា (១៩) ខ្ល នេះ
សផលានិសង្សនៃឱកហ្លាងអព្ទោរាជ (២០) មានកត្តុញកត្តវេទិ
ខ្ញុំមជូនកុសលផលបុន្យនេះ (២១) បំរេនអ្នករោង្គអំបាលនេះ
ទោះបិអ្នករោង្គ (២២) អំប៉ាលនេះរង្វេងទោលខ្លៀងព្ទតបិតុរា
បាយ (២៣) ភូមគុះ នោតេជះផលានិសង្សគេះស៊ូលំតោះ (២៤)
ឱយរ៉ូបលែងភៃយបតុរាបាយ ទោពន្ធរា (២៥) យព្ទត្រិពិធ

សម្បត្តសម្បូណ៌រឹង ទោះបីអ្ន (២៦) កជោង្គអំបាលនេះបាន
ស្មោះផ្ដោះទៅស្មោយទំ (២៧) ព្យសំបាតសម្បូណ៌ហើយនោ
តេជះផលានិស (២៨) ង្សនេះសុំទៅបំរេនទំព្យសម្បត្តរឹងសំ
មបូណ៌ (២៩) ពិ្យពទ្ធំមួយសារ លុះបានបួលតបទមោក្សមហោ
(៣០) នគរនិព្វានជាបនតិសហោង ០ បពិត្រនោតេ (៣១)
ជះនៃសំតេចព្រះមហាគិរត្ន ត្រៃបរមបពិត្រ នុ (៣២) តេជះ
សិទ្ធិសក្តិនៃទេព្វតាមហាខ្សេត្រដោង (៣៣) នាគ្រោងប្រនិ
ប័តព្រះសាស្នានេះ សុំជ្រោមរ័ក្សឱ (៣៤) កប្បាងអភៃវាជនេះ
សុំបំរេនព្រះពរមង្គលស្ត (៣៥) លតេមសំឫទ្ធិស្មិរទំយាយុះ
លុះតលសុក្ខសុំ (៣៦) ស្ពាធិការពិពទ្ធំមួយសារលែងបាន
បួសសំនកត (៣៧) ព្រះសាស្នាឱត្បាប្រនិបាត្តក្រិតតោយ
ព្រះបន្ទូល (៣៨) ហោង នុផលានិសង្សនេះសុំតោយនូបំន
(៣៩) ងឱកប្បាងអព្ទៃវាជហោង ឱទំសកុសលផលដោ (៤០)
ងទោគិទេព្វតាមហោខ្សេត្រនុបិត្តរគណដោង សុំ (៤១) ស្ដោះ
លែងសត្វទុក្ខសត្វសោកសត្វរោកសត្វ (១) ភៃសត្វបង្រៃសត្វ

ឱប្បទ្រព្យអន្តរាយដោយនានា (២) ប្រកាយស្ញុំបំពេនសត្វ
សុក្ខស្ញុំស្ដាធិការពិ (៣) ពន្ធ៍មួយសារឥសកាលតលុង្សហោង
ស្ញុំឈ្នះសត្វសត្រូ (៤) ដោងតសំមួទាយ ទោះបិមានរាជសត្រូ
ដោងស់ទិសបិ (៥) មានបិតគិតនុមោកបៀតបៀនកម្ពុជទេស
នេះនុ (៦) មោករំលោងសាស្នាព្រះមហាសរិកជាតុគុះ នោះតេជះ
(៧) ផលានិសង្សនេះស្ញុំទេព្វតាដោងបន្តនបិត្រាជស (៨)
ត្រូនោះកំបិឱយមោកបៀតបៀនកំម្ពុជទេស នុ (៩) ព្រះសាស្នា
ព្រះមហាសារកជាតុលេយ ស្ញុំរាស្ត្រដោ (១០) ងអំបាលកំលុង
កំម្ពុជទេសនេះនុសុក្ខឡេមខ្សា (១១) នកំបិមានបលាបល្នី
លេយ បតិទស្ញុំមធុត ៗ (១២) រោះសាធុប្រណិធាណនេះ
រោះព្រះមហាសត្វ្ជ (១៣) ពុទ្ធក្រតេងយេងសំតេបបន្ទូល
ហោង ០ (១៤) នុសំមញ្ចេតបោសព្រះអងទងធាតន្តសកុ
សលទាងអំបាល (១៥) នេះជូនទោវអ្នកឱកជារ (១៦) នេះ
អ្នកអកហ្វងអប្ថេយរាជ្ជមានញាកស្បិបាជ (១៧) ដ្ឋាទោះហ
ក្ខនអញឯងគ្គីយ ក្ខយអញគ្គិយ (១៨) ទោះហហោរអញជាព្រះ
សយ័គ្គិយជាគ្រូហ្យ (១៩) គ្គិយ ត្យូក្ខយក្ខនហោរទាងនេះអញ

ពុំឱ្យ (២០) ត្បិងលេយ ឱ្យពមពេញទាទនេះត្បូបក្រិស្នាជា (២១) លីយតលបូលនិញ៉ានហោង (២២) គ្តិនៃទេព្វតា (២៣) ព្រះសាស្នានេះសូមជ្រោមរក្សាអកហ្លួងអភៃ្យរាជ (២៤) សូមបំមរេនព្រះពរមងគលស្កុលសម្ទ្ធិស្មិរទិយា (២៥) យុះលុះ តលសុក្ខពិពទ្ធីមួយសារសូមបានបួស

លេ ១៧

(១) សព្វមសតុផៃយាសទិតិរេក ១៥៤៤ បហ ន (២) ក្សត្រ ខែភទ្របុត្រ ១៥ រោបថ្ងៃយអ (៣)....សា (៤) រទ្វាសូម លុហាប្រាទ្វនាស្មោះហបពោះហ (៥) បានទនព្រះសីអារមៃត្រីយ ពោធីសត្វ (៦) ព្រះអង្គមោកត្រាសធម្មិប្ញីសូមបានជា (៧) ព្រះពុទហោង

លេ ១៨

(១) សព្វមស្សស្តុជយ្យាតិរេក្ក ១៥៤៧ ស (២) កត្តរ អ្នក្សត្រ ខែមាឃបួនរោបអាទិត្យ (៣) ពារ ឱកហ្លួងបក្រីតគៃ្សង និមន្ត្រព្រះអ (៤) រិយសង្ឃដោងជំនុំ តបទឱក្កហ្លួងរា (៥) ជា តេជះហាបៅងឱក្កហ្លួងបក្រីតនៃ្សង (៦) ប្រោសខ្ញុំមទុំគ្រូវក្ខណា

បរិវត្ត ម្សៅកេត (៧) ក្នុងបំម្រើរាសអាពុកឈ្មោះខុណបញ្ចុងរ (៨) ទុយ ព្រពុនឈ្មោះមេអេតុក្កូណប្រុសឈ្មោះ (៩) គឺរ ១ ឈ្មោះ. .. ១ ស្រីយ ១ ឈ្មោះមេ.. (១០) .. ក្នុងបំម្រើរាស ឱយឱកហ្លួងបក្រិតស្បែ. (១១) ..ក៏ទបគ្គាមបំម្រើរាសផោង នោះខ្លាប្ប កាលនោះ (១២) តមានហ្លួកុសល ១ ហ្លួអនក្កូណ គ័តឯង ១ (១៣): ពង្សាបរទេស ១ ឱកហ្លួងរាជាអប្បការ ១ អ្ន (១៤) ក សង្ស្រើរសត្តា ១ ឱកហ្លួងពង្សាទកុល ១ ហ្លួ (១៥)..រ ១ ហ្លួប័ន្ទ្រ ១ អ្នកស្ដេចព្រះយស្សធរ ១ អ្ន (១៦) កម្លាប៉េរសរ ១ ហ្លួន្នក ១ ហោរង្ហែយ ១ ហ្លួអន (១៧) ១ ហ្លួនោក ១ ឥស្សរអ្នកទំអម្បាលនោះជាសាក្សី ឱ (១៨) ក. ហ្លួងរាជាតេជ្ជះប្រោសខ្ញុំមហ្លួងព្រះអ្នកស្ដេ (១៩) បយសឯង អំពិត្តឆ្នាំមខាលហ្លួម្អែងជាប្រាំពិល (២០) ទូហោយ លុះតលឆ្នាំម ធរជាឆ្នាំម ២៤ ខែទេ (២១) មេសរស្រីតពីព្យាពាធិបំម្រើរាសតាម ក្តីមោកតលឥស្ស (២២) [ហ្លួ] រក្រិមស្នូការោកក្តីពីពាក្យាតាម ក្តីតលហ្លួរ (២៣) [ព] ញាស្នួរនតន្ត្រារាធិប្បត្តិស្រីយអង្គឯក អគ្គសេ (២៤) [ន] យោទ្ធាភិមុក្ខអង្គរតន្ទិប្រោស្សការត្តក្តីនេះជា

(២៥)...ទៃហាបំម្រោសហោង ទេប្បូឱយឱកហ្វូងប (២៦) ក្រ្កិ ឥស្សែងនិមន្ត្រឥស្សព្រះអរិយសង្ឃផោងជុំ (២៧) ន្រុំ បោះបា រិកឲយឱកហ្វូងបក្រ្កិឥស្សែង មាគអ្នុ (២៨) ក្រ ព្រះធម៌ក្ខិពិម្ហា សង្គរាជបពិត្រជាព្រះជាគ អ្នក (២៩) ព្រះសូគុណម្ហាសង្គរាជ សសីរបារិកនេះបញ្ចុះនោ (៣០) វព្រះពិស្សនូលោក្ក ក៌រអ្នក ស្តេចព្រះម្ហាមង្គល (៣១) បពិត្រ អ្នកស្តេចព្រះរាជរោបីសមុះ អ្នកស្តេចប (៣២) ម្ហាឱត្តល អ្នកស្តេចព្រះធម្មបារម្មី អ្នកស្តេចព្រះ ឥន្ទ្រទ៌ (៣៣) ព្យូក្រ អ្នកស្តេចមោកអ្នកម្ហាបេរព្រះធម្មអរិយ អ្នុ (៣៤) កបញ្ញាសុត្ត អ្នកស្តេចប្រញ្ញាគគ អ្នកស្តេចព្រះបញ្ញា (៣៥)ផេដ្ឋ អ្នកបរិបញ្ញាទុំពិរ អ្នកស្តេចសមេត្តបញ្ញា អ្នក(៣៦) កស្តេចព្រះឥគកីលាស អ្នកស្តេចព្រះរាជកិរិយ អ្នក (៣៧) ម្ហា បេរអរិយភីញ្ញាណ អ្នកមបេរវិរិយ្យាមរម្មិ អ្នកព្រះ (៣៨) ម្រុ និសធម្ម អ្នកម្ហាបេរបរិគាថាម្ហាបាលិ អ្នកម្ហា (៣៩) បេរបរិ ទក្ខិណា ឥស្សស្តេចព្រះគ្រូបេរាន្វបេរភិ (៤០) ក្ខសូសង្ឃសោម នេរផោងជាសាក្សីពេជញ្ញាណា (៤១) ប្ហោគ្នក ប្ហោគុកប្ហោមោក ត្បូងផោងអ្នកឱកហ្វូង (៤២) បក្រ្កិ ឥស្សែង...នេះទោះបេហាគគា

មួយកូណាប្លោរ (៤៣) ផោងឯក្រៀបេហាមោកស្រីតេហោយោក្ក ជាវិមវិញ (៤៤) ទោះព្រះពុទ្ធត្រ័ស្បអម្ប៉ាលកែ្បចកន្ទោងទៅ ហេយ (៤៥) ក្តី មោកត្រស្បងក្រៀអម្ប៉ាលកែ្បចក្តិ កុំម្បីប្រោស អ្នក (៤៦) នោះលេយ ឲយអ្នកទោះទោវកេតព្វតបញ្ញូនទត រិក (៤៧) ៥០០ ព័នជាតក្តិកុំម្បីលតោះបិញអំម្បីទ្រុកនោះ (៤៨) ល្បេហោង អ្នកឱកហ្សងបក្រិ៍តស្បែព្រហ្មវង្សា (៤៩) អ្នកស្តុំបព្រះតនកិលាសប្ញេហាគូសលនេះ (៥០) ជូនទៅអ្នក ឱក ហ្សង... (៥១) សូម្បានទោរកេតនាតុស្ប៊ុទ្ធ (៥២) ហោង

លេខ ១៩

(១) នែះឱកញ្ញាស្មណសង្គ្រាម្មនាងឯប្ល ទូឱកញ្ញាពេជ្រ (២) សង្គ្រាម្ម ទូហោពញ្ញាជៃ្យធិប្បត្យិនាងព្រះ ទូហោពញ្ញាតេជោ ដៃ (៣) នាងរស ទូហោពញ្ញាស្មាសង្គ្រាម្មនាងអំ ទូហៅជសទូ អ្នកសំម្តេ (៤) បម្មោកទូនាងសរទូនាងនុងទូនាងមាហេទូកី ហោកេរទូហោសោម្មទូហោ (៥) រាជ តសអ្នកទាំងនេះសឹងសាទ្ធា សោមនុសព្រោមនិងឱ (៦) កញ្ញាស្មនមោកសាងកុសល ស្រែហេបុនប្រោសខ្ញុំម្ម (៧) សក្តមត្តុ ១៥៣៩ មសេញគក្សត្រិ

ទុត្តិយ្យាសាធ (៨) ២ កេតអង្គារពារសោរតា ម្នាជំនុមអ្នក
ព្រះធម្មិទិត្តិ (៩) មហាសឃ៉ារាជបូពិត្រ នូអ្នកព្រះសោគុណា
មហាបូពិ (១០) ត្រ នូអ្នកព្រះមហាមង្គល នូអ្នកព្រះរាជវោបឹស
មុ (១១) ហ នូអ្នកព្រះឪត្តលជេត្ត នូអ្នកព្រះព្រិមរត្ត នូអ្នកព្រះធ
(១២) មិកាយ នូអ្នកពុទ្ធរាម្ម នូអ្នកសម្តេចមោក នូអ្ន (១៣)
កព្រះធម្មអរិយ្យ បេរានុបេរភិក្ខុសុស៍ [ យ ] ផោងគឺជាសទិវិញា
(១៤) អកញាស្មនម្នាបិត្តសារទ្ធាសាងអំម្តេហាកុសលផលបុន
ប្រោ (១៥) ស្សក្កូនមេតោយអាសុក្ខឈ្មោះ មេអប្ប ១ មេ
តិយ ១ ឪយស្រុប (១៦) ជាព្រៃយ ឪយរក្សាបង្ហាណាអ្នក
សម្តេចមោកហោង បេហ (១៧) នតាពិពាត្តមាត្រ្តាលេយឪយ
ព្រះពុទ្ធអម្បាលខ្សែបមោក (១៨) ត្រាស្សក្តិកុំប្បីប្រោស្សអ្នក
តោះលេយ ឪយអ្នកតោះទោរ (១៩) កេតពួតបញ្ចូនត្តរិកទ្រក
ទំង ៥០០ ជាតក្នុំគេតកំម្បីយល (២០) តះហាមោកលេយ
ហោង ឯញាតអកញាសោតមានពញាជ្បៀ (១១) ១ ព្រះមគិ
ស្មត្ត ១ អធុល ១ មេសរ ១ មេនង ១ តិស្សញាតអម្បាល
(២២) នែះជួយតឹងផោងសោតហោង សម្ពស្ត ១៥៤៩ សក្យហោះ

(២៣) អ្នកប្រែងម្ទំកេត្រទុត្តិយប្យសាធ្យនោផាប្រឋំម្នុសាធ្យលេយ
អង្គារ (២៤) ញារ មគ្គិអកញ្ញាស្មុនឆុឆាងឯប្បរន្តាប្បផាកុសល
អារាទឆា (២៥) ឆិមន្ត្រិតស្បុសយ៉ងោងមោកឆ្លោងព្រៈពុទ្ធប្រត្តិ
មា តោះទេព្យអក (២៦) ញាស្នុទឆុឆាងឯប្បមានបិត្រនោះត្រិក
អរសាទ្ធារិពិងអនិប៉្ងធម្ម (២៧) នេះពុំឡេងលេយ យលជា
បប្តិមវ៉ៃយហោង ទេព្យបន្ទាលបិត្រ (២៨) គិត្រាកតញ្ញត់រើឲ្យ
បំម្ប្យសអ្នកស្នុណាអារិយ្យឲយ្យបានអប្បួស (២៩) ម្ប្យាត្រផា
ភិក្ខុបរប្បរស្រលេះឥត្រកំតិងលេយ ម្ប្លុប្រោសម្បេកេនក្ខ (៣០)
ណាអ្នកស្នុណាអារិយ្យក្ខូណាមេកែនប្រស ១ ឈ្មោះអាធុនឲយ្យ
(៣១) ស្រលេះផាព្រៃយ្យឥតក្នុតឹងលេយ រអ្នកគិផាសឱរិញាណ
មាណ (៣២) សម្តេចព្រះគ្រិយសព្វេជព្រះពុទ្ធក្រ្យយេងផា
ប្រធាណឱតម្ម ឯស (៣៣) យ៉សោត្រមានអ្នកសម្តេចព្រះមហា
មង្គលបុពិត្រអ្នកសំ (៣៤) តបមោកបុពិត្រ អ្នកសំតែបព្រះ
ធម្មអរិយបុពិត្រ អ្នកស (៣៥) ម្តេចព្រះប្បរម្មណិបុពិត្រ អ្នក
សម្តេចឱឡេបញ្ញាបុពិត្រ អ្នកព្រះអរិ (៣៦) បុពិត្រ អ្នកព្រះ

មហាថេរព្រហ្មបុពិត្រ អ្នកព្រះស្មណាធម្មបុតិ ឆ្ងតស (៣៧) ថេរា
នុថេរភិក្ខុសុសយ៍ផោងប្រែណា រិងគ្របហាវាសសោត្រមាណាប្ញោ
ហ្វ (៣៨) ឯមន្ត្រិយពិរភា ប្ញោរាដ ព្រះរិជាស្នុត ឝុតសក្ខ័យ
ក្ខណាប្ញោផោរិពាណ៌ (៣៩) មហាសត្វបព្រិសផោង់ប្រែណាសិ៍ជា
សិក្ខិវិញ្ញាណកំម្សិមាណាក្រៀនា ៗ (៤០) វេហាយោគជាខ្ញុំម
ប្រយោជអាត្មាលេយ ម្ហុឃ្មិកំម្សិមាណាបោងផ្តូណា (៤១) ក្ខណា
ប្ញោផោរិពាណ៌ផោងតា ៗ បីនុមោកវេហាលេយ ទោះអ្នកនាបី
(៤២) វេសោត្រិឲយអ្នកនោះទោរិធ្លុណានោនាបញ្ញានន្តរិកនា
យតរា (៤៣) បព្រះពុទ្ធត្រាសអំម្សាលខ្ញែប្រកឆ្លោងទោរិហោយ
ក្តិយអម្សាលខ្សែប (៤៤) ទុមោកឯក្មេកក្តិ កំម្សិឲយប្រោសអ្នក
នោះបានលេយ ម្ហុឃ្មិឲយ (៤៥) វន្ទុះទាំងអានន្ទបក្រាវាឡនែះ
កំម្សិឲយបែញឈោព្រៃយទៀ (៤៦) តលេយ ឲយបែញ
តៃហាអ្នកតវេហាបំម្រោសនេះសប្ប ៗ ជាត (៤៧) កំនេត្រិក័
ម្សិតៃបលេយ ម្ហុឃ្មិទោះក្រៀក្រិកាយ៉ុនាប្សិង្គាបឲ (៤៨)
យយោ្ហជាខ្ញុំមឲយក្រៀក្រិកាយ៉ុនោះទោរិវេ្ញាយទុក្ខវេទនាពួត

(៤៩) បញ្ជូនន្ទរិកឆាយឥស្កាលនោះតរបងហោង នោះក្រៀក្រិកាយ៉ៀ (៥០) ឆាសោត្រជ្រោមអនុមោទនាញុំឲយរេហសោត្រឲយក្រៀក្រិកា (៥១) យ៉ៀនោះបាណទោវស្មោយត្រិពិត្រសម្បាតតរាព្វតរលនិញ៉ាំនហ៉ោ (៥២) នេះអកញ្ញាស្មុណាគតឯងមោកឲយបោះហហរិកនេះឥស (៥៣) ជំនុមតជាសរេបុហោង ០ ។

បទានុក្រម

# អធិប្បាយសព្ទក្នុងសិលាចារិក

ទគវត្ត

(១) ព្រះធម្មខេត (ភា.) ព្រះធម្មខេត្ត តែក្នុងទីខ្លះឃើញសរសេរជាធម្មចិត នាំឲ្យនឹកថា ប្រែហែលជា ព្រះធម្មលិខិត ទេដឹង? តែធម្មខេត្តនោះក៏ល្មមប្រែបានសេចក្ដីហើយ ។

(១) ពេជិញាន សំ. ពេជ្ជាណ (ម. វិញ្ញាណ) ក្នុងទីនេះប្រែថា ជាអ្នកដឹងផង ។

(៧) វិហារស្ប្បាត សំ. វិហារស្បាទ រូបដើមជាវិហារស្បទ កាត់បទជាវិហារ–អាស្បទ ប្រែថា វិហារជាទីនៅ ។

(១១) សុពណ្ណវិលេប្ប សំ. សុពណ៌វិលេបនៈ = មាសសម្រាប់បិទ ឬមាសសម្រាប់លាប ។

(១២) អដ្ឋារស្ស ម. អដ្ឋារស = ដប់ប្រាំបី (គឺ ១៨ អង្គ ឬ ១៨ ហត្ថ ។ល។ ) ។

(១៣) ចៃយតិយ សំ. ចៃតិយ ឬ ចៃត្យ (ម. ចេតិយ) ។

(២៤) វិធីទាំង ៣ គេះ ខ. វិធីទាំង ៣ នេះ ។

(២៥) បម្បុស្បជាពណ្ណស្រម ខ. សំ. បំបួសជា - ពណ៌ស្រមណ៍ ។ ពណ៌ស្រមណ = ជាភេទសមណ; ឬជាសមណដ៏ទ្រទ្រង់គុណ ។

(៣០) បួសបរបួរបានឧបសម្បាត ខ. សំ. បួសចរិបូណ៌ បានឧបសម្ប័ទ ។

(៦-៧) មន្ត្រិយចតុរងសេនាបតិយសុភាសុហិនក្តិ សំ. មន្ត្រី-ចតុរង្គ-សេនាបតិ-សភា-ស្ថាន-ក្តី ។ គឺ ស្ថានជាទីប្រជុំរបស់មន្ត្រីចតុរង្គ គឺសេនាបតីទាំង ៤ រូប ។ មន្ត្រីចតុរង្គ ឲ្យគប្បីដឹងថាជាឈ្មោះហៅសេនាបតីទាំង ៤ ។ សេនាបតិសភា ឲ្យគប្បីដឹងថាជាឈ្មោះហៅទីកន្លែងដែលសេនាបតិប្រជុំពិភាក្សាកិច្ចការផែនដី ត្រូវនឹងពាក្យដែលហៅក្នុងកាលឥឡូវនេះថា សាលាកុន្សីយ ។

(៧-៨) គេហមោកអង្វរគតិយ ខ. គេមកអង្វរក្តី ។

(១៣) សព្វញុតញ្ញាណ្ណំ បដិវិធំ ម. សព្វញ្ញុតញ្ញាណំ បដិវិទ្ធំ ប្រែថា ចាក់ធ្លុះនូវសព្វញ្ញុតញ្ញាណ ។

(១៤) ហោពិសតិឥ ខ. ម. ចៅ-ភិក្ខុ ឥន ឬចៅ-ភិក្ខុគន្ធ (ឲ្យមើលពាក្យ លេខ ៦ (១) សឹងមានតទៅ ។

(១៥) សត្ថមាសតុ សំ. សុកមស្តុ (ម. សកមត្តុ) = សេចក្តីល្អចូរមានដល់ខ្ញុំ ។ តទៅមានច្រើនអន្លើហើយផាក់ច្រើនតែខុស ឲ្យគប្បីដឹងតាមនេះ ។

(១៨) ត្រលែងកែង ជាឈ្មោះហៅស្ថាន ទី ឬរបស់ដែល គេធ្វើជាមុខ ៤ ដូចយ៉ាងព្រះពុទ្ធរូប ៤ អង្គដែលគេធ្វើព្រះភក្ត្រចេញទៅ តាមទិសទាំង ៤ នៅក្នុងត្រលែងកែង ស្រុកលង្វែក ហៅថា ត្រលែងកែង ។

(១៩) ទុក្ខ-បញ្ញប្រាសាត្រ ទ. សំ. ទុក-បញ្ចប្រាសាទ ប្រាសាទកំពូលប្រាំ ។

(១៩) ពុទ្ធរូបសំឆ្ហា ទ. ពុទ្ធរូបសំណា ។

(២០) ព្រះសម្រឹតិ សំ. ព្រះសម្រិទ្ធ ។

(២១) ភិមព្រះពុទ្ធរូបតិ ម. ទ. ពិម្ព-ព្រះពុទ្ធរូប-ដី ។

(២១) ព្រះបង ម. ព្រះបន្ទន់ = ព្រះ (ពុទ្ធរូប) ធ្វើអំពីទ្ទឹម បន្ទន់ ។

(២២) បញ្ចុះឃាព្រះឡាត ទ. ម. បញ្ចុះព្រះ-ធាតុ ។

(២៣) កតទងប្រើឆាត ទ. កាត់ទង់ធ្វើឆត្រ ។

(២៦) តិសពួកទេពតា ទ. រស់ពួក-ទេពតា ។

(២៧) តិលេហាតល-អឃនិសេព្រហ្ម ទ. សំ. ឯលើដល់ អកនិស្ឋព្រហ្ម ។

(២៨) ក្តូស្បូតត្រធីរាជ សំ. ក្សត្រាធិរាជ ។

(២៩) ម្ដាយអាព្ញក ខ. ម្ដាយអាពុក ។

(២) សាកសីពេជញាណឱត្ដំ សំ. សាក្សីពេជ្ញាណឧត្ដម ។

(៣) កលញាណនូមិត សំ. កល្យាណមិត្រ = មិត្រល្អ ។

(៥) ព្ហ់ពែងបញ្ញបិម ខ. ពហ៍ពៀងបំភ្លឹម ។

(៨) ឱយព្រោបលែងភៃ ខ. ឲ្យរួចលែងភ័យ ។

(៩) ពនរាយនូត្រិភិធសម្បាត សំ. ពណ៌រាយនូវត្រិពិធ-
សម្បត្តិ ។

(១៤) តល-ទុសសហាសបក្រពាល ខ. ម. ដល់-ទស-
សហស្សប្រក្រពាឡ = ដល់ហ្មឺនចក្រវាឡ ។

(១៧) កេត – ទ្វេត្រឹង្សម្ហាបរសលោក ខ. សំ. កើត
ទ្វេត្រិង្សមហាបុរសលក្សណ៍ = លក្សណៈនៃមហាបុរស ៣២ ប្រការ ។

(២០) ហត្ថិរត – អាជានៃយរត ម. ហត្ថីរតន — អាជា-
នៃយរតន = ដំរីកែវ = សេះកែវ ។

(២០) សុបកែវសត្ពទីតរត ខ. ម. សូមកែវ — សត្ត
ទិព្វរតន ? ។ សត្តទិព្វរតន = កែវវិញ្ញូឲ្យដំសារម្រេចនូវសេចក្ដីប្រាថ្នា
គ្រប់ប្រការ ។

(២៣) សបញ្ញតញាណំ បបេយោ ហោតុ ម. សព្ញាត-ញាណំ បច្ចយោ ហោតុ ។

លេខ ៥

(១) អកហ្វាងអក្លែយរាជ ខ. ម. អកហ្វុន—អកយពជ ។

(២) ពាកស្សបាជង្ហា ម. ខ. ពាក្យ—សបថ—ថា ឬ ពាក្យស្បថថា ។

(៥) ពុំមឱយតុ្យងលេយ ខ. ពុំឲ្យដឹងឡើយ ។

(៦) ពមពេញ ខ. បំពេញ ។

លេខ ៦

(១) ប្ហូបាឬក ខ. ប្ហូ ប្រហែលជាបារ គឺបារ—បារីក ។

(៤) សុក្កុរអ្នកខ្សត្រ សំ. ខ. សក-កុរ-នក្សត្រ=ឆ្នាំកុរ នក្សត្រ ។

(១០) ព្រះសមងហ ខ. ព្រះសំណា ។

(១២) គិ-អស្ឋារសយ័ ខ. សំ. គឺ—អស្តាឫសន្ស្ស=អរិយ-សន្ស្ស ៨ ពួក ។

(១៤) ដោយ (ក) យថាសាស្ត្រ ខ. សំ. ដោយ—យថា-សាស្ត្រ ។ តួ (ន) លើសចូលមក ។ បើពុំដូច្នោះទេ គឺ "ដោយនុយថាសាស្ត្រ" គឺបាត់ស្រៈនុវិញ ។

(៣៧) បួសសំនកតព្រះសាស្នា ខ. បួសសំណាក់តព្រះសាស្នា ។

(៣៧) ឱត្សាប្រតិបត្ត សំ. ឧត្សាហប្រតិបត្តិ ឬឧត្សាហប្រតិបត្តិ ។ (ម. ឧស្សាហ) ។

(៤០) ទោគិទេព្វតាមហាខេត្រ ខ. សំ. ទៅគឺ-ទេពតាមហាក្សេត្រ ។

(២) នានាប្រាកាយ៍ សំ. នានាប្រការ = ប្រការផ្សេងៗ ។

(៥) សទិសបិមានបិត សំ. ខ. សទិស—បិមានចិត្ត សទិ-ស ប្រែថា ប្រកបដោយទិស — មានទៅក្នុងទិស (សព្វទិស?) ។

(១៤) សំម្ពោតពោលព្រះអង់ ទង់ធាតត្តសកុសល ខ. សម្ពោធបុះព្រះទង់ធត្រ, អស់-កុសល ។ ពោល ឬ បុះគឺសាង ។

(១៦) មានពាកស្បិហាដង្ហា ខ. មានពាកស្បថថា ។

(១៧) ទោះហាកូនអញឯងគ្តិយ ក្មួយអញគ្តិយ ខ. ទោះកូនអញឯងក្តី ក្មួយអញក្តី ។

(១៨) ព្រះសយ័គ្គិយ ជាគ្រហាប្បគ្គិយ ខ. ព្រះសង្ឃគ្គី ជា គហស្ថគ្គី ។

(២០) ពុំឱ្យតៀងលេយ ខ. ពុំឲ្យដឹងឡើយ ។

លេខ ១៧

(១) សព្វមសត្តដៃយាសទិតិរេក សំ. សុកមស្តុ ដៃយា សិទ្ធិតិរេក ។

(៤) ស្វមលុហាប្រាទ្ធនាស្មោះហាបហាពោះ សំ. ខ. សូម លុះ — ប្រាថ្នា — ស្មោះចំពោះ ។ ប្រាថ្នា សំ. ជា ប្រាថនា ។

(៥) បាគទុគព្រះសីអារមៃត្រិយ ខ. សំ. បានទាន់ព្រះគ្រី-អារ្យមេត្រៃយ ។ ១ យ៉ាងទៀត "ទន់" ប្រែថា "ថ្វាយបង្គំ" គឺបាន ថ្វាយបង្គំព្រះគ្រីអារ្យមេត្រៃយ ។

(៧) ជាព្រះពុទហោង ម. ជាព្រះពុទ្ធហោង ។

លេខ ១៨

(៤) គបទ — ឱក្កហ្សាង រាជាតេជះហា ខ. ម. ដង្កួតទកហ្វូង កដគេដ: ។

(៦) ប្រោសខ្ញុំមទ្ទំស្ត្រីវក្លួណបិន័ក ខ. ប្រោសខ្ញុំទាំងស្ត្រី កូនបីនាក់ ។

(៧) កេតក្នុងបំម្រោស ខ. កើតក្នុងបម្រោស គឺកូនដែលកើតក្នុងវេលាដែលម្ដាយអាពុកនៅជាខ្ញុំគេ ហៅថា បម្រោស ព្រោះជាអ្នកដែលគេត្រូវប្រោសលែង ។

(៨) ខុណបញ្ចូងរទយ ខុនបញ្ចូន៍ហ៊ុទ័យ ។

(១៣) ឱកហ្វ៊ូងរាជាអប្បុករ ម. ឱកហ្វ៊ុន៍រាជឧបករណ៍ ។

(១៤) សង្ស្វរសត្វា ម. សំរេសត្វា = សាស្តាសង្រ្គម ។

(១៤) ឱកហ្វ៊ូងពង្សាកុល ម. សំ. ឱកហ្វ៊ុន៍ពង្សានុកូល ។

(១៦) ហ្វ្ហោន្អក ខ. ហៅនក ។

(១៩) ហ្វ្ហោម្អឹង ខ. ហៅមឿង ។ ប្រកបស្រះថែបនេះហើយដែលសៀមយកទៅប្រើតាមដកបដល់សព្វថ្ងៃនេះ ។

(២១) ស្រិតីពីញាធិ ខ. សំ. ស្រដី-ពិញាទ = ស្រដីទាស់ទែង ។ (ម. វិវាទ) ។

(២២) គាំមក្តិមោកតល ខ. នាំក្ដីមកដល់ ។

(២២) សូភាពោកក្តិ ខ. សុភាកេក្ដី ។

(២៣) ពញាសូរេន្ទ្រាធិប្បត្តិស្រិយ... *សំ. ពញា-សុរេន្ទ្រា-ធិបតីស្រី .... ។*

(២៤) អង្គរឥន្ទ្រិប្រាស្បកាត្តក្តិ *សំ. ១. នគរ-ឥន្ទ្រប្រស្ថ-កាត្តិ ។ (ម. នគរឥន្ទ្របថ) ។*

(២៩) សសីរបារិក *ខ. សរសេរបារិក ។*

(៣០) ព្រះពិស្សនូលោក្កក៍រ *ពាក្យនេះប្រហែលជាលើសអក្សរខ្លះ ដែលត្រូវ គឺ ព្រះពិស្ណុលោក ។*

(៤១) ហ្វោមោកត្បងដោង *ខ. ហៅមោកដឹងផង ។*

(៤៦) បញ្ចននតរិក *ម. បញ្ចានន្តរិក = ជាឈ្មោះនរកដែលអ្នកធ្វើកម្មត្រូវទៅកើតក្នុងជាតិជាលំដាប់ រាប់តាមចំនួនអំពើដែលធ្វើមាន ៤ យ៉ាង ។*

(៤៧) លតោះបិញអម្បីត្រ *ខ. ល្ហោះចេញអំពីនរក ។*

(៤៩) ប្វើហាគូសល *ខ. ម. ធ្វើកុសល ។*

(៥១) កេតនាតុស្សិទ្ធ *ខ. ម. កើតនាតុសិត ។*

លេខ ១៩

(១) ស្មណសង្គ្រាម្ម សំ. សមណសង្គ្រាម = អ្នកមានសង្គ្រាមរម្ងាប់ហើយ ឬអ្នករម្ងាប់សង្គ្រាម ។

(២) ពេជ្ជសង្គ្រាម សំ. ពេជ្រសង្គ្រាម = អ្នកមុត អ្នករឹងក្នុងសង្គ្រាមបីដូចជាពេជ្រ ។

(៥) សោមនុស-ព្រោម ម. ខ. សោមនស្ស-ព្រម ។

(១៦) ឲយប្រុបជាព្រៃយ ខ. ឲ្យរួចជាព្រៃ ។ មនុស្សដែលបានឈ្មោះថា "ព្រៃ" តាមសេចក្ដីក្នុងសិលាចារឹកនេះបានទីនមនុស្សក្នុងជាន់ដើមជាខ្ញុំរបស់គេ យូរមកគេលើកលែងឲ្យធ្វើជាខ្ញុំ គេលែងឲ្យទៅនៅ ឬគេសុំតាមចិត្តក៏មាន គេកំណត់ឲ្យនៅដោយខ្លួន ដូចយ៉ាងឲ្យនៅបំរើព្រះសង្ឃ បោសប្រាសវត្តជាដើមក៏មាន ហៅ "ព្រៃ" ដែរ យើងហៅសព្វថ្ងៃនេះថា ពាព្រៃ សឹងឃ្លៀងឃ្លាតអំពីពាក្យដើម ។

(១៧) នគាពិពាត្ត ខ. សំ. នរណា-ពិពាទ = នរណា-វិវាទ ។

(១៩) ជាតុក្នុំនេតកំម្បិយលតះហ ខ: ជាតិកំណើតកុំបីល្ហោះ ។

(២១) ព្រះមន៏ស្មូត ឈ្មោះ ព្រះមុនីសម្មត ? ឬក៏ព្រះមុនីសុមេធ ។

(២១) អធិល (ឈ្មោះ) អា ផល ។

(២៣ ឯម្មិកើត្រទុត្តិយស្យសាធ្យ ១. សំ. ឯមួយកើតទុតិយាសាធ (ម. ទុតិយាសាឍ្ហ) ។

(២៨) កតញ្ញូត់វេទិ្យ ម. កតញ្ញូ កតវេទី ។

(២៨) ស្មូណអារិយ សំ. ស្មណអារ្យ ឬ សមណអារ្យ (ម. សមណអរិយ) ។

(២៩) អប្បសម្បាត្រ ម. ឧបសម្បទ ។

(២៩) ឥត្រកំពឹងលេយ ១. ឥតកំដឹងឡើយ គឺឥតបើដឹងឡើយ ។

(៣២) ព្រះពុទ្ធក្រ៉យយេង ១. ព្រះពុទ្ធក្រ៉យយើង ឬ ព្រះពុទ្ធក្រៃយើង ។ ក្រ៉យ ឬក្រៃនេះ ប្រែថា លើសលប់ជាង — ធំជាង ឬប្រែថា លើ ដូចពាក្យថា ក្រៃកែវហ្ន៎ ប្រែថា កែវលើមេឃ ។ តែក្នុងទីខ្លះ ប្រែថា "អ្នកណា" ។

(៣៨) ហ្វូងមន្ត្រិយពិរភា ១. សំ. ហ្វូង មន្ត្រីពីរគាព ។ ធ្លាត់អក្សរ ព. ។

(៣៩) មហេ.សត្វបវ្រស សំ. មហាសត្បុរេស ឬមហា-សប្បុរេស ។

(៣៩) សិំជាសិក្ខិវិញ្ញាណ ខ. ម. សិងជា សខិវិញ្ញាណ (សំ. សក្ស្រពេជ្ញាណ) ។ ជាត់អាកាស ៉ ឃើញប្រើជំនួសអក្សរ “ង” ជាប្រើនអន្ទើ ។

(៣៩) កុំម្បិមាណគ្រ្យ៉ានានា ខ. កុំបីមាន—ក្រយ៉—នានា គឺកុំបីមាន - អ្នកណា - នានា ឬថា កុំបីមានអ្នកណាផ្សេងៗ ។ ក្រយ៉ ឬក្រៃ ត្រូវទឹងពាក្យថាអ្នកណា ។ នានា ប្រែថា ផ្សេងៗ ។

(៤០) មួឃ្នីកិម្បិមាណ... ខ. មួយនីកុំបីមាន ។

(៤២) ទៅឆ្អណ ខ. ទៅឆ្អិន ឬ ទៅឆ្អែតឆ្អន់ ទៅឆេះ ។

(៤៤) ឯភ្នេកក្ដិ ខ. ឯភ្នែកក្ដី = ឯមុខក្ដី ។

(៤៥) អានន្ទុបក្ក្រាភិឡ សំ. អនន្តបក្រាំឡ = បក្រាំឡដ៏ធំរកទីបំផុតគ្មាន ។

(៤៥) បែញឈេព្រៃទ្យេត ខ. បាញ់ឈើព្រៃទៀត ។

(៤៧) ទោះក្រ្យ៉ក្រិកាយ៉្យឆាប្បិង្គាប ខ. ទោះក្រយ៉ក្រមការនាបីបង្គាប់ គឺ ទោះអ្នកណាក្រមការនាបីបង្គាប់ ។

(៥២) ប្បោះហាបារិកនេះ ខ. បុះបារិកនេះ = សាងបារិកនេះ ។

# ណេភកាន៍យ

របស់ឧកញ៉ាវង្សាសារពេជ្រ (នង)

(ត)

បុរោហិតព្រាហ្មណ៍ព្រឹទ្ធឆ្លើយថា ធនញ្ជ័យឿយបា អញមិនបេះ ឯង ៗ មានច្បាប់សន្តាប់តពីព្រេង អាចារ្យលោកថែង ចងជាគាថា ៗ ដោយបទកំណត់ទិសា ម្ដេចទៅចរចា ផ្ដាញ់ផ្ដាលតែអញ ៗ អ្នកឆ្លើយ ចម្លើយទៅវិញ ថាព្រាហ្មណ៍មើយអញ ពុំសើចពុំថា ៗ ព្រះធម៌សម្មា ឡើយណា អញផ្ដាលអញថា អ្នកថាពុំត្រូវ ៗ ពុំយល់ពុំស្គាល់ អាថិកូវ ព្រាហ្មណ៍ថាឥឡូវ ទៅប្រែដូចម្ដេច ៗ ចូរថ្លែងសំដែង បានតិច ឲ្យអញដឹងកិច្ច ដំណើរនោះណា ៗ ពោធិសត្វវិសេសថា ហៃបុរោហិតា បើអ្នកមិនបេះ ៗ ចូរស្ដាប់ត្រង់ត្រាប់ត្រេកត្រិះ ឲ្យជាក់ចាំបេះ ទុកក្នុងចិន្ដា ៗ អញប្រែបន្ទូគាថា ឲ្យស្ដាប់កាល គ្រា ឥឡូវនេះហោង ៗ បទកាកគតិ កាល្អេះកូហាល ពន្ទក ច្បាស់ច្បង ប្រុសប្រាជ្ញប្រតិយ័ត្ន ទីងអ្នកផ្ទឹមផង ថ្លាថ្លែងសាសង អធិប្បាយថា ៗ ម្ដាយអាពុក នោះសោតលោកទុក ជាទិសបូព៌ា ហេតុលោកកើតមុន ធ្វើបុណ្យប្រាថ្នា ឲ្យបានយើងជា កូនកើតមក ផង ៗ ម្ដាយអាពុក ចិញ្ចឹមជាក់ទុក ក្បាបួនគ្រង នោះទើបលោក ទុក ម្ដាយអាពុកផង ផ្សិតលោកនោះហោង ស្មើទិសបូព៌ា ៗ នរណា បើស៊ី សពើចំណី ហូបចុយក្ដណា លោកប្រេះផ្ដាះទឹក ពុក មាតា នូវបិតាជា នោះទើបឲ្យស៊ី ៗ អ្នកនោះនឹងមាន អាយុ យឺនបាន សុខនាលោកិយ ដល់បរលោកនាយ ពណ្ណកាយសោភី

សុខសំរិទ្ធិ ដូចចិត្តប្រាថ្នា ។ រីគ្រោះក្សាយ ប្រាប់ធមិទាំងឡាយ
ម្បូនសីលសាស្ត្រា លោកទុកជាង ត្បូងប្រែស្រាយថា បន្ទូលចេញជា
ទុក្ខណានោះ ។ គាថាតែងថា ឯត្បូងក្តីណា សឹងបានចំពោះ
ទឹងថាឯស្តាំ នានាំផ្លូវនោះ បង្ហាញផ្លូវស្មោះ សោតសឹងតែបាន ។
ហេតុគ្រប់ខ្ទៃ ប្រដៅនាំណែ ផ្លូវសួគ៌និព្វាន ហូបបាយឲ្យនឹក រពេក
ផ្ទះថ្កាន គ្រហើយទឹងបាន របស់ទ្រព្យ ។ រីទិសឯលិច ទុកជា
ញាតិសាច់ ផ្សិតញាតិប្រាថ្នា ចិត្តចង់ឲ្យបាន ឲ្យមានយសា ទៅ
ភានពឹងអា- ស្រ័យហេតុនោះហោង ។ លោកថាបើសុំ អាហារចំណី
ឲ្យនឹកញាតិផង ទឹងកើតយសា ប្រសប្រាកដហោង កិរិយាស្នេហ៍ស្នង
នោះលោកទុកជា ។ រីឯជើងទ្វា ឯជើងបាទ្បី ថាឧត្តរ ឧត្តរប្រែ
បន្ទូលចេញថា ប្រសើរធម្មតា កិរិយាទាំងឡាយ ។ សឹងបំពេញក្តី
ប្រកបពោធិ- សត្វសព្វសម្លាយ សឹងយកកិរិយា ជាបរិច្ចាគចាយ
ទានទើបប្រាជ្ញប្រាយ លោកទុកកិរិយា ។ ស្មើទិសឧត្តរ ទោះបន្ទូលប-
គោគគោជនា នោះឯងឲ្យនឹក ព្រេកកិរិយា កាលនៅផងគ្នា មូលមួយ
ទឹងប្តី ។ ទើបពង្រាក្សា អ្នកសូត្រគាថា ដែលមៀតនោះទ្វី បងអ្នកទឹង
ប្រែ បន្ទូលសេចក្តី ឲ្យដេរ្សងទឹងពី ដើមនោះវិញណា ។ បុត្រ កុញ្ញ
អាយេត្តិ បើចង់មានអា- យុយឺនៈបស់ ចំណីកាលណា ឲ្យនឹកមាតា
ពីតាប្រធាន ។ ធនត្តិទ- ក្ខណាមុខៈ បើចិត្តចង់បាន សម្បត្តិឲ្យសុំ ចំណី

ទឹកថ្កាន ព្រោះគ្រប់ទីបាន ទ្រព្យដូចផ្កាថ្ម ៗ យសត្ថិប- ជ្ជរមេទេវ
ចង់បានយសា បើហូបបាយស៊ី ចំណីក្តីណា ទីញាតិកា សន្តាន
ផៅផង ៗ ទេវ កុញ្ញា តកមុខិ ករិយាសូនគ្រង លោកគុំឲ្យទឹក
ពេកឡើយហោង ហេតុរម្មស្នេហ៍ស្នង ទីដប្តីសត្វថ្ងៃ ៗ បុរោហិតា
ស្តាប់ហើយឲ្យសា- ធុការថាហៃ ឆន្ទញ្ញយបណ្ឌិត ពាក្យពិតប្រពៃ
ជាតំនាក់នៃ លោកផងទាំងឡាយ ៗ នាព្រះសាស្នា ព្រះពុទ្ធនេះជា
តំនាក់រូបកាយ ជាថ្មីមថ្លៃ ប្រពៃពណ៌ពាយ អញពុំគិតស្តាយ
សាសន៍អញឡើយណា ៗ អញទៅរៀនយក សាសន៍ព្រះពុទ្ធមក
តំនាក់អាត្មា ចូរទៅសំដែង ថ្លាថ្លែងទេស្នា ច្បាប់បុរោហិតា អញទីង
រៀនផង ៗ ពោធិសត្វស្តាប់ អស់អាថ៌សាសត្រ ឆ្លាស់ឆ្លើយរឹងស្នង
ថាហៃបុរោហិត បើចិត្តប៉ុនប៉ង ចង់រៀនពោះហោង ចូរព្រះស្តង
ស្តាប់ ៗ អញទឹងសំដែង ទិពានបាយបែង គ្គន្នានវិច្បាប់ បុរោហិតា
ព្រាំប្រការគាប់ ចូរចាំត្រង់គ្រាប់ ទុកក្នុងចិន្តា ៗ ប្រការ ១ នោះ
ឲ្យពូជភាជន៍ស្នោះ មួយនោះសោតណា ឲ្យផឹងទឹកអប់ គោរនាំយាត្រា
ទៅថ្វាយក្សត្រា ជាប្រក្រតី ៗ មួយឲ្យផុតអស់ ក្តីអប្បៈយស នៃ
ព្រះចក្រី មួយឲ្យប្រផៅ ធម៌អាថ៌បារមី មួយនោះឲ្យទិ- យាយថ្វាយ
ក្សត្រា ៗ រីចប់ពាំងព្រំ ហៅបុរោហិតធម វិភាជន៍នោះណា គឺអង់

# ក្បួនជំរះឧត្បាទ៍
# របស់បូរាណ

(គ)

បើបានប្រណិប័តន៍ ធម៌ខ្ជាប់ក្នុងកាយ កស្ដិ៍ផងឥតទុក្ខ ក្សេមសុខ សប្បាយ លុះបរលោកនាយ បានសោយសួគ៌ា ។ ពុំដែលរួចលែង ឋានសួគ៌នោះឯង ដូចកលទឹកមហា- សមុទ្រជន់ជោរ ពុះពោរដលសា ពុំកន្លងនា ច្រាំងនោះបានឡើយ ។ ពុំនោះដូចអំ- ពៅមានថ្នាំងពុំ លះផ្អមបានឡើយ អំពៅដូចមហា- ក្សត្រាត្រាណាត្រើយ ថ្នាំងនោះ ឯងហើយ ដូចច្បាប់ទាំងប្រាំ ។

បុរោហិត ឲ្យគិតរក្សា សីល ៥ ប្រការ ប្រក្រតីកុំខាន ។ នាថ្ងៃ
អដ្ឋមី ឧបោសថក្តី ឲ្យអធិដ្ឋាន ឧបោសថសីល កុំខ្ជិលឲ្យមាន
ព្យាយាមហៅបាន ពួកភាជន៍នោះណា ។ រីឯកអប់គោរ គឺសត្តតិស
តោ- ធិបក្ខិយធម្ម ជាទឹកអម្រឹត ពីបិត្រថ្លៃថ្លា តែងទៅទេស្នា ឲ្យ
មហាក្សត្រក្សាន្ត ។ រីនាដ្ឋកអស់ ក្តីអប្បះបេះ នោះឲ្យក្សត្រមាន
ព្រះទ័យលោកលះ តាមប្រាជ្ញាញាណ ដំរះបាបបាន ដោយព្រះ
ធម៌ថា ។ ឲ្យប្រដៅអាចិ ទសពិធរាជធម៌ ក្រិត្យនៃក្សត្រា ឲ្យទួល
រំពុក កាលព្រឹកនោះណា ក្តីអ្វីមួយបេណា ជាសំណើចអ្នកផង ។
ឲ្យបង់បំបាត់ ក្តីក្រោធចេញផ្ដាត់ កុំឲ្យមានម៉ង កាន់កិច្ចក្សត្រា
ប្រាំប្រការផង តាមដោយទំនង ព្រះធម៌ថ្លាថ្លៃ ។ ជុតិនោះណា គឺ
ព្រះប្រាជ្ញា វៃអធ្យាស្រ័យ យល់ទុក្ខនៃរាស្ត្រ ទាំងផ្កាសនោះនៃ មិន
ឲ្យសង្ស័យ ដំនៀលនិទ្រា ។ មួយគឺខន្តី ឲ្យក្សាន្តកុំបី យកទោស
ព្រះពញា រាស្ត្រផងទាំងឡាយ រំសាយក្រោធា សមាទានរក្សា
សីលជាប្រក្រតី ។ មួយគឺសច្ចា កុំឃ្លៀងសត្យា សម្ពុរាទី មួយ
គឺមនោ សាន្តសោបិត ទ្រង់ព្រះមេត្រី ត្រេកត្រង់សន្ធា ។ មួយ
គឺឲ្យបាន ពីព្យាយាមមាន វិធម៌ប្រាំប្រ- ការនេះឲ្យគុណា ជាបុណ្យ
ថ្លៃថ្លា ប្រះសីរនៃមហា- ក្សត្រផងទាំងឡាយ ។ លោកថាមហាក្សត្រ

ទោះក្របីព្រៃចូលតម្បន់ ក្នុងស្រុកកាចលន់ សំប្រាសកូនចៅឯង ហោង ។ ឧត្បាទផ្ទាល់ឆ្នាំពីផង នឹងកើតមានហ្នឹង ខ្សត់ខ្សោណាហ៊ន ហោចស្រុកស្រែ ។ ទោះចចកចូលមកឯង ក្នុងស្រុករវេ រលំរលស់ កើតកាច ។ បូជាបាយទឹកនូវលាជ មាសប្រាក់ដីសម្បាច រណ្ដាប់បូជា ឲ្យថៃ ។ និមិត្រសត្វទោចនូវក្តែ ដេញគ្នាឯង ចូលមកក្នុងស្រុកចង្រៃ ។ នឹងកើតទោសទុក្ខកិតភ័យ ចាំងគ្នាឯងនៃ នឹងប្រាសវិនាសទីស្ថាន ។ ឲ្យយកដំរីសេះយាន ខែលដាវគ្រឿងអាខ ឲ្យលាងក្នុងទឹកហើយណា ។ ឲ្យរៀបប្រងាប់ប្រដា ថ្កល់ថ្កើងបូជា សូមតេជតេជះជោគជ័យ ។ ទោះឈ្លូសចូលក្នុមឯង សិងកាចពេកក្រៃ បើថ្ងៃនោះនឹងក្ដៅស្មោះ ។ នឹងប្រាសពីលំនៅនោះ កើតទុក្ខសូន្យសោះ ចំពោះឲ្យរៀបបូជា ។ ទោះគោសម្រាលកូនណា កើតជាមនុស្ស ឧត្បាទពុំជាឡើយនៃ ។ នឹងមានហេតុកេទទុក្ខភ័យ ខុនណាងចៅខែ ចង្រៃឲ្យចាំសីលា ។ ឲ្យបានប្រាំពីរទិវា បើពុំធ្វើណា នូវបង់ខុនគាលនូវខ្លួន ។ បង់ខុនណាងចៅមឿងថៃធូន បូជាឲ្យមួន កុំឲ្យប្រហែសឡើយណា ។ ទោះត្រកួតចូលក្នុងគ្រឹះហា ទិសក្តៀសានណា បូពាទិសពីចង្រៃ ។ ឲ្យរៀបបូជានោះនៃ មាសប្រាក់នូវចំណី ស្រាលាជប្រេងម្សៅគន្ធ ។ នូវស្រូវអង្ករផ្កាកញ្ញ សំពត់សច្ឆ នូវល្ងសណ្ដែកនោះផង ។ ទោះមនុស្សបាត់ស្រមោលហោង ឧត្បាទក្បាលជាមួង នូវក្សយជិវិតវិញណា ។ ធ្វើបុណ្យ

បង្សុកូលអនិច្ចា ឲ្យទានផងណា លំដោះអស់គ្រោះកាចបាន ។ ទោះផ្សិត
ដុះកន្ទបក្រោន នោះសោតនូវមាន សិរីសួស្តីឯងហោង ។ នឹងបានមាស
ប្រាក់កែវកង អំពីមិត្រផង សំឡាញ់សម្បូតទ្រព្យ ។ ឲ្យរៀបបូជា
ស្រែចស្រោប តាមក្បួនបង្គាប់ មាសប្រាក់សំពត់ព្រាលស ។ សំពត់
ខ្មៅមេម៉្រៅប្រែផ្លូ នូវស្រូវអង្ករ ផ្កាសទៀនធូបម្លូស្លា ។ បំណើបំណាប
ញាំក្លា បន្ថែមគ្រប់ណា យកទៅបូជាតាប់ពៃ ។ ទោះក្លាយផ្គិនហើយ
ដុះក្តី នឹងមានពសភ័យ ឲ្យរៀបបូជាឲ្យទាន ។ សំពត់ស្រូវអង្ករបាន
បំណើផងមាន ម្លូស្លាទៀនធូបក្រឿងព្រាល ។ ទោះអង្ករគ្រាំដុះផាល នឹង
កើតសឹកសា មកដេញឲ្យបែកគ្រប់គ្រា ។ ផ្សិតដុះកន្ទាំងបាយ
ណា ជម្ងឺកើតា ជក់ស្លាប់បាត់ខ្លាត់ខ្លាយ ។ ឲ្យរិះគិតនូវខ្វល់ខ្វាយ បូជា
សព្វសាយ ឲ្យចោលឆ្នាំងបាយនោះចេញ ។ ទោះដង្កូវដុះលើខ្នងមិញ
ឲ្យលំដោះគ្រោះចេញ ស្រូវពេញកញ្ជើ ១ ណា ។ ឲ្យរៀបណ្តាប់បូជា
បានបរិបាក អាត្មាគិតយោសួស្តី ។ ទោះឃើញឆ្នុះកន្ទុះក្តី បូជាផ្កាភ្ញី
មាសប្រាក់នឹងមានលាភវិញ ។ ទោះដីដុះក្រោមផ្ទះពេញ ឲ្យបូជាចេញ
ស្រឡះនឹងមានលាភក្រៃ ។ ទោះត្បាល់ដើរឯងយប់ថ្ងៃ លែងលំនៅនៃ
ឲ្យរៀបបូជាឯងឯង ។ ទឹកឃ្មុំនូវទឹកទន្លេ ទឹកដូងចាក់តែ យកព្រហ្មចារី
អង្គុយឯក ។ នូវស្រូវមួយផ្លែកគាត់តែក ពែរួកពែបែង សំពត់ពណ៌ស
ក្រហម ។ បើពុំបូជាឲ្យព្រម រៀបចំឲ្យល្អម ម្ចាស់ផ្ទះនឹងស្លាប់ពុំ

ខាន ៗ ទោះឆ្នាំងដើរចេញពីក្រាន ម្ចាស់ឆ្នាំងនឹងមាន ទុក្ខឲ្យហិន
ហោចទ្រព្យ ៗ ឲ្យរៀបប្រដាប់បូជា ដូចត្រាល់នោះណា នឹងបាន
ប្រកបសាន្តសុខ ទោះរទេះដើរឯងក្នុងស្រុក ថ្ងៃ ១ ពុំសុខ កើត
ទុក្ខបោលស្រុកទីឋាន ៗ ឲ្យរៀបបូជាទើបបាន សូត្រមន្តកំសាន្ត
ប្រគេនរទេះចេញទៅ ៗ ទោះស្រមោចសង្អារឡើងនៅ ពោមផ្ទះ
ចៅពៅ ប្រសេចប្រសាចសោះសា ៗ ក្រែងខុនណាងនូវរាស្ត្រប្រជា
ស្រដីផងគ្នា ពុំត្រាស្តាប់ពាក្យគ្នាឡើយ ៗ លំអៀងពុំទៀងព្រងើយ
កាចពេកណាស់ហើយ ថ្ងៃប្រាំនូវបង់ស្រុកពិត ៗ ដូច្នោះយល់ទុច្ចរិត
ខុនណាងព្រួយចិត្ត ចាស់ព្រឹទ្ធាចារ្យកង្វល់ ៗ អស់រាស្ត្រប្រជាអំពល់
នាងដីថេរខ្វល់ របល់ពុំស្រណុកឡើយ ៗ ទោះទូកលើបង្គងដាក្រើយ
ស្រែកហៅកៅហើយ លូនលឿនពីបង្គងចេញ ៗ នឹងស្លាប់ខ្ញុំកូន
ចៅវិញ នឹងកើតទុក្ខម្ដេញ ឲ្យរៀបបូជាលំដោះ ៗ ឲ្យសូត្រទិព្វមន្ត
លំដោះគ្រោះ ហើយឲ្យចំពោះ ប្រគេនទូកនោះទៅតាប់ ៗ បើឈប់
យូរទៅពុំស្តាប់ ប្រាំពីរថ្ងៃពុំគាប់ កុំឲ្យប្រហែសឲ្យក្រែង ៗ ទោះ
ដឹងបែកក្អកដៃឯង បូជាគាក់តែង ដំរីសេះសោតទ្រព្យផង ៗ ទោះដូង
ផ្ទះទាំងក្ដាយហោង បង់ខ្លួនជាម្ដង ឲ្យផ្ទង់បូជាឲ្យគ្រប់ ៗ ឲ្យប្រ-
ដាប់បាយទឹកឲ្យសព្វ ទៀនផ្កាទឹកអប់ សូត្រមន្តឲ្យទានបម្រែក ៗ ទោះ
ដូងផ្ទះប្រែងជាមែក ជាពីរចុងបែក នូវបង់កូនចៅដៅពាណ៍ ៗ ទោះ

អំពៅខ្មៅផ្កា សោតទ្រព្យសជា មួនអំពីលំនៅស្ថាន ។ នោះដំបូក
ទិសបូព៌ាទ្រព្យបាន គោក្របីយាន ដំរីសេះសោតក្រៃ ។ នោះដំបូក
អគ្នេយ៍ទិសា ភ្លើងឆេះពុំជា ជួយគ្នាប្រដាប់ឲ្យគ្រប់ ។ ឲ្យរៀប
បូជាសាយសព្វ ស្រេចហើយផ្គាប់ រំលាយដំបូកចេញជា ។ នោះ
ដំបូកនៅទិសទក្ខិណា នូវចង់ទ្រព្យា បូជារំលាយចេញទៅ ។ នោះ
ដំបូកនៅទិសនិរតី ឲ្យទោសឯងក្ដី ហើយឲ្យរំលាយចេញណា ។ នោះ
ដំបូកនៅទិសបច្ចិមា ឲ្យផ្គត់ក្រៃ បូជាថ្ងៃសៅរ៍អង្គារ ។ ឲ្យគុណលើស
លន់ក្ដាត់ណា ទឹងមានបរិវារ បរិវារខ្ញុំប្រុសខ្ញុំស្រី ។ រទេះទូកសេះដំរី
ទឹងមានសួស្ដី មានទ្រព្យធនច្រើនគួរគាប់ ។ នោះដំបូកនៅទិស
ពាយ័ព្យ នោះទឹងគួរគាប់ បានខ្ញុំអាយ៉ាត់វេរ ។ នោះដំបូកនៅទិស
ឧត្ដរ មង្គលដ៏បវរ នូវបានមាសប្រាក់កែវកង ។ បូជាផ្កាក្រឡាដផង
ទឹកឃ្មុំសោតហោង ទៀនធូបប្រេងម្សៅឲ្យបាន ។ នោះដំបូកនៅទិស
ឦសាន នោះសោតទឹងបាន ទ្រព្យធនពេកពន់មហិមា ។ ឲ្យរៀប
ប្រដាប់បូជា គ្រឿងគន្ធមាលា ផ្កាភ្ញីទៀនធូបពាដដង ។ បើពុំធ្វើ
ឈ្មោះឡើយហោង ដំបូកចឹងផង អាក្រក់នូវធ្វើទោសា ។ ឲ្យស្លាប់បង់
បាត់ផ្ទះ បង់ទាំងទ្រព្យា បង់ភូមិលំនៅស្រឡះ ។ នោះដំបូកនោះ
ផ្ទះក្រោមផ្ទះ មានភ័យដំខ្ទះ អ្នកផងឲ្យទ្រព្យគៀបគ្រា ។ នោះដីកន្ទ្រ
ឈ្មោះក្រានណា ប្រែរែកចេញជា តែបើដំបូកពុំគាប់ ។ ឲ្យរៀបបូជា

ដោយសណ្ដាប់ សំពត់ស្រែចស្រាប់ ដំរីទ្វារសេះគោជនា ៗ បើពុំធ្វើ
ដូច្នោះណា ទឹងកើតទោសា ឃ្លាតបង់ទ្រព្យខ្ញុំកូនចៅ ៗ ពោល
ស្រុកវិស្ថានលំនៅ ឲ្យកើតទុក្ខក្ដៅ ព្រាត់ប្រាសវិនាសពុំក្សាន្ត ៗ
ទោះស្រាពុះក្នុងដបចាន ទឹងផឹកពុំបាន ឲ្យរៀបបូជាមាសប្រាក់ ៗ
សំពត់សខ្មៅទៅពាក់ ស្រូវអង្ករដាក់ កន្ទាំងសណ្ដែកនូវល្ង ៗ បើពុំ
បូជាទល់ទ្រ ទឹងកើតទោសមរណ៍ ដល់ខ្លួនបង់ស្រុកបង់ទ្រព្យ ៗ
ទោះខ្លួនចូលស្រុកគួរគាប់ ឲ្យរៀបប្រដាប់ ស្លៀកសហើយបន្ទក់ណា ៗ
ទោះត្រកួតឡើងផ្ទះសឹងជា ឲ្យរៀបម្ជុំម្ជា បូជាមាសប្រាក់គប់ហោង ៗ
ទឹងកើតសួស្ដីដ៏កខ្វង់ ទូវបានស្រូវផង ពេញតឹកពេញឃ្លាំងឯងណា ៗ
ទោះអណ្ដើកចូលភូមិពុំជា ឲ្យយកអស់គ្នា ម្ជុម្ជាបូជាក្នុងស្រុក ៗ បើពុំ
បូជាកើតទុក្ខ នោះទឹងពោលស្រុក ប្រាកដពុំលែងឡើយហោង ៗ ទោះ
កណ្ដៀរនៅសសរផង កើតទុក្ខសៅហ្មង ឲ្យរៀបបូជាឯងឯង ៗ ទោះ
កណ្ដៀរនៅទិសអគ្នេយ៍ ជ្មមកណ្ដាលទេ ប្រមេកណ្ដាលកាចក្រៃ ៗ
នៅសសរកណ្ដាលចង្រៃ ទឹងកើតទុក្ខភ័យ អំពល់ទូវទ្រព្យពេកពន់ ៗ
ទោះកណ្ដៀរនៅសសរទក្សិណ កាចក្រៃលើសលន់ ទឹងមានរោគភ័យ
ជិតជល់ ៗ ឲ្យទានចាំសីលសោតសល់ ហើយឲ្យឆ្ងាយខ្វល់ និមន្ត
សូត្រមន្តផងទ្វី ៗ ទោះកណ្ដៀរនៅសសរនិរតី ទឹងកើតអប្រិយ គេ
ទឹងធ្វើទោសឥតធ្ងឹម ៗ ទោះកណ្ដៀរនៅទិសបស្ចិម ជាកាបសឡើម

បូជាសន្ទៀងឯងឯក ៗ ស្រូវអង្ករទូវល្ងសណ្តែក លាជផ្កាអខេក ប្រេង ម្សៅទៀនធូបគួរគាប់ ៗ ទោះកណ្តៀរនៅសសរពាយ័ព្យ គេនូវឲ្យ ទ្រព្យ សម្រាប់ប្រសើរបវរ ៗ ទោះកណ្តៀរនៅសសរឧត្តរ មាន លាភអំណរ កុំបីសន្ទិះទើងបាន ៗ ទោះកណ្តៀរនៅសសរឦសាន នោះសោតទើងមាន សាប់ញាតិបង់ប្អូនសំណាក់ ៗ ឆ្នាំទី ១២ ជើងជាក់ ព្រះឥន្ទ្រអ្នក ព្រះកេតុទេវតាសំដៅ ៗ ប្រើអ្នកឲ្យដើង ខុសត្រូវ ឲ្យអ្នកផងគួរ រៀបចាំទទួលបូជា ៗ ទៀនធូបគន្ធមាលា គ្រឿងបាយគ្រឿងស្លា ផ្កាស្លាពិពណ៌អតិរេក ៗ សំពត់សខ្មៅព្រាល ពេក នូវល្ងសណ្តែក ម្សៅប្រេងលាជសើងព្រមគ្នា ៗ បន្ថែមសោត ថែមញាំភ្លា ទឹកអប់ផងណា សំពត់អង្កាញ់ធ្វេងស្តាំ ៗ មាសប្រាក់ ដាក់ពានប្រចាំ កន្ទោងមួយទាំ តែទៅដោយទិសសម្ពាយ ៗ ឲ្យ សូត្របាទមួយដងថ្វាយ(១) គប់គ្រឿងទាំងឡាយ ថ្វាយទៅព្រះឥន្ទ ទេវតា ៗ លំដោះទុក្ខទោសភយា សែនព្រេនបូជា ម្ចាប់និមិត្តកាប ក្រែ ៗ អំពិលអំពែកនោះនៃ បូលផ្ទះសព្វថ្ងៃ មានលាភឲ្យរៀប បូជា ៗ ទើបបានដូចចិត្តចិន្តា បើពុំបូជា ឡើយលុះអំពើសៅហ្មង ៗ ស្រេចចប់គ្រាន់គ្រប់ហើយហោង តាមដម្រាផង សិងលើកជាល្បើក តទុក ៗ ឲ្យបានកើតកបទៅមុខ ជាច្បាប់ក្បួនទុក អ្នកផងដើង

---

១ មានពាក្យសម្រាប់សូត្របូជាថ្វាយទេវតា ដូចមានសំដែងទុកខាងក្រោយ ។

ឧត្បាទទាំងឡាយ ៗ សូមជ័យព្រះឥស្សរព្រះនារាយណ៍ ឥន្ទព្រហ្ម សម្ពាយ ចំរើនអាយុយឺនហោង ៗ ហើយឲ្យមហាជនផង បាន ស្ដាប់ហើយហោង ឲ្យស្បើយជម្ងឺទុក្ខភ័យ ៗ ឲ្យស្បើយអស់ទាំងចង្រៃ គ្រោះកាចនោះនៃ នូវសូមស្រាកស្រាន្តពេគា ៗ ទោះផ្ទុះទ្រាម ទ្រុឌុក្ខណា សូមអស់ទេវតា មកជួយដម្រង់ជ្រោមជ្រែង ៗ ទោះ ភ្លើងឆេះចង្ក្រានស្ដែង សូមជួយតាក់តែង បន្សាត់បំបាត់ចង្រៃ ៗ ទោះកុកឃុំពស់នោះនៃ ពង្រូលពស់ព្រៃ នូវសត្វអណ្ដើកតំរួន ៗ ទន្ទះបាញ់ទីភូមិស្ថាន អ្នកផងមែនមាន មនុស្សនាលោកិយនេះណា ៗ មហាជ័យនេះថ្ងៃសោតជា បន្សាបអស់អារ៏ នូវពិសកម្មកាចអប្រិយ ៗ ឲ្យមនុស្សផងមានបុទ្ធិ ដូចគេជអំពី ព្រះពុទ្ធព្រះធម៌សង្ឃ ផង ៗ កុំឲ្យកើតក្ដៅក្រហាយហោង ត្រជាក់ជាម្លប់ ដូចទឹកអម្រឹត វិស័យ ៗ ព្រះព្រហ្មឥស្សរនោះនៃ សំដឹងឲ្យពរជ័យ រក្សាសព្វថ្ងៃ ទៅហោង ៗ

# រឿងសុភាទន្សាយ

# រឿងសុភាទន្សាយ

នេះនឹងស្រដី ពីសត្វប្រាំនៃហោនណា គេមានអកខ្វា នឹងទន្សាយ ទាំងប្រាំនាក់ ៗ គិតគ្នាធ្វើដូះ នឹងបានប្រើប្រាស់ទុកដាក់ គ្រាន់បាន សំណាក់ នឹងបានគិតការតទៅ ៗ ខ្លាថាបើដូច្នោះ ព្រមគ្នាចំពោះឥឡូវ យើងទៅច្រូតស្រូវ រួចហើយសឹមយើងគិតសង់ ៗ គិតស្រេចហើយណា បបួលគ្នាដើរត្រង់ ពុំហានបង្អង់ ពុំបានឈប់ឈរឡើយណា ៗ ដើរទៅដល់ព្រៃ គយគន់រំពៃព្រឹក្សា ឃើញពាលស្រូវណា នេះហើយគេហៅស្រូវល្អ ៗ ដល់បោះជំរំ និយាយគ្នាជុំមាត់ក ថានេះស្រូវល្អ យើងរកទៅទៀតក្រែងគ្មាន ៗ យើងច្រូតវៀងអាយ តោះក្រតោះ ឆ្ងាយគង់បាន ទៅទៀតក្រែងគ្មាន ពុំបានប្រទះស្រូវល្អ ៗ កេថាឥឡូវ ឲ្យអ្នកណានៅចាំស្ងួ យើងទាំងទៅរក ច្រូតស្រូវរួចមកស៊ីបាយ ៗ អកធ្លាស់ឆ្លើយថា បង់ឲ្យបងខ្លានៅអាយ ចាំដៃរៀបបាយ រៀបស្ងោរដណ្ដាំឲ្យស្រេច ៗ ថាហើយនាំគ្នា ដើរទៅម្នីម្នារំពេច ដល់ទៅព្រៃស្រេច ទន្សាយថាគ្នាយើងអើយ ៗ យើងច្រូតនៅនេះ ទៅឆ្ងាយម្ដេចម្ល៉េះអ្នកកើយ ស្រូវច្រើនម្ល៉េះហើយ នេះឯងហៅស្រូវល្អណាស់ ៗ កេអកឡូវមាន ព្រមគ្នាស្រុកន់រហ័ស ច្រូតស្រូវបាប់ណាស់ តែមាន់នឹងអកឡូវកេ ៗ ឯអាទន្សាយ រកកលនាយអាយវេះវៃ គៀសប្រាប់ទៅគេ ថារុឺយ យើយគ្នាឈឺពោះ ៗ តែរាធ្វើកល- កិច្ចដោយៈយោបល់រានោះ រាថា

ឈើនោះ តែកំបង់ទៅមើលភ្នា ៗ ក៏ដើរត្រៀតឈ្លប តិច ៗ លលប ម្នីម្នា ជួនប្រទះភ្នា លោតចាប់ឯក្ដាន់នោះបាន ៗ ក៏ឃើញជាក់មិញ រត់ទៅឃ្មាតខ្មាញ់ដោយដាន ដៃទប់ខ្លួនប្រាណ ក៏ធ្វើជាគ្រុនញញ័រ ៗ ដៃមួយស្ទាបពោះ ក៏ដើរទៅរទោះរទេរ ញញីញញ័រ ក៏ធ្វើឲ្យគេជឿ ហោង ៗ តាមាន់ទូអែក ឃើញដណ្ដឹងមកគីងកង ហើយដើរពង អាចោរម្ដេចអាព្រៃងើយ ៗ មិនកែប្រែក្បួរ ម្ដេចអាលេងនៅកន្ទើយ ឱបដៃត្រាងើយ ដើរលេងសព្វព្រៃព្រឹក្សា ៗ ទន្សាយឆ្លាស់ឆ្លើយ ថាឱអ្នកកើយអស់គ្នា កុំអាលផ្ដាសា ចាំខ្ញុំដំណើរប្រាប់អ្នក ៗ អ្នក កើយខ្ញុំគ្រុន ស្ទើរស្លាប់ប៉ប្រិនញ័រញាក់ ពោះខ្ញុំឈឺចាក់ ជោគហើយ ចុះថ្ងៃខ្ញុំងង ៗ ក៏ឈឺពោះខ្លាញ់ ដូចគេត្រដាញ់ណាស់ហោង អាសូរ ខ្ញុំផង ខ្ញុំមិនមានពុតទេណា ៗ តមាន់ទូអែក ពួកប្រាប់មកសោះសា មិនស្រដីថា ទៅវិញទៅមកឡើយទេ ៗ ប្រែក្បួរតិចទៅ ទន្សាយ នោះក៏ស្រដី ថារ៉ីយ៉ើរ៉ី ដល់យើងទង់ទៅល្ងាចណា ៗ យើងបាន ត្រីសាច់ ខ្ទះទេបន្ដិចអាហារ គ្រាន់បរិភោគា នោះមានឬទេអ្នកកើយ ៗ ទន្សាយតាប៉េ ដោយយាមអាញមើលជាត្រើយ ដល់ទៅល្ងាចហើយ ប្រាកដជាមានលាភជ័យ ៗ តមាន់អកខ្វា បើឈ្មោះលង់អាតាយទេ ឲ្យប្រាកដកែ ឥឡូវនេះលង់មើលអា ៗ ទន្សាយឆ្លាស់ឆ្លើយ ថាឱ អ្នកកើយគ្រប់គ្នា ដល់យើងទៅណា ប្រាកដជាបានសាច់ក្ដាន់ ៗ បើ

អញទាយត្រូវ ប្រាកដឡោះគូរជាក់ស្បាទ់ ថាបានសាច់ក្ដាន់ អស់អ្នក កុំស៊ីឡើយណា ៗ គេមាទ់អកនៃ ថាអើនៃវុំយើងប្រា· ក.ដមិនស៊ីណា យើងឡើតែអាស៊ីហោង ៗ លុះល្ងាចនាំគ្នា ដើរមកប្ដីម្ដាត្រសង ដល់ ដៃហើយហោង់ ហើយដណ្ដឹងទៅបងខ្លា ៗ ថានៃអ្នកបង អ្នកបាន អ្វីហោងជាអា· បារបរិភោគ្គា ខ្ទះទេប្តុគ្នានឡើយនៃ ៗ ខ្លាឆ្លើយប្រាប់ មក ថាអញទៅរកក្នុងព្រៃ បានក្ដាន់មួយនៃ យកមកចំអិនហើយណា ៗ ខន្សាយស្ដាប់ជាក់ ថាវុំយអស់អ្នកគ្រប់គ្នា មែនដូច្នេះណា ថាឯង មិនស៊ីឡើយហោង ៗ ឥឡូវមែនហើយ ឯងកុំស៊ីឡើយជាម្ដង សាច់ នោះឯងហោង អញស៊ីតែទឹងបងខ្លា ៗ គេមាទ់អកនោះ ស្ដាប់ហើយ ទ្រគោះសោះសា ដើរថាបៃអា ៗ· នេះដកខង់ចោរខ្ចប ៗ ចូរបើអញស៊ី យើងមិនសូមដីដូនដូច អាកុហកខ្ចប រកតែកំភូតមាយា ៗ អ្នកទាំងប្រាំ បរិភោគហើយនាំគ្នា ដេកលុះព្រឹកណារ ហើយមកគិតគ្នាទៀតនៃ ៗ ថ្ងៃនេះយើងចង់ ឡើគេបាំរង់នោដៃ យើងទាំងប្អូននៃ ទឹងទៅច្រូតពីព្រឹក ហោង ៗ គិតស្រេចហើយណា នាំគ្នាយាត្រាជាម្ដង ដល់ព្រៃស្រូវ ហោង ច្រូតស្រូវទ្រហឹងរឹករ ៗ គេនៅចាំដៃ ទៅមុជចាប់ត្រីខ ៗ បាន ឆ្កោមកស្ង ចាំរង់អស់គ្នាច្រូតស្រូវ ៗ ខន្សាយនោះណា ច្រូតបាន តិចណាស់ទៅ លបមើលគេក្ដី យើញគេចាប់បានឆ្កោជាក់ ៗ យើញ ហើយរិលទៅ ខ្លាអកមាន់នៅភ្ញាភ្ញាក់ អាចោរអប្បលក្ខណ៍ ពាខ្ចបអា

ទៅឯណា ៗ ទន្សាយម្ចាស់ត្រើយ ដូចពីដើមឡើយសោះសា អស់ត្រីនេះណា ដូចយើងស្រដីមុនហើយ ៗ ត្រីបេះអោយហោរ ដូចពីដើមមកអ្នកកើយ ពុតមិនពាក់ឡើយ ត្រីនេះត្រីនៅមិនបាត់ ៗ ប្រែតលុះល្ងាចមក ភ្លមាត់ទុកពុំស្ងាត់ មកដល់ពុំបាត់ ញ័រញាក់ដណ្តឹងទៅគេ ៗ ថាអ្នកចាំដៃ បានមួយចំណាប់ទេ នោះទើបឯគេ ប្រាប់មកថាបានត្រីត្ដោរ ៗ ទន្សាយស្ដាប់ជាក់ ហើយថាអស់អ្នកគោគហោរ អញពប់ដៃរ ឥឡូវប្រាកដមែនណា ៗ អស់នេះយើងបាន ស្រដីមែនមានទាក់ប្រា- កដពីដើមណា ដំណើរសឹងដូចគ្នាហោង ៗ អស់អ្នកចាំងប្រាំស៊ីបាយហើយនាំគ្នាផង ដេកដល់ព្រឹកហោង មកគិតទីគ្នាទៀតនៃ ៗ ថ្ងៃនេះយើងឲ្យ បងអកចាំគយនៅដៃ អស់យើងទៅព្រៃ ចាំងប្អូនអ្នកនោះហោងណា ៗ គិតហើយលាលា ដើរទៅម្នាសោះសា ដល់ស្បូវប្រែតណា ដល់តិចទន្សាយរេះបាត់ ៗ ក្រោយនោះបងអក គាត់ទៅសំកកចាំចាប់ ត្រីប្រាបានខ្ទប់ រួចហើយទើបយកមកស្ល ៗ ទន្សាយទៀតឈ្លប ដើរមកលលបដកក ហើលជាក់ហើយចរ លាលាទៅវិញជាមួង ៗ ដំណើរនេះនៃ ដូចយើងស្រដីវេះហោង ពុតណាសក់ទន្ងត្រីហោរនោះដូចដើមណា ៗ លុះល្ងាចលាលា ដើរមកម្នាសោះសាដណ្តឹងអកថា អ្នកតែងចាំដៃនោះហោង ៗ បងអើយបងអក ឥឡូវយើងមកជាមួង បងបានអ្វីហោង គ្រាន់ស៊ីជាមួយបង្កូទេ ៗ អកឆ្ងាស់ត្រើយ

ប្រាប់ ទៅគេឆាប់ៗថាទេ ខ្លាចក្រែងតែគេ នៅពុំដូចអញនេះហោង ៗ ឥឡូវអញបាន ប្រាមួយមកមានជាម្ដង ចំអិនហើយហោង ទុកឲ្យ អស់អ្នកកល់គ្នា ៗ ទន្សាយស្ដាប់ជាក់ ថាឲអស់អ្នកកាល់គ្នា អញទាយ នេះណា ថាបានត្រីប្រាស៊ីហោង ៗ ដំណើរទន្សាយ កុតខ្ចូចកាយ មាយកទួង ដូចពីដើមហោង រៀនរៀបមកនោះឯងណា ៗ អស់អ្នក ទាំងប្រាំ ស៊ីបាយហើយនាំគ្នា ដេកលុះព្រឹកណា គិតគ្នាអោកអឹង កង ៗ ថ្ងៃនេះឯងនៃ ឲ្យមានចាំដៃនោះហោង យើងទាំងបួនផង ទៅគេប្រូតស្បូវហោងណា ៗ

(មានតទៅទៀត)